# ខ្ញុំមានទោសព្រោះអ្វី?

អ្នកនិពន្ធៈ ជ្រឹញ-ខ៉ាញ



យើងសូមថ្លែងអំណរគុណចំពោះ

លោក **អ៊ុច ភិរម្យ**

ដែលបានចែកចាយសៀវភៅនេះដើម្បី

ជូនដល់បងប្អូនរួមជាតិបានអាននៅថ្វីដៃអក្សរសាស្ត្រខ្មែរ



*In kind appreciation to*

*Mr. Perom Uch*

*for making this book available*

*for all to enjoy Khmer literature.*

# ជីវប្រវត្តិរបស់អ្នកនិពន្ធ

# ទ្រិញវ៉ាញ



នៅក្នុងអំឡុងឆ្នាំ១៩៦៣លោកទ្រិញវ៉ាញបានបំពេញមុខងារជាតំណាងរាស្ត្រ  លោកក៏មានតួនាទីជាសមាជិកការិយាល័យរបស់រដ្ឋសភាដែរព្រមទាំងជាប្រធានគណៈកម្មការសភា។ ក្នុងខែមិនា១៩៧០  លោកជាតំណាងរាស្ត្រមួយរូបដែលបានចូលរួមបោះឆ្នោតដកសម្តេចនរោត្តមសីហនុពីតំណែងប្រមុខរដ្ឋនៃរាជាណាចក្រកម្ពុជា។  នៅក្រោមរដ្ឋាភិបាលសាធារណរដ្ឋខ្មែរលោកបានបំពេញបេសកកម្មជារដ្ឋមន្ត្រីក្រសួងឃោសនាការ។

លោកបានប្រសូតនៅថ្ងៃទី៩ខែកញ្ញាឆ្នាំ១៩២៤នៅឯត្រពាំងឫស្សីខែត្រកំពង់ធំ។  លោកត្រូវជាបុត្ររបស់លោកទ្រិញបាក់និងលោកស្រីស៊ុយហួយ។  ភរិយារបស់លោកគឺលោកស្រីម៉ាម៉ុងក្រេ លោកនិងភរិយាមានបុត្រានិងបុត្រីទាំងអស់ចំនួន១០នាក់។

លោកបានបំពេញការសិក្សានៅឯសាលាគរុវិជ្ជា  ហើយក៏បានបំពេញបេសកកម្មនៅឯក្រសួងឃោសនាការ  បរមរាជវាំង  រដ្ឋសភា  រួមជាមួយគ្នានេះដែរលោកក៏ជា  សមាជិកមួយរូបនៃរាជរដ្ឋាភិបាលខ្មែរ។

លោកធ្លាប់ធ្វើជាអ្នកសរសេរកាសែតអ្នកជាតិនិយមនៅក្នុងសម័យសង្គមរាស្ត្រនិយម ព្រមទាំងបាននិពន្ធសៀវភៅមួយចំនួនទៀតផង។

លោកបានទទួលមរណៈភាពក្រោយបន្ទាប់ពីជ័យជំនះរបបខ្មែរក្រហមនៅឆ្នាំ១៩៧៥។

យើងសូមថ្លែងអំណរគុណលោកដែលបានចែងទុកជាអនុស្សាវរិយ៍នៅសៀវភៅ **ខ្ញុំមានទោសព្រោះអ្វី?** នេះ។ សូមវិញ្ញាណក្ខន្ធរបស់លោកបានជួបតែនឹងសុគតិភព កុំបីឃ្លាងឃ្លាតឡើយ។

# Author's Biography



**TRINH HOANH**

—

Député à l'Assemblée Nationale, Membre du Bureau de l'Assemblée Nationale, Président de Commissions Parlementaires, Commis de l'Information de 1re classe.

Né le 9 Septembre 1924 à Trapeang-Russei (Kg.-Thom), fils de M. Trinh Bac et de Mme née Suy Huoi. Marié le 15 Novembre 1945 avec Mlle Mar-Mongkre. Enfants : V , P , V , V , V , V , V , V , V , V .

Ecole de Formation des Instituteurs. Chef de Bureau et Chef de Service au Ministère de l'Information, Chef du Secrétariat du Palais Royal, Questeur de l'Assemblée Nationale, Membre du Gouvernement, ancien Rédacteur en Chef du «Neak Cheat Niyum». Auteur de plusieurs Ouvrages, dont les «Préceptes du Bouddha» et «l'Arithmétique Expliquée». Plusieurs fois en mission à l'étranger. Commandeur du Monisaraphon, Officier de l'ORC, Officier du Sowathara, Médaille d'Or du Travail, Commandeur de l'ordre du Soleil Levant (Japon).

Membre du Comité Central du Sangkum, du Comité Directeur de la J.S.R.K., du Comité Directeur de l'Association des Ecrivains Khmers, de l'Association des Parents d'Elèves du Lycée Descartes, de l'Association Sportive du Lycée Descartes, de l'Association Mondiale du Bouddhisme.

Sports : Foot-ball, basket-ball, volley-ball - Distraction : Musique.

Adresse privée : 3 rue Nhiek Tioulong, Phnom-Penh, Téléphone : 53 Chak Angré.

*(after "Personalités du Cambodge" 1963 Edition)*

Member of Parliament (1963), Member of the National Assembly office, President of the Parliamentary Commissions, First Class Information Clerk.

Born on September 9, 1924 in Trapeang Russei (Kampong Thom Province), son of Mr. Trinh Bac and Mrs. Suy Huoi. Married on November 15, 1945 to Miss Mar Mongkre. Ten children.

Completed teacher's formation school. Supervisor and Department Head at the Ministry of Information, Office Manager of the Royal Palace, Treasurer of the National Assembly, Government Official, Chief Editor of the "Neak Cheat Niyum" newspaper. Author of several books including "Buddha's Precepts," "Arithmetic explained." Completed several foreign missions. Commander of the Monisaraphon, Officer of the Royal Order of Cambodia, Sowathara Officer, Gold work medal, Commander of the Rising Sun order (Japan).

Member of the Central Committee of the Sangkum Reastr Niyum, Director of the Khmer Royal Socialist Youth (J.S.R.K.), Member of the Directorate committee of the Association of Khmer Writers, of the Association of Student's Parents of Descartes High School, of the Sport Association of Descartes High School, of the Buddhism World Association.

Hobbies: soccer, basketball, volley ball, music.

Private Address: 3 Nhiek Tioulong Street, Phnom Penh. Telephone: 53 Chak Angre.

**Note**: In 1970, Mr. Trinh Hoanh was also a Member of Parliament. He was one of the MP who voted to remove Samdech Sihanouk from power on March 18, 1970. Upon the formation of the Khmer Republic, he was nominated as Information Minister.

Following the victory of the Khmer Rouge forces in April 1975, Mr. Trinh Hoanh whereabout remains unknown. It is presumed that he found his death shortly after the advent of the Khmer Rouge regime, or during the Khmer Rouge era (1975-1978).

ក្រសួងអប់រំជាតិ

# យោបល់

## គណៈកម្មការបច្ចេកទេសខាងភាសាខ្មែរ

គណៈកម្មការបច្ចេកទេសខាងខេមរភាសា បានប្រជុំកាលពីថ្ងៃពុធទី ១៥ តុលា ១៩៦៩ ម៉ោង ៩ កន្លះ ដែលមានសមាជិកដូចតទៅ គឺៈ លោក មាស នឹម, ឡុច ផ្លេង, អ៊ុក សាម៉ន និង លាងហ៍បអាន ដើម្បីពិនិត្យសៀវភៅប្រលោមលោក មានចំណងជើងថា «ខ្ញុំមានទោសព្រោះអ្វី» និពន្ធដោយលោក ទ្រិញ វ៉ាញ ដែលក្រសួងអប់រំជាតិផ្ញើមក «ដើម្បីពិនិត្យនិងផ្តល់យោបល់» តាមដីកាបញ្ជូនដែលត្រូវតបលេខ ៣០៩-ខ-សយ. ចុះថ្ងៃ ២៥-៨-៦៩ ។

ក្រោយដែលបានប្តូរយោបល់គ្នាយ៉ាងយូរ ហើយនិងពិនិត្យលើកំណត់ហេតុនៃគណៈកម្មការសិក្សាផ្នែករងទី ៣ ខាងខេមរៈ ចុះថ្ងៃ ១៥ កុម្ភៈ ១៩៦៩ មក គណៈកម្មការយល់ឃើញថា «ពុំអាចបញ្ចូលសៀវភៅនេះក្នុងកម្មវិធីមធ្យមសិក្សាថ្នាក់ណាមួយបានទេ» ប៉ុន្តែ «អាចចាត់ទុកជាសៀវភៅសម្រាប់ការអាន ដោយណែនាំ (Lecture dirigée) ក្នុងគ្រឹះស្ថានសិក្សាបាន» ។

ភ្នំពេញ ថ្ងៃទី ១៦ ខែតុលា គ.ស. ១៩៦៩

*ប្រធានគណៈកម្មការ,*

ហត្ថលេខាៈ កែ ម៉េង ហាប់

**បោះពុម្ពនៅថ្ងៃទី ១ មេសា ១៩៧៥**

គណៈកម្មការសិក្សា
ផ្នែករងទី ៣

## សេចក្ដីដកស្រង់កំណត់ហេតុនៃគណៈកម្មការ ពិនិត្យសៀវភៅនៅមធ្យមសិក្សា

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

ក្រោយពីបានពិភាក្សាលើចំណុចផ្សេងៗនៃសៀវភៅ «ខ្ញុំមានទោសព្រោះអ្វី» នេះ អស់ពេលដ៏យូរមក គណៈកម្មការមានយោបល់ដូចតទៅ :

**១- ចំពោះអត្ថន័យ:** សៀវភៅនេះបានលើកយកមកចោទនូវបញ្ហាសំខាន់ៗ:

- ប្រវត្តិសាស្ត្រខ្មែរយើង ក្នុងការបង្ក្រាបជនក្បត់ជាតិ (ជំពូក ២)
- ការបំរើជាតិដោយស្មោះត្រង់ កលល្បិចនិងជោគជ័យរបស់ការិយាល័យទី ២ ក្នុងបដិចារកិច្ច
- ចិត្តស្នេហាជាតិ និង ភក្ដីភាពចំពោះជាតិ
- ចិត្តស្មោះត្រង់និងបទបញ្ជា គឺវិន័យក្នុងកងទ័ព ។

**២- ចំពោះអត្ថរូប :**

- មានការប៉ិនប្រសប់ក្នុងរបៀបនិទាន ដោយលើកយកបញ្ហាបិទមុខដាក់ខាងដើម ធ្វើឲ្យអ្នកអានចង់ដឹងរឿង
- ដំណើររឿងចេះតែជឿនលឿនរហ័សទាន់សម័យ
- ភាសានិយាយស្របនឹងប្រភេទនៃសៀវភៅ ប៉ុន្តែបានភ្លាំភ្លែកបន្តិចបន្តួចខាងពាក្យសំដី ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

**៣- ចំពោះអត្ថរស :**

- មានលក្ខណៈជាតិទាំងទឹកខ្មែរ តួអង្គ ចិត្ត សង្គម . . .
- មានការអប់រំ (ដាស់តឿនឲ្យស្រឡាញ់ជាតិ-ស្នេហាស្មោះត្រង់) ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៥ កុម្ភៈ ១៩៦៩

*អគ្គប្រធាន*

ហត្ថលេខា : **ត្រាំ ម៉ល**

*ហត្ថលេខា សមាជិក :*

**ចាន់ គន្ធ - ឡុច ឡែម - តាន់ អ៊ឹម**

*អគ្គនាយកដ្ឋាន នៃ ក្រសួងវាំង*

*ក្នុងព្រះបរមរាជវាំង*

*លេខ ៤០៩ - ល - ដ្ឋ*

ភ្នំពេញ នៅថ្ងៃទី ២៨ ខែកក្កដា គ. ស. ១៩៦៧

អ្នកអង្គម្ចាស់ អគ្គនាយកក្រសួងវាំង នៃព្រះបរមរាជវាំង

ជំរាបមកសហជីវិន ទ្រិញ - ភិក

បានជ្រាប ។

សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានទទួលនូវសៀវភៅប្រលោមលោក ២ សៀវភៅ មានចំណងជើងថា «ខ្ញុំមានទោសព្រោះអ្វី» ដែលសហជីវិន បាននិពន្ធចងក្រង ហើយបានផ្ញើទៅថ្វាយចំពោះព្រះអង្គ តាមបុតហ្វាយចុះថ្ងៃទី ១៣ កក្កដា ១៩៦៧ នោះហើយ ។

សម្ដេចជាអម្ចាស់ ទ្រង់មានព្រះរាជបណ្ណាំដូចតទៅនេះ :

“ អរគុណណាស់ ដែលផ្ញើរឿង “ខ្ញុំមានទោសព្រោះអ្វី” មកថ្វាយនេះ ហើយនិងសូមសរសើរ អំពីកម្លាំងកាយហើយនឹងកម្លាំងចិត្ត ដែលមានការច្រើនជាបន្ទុកធំធ្ងន់ៗ ដល់ទៅ ៨ មុខហើយ មានពេលសរសេរសៀវភៅបានទៀតនេះ គួរឲ្យកោតណាស់ សូមសរសើរដោយសុទ្ធចិត្ត និង ឲ្យពរដែលបំរើជាតិ និង រាជបល្ល័ង្កនេះ សូមឲ្យបានសុខតរៀងទៅ ”

*ព្រះហស្តលេខា : នរោត្តម កុសុម*

ខុទ្ទកាល័យនៃសម្តេចសហជីវិន

ព្រះប្រមុខរដ្ឋ

លេខ -១១០០-ខ-ស- ៦២៣

ភ្នំពេញ ថ្ងៃទី ២០ កក្កដា គ. ស. ១៩៦៧

" ទទួលព្រះបរមរាជឱង្ការទុកលើត្បូង "

តាមលេខាធិការដ្ឋានផ្ទាល់សម្តេចសហជីវិនព្រះប្រមុខរដ្ឋ

ជំរាបមកសហជីវិន ទ្រឹញ-ភ៊ីញ ប្រធានគណៈកម្មការឃោសនាការ

និងពត៌មាននៃរដ្ឋសភា ក្រុងភ្នំពេញ

ខ្ញុំបានទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់ពីសម្តេចព្រះប្រមុខរដ្ឋ ទ្រង់ព្រះបញ្ជាឲ្យខ្ញុំថ្លែងក្នុងព្រះនាមនៃព្រះអង្គ នូវសេចក្តីសរសើរយ៉ាងអនេក ចំពោះសហជីវិនដែលបានខិតខំព្យាយាមនិពន្ធរឿងប្រលោមលោក ដែលមានចំណងជើងថា " ខ្ញុំមានទោសព្រោះអ្វី " ជាប្រលោមលោក ដែលមានន័យនិងសារប្រយោជន៍យ៉ាងសំខាន់សំរាប់ដាស់សតិជាតិយើងឲ្យស្គាល់ច្បាស់នូវកិច្ចសង្គ្រោះគ្នា អាណិតអាសូរ និងការជិះជាន់ រំលោភនៃពួកប្រតិកិរិយា ។ល។

ប្រលោមលោករបស់សហជីវិននេះ មុខជានឹងបានជាគុណប្រយោជន៍យ៉ាងសំខាន់សំរាប់ប្រទេសយើងតទៅអនាគតជាពុំខាន ។

នៅទីបំផុតសម្តេចឪ ទ្រង់មានព្រះរាជហឫទ័យសោមនស្សរីករាយ និងជឿជាក់ថា សហជីវិន នឹងព្យាយាមបន្តការនិពន្ធផ្សេង ៗ ទៀត ឲ្យបានចំរើនលូតលាស់ជាពុំខាន ។

សូមសហជីវិន ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ហត្ថលេខា: ខែម-សួន

# អារម្ភកថា

ខ្ញុំពុំមានចំណេះជ្រៅជ្រះប៉ុន្មានទេ តែកាលនៅរៀនសាលាគរុវិជ្ជា ខ្ញុំធ្លាប់បានលេខ ១ ខាងតែងសេចក្ដីខ្មែរ លោកញឹក-ធូវ "ឧកញ៉ាមហាមន្ត្រី ញឹក-ធូវ" បានឲ្យពិន្ទុខ្ញុំដល់ទៅ ៩ ក្នុងភាគ ១០ ក៏សឹងមាន ។

ខ្ញុំធ្លាប់បានសរសេរអត្ថបទសារព័ត៌មានតាំងពី គ. ស. ១៩៤៨ ហើយការព្យាយាមរបស់ខ្ញុំនេះ បានរហូតដល់ឋានៈជានិពន្ធនាយកសារព័ត៌មាន កម្ពុជា, ឈាមខ្មែរ, សង្គមរាស្ត្រនិយម និងអ្នកជាតិនិយម ។ មិត្តអ្នកអានទាំងឡាយបានស្គាល់នូវរបៀបសរសេរអត្ថបទរបស់ខ្ញុំយ៉ាងច្បាស់ ហើយនិយមអានព្រោះមានខ្លឹមសារ ។ ខ្ញុំធ្លាប់បានសរសេរទស្សនាវដ្ដី និងសៀវភៅផ្សេងៗទៀតជាច្រើនដែរ តែសុទ្ធជាអត្ថបទរាប់រៀបពីហេតុដែលមាន គឺព្រឹត្តិការណ៍ផ្សេងៗ ឬក៏បង្ក្រងធ្វើអត្ថាធិប្បាយនូវច្បាប់ដែលមានស្រាប់ ។ ខ្ញុំបាន

សរសេរសៀវភៅ "ឥឡូវមានធម៌" មួយ បានប្រឡងជាប់លេខ ៣ ក្នុងកម្ពុជរដ្ឋ ក្នុងពិធីបុណ្យខួប ២៥០០ វស្សានៃព្រះសម្មាសម្ពុទ្ធ តែក៏ជាការអត្ថាធិប្បាយវែកញែកដែរ, ខ្ញុំពុំដែលហ៊ានសរសេរប្រលោមលោកទេ ព្រោះប្រលោមលោកត្រូវមានការព្យាយាមច្រើន ដើម្បីរៀបចំឲ្យត្រូវតាមបច្ចេកទេស ដូចជាការបង្ក្រងឲ្យមានដំណើររឿងកុបតិន, ឆ្នៃរចនាពាក្យសំដីឲ្យត្រឹមត្រូវតាមលក្ខណៈរបស់វា និងល្បិចកលសំកប់ធ្វើឲ្យអ្នកអានជាប់ចិត្ត អានជក់មិនធុញទ្រាន់ជាដើម ។ តែខ្ញុំនៅរក្សាបំណងមួយជាប់ជានិច្ច គ្មានជាទីបំផុត ខ្ញុំក៏ជាប់ចិត្តសរសេររឿង "ខ្ញុំមានទោសព្រោះអ្វី ?" នេះដែលជាប្រលោមលោក ទាក់ទងក្នុងមនោសញ្ចេតនាដ៏វែងឆ្ងាយ, មានការសង្គ្រោះដោយស្អប់ការជិះជាន់រំលោភ មានការលះបង់ជីវិតដើម្បីជាតិ ទប់ទល់នឹងជនលោភបុណ្យលក់ជាតិ បំរើសេអាគូ ។



ខ្ញុំសរសេរនេះគឺមានប្រាថ្នា ទាញចិត្តមិត្តអ្នកអានឲ្យតែចង់ដឹងដំណើររឿងជានិច្ច តែលទ្ធផលយ៉ាងណា ជាភារៈលើមិត្តអ្នកអានទាំងអស់ ព្រោះខ្ញុំមានសង្ឃឹមថានឹងបានទទួលនូវសេចក្ដីរិះគន់ ជួយកែតម្រូវអំពីមិត្តអ្នកអានជាពុំខាន ។

ក្នុងប្រលោមលោក "ខ្ញុំមានទោសព្រោះអ្វី ?" នេះ ខ្ញុំប្រើពាក្យថា "ខ្ញុំ" ជាតួឯកក្នុងផ្ទៃរឿង តែពុំមែនជារឿងពិតផ្ទាល់ខ្លួនរបស់ខ្ញុំទេ គឺគ្រាន់តែជាបច្ចេកទេសម៉្យាងក្នុងការសរសេររឿងតែប៉ុណ្ណោះ ហើយសូមមិត្តអ្នកអានមេត្តាកុំប្រែសេចក្ដីនៃរឿងនេះទៅជាអ្វីដទៃឡើយ ។

ថ្ងៃទី ១០ សីហា ២៥០៥ / ១៩៦២

សូមអរគុណ

**ធិញ-ម៉ាញ**

# ជំពូកទី ១

## វគ្គទី ១

## រឿងអាថ៌កំបាំងបិទមុខ

នៅក្រុងបាងកក រាជធានីនៃប្រទេសថៃឡង់ ក្នុងគ. ស. ១៩៦២ មានរឿងមួយដ៏ចំឡែកអស្ចារ្យ បានធ្វើឲ្យមហាជនភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះជារឿងអាថ៌កំបាំង បិតនៅក្នុងការងឿងឆ្ងល់នៃមហាជន ចាប់តាំងពីជនសាមញ្ញធម្មតា រហូតដល់អ្នកកាសែត អ្នកនិពន្ធរឿងបិទមុខ អ្នកចិត្តសាស្ត្រ អ្នកវិញ្ញាណសាស្ត្រ តែងនាំគ្នាស៊ើបសួរថា តើរឿងការពិតប្រាកដនោះយ៉ាងណាខ្លះ ?

ក្រោយសង្គ្រាមលោកលើកទី ២ បានរលត់ទៅក៏ពិតមែនហើយ តែប្រជាជនទាំងឡាយនៅពុំទាន់បាត់ស្រៀវឆ្អឹងខ្នងនៅឡើយ ។ ការប្រែប្រួលនៃពិភពលោក ដែលអាចកើត

ឡើងពីផលនៃសង្គ្រាមសម័យថ្មី សង្គ្រាមត្រជាក់ សង្គ្រាមពិសេស សង្គ្រាមឥតប្រកាសសង្គ្រាម ដែលគេច្រើនតែស្មានថា នឹងប្រព្រឹត្តទៅបែបនេះ បែបនោះយ៉ាងណា រឿងអាថ៌កំបាំងបិទមុខ ដែលកំពុងតែកើតមានឡើងក្នុងពេលនេះ ក៏នៅតែបានទទួលនូវការងឿងឆ្ងល់ និងការដៅស្មាននៃមហាជនពុំប្លែកគ្នាប៉ុន្មានពីរឿងសង្គ្រាមទាំងនោះដែរ.....

ប្រជាជនភាគច្រើននៅក្រុងបាងកក នាំគ្នាជឿថា មានខ្មោចបិសាចមួយដែលមានឥទ្ធិឫទ្ធិ តែពុំប្រទូសរ៉ាយនឹងមនុស្ស ព្រោះវាមិនដែលធ្វើអ្វីឲ្យវិនាសដល់អ្នកណាសោះឡើយ ។

បិសាចនេះ គ្រាន់តែជាបិសាចស្នេហាតែប៉ុណ្ណោះ ព្រោះវាមកជួបតែនឹងមនុស្សដែលវាស្រឡាញ់ ដោយវាអាចសម្តែងរូបកាយឲ្យក្លាយខ្លួនទៅជាមនុស្សបាន ។

មនុស្សដែលបិសាចនៅស្រឡាញ់ គឺស្រីម្នាក់បិតនៅក្នុងមជ្ឈិមវ័យ ឈ្មោះនាង យូរ៉េត ។ ឈ្មោះនេះក៏ល្មមជាឈ្មោះ



របស់ជនជាតិថៃបាន តែអ្នកផងបានដឹងច្បាស់ថា នាងយូរ៉េតជាជនជាតិខ្មែរ ។ នាងមានប្តីជាជនជាតិខ្មែរដែរ ហើយមានកូនប្រុសតូចម្នាក់ ដែលនៅក្នុងបន្ទុករបស់នាងសព្វថ្ងៃនេះ...

រឿងរ៉ាវមានតទៅទៀតថា កាលបើគូស្វាមីភរិយា នៅរួមសុខទុក្ខជាមួយគ្នា បានកូនប្រុសមួយនេះហើយ, ប្តីក៏ស្លាប់ចោលនាងទៅ ដោយសារឧបទ្ទវហេតុក្នុងពេលព្រឹកមួយ ដែលគេបានបើករថយន្តផ្ទាល់ខ្លួនចូលទៅទីក្រុង ដើម្បីកិច្ចការអ្វីមួយ ហើយទៅបុកដើមឈើនៅទីពាក់កណ្តាលផ្លូវ ។ ដោយសារការបើកបរលឿនពេក រថយន្តនោះបានជ្រុលជ្រួសទៅបុកដើមឈើយ៉ាងខ្លាំងក្រៃណាខ្លាំង ទាល់តែរថយន្តនោះឆេះខ្ទេចខ្ទីទាំងអស់ ។ ឯម្ចាស់រថយន្តគឺប្តីនាងយូរ៉េត ដែលជាអ្នកបើកបររថយន្តនោះ ក៏ត្រូវភ្លើងឆាបឆេះពេលកល ស្លាប់នៅជាប់នឹងដៃចង្កូតរថយន្ត ។ ភាពនេះជាភាពគួរឲ្យស្លុតរន្ធត់ជាខ្លាំង ...

ទីកន្លែងដែលរថយន្តបុកដើមឈើ ទាល់តែស្លាប់ម្ចាស់នោះ ជាកន្លែងស្ងប់ស្ងាត់គ្មានផ្ទះសម្បែងអ្នកស្រុកឡើយ ។ សងខាងផ្លូវថ្នល់មានដើមគគីរដុះជាជួរ តែឃ្លាតៗពីគ្នា ។ បើតាមការសន្និដ្ឋានរបស់ក្រុមព្រះនគរបាល ដែលបានទៅពិនិត្យមើលសាកសពនិងកំទេចរថយន្តក្នុងវេលានោះ ថា ប្រហែលជាម្ចាស់រថយន្តបើកបរលឿនពេក ពុំប្រយ័ត្នប្រយែង លុះមានហេតុការណ៍កើតឡើងចាប់ហ្វ្រាំងពុំទាន់ រថយន្តក៏ជ្រុលទៅបុកដើមឈើ ។ ដោយការបុកខ្លាំងពេក រថយន្តក៏ឆេះខ្ទេចខ្ទី បណ្ដាលឲ្យអ្នកម្ចាស់រថយន្ត ដែលជាអ្នកបើកបរនោះ ត្រូវភ្លើងឆេះពេលកលទៅជាមួយនឹងរថយន្តដែរ ។ ការពិនិត្យនិងសេចក្ដីរាយការណ៍ របស់ក្រុមព្រះនគរបាល បានផ្អែកទៅលើជំនឿថា រថយន្តដែលត្រូវភ្លើងឆេះនេះ ជារថយន្តរបស់ប្ដីនាងយូរ៉េត ឯអ្នករងគ្រោះស្លាប់ក្នុងរថយន្ត ក៏គឺប្ដីរបស់នាងយូរ៉េតនុ៎ះឯង ....



ហេតុការណ៍ដូចពោលមកនេះ បានកើតឡើងបីឆ្នាំកន្លងមកហើយ ...

កាលបើអត់ពីខ្មោចប្ដីទៅហើយ នាងយូរ៉េត ក៏នៅតែសំណាក់អាស្រ័យនៅក្រុងបាងកកដដែល ។ ក្រោយពេលចាត់ការធ្វើបុណ្យបូជាសពជូនខ្មោចប្ដីហើយ នាងយូរ៉េតរស់នៅដោយការស្ងប់ស្ងៀម ពុំសូវមានទាក់ទងនឹងអ្នកណាឡើយ ។ ផ្ទះរបស់នាងជាផ្ទះឈើប្រក់ស័ង្កសី សង់នៅលើដីភូមិមួយនៅជាយក្រុង តាមផ្លូវដែលចេញពីទីក្រុងទៅចន្ទបុរី ។

រឿងរ៉ាវអាថ៌កំបាំងចំមុខនេះ កាលពីបីឆ្នាំកន្លងទៅនេះ មានដំណឹងលេចឮថា ខ្មោចប្ដីនាងយូរ៉េត អាចសំដែងឥទ្ធិឫទ្ធិ ឲ្យកើតទៅជារូបមនុស្សបាន ។ មិនតែប៉ុណ្ណោះ ខ្មោចនេះ អាចនិយាយស្ដីឆ្លើយឆ្លងជាមួយនឹងនាងបានទៀតផង ។ រឿងនេះ មានមនុស្សលបមើលឃើញ ។ ដំបូងមានអ្នក

ឃើញតែពីរបីនាក់ប៉ុណ្ណោះ តែលុះដំណឹងនេះ ចេញពីមាត់មួយ ចូលត្រចៀកមួយទៀត ក៏រឹតតែលេចឮសុសសាយច្រើនឡើងៗ ស្ទើរតែពាសពេញប្រទេសថៃទាំងមូល ។

កាលបើដំណឹងនេះ លេចឮច្រើនឡើង ការងឿងឆ្ងល់របស់មហាជន ក៏រឹតតែមានច្រើនឡើងដែរ ពាល់តែក្លាយទៅជារឿងកាចិកំបាំងបិទមុខ និងជារឿងដែលមានជាប់នៅលើទំព័រសារពត៌មាន ។

ក្នុងការនាំសារចុះឡើងនៃពាក្យសំដី របស់សង្គមមនុស្ស សូម្បីអ្នកដែលពុំជឿខ្មោចបិសាចសោះក៏ដោយ ក៏បែរជាបណ្តោយពេលវេលាឲ្យខូចខាតទៅ ដោយសារតែការចង់ដឹង ចង់ឮ នូវរឿងនេះដែរ ។

ដោយហេតុថារឿងនេះ ពុំមែនជារឿងអាជ្ញា ពុំមែនជារឿងដែលបង្កប់អាចចូលទៅជ្រៀតជ្រែក ឬចូលទៅពាក់ព័ន្ធបានផងនោះ ខាងក្រុមព្រះនគរបាល ក៏គ្មានអំណាចកោះហៅ



នាងយូរ៉េត យកទៅសាកសួរករណីពិតបានឡើយ ។ មានអ្នកងឿងឆ្ងល់ជាច្រើនបាននាំគ្នាទៅចោមរោម សាកសួរនាងស្ទើរតែគ្មានចន្លោះពេលសោះ តែនាងយូរ៉េត ពុំព្រមឆ្លើយថាអ្វីឡើយ ក្រៅពីថា នាងពុំអាចបដិសេធនូវពាក្យចចាមអារ៉ាមដែលលេចឮថា បិសាចខ្មោចប្តីនាងប្រែក្រឡាខ្លួនជាមនុស្សមកជួបនឹងនាង តែក៏ពុំអាចធានាអះអាងថា រឿងនេះ ជារឿងពិតដែរ ។

" តែរឿងនេះ មានមនុស្សឃើញច្បាស់នឹងភ្នែកថា:

បិសាចខ្មោចប្តីរបស់អ្នកស្រីមកអង្គុយនិយាយគ្នា ជាមួយអ្នកស្រីនៅលើគ្រែក្រោមដើមក្រូចខាងមុខផ្ទះ " (អ្នកកាសែតម្នាក់និយាយជាមួយនាង ( យូរ៉េត )

" បើគេឃើញច្បាស់នឹងភ្នែកគេយ៉ាងនោះហើយ លោកចាំមកសួរខ្ញុំធ្វើអ្វីទៀត " ( នាងយូរ៉េតឆ្លើយ )

— តែខ្ញុំចង់ដឹងនូវករណីពិត ដែលចេញពីមាត់អ្នកស្រី

ឲ្យបានច្បាស់លាស់

– ប្រសិនបើមានមនុស្សគេបានឃើញច្បាស់និងភ្នែកគេទៅហើយ លោកគួរតែជឿតាមគេទៅចុះ ពុំចាំបាច់មកសាកសួរខ្ញុំធ្វើអ្វីទៀតទេលោក

– ប្តីរបស់អ្នកស្រីស្លាប់ដោយគ្រោះថ្នាក់ចរាចរមែនទេ ?

– ចាស !

– អ្នកស្រីធ្វើសក្ការបូជាសពប្តីរបស់អ្នកស្រីជានិច្ចឬ ?

– ចាស ខ្ញុំធ្វើជានិច្ច ! នេះជាកិច្ចវត្តពិសេសដែលខ្ញុំធ្វើរាល់ល្ងាចពុំដែលខាននោះ ។

– ចុះអ្នកស្រី បានឃើញបិសាចខ្មោចប្តីរបស់អ្នកស្រីរាល់ល្ងាចដែរឬ ?

– មិនដែលឃើញទេ ទើបតែមកឃើញក្នុងពេលថ្មីៗនេះ

– បើអញ្ចឹងបានសេចក្តីថា អ្នកស្រីបានឃើញបិសាចខ្មោចប្តីរបស់អ្នកស្រីពិតប្រាកដមែន មែនឬទេអ្នកស្រី ?



– ត្រង់នេះខ្ញុំពុំអាចបដិសេធបានទេលោក

– អ្នកស្រីជឿឬទេថាជាបិសាចខ្មោចប្តីរបស់អ្នកស្រី ?

– ខ្ញុំពុំជឿថាជាអីទេ ហើយក៏ពុំដឹងជាថាអ្វីទាំងអស់

– និយាយឆ្លើយឆ្លងគ្នាបានមែនទេអ្នកស្រី ?

– អ្នកណាជំរាបលោកថា និយាយឆ្លើយឆ្លងគ្នាបាន ?

– ទេ ! នេះខ្ញុំសួរអ្នកស្រី

– ចុះលោកយករឿងអីមកសួរខ្ញុំ ?

– គឺមានមនុស្សគេនិយាយលាន់ៗថា មានគេបានឃើញអ្នកស្រីនិយាយឆ្លើយឆ្លងគ្នានិងបិសាចខ្មោចប្តីរបស់អ្នកស្រី

– បើអញ្ចឹងគួរតែលោកអញ្ជើញទៅសាកសួរ អ្នកណាដែលគេនិយាយនោះទៅវិញទៅស្រួលជាជាង

– អ្នកស្រីពុំពេញចិត្តនឹងជួយបំភ្លឺខ្ញុំខ្លះក្នុងរឿងនេះទេឬ ?

– ខ្ញុំសុំជំរាបលោកតាមត្រង់ថា ខ្ញុំពុំ[illegible]ចិត្ត[illegible]នោះ

— បើខ្ញុំសុំដឹងបន្តិចតទៅទៀតបានឬទេ ជាព្រោះហេតុអី?

— ព្រោះយើងត្រូវតែគោរពចំពោះវិញ្ញាណក្ខន្ធ របស់បុគ្គលដែលស្លាប់ទៅហើយ, ប្ដីរបស់ខ្ញុំស្លាប់ទៅហើយ ខ្ញុំពុំពេញចិត្តឲ្យអ្នកណានាំយករឿងនេះ ទៅនិយាយឲ្យលេចឮឡើងយ៉ាងនេះយ៉ាងនោះគ្មានទីបំផុតសោះ ព្រោះពេលនេះជាពេលដែលគួរតែទុកឲ្យវិញ្ញាណក្ខន្ធនៃសពប្ដីរបស់ខ្ញុំ បានទទួលនូវការឈប់សំរាកដ៏សុខក្សេមក្សាន្ត ពុំគួរនឹងត្រូវរុកគួនអ្វីទេ

— តែជារឿងដែលទាក់ទងនឹងការងឿងឆ្ងល់ របស់មហាជន

— សុំលោកជួយប្រាប់មហាជន តាមទំព័រកាសែតរបស់លោកផងថា នេះជារឿងផ្ទាល់ខ្លួនរបស់ខ្ញុំតែឯកឯងទេ ពុំមែនជារឿងរបស់អ្នកដទៃឡើយ ។

ក្រោយពេលដែលអ្នកកាសែតចេញពីផ្ទះ របស់នាង



យូរ៉ែត ទៅហើយនាំយកពាក្យឆ្លើយ របស់នាងលើ ទៅចុះផ្សាយតាមទំព័រសារពត៌មាននោះ ក៏រឹតតែធ្វើឲ្យមហាជនងឿងឆ្ងល់ខ្លាំងឡើងទៀត ។ ប៉ុន្តែមានមនុស្សជាច្រើនគេគិតថា ពុំគួររវល់ក្នុងរឿងនេះ ដែលជាហេតុនាំឲ្យនាងយូរ៉ែត ខ្វល់ចិត្តនោះទេ ព្រោះម្ចាស់របស់រឿងគេពុំចង់ប្រាប់សោះ ដោយនាងគិតថា ជារឿងរបស់បុគ្គលដែលស្លាប់ទៅហើយ ។ បុគ្គលអ្នកស្លាប់ មានសិទ្ធិត្រូវតែបានទទួលសម្រាកសម្រាន្តជាសុខសាន្ត ពុំគួរជាត្រូវគេរុកគួនអ្វីឡើយ ។

នាង យូរ៉ែត បេះតែបដិសេធ ពុំព្រមបំភ្លឺអ្វីឲ្យបានសមនឹងសេចក្ដីស្រេកឃ្លានរបស់អ្នក ដែលចង់ដឹងចង់ឃើញនោះឡើយ ។

ការចង់ដឹងចង់ឃើញរបស់មហាជន រឹតតែមានឡើងៗ ។ នាងយូរ៉ែត បេះតែព្យាយាមគេចពីការរុកគួន របស់ពួកអ្នកសួរ តែក៏ពុំអាចគេចផុតឡើយ ។ ពេល

ដែលនាងត្រូវអុជទៀនធូប ធ្វើសក្ការបូជាសពប្ដីរបស់នាងនោះ ជាពេលយប់ ។ នាងដឹងខ្លួនថា មានមនុស្សលបមើលជានិច្ច ។ កាលបើត្រូវគេរុកគួនខ្លាំងឡើងៗ ។ នាងយូរ៉េត ក៏លក់ផ្ទះ ហើយនាំកូនធ្វើដំណើរចេញពីទីក្រុងបាងកក ។ អ្នកស្រុកជិតខាងក៏ឥតបានដឹងថានាងទៅនៅទីណាសោះឡើយ ។

រឿងដែលម្ដាយនិងកូនភៀសខ្លួនចេញបាត់ពីក្រុងបាងកកនោះ ជារឿងដែលគេអាចសន្និដ្ឋានបានដោយងាយ គេនាំគ្នានិយាយថា នាងយូរ៉េត ធុញទ្រាន់នឹងពួកអ្នកចង់ដឹង ចង់ឃើញ ដែលចេះតែទៅរំខានសាកសួរនាងអំពីរឿងរ៉ាវ ដែលនាងពុំចង់ប្រាប់ ។ ហេតុនេះហើយបានជានាងត្រូវភៀសខ្លួនចេញ ។ នាងយូរ៉េត ទៅតែខ្លួន ពុំបានយកអដ្ឋិធាតុប្ដីរបស់នាងទៅជាមួយផងឡើយ ។ ឯបិសាចនោះ កាលបើនាងយូរ៉េត ភៀសខ្លួនបាត់ទៅ ក៏លែងសំដែងឫទ្ធិ ប្រែក្រឡាឲ្យអ្នកណាឃើញទៀតដែរ ។



រឿងរ៉ាវទាំងអស់នេះ តែងឋិតនៅជារឿងបិទមុខនៅក្នុងក្រុងបាងកកដដែល ៗ សូម្បីនាងយូរ៉េត បានភៀសខ្លួនបាត់យូរទៅហើយក៏ដោយ ក៏មហាជននៅតែងឿងឆ្ងល់ដដែល ។ ពួកអ្នកកាសែត ដែលពុំទាន់អស់ការងឿងឆ្ងល់ក្នុងរឿងនេះ ក៏នៅតែលើកយករឿងដដែល ៗ នេះ ទៅចុះផ្សាយក្នុងទំព័រកាសែតរបស់ខ្លួនតាមការដៅស្មានរបស់ខ្លួន និងតាមពាក្យចចាមអារាមដែលគេបានឮមកពីប្រភពនេះខ្លះនោះខ្លះ ។ យូរៗទៅពាក្យចចាមអារាមក្នុងទំព័រកាសែតនោះ ក៏ជំទាស់តែគ្នាឯង ពុំអាចនឹងស្ដាប់យកសេចក្ដីត្រង់ណា ឬកាសែតណា ថាជាការណ៍ពិតប្រាកដបានឡើយ ។ អ្នកខ្លះថា ឃើញនាងយូរ៉េត នៅឯណេះ អ្នកខ្លះថាឃើញនៅឯណោះ អ្នកខ្លះទៀតថា បិសាចខ្មោចប្ដីរបស់នាងបាននាំនាងយកទៅ ... គិតៗទៅមានអណ្ដាតចេះតែរលាស់ ពុំពិចារណាឲ្យហ្មត់ចត់ ។ ដោយអាងតែអណ្ដាតឥតឆ្អឹង គេក៏ចេះតែនិយាយឲ្យតែរួច

ភិនាក់ ។ លុះគេនិយាយយូរទៅ ហើយច្រើនឡើងៗ ពាក្យសំដីក៏ពុំគាប់ចុះសម្រុងយល់ស្របគ្នាបានឡើយ ។

រហូតមកដល់ពេលឥឡូវនេះទៀត មើលទៅក៏ដូចជាគ្មាននរណាបានដឹងនូវការណ៍ពិតប្រាកដ នៃរឿងរ៉ាវរបស់នាងយូរ៉េកា នោះសោះឡើយ ។ ប៉ុន្តែខ្ញុំបានដឹង . , . . .

ការណ៍ពិតដែលទាក់ទងនិងរឿងរ៉ាវរបស់នាងយូរ៉េកា នោះបិតនៅក្នុងក្រញាំដៃរបស់ខ្ញុំ ។ ខ្ញុំអាចសរសេររឿងនេះផ្សាយដំណឹង ដើម្បីបំបាត់នូវការងឿងឆ្ងល់នៃអ្នកស្រុកឃ្មានដឹងបាន ព្រោះខ្ញុំបានពិនិត្យមើលទៅពុំឃើញថា ជារឿងដែលត្រូវបិទបាំងធ្វើអ្វីតទៅទៀតឡើយ ។ ប៉ុន្តែក្នុងពេលនេះ ខ្ញុំនៅពុំទាន់ដកបនរណាឲ្យដឹងថា នាងយូរ៉េកា នៅឯណា ខ្ញុំនៅឯណា មានជីវិតប្រព្រឹត្តទៅយ៉ាងណាឡើយ ។

ការណ៍ដែលខ្ញុំត្រូវលាក់ខ្លួនពួនរកគ្នានោះ ក្រៅពីមានហេតុផលតាមរឿងដែលនឹងត្រូវបរិយាយតទៅខាងមុខនោះ



ចេញ ខ្ញុំនៅមានសេចក្តីត្រូវការម្យ៉ាងទៀត គឺការស្ងប់ស្ងាត់ក្នុងជីវិតរបស់ខ្ញុំ ។ ខ្ញុំធុញទ្រាន់ចំពោះការប្រព្រឹត្តទៅនៃពិភពលោកជាខ្លាំង ។ ខ្ញុំបានទទួលដល់វត្តសក្តិសិទ្ធិក្នុងលោក សុំជួយបណ្តាលឲ្យមនុស្សលោកចេះស្រឡាញ់រាប់អានគ្នា ចេះជួយគ្នា អនុគ្រោះគ្នា សន្តោសគ្នា កុំឲ្យមានចិត្តដូចក្នុងរឿងរ៉ាវរបស់នាងយូរ៉េកា ដែលខ្ញុំនឹងសរសេរតាមការណ៍ពិតដែលខ្ញុំបានដឹងបានឮនេះ ។

រឿងរ៉ាវក្នុងជីវិតរបស់នាងយូរ៉េកា ជារឿងរ៉ាវដែលគួរដឹង ព្រោះជារឿងរ៉ាវក្នុងជីវិតមួយ មានសភាពប្លែកពីជីវិតធម្មតា តែក៏ពុំមែនជាប្លែកពាលតែផុតវិស័យមនុស្សលោកនេះ ។ បើយើងព្រមទទួលថា ក្នុងលោកនេះ គ្មានអ្វីប្លែក គ្មានអ្វីថ្មី រឿងរ៉ាវរបស់នាងយូរ៉េកា នេះ ក៏ជារឿងរ៉ាវធម្មតាដែរ តែថារឿងរ៉ាវធម្មតានេះឯង មានច្រើនបែប ច្រើនយ៉ាងណាស់ ហើយ ការប្រព្រឹត្តទៅនៃជីវិតរបស់មនុស្សយើង ក៏ជាការដែល

យើងរៀនពុំចេះអស់ពុំចេះចប់ និងគ្មានទីបំផុត ។ ក្នុងលោកនេះគ្មានអ្នកណាមួយអាចសន្និដ្ឋានបានថា ខ្លួនបានរៀនចេះចប់ខ្វូរឿងរ៉ាវនៃជីវិតនេះឡើយ ព្រោះថារឿងរ៉ាវនៃជីវិតនោះ បើយើងរៀនច្រើនៗទៅ យូរៗទៅ ក៏រឹងរិតតែដឹងខ្លួនៗឯងថា យើងចេះតិច ចេះពុំអស់ ចេះពុំចប់ ហើយក៏ចេះតែត្រូវការបន្តរៀនតទៅមុខទៀតជានិច្ច ។

## វគ្គទី ២

# ដើមហេតុនៃរឿង

មេឃស្រឡះអាកាសក្តៅ ។ ព្រះអាទិត្យកំពុងតែរៀបអស្តង្គតទៅហើយ ដោយបានបញ្ចេញនូវរស្មីពណ៌ក្រហមឆ្អៅពាសពេញផែនដី ។

នាកណ្តាលសភាពក្តៅស្អាប់ស្អុះនៃធាតុអាកាសយ៉ាងនេះ នៅតាមផ្លូវភ្នំពេញ-កំពត មានរថយន្តធ្វើចរាចរទៅមកជាច្រើន ដែលជាការណ៍អាចធ្វើឲ្យមនុស្សម្នាក់វិលមុខបាន ប្រសិនបើមនុស្សនោះ ឈរចាំតែមើលរថយន្តទាំងនោះ ។ ប៉ុន្តែថ្ងៃនេះ ការធ្វើចរាចរនៃរថយន្តចូលមកទីក្រុងភ្នំពេញច្រើនជាងចេញទៅកំពត ព្រោះថ្ងៃនេះជាថ្ងៃអាទិត្យ ។ ពួកអ្នកធំនិងអ្នកមាននៅកជធានី តែងនាំគ្នាធ្វើដំណើរទៅស្រូបយកអាកាសបរិសុទ្ធនៅកែប នៅវេលាល្ងាចថ្ងៃសៅរ៍ លុះល្ងាចថ្ងៃអាទិត្យគេត្រូវធ្វើដំណើរត្រឡប់មករាជធានីវិញ ម៉ោះហើយ

នៅតាមដងផ្លូវភ្នំពេញ-កំពត តែងមានសេះរទេះគ្រឿងចក្រ និង ស៊ីក្លូរថយន្តគ្រប់ម៉ាកគ្រប់ម៉ូតជាប់ៗគ្នា រសៀវតែពុំដាច់សូរៗ

ល្ងាចនេះ ខ្ញុំក៏បានរួមធ្វើដំណើរត្រឡប់មកភ្នំពេញវិញ ជាមួយនឹងមិត្តជិតស្និទ្ធម្នាក់ ដោយរថយន្តដឹកអ្នករបស់គេ ហើយដែលម្ចាស់គេជាអ្នកកាន់ចង្កូតដែរ ។ មិត្តរបស់ខ្ញុំ ធ្លាប់បើកឡានដូចគេហោះ តែពេលនោះ គេបើកក្នុងល្បឿនធម្មតា ព្រោះយើងរវល់ជជែកគ្នា ពីនេះ ពីនោះលេង ដោយការសប្បាយរីករាយ ដែលជាការជួយបន្ធូរការធុញទ្រាន់ ក្នុងពេលដែលយើងធ្វើដំណើរត្រឡប់មកផ្ទះវិញ ។

— សំឡាញ់ ! គ្នាដូចជាឆ្ងល់ទឹងឯងណាស់ ! ( មិត្តរបស់ខ្ញុំ បានសួរខ្ញុំ ក្នុងខណៈដែលរថយន្តបានលួនឆ្លងចេញផុតពីតាកែវ ) ហេតុដូចម្តេច ក៏បានជាឯងចេះតែប្រកែកនឹង បំណងល្អរបស់ប៉ាទីងមាក់ឯង ក្នុងរឿងគូស្រករបស់ឯង ។

ខ្ញុំងាកមើលមុខសំឡាញ់របស់ខ្ញុំ ដោយការងឿងឆ្ងល់ថា



ហេតុអ្វីក៏បានជាគេលើកយករឿងគូស្រករនេះមកនិយាយ

— សំឡាញ់ ! គ្នាមិនចង់ឮរឿងហ្នឹងសោះ តែបើឯងចង់ដឹង គ្នាក៏ពេញចិត្តនឹងប្រាប់ឯងឲ្យបានដឹងដែរ ( ខ្ញុំឆ្លើយ ) រឿងប្រពន្ធពុំខុសគ្នាពីផ្ទះប៉ុន្មាន ផ្ទះដែលយើងនៅជាសុខសាន្តបាន គឺផ្ទះដែលយើងពេញចិត្ត ដូច្នេះមុននឹងសង់ផ្ទះ ត្រូវយើងរៃលកទៅតាមចិត្ត ដែលយើងស្រឡាញ់ បើយើងឲ្យគេសង់ឲ្យដោយពុំបានប្រាប់ថា យើងស្រឡាញ់ផ្ទះបែបនេះ បែបនោះទេ ផ្ទះនោះមុខជាទាស់ចិត្តយើង ឯប្រពន្ធវិញក៏យ៉ាង នោះដែរ បើប៉ាម៉ាក់ខ្ញុំពេញចិត្ត តែគ្នាពុំស្រឡាញ់ តើឲ្យគ្នារៀបការជាមួយយ៉ាងម៉េចកើត ឯងគិតមើល ! យើងត្រូវនៅរួមរស់ជាមួយគ្នាអស់មួយជីវិត ចុះបើយើងពុំពេញចិត្តនឹងគ្នា ពុំស្រឡាញ់គ្នា តើឲ្យនៅជាមួយគ្នាយ៉ាងម៉េចកើតសំឡាញ់ !

— ហ៊ឹះ ! ( សំឡាញ់របស់ខ្ញុំដកដង្ហើមធំ ហើយនិយាយតទៅទៀត ) រឿងនេះដូចជាពិបាកគិតដែរ តែគ្នាសង្កេតឃើញ

ថាប៉ាខឹងម៉ាក់ឯង ពិបាកចិត្តខឹងឯងខ្លាំងណាស់ ព្រោះលោកគិតថា ឯងពុំតាមទុកទេលោក

— រឿងអ្វីៗ គ្នាអាចធ្វើតាមបំណងលោកបានទាំងអស់ តែរឿងនេះ គ្នាដូចជាធ្វើតាមពុំកើត ព្រោះគ្នាយល់ថា រូបគ្នានេះទេតើ ដែលជាអ្នកទទួលបន្ទុកដ៏ធ្ងន់ ក្នុងគ្រួសារតទៅអនាគត —

— ពិតណាស់ហើយសំឡាញ់ ! គ្នាក៏យល់ចិត្តយល់ថ្លើមឯងណាស់ហើយដែរ តែការណ៍ដែលគ្នាលើកយករឿងនេះមកនិយាយ ក៏ពុំមែនប្រែសេចក្ដីថា គ្នាបង្ខិតបង្ខំឯងទេ ។

បរិយាកាសបានស្ងប់ស្ងៀមមួយសន្ទុះ ដោយយើងគ្មានឮអ្វីក្រៅពីស្នូរនៃរថយន្ត ។ បន្តិចមកយើងក៏បានចាប់ផ្ដើមនិយាយលេងពីនេះពីនោះតទៅទៀត ដោយការសប្បាយរីករាយ ។ យូរៗ សំឡេងសើចក្អាកក្អាយនៃយើងទាំងពីរក៏បានលាន់ឮឡើងបង្គ្របលើសម្លេងរថយន្តម្ដងៗ ។



ការធ្វើដំណើរហាក់ដូចជាឆាប់រហ័សសម្រាប់អ្នកពុំគិតគូរពីរយៈចម្ងាយផ្លូវ ។ រថយន្តបានលូនចូលមកដល់អង្គតាសោម ក្នុងខណៈដែលយើងពុំបានដាច់កថា ។ សំឡាញ់របស់ខ្ញុំក៏បានបញ្ឈប់រថយន្តនៅទីនោះ ហើយយើងទាំងពីរនាក់ក៏បានចុះទៅទទួលទានភេសជ្ជៈនៅក្នុងភោជនីយដ្ឋានមួយ ។

អង្គតាសោម ជាកន្លែងពិសេស សំរាប់ទទួលភ្ញៀវទេសចរទាំងទៅទាំងមក . . . . . ក្នុងភោជនីយដ្ឋានមួយៗ តែងមានភ្ញៀវចូលទៅអង្គុយបរិភោគអាហារ ឬ ភេសជ្ជៈយ៉ាងត្រៀបត្រា ពុំសូវមានកន្លែងទំនេរ . . .

យើងបានចូលទៅអង្គុយនៅត្រង់តុទំនេរមួយ ដែលឋិតនៅចំកណ្ដាល ព្រោះអ្នកដែលចូលទៅមុនបានរើសយកតុដែលនៅខាងៗអស់ ។ យើងបានទទួលទានទឹកដូងដ៏មានឱជារស ព្រោះការស្រេកទឹករបស់យើងៗ ។ យើងបានអង្គុយសន្ទនាគ្នាយ៉ាងស្ងប់ស្ងៀម ។ ក្នុងខណៈជាមួយ

គ្នានេះ ខ្ញុំបានចាប់អារម្មណ៍ទៅលើគូមួយ ដែលឋិតនៅពីខាងលិចខ្ញុំ ។ គូនោះ មានមនុស្សអង្គុយបីនាក់ គឺបុរសឋិតនៅក្នុងផ្នែកកណ្ដាលម្នាក់ ស្រីចំណាស់ម្នាក់ និងសុភាពនារីម្នាក់ទៀត ។ ការអ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍នោះ គឺខ្ញុំបានសង្កេតឃើញថា មនុស្សទាំងបីនាក់នេះ និយាយគ្នាយ៉ាងតិចជាទីបំផុត ។ ម្នាក់ៗសុទ្ធតែមានទឹកមុខស្រពោនក្រៀមក្រំ វៀរលែងតែបុរសចេញ ដែលមើលទៅហាក់ដូចជាមានការសប្បាយរីករាយណាស់ ក្នុងការដែលគេខំយកចិត្តយកថ្លើមសុភាពនារី ។ ប្រសិនបើការស្មានរបស់ខ្ញុំពុំខុស ខ្ញុំគិតថាសុភាពនារីនេះ មានអាយុយ៉ាងច្រើន២២ឆ្នាំ ។ ដំបូងខ្ញុំគិតថាបុរសនិងស្រីទាំងពីរនាក់នេះ ជាប្ដីប្រពន្ធនឹងគ្នា ឯយាយចាស់ម្នាក់ទៀតនោះ គឺប្រហែលជាម្ដាយរបស់បុរសឬស្ត្រីនោះ ។

ខ្ញុំបានលួចពេលកន្ទុយភ្នែកក្រឡេកមើលយូរៗ ទៅឃើញសុភាពនារីនោះ ដូចជារឹតតែស្អាតឡើងៗ ស្អាតទាល់



តែអាចស្រូបទាញក្រសែភ្នែករបស់ខ្ញុំ ឲ្យចេះតែលួចសំឡឹងទៅនាង ។ ប្រសិនបើការសង្កេតពិនិត្យមើលរបស់ខ្ញុំ ពុំខុសទេនោះ ស្រីដ៏ស្អាតដែលខ្ញុំចាប់អារម្មណ៍នេះ គ្មានការត្រេកត្រអាល ឬរីករាយអ្វីជាមួយនឹងបុរសដែលនាំមកជាមួយនេះឡើយ ។ ទឹកមុខរបស់នាងបានសំដែងឲ្យឃើញនូវអាការពុំសូវជាសប្បាយរីករាយ ។ សូម្បីក្នុងពេលដែលបុរសនោះនិយាយជាមួយ ក៏មើលទៅនាង ហាក់ដូចជាពុំយកចិត្តទុកដាក់ចង់ស្ដាប់ឡើយ ហើយនិយាយឆ្លងឆ្លើយទៅបុរសនោះវិញក៏តិចតួចដែរ ហើយក្នុងពេលនិយាយនោះទៀត នាងក៏ពុំសំឡឹងមើលមុខបុរសនោះផង ។ ខ្ញុំបានលួចគិតតែម្នាក់ឯងថា អាការជ្រប់ស្រពោនយ៉ាងនេះ ជាការសំដែងឲ្យដឹងថា នាងប្រហែលជាមានទុក្ខព្រួយអ្វីម្យ៉ាងនៅក្នុងទ្រូង ។

— ខែ / សំឡាញ់ (សំឡាញ់របស់ខ្ញុំសួរខ្ញុំតិចៗ ក្នុងខណៈដែលខ្ញុំកំពុងតែលួចសង្កេតមើលគេ) គ្នាសង្កេតមើល

នៅឯង ហាក់ដូចជាចាប់អារម្មណ៍នឹងស្រីនោះណាស់

– អញ្ចឹងឬ ? (ខ្ញុំសួរទៅវិញ)

– ជាប់ចិត្តមែនឬទេសំឡាញ់ ? (គេសួរបញ្ឆាក់ខ្ញុំម្ដងទៀត)

ខ្ញុំពុំឆ្លើយថាអ្វី ។ ខ្ញុំលួចចោលកន្ទុយភ្នែកមើលនាងតទៅទៀត ។ សភាពការណ៍ក៏បានប្រព្រឹត្តទៅដូចដើមគឺ បុរសនិយាយច្រើន ស្រីនិយាយតិច ។ នេះជាលក្ខណៈដែលនិយាយបានយ៉ាងងាយថា អ្នកទាំងពីរនាក់នេះមុខជាមានការអើពើចិត្តនឹងគ្នាក្នុងរឿងអ្វីមួយពុំខាន ។

ការដែលខ្ញុំនៅស្ងៀមពុំឆ្លើយថាអ្វីនោះ មិត្តខ្ញុំបានយល់ច្បាស់ថា ខ្ញុំពុំបានបដិសេធនូវសំនួររបស់គេឡើយ ។

ក្នុងខណៈដែលយើងនៅស្ងៀមនេះ អ្នកទាំងបីនាក់ក៏នាំគ្នាក្រោកដើរចេញពីតុសំដៅទៅរករថយន្ត ដែលគេចតទុកនៅខាងក្រៅ ដោយបុរសជាអ្នកដើរនាំមុខ ។ ភោជនីយដ្ឋាន



នេះ មានតុកៅអីជាច្រើន ម្ល៉ោះហើយចំកន្លែងក៏ចង្អៀតស្ទើរតែគ្មានផ្លូវដើរ ។ នៅពេលដែលគេដើរចេញមកដល់តុដែលយើងអង្គុយ គេគួរតែលៃលកដើរឲ្យបានស្រួលដើម្បីកុំឲ្យមានការប៉ះទង្គិច ឬបើមានការប៉ះទង្គិចបន្តិចបន្តួចក៏គួរណាស់តែសូមអភ័យទោសពីយើង តែនេះផ្ទុយទៅវិញ, គេដើរធ្វើឫកព្រងើយ មកប៉ះនឹងកៅអីដែលសំឡាញ់របស់ខ្ញុំអង្គុយហើយ ក៏ធ្វើឫកព្រងើយដើរហួសទៅទៀត ។ ការដើរមកប៉ះនេះ ក៏ខ្លាំងល្មមធ្វើឲ្យទឹកដូងក្រឡុកចេញពីកែវហៀរទៅលើតុ នារីដែលដើរតាមក្រោយមកនោះ ក៏ហាក់ដូចជាភ្ញាក់ស្រឡាំងកាំងនឹងអាការៈបែបនេះដែរ តែនាងក៏ពុំស្ដីថាអ្វី ហើយក៏ដើរហួសទៅទៀត ។ តាមការសង្កេត ខ្ញុំយល់ឃើញថា នាងដឹងនូវកំហុសរបស់បុរសដែលនាងមកជាមួយនោះដែរ ហើយនាងក៏ពុំពេញចិត្តនឹងសភាពបែបនេះដែរ តែនាងពុំដឹងជាធ្វើដូចម្ដេច ក្រៅពីគ្រាន់តែចោលក្រសែភ្នែក

ក្រឡេកមើលមុខខ្ញុំដោយអន្ទីករនោះឡើយ ។

គ្រាន់តែខ្ញុំងាកមុខមកខាងគេភ្លាម សំឡាញ់របស់ខ្ញុំក៏ក្រោកឡើងយ៉ាងឆាប់រហ័ស ហើយស្ទុះទៅតាមបុរសនោះដែលដើរផុតទៅហើយប្រហែលជាប្រាំម៉ែត្រ ។ សំឡាញ់របស់ខ្ញុំក៏ជាសភាពបុរស ដែលមានទឹកចិត្តជាអ្នកកីឡាដែរ ។ គេពុំរាយមនុស្សពីខាងក្រោយដោយអ្នកម្នាក់ពុំដឹងខ្លួនឡើយ ។ គេស្ទុះទៅតាមបុរសនោះហើយ ក៏គេះស្មាបុរសនោះ ឲ្យងាកមុខមករកគេ ។

ដោយសារពាក្យសំដីតិចពេក ខ្ញុំក៏ពុំអាចឮឲ្យបានច្បាស់លាស់ថា តើសំឡាញ់របស់ខ្ញុំបានសួរបុរសដល់លើយនោះថាដូចម្ដេចឡើយ តែខ្ញុំសង្កេតឃើញថា សំឡាញ់របស់ខ្ញុំបានប្រើកិរិយាយ៉ាងសុភាពរាបសា ទៅរកបុរសនោះ ។ ខ្ញុំបានឮជាក់ច្បាស់នូវពាក្យសំដីរបស់បុរសនោះ ដែលនិយាយមករកសំឡាញ់របស់ខ្ញុំ ។ ពាក្យសំដីនោះ ជា



ពាក្យសំដីយ៉ាងព្រហើនកោងកាច ដែលសូម្បីតែរូបខ្ញុំ មើលទៅក៏ពិបាកនឹងអត់ធុនឲ្យដែរ ។ គេនិយាយទាំងកម្រោលថា "គេដើរតែតាមផ្លូវ គេឥតដើរជាន់ក្បាលអ្នកណាទេ" ។

គ្រាន់តែឮបុរសនោះនិយាយដោយពាក្យសំដីព្រហើនកោងកាចដូច្នេះ ខ្ញុំក៏ស្ទុះចូលទៅដែរ ។ ការដែលខ្ញុំស្ទុះចូលទៅនេះ គ្មានបំណងអ្វីក្រៅពីគិតថា ស្ទុះទៅឃាត់អ្នកទាំងពីរកុំឲ្យមានរឿងរ៉ាវឈ្លោះទាស់ទែងគ្នាទេ ព្រោះខ្ញុំធ្លាប់ស្គាល់ចិត្តសំឡាញ់របស់ខ្ញុំថា ជាមនុស្សមានចិត្តឆេវឆាវពុំសូវគិតមុខគិតក្រោយ ។ ខ្ញុំមានស្ទុះទៅទាន់ឯណា ពុំទាន់ស្ទុះទៅដល់ផង ស្រាប់ក៏លាន់ឮឡើង ។ នេះជាស្នូរដៃដែលសំឡាញ់ខ្ញុំបានដាល់ត្រូវកញ្ចប់មាត់របស់បុរសព្រហើននោះ បន្ទាប់គ្នានឹងពាក្យកោងកាច ដែលគេបាននិយាយមកកាន់សំឡាញ់របស់ខ្ញុំ ។ បុរសនោះទ្រេតទ្រោតតេះតះទៅខាងក្រោយ តែរាទប់ខ្លួនបាន ក៏ស្ទុះចូលមកម្ដងទៀតដូចខ្លាត្រូវបួស ប៉ុន្តែក៏

ត្រូវថែមមួយផាច់ទៀត ។ ម្តងនេះ បុរសនោះដួលអុកគួចទៅលើដី ។ ខ្ញុំក៏ចូលទៅកាំងពីមុខសំឡាញ់របស់ខ្ញុំ ហើយទាញដៃគេដើរត្រឡប់ទៅរកគូវិញ ។

– គួរតែប្រដៅកឲ្យខ្លាំងជាងនេះបន្តិច អាដំលើយថែបហ្នឹង ! ( សំឡាញ់ខ្ញុំបាននិយាយ )

– ណ្ហើយ ! ប៉ុណ្ណឹងបានហើយកុំឲ្យខ្មាសគេ សព្វបើរឿងតិចតួចអញ្ចឹង ! ( ខ្ញុំនិយាយ )

មនុស្សម្នាក់បានផ្អើលងាឡេឡើងមើលការណ៍ដែលបានកើតឡើងនោះ ។ បុរសនោះក្រោកឈរឡើងហើយក៏និយាយឡូឡា តែខ្ញុំក៏ពុំអាចស្តាប់បានថា គេនិយាយអ្វីឡើយ ព្រោះសំឡេងអ៊ូរអែនៃមនុស្សដែលភ្ញាក់ផ្អើលនោះ ឮឡើងខ្លាំងពេក ។

មួយសន្ទុះក្រោយមក បុរសនោះក៏ដើរទៅឡើងជិះរថយន្តហើយក៏បើកបរចេញបាត់ទៅ ។



សភាពឡោឡាក៏រលាយបាត់ បរិយាកាសស្ងប់ស្ងាត់ក៏កើតមានឡើងវិញនៅក្នុងភោជនីយដ្ឋាន ។ យើងបាននាំគ្នាអង្គុយនៅតុដើមវិញ ។ ក្នុងបរិយាកាសស្ងប់ស្ងាត់នេះ ការងឿងឆ្ងល់ក៏កើតឡើងទៀតដល់រូបខ្ញុំ ពីដើមខ្ញុំគិតថា បុរសស្ត្រីនេះជាប្តីប្រពន្ធរបស់គេ តែឥឡូវខ្ញុំដូចជានឹកសង្ស័យថាពុំមែនទៅវិញ ព្រោះខ្ញុំបានសង្កេតឃើញ បុរសនោះកាន់ចង្កូតរថយន្តបើកបរដោយខ្លួនឯង ហើយស្រីចាស់អង្គុយខាងមុខជាមួយ ឯសុភាពនារីអង្គុយខាងក្រោយតែម្នាក់ឯងទៅវិញ ឃើញដូច្នេះ ខ្ញុំប្រែសេចក្តីថា បុរសស្ត្រីនេះ ពុំមែនជាប្តីប្រពន្ធឡើយ ព្រោះបើប្តីប្រពន្ធរបស់គេ គេមុខជាអង្គុយខ្ទឹមគ្នានៅខាងមុខ ដោយទុកឲ្យស្ត្រីចាស់នោះអង្គុយខាងក្រោយជាពុំខាន ។

លុះរថយន្តរបស់បុរសព្រហើននេះ ចេញផុតបន្តិចទៅ បុរសម្នាក់ដែលអង្គុយនៅជិតតុខ្ញុំ បានងាកមុខមកនិយាយ

ប្រាប់សំឡាញ់របស់ខ្ញុំថា បុរសដំលើយអម្បាញ់មិញនេះ ជាអនុសេនីយ៍ទោ លោកមេទ័ពដាប-ឈួន នៅសៀម-រាប ឯស្ត្រីទាំងពីរនាក់នោះ គេក៏ពុំបានស្គាល់ដែរ តែគេបានបញ្ជាក់ថា ពុំមែនជាប្រពន្ធរបស់បុរសនោះឡើយ ព្រោះគេធ្លាប់ស្គាល់គ្រួសារនៃអនុសេនីយ៍ទោនោះ ។ គេនិយាយតទៅទៀតថា អនុសេនីយ៍ទោនេះឈ្មោះ ស៊ី ជាមនុស្សកោងកាចសាហាវជាទីបំផុត ។ អនុសេនីយ៍ទោនេះ ជាសេនាឆ្វេងរបស់ដាប-ឈួន ។ អ្នកស្រុកសៀមរាបខ្លបខ្លាចនាយទាហាននេះ ស្ទើរតែពុំហ៊ានមើលមុខចំផង ព្រោះវាធ្លាប់សម្លាប់មនុស្សស្ទើរតែរាប់ពុំអស់មកហើយ . . .

គ្រាន់តែឮដូច្នេះ ខ្ញុំដូចជាមានការព្រួយបារម្ភបន្តិចដែរ ព្រោះខ្ញុំគិតថា ក្រែងលោថ្ងៃក្រោយនឹងកើតរឿងរ៉ាវធំដុំទៅទៀត ព្រោះបក្សពួកដាប-ឈួនសម័យនោះមានឥទ្ធិពលយ៉ាងខ្លាំង ។ តែចិត្តមួយគិតថា ពុំគួរជាភ័យខ្លាចអ្វីទេ ព្រោះ



ថាបើទុកជាបក្សពួកកូនចៅដាប-ឈួនវាមានឥទ្ធិពល ក៏វាមានតែឯសៀមរាបឯណោះទេ វាពុំអាចប្រើឥទ្ធិពលរបស់វាឲ្យមកគ្របសង្កត់លើរូបខ្ញុំនិងសំឡាញ់របស់ខ្ញុំ ដែលនៅឯភ្នំពេញឯណេះបានឡើយ ហើយម្យ៉ាងទៀត ខ្ញុំនិងសំឡាញ់របស់ខ្ញុំក៏ជានាយទាហានដែរ តែសភាពនាយទាហានរបស់យើងនេះ យើងពុំដែលប្រើអំណាចកោងកាចជិះជាន់អ្នកណាឡើយ ។ យើងបានតាំងចិត្តជានិច្ចថា សភាពជានាយទាហានរបស់យើងនេះ ជារបងសំរាប់ការពារប្រទេសជាតិមាតុភូមិ . . .

ហើយ ក្នុងសម័យសង្គម ដែលសម្តេចសហាជីវិនគ្រង់ចាងដឹកនាំនេះ ទាហានយើងក្រោមកិច្ចចាត់ចែង នៃលោកឧត្តមសេនីយលន់-នល់ ជាទេសរដ្ឋមន្ត្រីការពារប្រទេសនិងជានាយអគ្គសេនាធិការកងទ័ពជាតិ ពុំគ្រាន់តែជារបងការពារប្រទេសតែប៉ុណ្ណោះទេ

ដែលដាំដំណាំនាំគ្នា ជួយស្ថាបនាជាតិគ្រប់វិស័យ មានការស្ថាបនា ផ្លូវថ្នល់ ស្ពាន សាលារៀន ផ្ទះពេទ្យ វត្តអារាម និងទីតាំងខេត្តថ្មីៗ ជាដើមទៀតផង . . . . .

ក្រោយការកើតហេតុនោះបន្តិចមក យើងក៏នាំគ្នាបន្តដំណើរមកភ្នំពេញទៀត ។ ខ្ញុំភ្លេចប្រាប់ឈ្មោះសំឡាញ់របស់ខ្ញុំនេះ តើគេឈ្មោះអ្វី ? គេឈ្មោះសុខ-សម្បូរ ។ យើងធ្លាប់រៀននៅក្នុងសាលានាយទាហានជាមួយគ្នា ។ ក្នុងសម័យនោះសុខ-សម្បូរ ក៏ដូចរូបខ្ញុំដែរ យើងមានឋានន្តរស័ក្តិជាអនុសេនីយទោដែរ តែគេធ្វើការនៅក្នុងកងកាំភ្លើងធំ ឯរូបខ្ញុំវិញ ធ្វើការនៅក្នុងការិយាល័យទី ២ នៃអគ្គសេនាធិការកងយោធពលខេមរភូមិន្ទផ្នែកចារកម្ម ។

វគ្គទី ៣

## ជួនជាជួប

យប់នេះ ខ្ញុំទទួលបានដំណេកពុំលក់សោះ បើទុកជាខំធ្មេចភ្នែកយ៉ាងណាក៏ដោយ ។ ខ្ញុំចេះតែស្រមៃឃើញវង្សភក្ត្ររបស់សុភាពស្ត្រី ដែលខ្ញុំបានជួបនៅឯអង្គតាសោមកាលពីថ្ងៃដែលហាក់ដូចជាមានអ្វីមកជម្រុញចិត្តខ្ញុំឲ្យគិតថា នាងប្រហែលជាមានការលាក់កំបាំងអ្វីមួយនៅក្នុងខ្លួន . . . ខ្ញុំបាននឹកឃើញជម្លោះកាលពីថ្ងៃ . . . ខ្ញុំដណ្ដឹងសួរខ្លួនឯងថា ខ្ញុំជាប់ចិត្តជាប់ថ្លើមស្រឡាញ់នាងឬ ? ខ្ញុំពុំអាចឆ្លើយខ្លួនឯងបានឡើយ ប្រសិនបើខ្ញុំឆ្លើយថា ខ្ញុំស្រឡាញ់នាង ក៏ដូចជាពុំសមព្រោះខ្ញុំគ្រាន់តែបានឃើញមុខនាងម្ដងប៉ុណ្ណោះ ពុំទាន់បាននិយាយស្ដីជាមួយគ្នាផង តែបើឆ្លើយថាពុំស្រឡាញ់ ក៏ដូចជាពុំសមដែរ ព្រោះខ្ញុំចេះតែស្រមៃឃើញនាងនៅជាប់នឹងភ្នែកជានិច្ច . . .

ខ្ញុំបានភ្ញាក់ពីដំណេក នៅពេលដែលខ្ញុំបានឮសំឡេងនាឡិកាក្មេងរាយម៉ោង ៧ ។ ខ្ញុំគិតថា ខ្ញុំទើបតែនឹងធ្មេចភ្នែកលក់តែមួយស្រឡេតប៉ុណ្ណោះ ក៏ស្រាប់តែដល់ពេលថ្ងៃរះខ្ពស់ណាស់ទៅហើយ ..... ខ្ញុំចាំបាច់ត្រូវស្ទុះក្រោកឡើងពីដំណេកយ៉ាងឆាប់រហ័ស ដើម្បីរៀបចំខ្លួនប្រាណទៅធ្វើការ ព្រោះថ្ងៃនេះយឺតពេលបន្តិចទៅហើយ .....

ក្នុងខណៈដែលរថយន្តហ្ស៊ីបរបស់ខ្ញុំកំពុងតែលូនយ៉ាង-លឿនតាមដងវិថីព្រះសីហនុ ខ្ញុំក៏ដូចជានឹកស្រមៃដល់សុភាពស្ត្រីកាលពីម្សិលមិញនោះទៀត ។ ខ្ញុំហាក់ដូចជាភាំងស្មារតីមួយភ្លែត ។ ព្រោះតែការនឹកស្រមៃនោះ ។

នៅពេលដែលរថយន្តបានធ្លងផុតមហាវិថីព្រះមុនីវង្ស ហើយសំដៅទៅទិសខាងកើត តាមដងវិថីព្រះសីហនុដដែលនោះ ខ្ញុំដូចជាធ្លាក់ថ្លើមក្តុកដោយការរំភើបចិត្ត ក្នុងពេលដែលខ្ញុំបោលភ្នែកក្រឡេកមើលតាមផ្លូវខាងត្បូង ... ខ្ញុំបាន



ដួចប្រៈ ទិនីនារីដែលខ្ញុំស្រមៃឃើញ ហើយដែលខ្ញុំពុំបាននឹកនាថានឹងបានជួប ! ... ខ្ញុំបានឃើញនាងឈរនៅត្រង់រោងណាំងផ្ទះខាងមុខ សំឡឹងមកខាងដងផ្លូវ ... ខ្ញុំដូចជាកុំចង់ជឿភ្នែកខ្លួនឯង ... ខ្ញុំគិតថាក្រែងប្រឡំទេដឹង ព្រោះមនុស្សមានមុខមាត់ស្រដៀងៗគ្នានោះច្រើនណាស់ ! ខ្ញុំពុំប្រឡំទេ ព្រោះភ្នែករបស់ខ្ញុំនៅភ្លឺល្មមតែស្គាល់ច្បាស់ មិនតែប៉ុណ្ណោះសោត រង្វង់មុខទន់ភ្លន់របស់នាង ខ្ញុំនៅចាំបានពិតប្រាកដណាស់ ព្រោះតាំងពីបានឃើញនៅអង្គតាសោមមកនោះ ខ្ញុំក៏ចេះតែស្រមៃឃើញនាងនៅជាប់នឹងភ្នែកជានិច្ច ដែលជាហេតុល្មមតែធ្វើឲ្យខ្ញុំប្រឡំពុំកើត ...

ខ្ញុំបានចំណាំផ្ទះរបស់នាងទុក ... ខ្ញុំជឿជាក់ថា ខ្ញុំគាបត្រឡប់មករកផ្ទះនាងនេះឃើញដោយឥតពិបាក ...

ថ្ងៃនេះពេញមួយថ្ងៃ ខ្ញុំអង្គុយធ្វើការដោយការអន្ទះសាក្នុងចិត្ត ។ ខ្ញុំចេះតែស្រមៃឃើញនាង ហើយចេះតែចង់

ទៅរកនាង ចង់ទៅរកនាងធ្វើអ្វី ? មានការអ្វី? ខ្ញុំពុំអាចឆ្លើយនឹងខ្លួនឯងរួច ។ ទីបំផុត ខ្ញុំបានសម្រេចចិត្តថា ត្រូវតែទៅរកនាង ទៅរកដើម្បីសុំទោសសុំពៃនាងចំពោះហេតុការណ៍ដែលកើតឡើងកាលពីម្សិលមិញ ។ ខ្ញុំគិតថា ការដែលខ្ញុំទៅសុំទោសនាងដូច្នេះ ពុំមែនប្រែសេចក្ដីថា ខ្ញុំឬមិត្តរបស់ខ្ញុំ មានកំហុសអ្វីឡើយ តែខ្ញុំគ្រាន់តែចង់ទៅសុំទោសនាងថា ពុំគួរជាមានការឈ្លោះទាស់ទែងគ្នារបៀបនេះកើតឡើងសោះ ព្រោះជាការគួរខ្មាសគេជាទីបំផុត ។

នៅពេលដែលខ្ញុំកំពុងតែអង្គុយធ្វើការដោយចិត្តអណ្ដែតអណ្ដូងនោះ ខ្ញុំបានទទួលដំណឹងពិសេសមួយពីសុខ-សម្បូរ មិត្តសំឡាញ់របស់ខ្ញុំ ដែលពុំដឹងជាគេទៅស៊ើបសួរដឹងពីណាមក ។ គេបាននិយាយខ្សូរស័ព្ទមកប្រាប់ខ្ញុំថា បុរសដែលមានរឿងឈ្លោះទាស់ទែងគ្នា ជាមួយនឹងគេកាលពីម្សិលមិញនោះ ឈ្មោះ ស៊ឺ ជាអនុសេនីយ៍ទោ ហើយជាសេនាជំនិតរបស់



ដាប-ឈួន មែន ឯសុភាពស្ត្រីនោះ ឈ្មោះនាងយូរ៉ែត ជាកូនចៅរបស់អ្នកស្រុកពួក ដែលដាប-ឈួន បានបញ្ជាឲ្យ ស៊ឺ ចាប់ចាំងអំណាចយកមកឲ្យធ្វើជាប្រពន្ធចុង តែគាប់ជួនជាពេលនោះដាប-ឈួន មានជម្ងឺជាទម្ងន់ ត្រូវទៅដេកព្យា-បាលពេកឯមន្ទីរពេទ្យ (ពេលនោះដាប-ឈួនធ្វើជារដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ) បានជា ស៊ឺ ត្រូវនាំយកនាងយូរ៉ែតមករង់ចាំ ដាប-ឈួន ចេញពីមន្ទីរពេទ្យ ។

កាលបើបានទទួលដំណឹងដូច្នេះហើយ ខ្ញុំក៏ចេះតែគិតដល់សុភាពនារីនោះខ្លាំងឡើងៗ . . .

ខ្ញុំគិតថា ខ្ញុំនឹងទៅរកនាងដោយពុំប្រាប់ឲ្យមិត្តរបស់ខ្ញុំដឹង ព្រោះប្រសិនបើខ្ញុំប្រាប់ គេមុខជាសុំទៅជាមួយដែរ ហើយនាងក៏នឹងពុំពេញចិត្តនឹងជួបបុរសដែលឈ្លោះទាស់ទែងគ្នានិងបុរសដែលនាងដើរជាមួយ ព្រោះខ្ញុំក៏ពុំច្បាស់ថា នាងត្រូវជាអ្វីនឹងស័ក្តិពីរ ស៊ឺ នោះដែរ ។ ខ្ញុំជឿជាក់ថា ខ្ញុំអាចទៅជួបនឹង

នាងបានយ៉ាងងាយ ដោយធ្វើឲ្យហេតុការណ៍ទាំងអស់ ប្រព្រឹត្តទៅដោយសុវត្ថិភាព ។

ល្ងាចនៃថ្ងៃនោះ ខ្ញុំបានជិះត្រីចក្រយានទៅដល់ផ្ទះដែល នាង យូរ៉េត សំណាក់នៅ ។ ស្រីបំរើម្នាក់បានចេញមក អញ្ជើញខ្ញុំឲ្យចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ, ដែលជាបន្ទប់តូច តែស្អាតស្អំ ។ មួយស្របក់ក្រោយមក ស្ត្រីចំណាស់ម្នាក់ រូបភាពជាមនុស្សមានអធ្យាស្រ័យល្អចេញមក តែពុំមែនជា ស្ត្រីចំណាស់ ដែលខ្ញុំបានឃើញឯអង្គតាសោម កាលពីម្សិល មិញនោះទេ ។ ស្ត្រីនេះបាននិយាយរាក់ទាក់នឹងខ្ញុំ ហាក់ ដូចជាធ្លាប់បានស្គាល់គ្នាមកយូរហើយ ។

— លោកអញ្ជើញមកមានការអី ?

— បាទ ! ខ្ញុំមករកអ្នកនាង យូរ៉េត

— យូរ៉េត បានសន្យាឲ្យលោកមកឬ ?

— បាទទេ ! ពុំបានសន្យាអីទេ គឺខ្ញុំមកដោយខ្លួនឯង



ព្រោះមានការចង់ជួបបន្តិច

— លោកធ្លាប់ស្គាល់គ្នាយូរហើយឬ ?

— បាទពុំដែលស្គាល់គ្នាទេ គឺខ្ញុំទើបតែបានឃើញ នាងតែម្តងប៉ុណ្ណោះ

— សុំទោសលោក យូរ៉េត នៅខាងក្នុង សុំលោក រង់ចាំបន្តិច ចាំខ្ញុំចូលទៅហៅ . . . ( ស្ត្រីចំណាស់ថែប នឿងឆ្ងល់ ក្រោយដែលបានឮខ្ញុំថាទើបតែបានឃើញតែម្តង ប៉ុណ្ណោះ )

និយាយផុតពាក្យ ក៏ក្រោកដើរចូលទៅខាងក្នុងផ្ទះ ។ ខ្ញុំអង្គុយចាំពុំយូរប៉ុន្មាន នាង យូរ៉េត ក៏ដើរចេញមកជាមួយ នឹងស្ត្រីចំណាស់អម្បាញ់មិញនេះ ។ នាងដូចជាភ្ញាក់ព្រើត ក្នុងពេលដែលក្រឡេកមើលមកឃើញខ្ញុំ ។ ខ្ញុំក្រោកឡើង ពីកៅអី សំដែងការគោរពចំពោះនាង ។ នាងលើកដៃសំពះ ខ្ញុំ ខ្ញុំក៏លើកដៃសំពះតបទៅនាងវិញ ។ នាងញញឹម

ញញែមដោយទឹកមុខដ៏ស្រស់បស់ ។ ខ្ញុំពុំបានបង្អង់យូរឡើយ ខាតពេល ពុំចង់ឲ្យនាងពិបាកសាកសួរខ្ញុំមុន ខ្ញុំក៏ចាប់ផ្ដើមនិយាយឡើងប្រាប់នាងភ្លាមថា ខ្ញុំមកសូមអភ័យទោសចំពោះរឿងហេតុដែលកើតឡើងកាលពីម្សិលមិញនោះ

— រឿងនេះ វាជាកំហុសរបស់ពួកខាងខ្ញុំទេ (នាងនិយាយយ៉ាងសុភាព) ខ្ញុំក៏ពុំពេញចិត្តនឹងមារយាទអាក្រក់របស់លោកស័ក្តិពីរហ្នឹងដែរ ។

— លោកស័ក្តិពីរនោះ ត្រូវជាយ៉ាងម៉េចនឹងអ្នកនាង ?

— ចាស ! ឥតមានត្រូវជាយ៉ាងម៉េចនឹងខ្ញុំទេ គ្រាន់តែជាអ្នកជូនខ្ញុំទៅលេងក្រុមចុំណោះ ។

— ខ្ញុំដឹងថា អ្នកនាងនៅសៀមរាប តែពុំដឹងជាពិតឬពុំពិតទេ

— ចាសលោក ! ខ្ញុំនៅសៀមរាបមែន សៀមរាបដែលពោរពេញដោយការអាក្រក់



— អត់ទោសអ្នកនាង ! (ខ្ញុំសួរដោយទឹកប្លែកក្នុងចិត្តខណៈដែលបានឮពាក្យសំដីនិងអាការៈរបស់នាងដែលសំដែងថានាងពេញចិត្តនិយាយជាមួយខ្ញុំ) អ្នកស្រុកសៀមរាបអាក្រក់យ៉ាងម៉េចទៅ ?

— លោកគិតមើលចុះ សម័យដែលប្រទេសខ្មែរបានឯករាជ្យដោយសារព្រះបាទសម្ដេចព្រះនរោត្ដមសីហនុ ប្រជារាស្ត្រខ្មែរទូទាំងប្រទេស គេមានសិទ្ធិសេរីភាពគ្រប់ៗគ្នានោះ អ្នកស្រុកសៀមរាប គ្មានសិទ្ធិសេរីភាពអ្វីទាល់តែសោះ អ្នកទាំងអស់គ្នាសុទ្ធតែត្រូវដាំដើមគ ។

សូម្បីការសន្ទនាគ្នាយ៉ាងសោះអង្គើយ ហើយគ្មានខ្លឹមសារអ្វីក៏ដោយ ក៏ខ្ញុំពេញចិត្តណាស់ ព្រោះខ្ញុំបានទទួលនូវបដិសណ្ឋារៈយ៉ាងប្រពៃ ពីនាងយូរ៉ែត ។ ខ្ញុំបានសូមអភ័យទោសនាងអំពីរឿងហេតុកាលពីម្សិលមិញម្ដងទៀត តែនាងឆ្លើយថា នាងគ្មានគិតអ្វីវែងឆ្ងាយដល់រឿងនោះឡើយ ។

- អ្នកនាងប្រហែលជានៅលេងភ្នំពេញយូរទៅទៀត ?

(ខ្ញុំសួរ)

- ចាស៎លោក ! ខ្ញុំជិតត្រឡប់ទៅស្រុកវិញហើយ

- ទេសភាពសៀមរាប ឥឡូវប្រហែលជាល្អណាស់មើលទៅ ?

នាងសើចហើយពុំឆ្លើយថាអ្វី ៗ ខ្ញុំប្រែសេចក្ដីនៃសំណើចរបស់នាងថា ប្រហែលជានាងពុំចង់និយាយច្រើនពេកទេមើលទៅ ,

- ខ្ញុំខានបានឃើញសៀមរាបពីរឆ្នាំមកហើយ (ខ្ញុំនិយាយតទៅទៀតដោយសង្ឃឹមថា នឹងធ្វើឲ្យការសន្ទនាគ្នាបានវែងតទៅទៀត ។

- ចាស៎ ! ឥឡូវនេះមានការប្លែកជាងពីដើមខ្លះដែរ

- ខ្ញុំចង់ទៅលេងសៀមរាបណាស់ឆ្នាំនេះ ហើយបើមានវាសនា ខ្ញុំមុខជាបានជួបនិងអ្នកនាងទៀតពុំខាន ។



នាងសើចម្ដងទៀត ហើយពុំឆ្លើយថាអ្វី ៗ សំណើចនិងការគ្មានឆ្លើយថាអ្វីនេះ បានសេចក្ដីថាយ៉ាងណានោះ ខ្ញុំក៏ពិបាកនឹងយល់បាន ៗ ប៉ុន្តែយ៉ាងណាក៏ដោយចុះ ខ្ញុំបានពិនិត្យមើលនាងតាំងពីដើមមកហើយ គឺតាំងពីឃើញនាងនៅអង្គតាសោម ឃើញថា នាងមុខជាមានការគាច់កំបាំងអ្វីម្យ៉ាងនៅក្នុងខ្លួនជាពុំខាន ...

- អ្នកនាងនឹងត្រឡប់ទៅសៀមរាបវិញថ្ងៃណា ?

- ចាស៎ប្រហែលជាពីរអាទិត្យទៀត

- អ្នកនាង ! ប្រសិនបើខ្ញុំសុំមកជួបនិងអ្នកនាងម្ដងទៀតមុនពេលដែលអ្នកនាងត្រឡប់ទៅស្រុកវិញ តើមេត្តាឬទេ ?

នាងសើចទៀត ហើយពុំឆ្លើយថាអ្វីដូចមុន ៗ ខ្ញុំគិតថាកិច្ចការរបស់ខ្ញុំក្នុងថ្ងៃនេះ មុខជាពុំបានសម្រេចលទ្ធផលអ្វីឡើយ ៗ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ខ្ញុំក៏គួរអរគុណនិងនាងក្នុងការដែលខ្ញុំបានមករកនាង ហើយបានទទួលនូវការរាក់ទាក់

ពីនាង ។ ខ្ញុំគិតថា ជាការធម្មតាដែលខ្ញុំពុំគួរខឹងសង្ស័យអ្វីឲ្យជ្រុលពេកទេក្នុងគ្រាដំបូងនេះ ។ ខ្ញុំបានលានាងត្រឡប់ទៅផ្ទះវិញ ។ ក្នុងពេលនោះ ស្រាប់តែរថយន្តមួយបានមកឈប់នៅមុខផ្ទះហើយបុរសម្នាក់បានចុះពីរថយន្តដើរចូលមកក្នុងផ្ទះ ។

ខ្ញុំនៅចាំច្បាស់ថា បុរសនេះឯងហើយដែលទាស់ទែងគ្នានឹងមិត្តសំឡាញ់របស់ខ្ញុំ នៅអង្គតាសោម ។ ខ្ញុំមើលចំមុខរបស់គេ ឃើញមានស្នាមជាំនៅត្រង់ថ្ងាសផ្នែកស្តាំនៅឡើយ ហើយស្នាមជាំនេះហើយ ដែលមិត្តសំឡាញ់របស់ខ្ញុំបានដាក់មេរៀនឲ្យគេ ( លទ្ធផលនៃស្នាដៃជាប់ជាលើកទី ២ ) ។

នាងយូរ៉ែត បាននិយាយណែនាំបុរសនេះឲ្យស្គាល់ខ្ញុំ។

– ខ្ញុំមកសុំទោស សុំទោសក្នុងការទាស់ទែងខ្វែងគំនិតគ្នារបស់ពួកម៉ាកខ្ញុំកាលពីម្សិលមិញ ។

– ខ្ញុំមិនចង់មានរឿងអីដែរ បើខ្ញុំទប់មិនបាន ប្រហែលជាខ្ញុំសម្លាប់ពួកម៉ាកលោកចោលទៅហើយ ។



ខ្ញុំគិតថាបុរសនេះ ដូចជាអ្នកគាងសម្រិម ។ សំដីដែលគេនិយាយ បែបភាពដែលគេសំដែងចេញមក សុទ្ធតែជាការអ្នកគាងទាំងអស់ ។ ខ្ញុំប្រមាណមើលទៅឃើញថា បុរសនេះដូចជាពុំសូវត្រូវនិស្ស័យគ្នានឹងខ្ញុំ ។

– លោកធ្វើការអ្វី ? ( បុរសនោះសួរខ្ញុំ )

– បាទ គ្មានធ្វើការអ្វីទេ ខ្ញុំជាអ្នករកទទួលទានធម្មតា (ខ្ញុំឆ្លើយកុហក ព្រោះខ្ញុំគិតថា ពុំចង់ឲ្យបុរសនេះដឹងដល់មុខការរបស់ខ្ញុំ ហើយពេលនោះខ្ញុំក៏ស្លៀកពាក់ជាជនធម្មតាសាមញ្ញ ដែលល្មមតែគេជឿបាន )

ខ្ញុំស្មានពុំខុស ។ បុរសរូបនេះ ពុំត្រូវនិស្ស័យគ្នានឹងខ្ញុំសោះឡើយ ព្រោះគ្រាន់តែជួបគ្នាមួយភ្លែតប៉ុណ្ណោះ គេហ៊ានសួរដល់មុខការរបស់ខ្ញុំទៅហើយ ។

ខ្ញុំគ្រេះគ្រុះចង់លាគេ តែនាង យូរ៉ែត និយាយប្រាប់បុរសនោះថា ខ្ញុំចង់ទៅលេងសៀមរាបដែរ ។

— បបួលពួកម៉ាកលោកទៅលេងផង ហើយលោកចាំមើលថា តើគេអាចត្រឡប់មកស្រុកវិញបានឬមិនបាន ប្រសិនបើគេហ៊ានឈានជើងទៅជាន់ដីសៀមរាបមែន គេមុខជាស្គាល់ស្នាដៃយើងវិញម្ដងហើយ ។

គ្រានេះខ្ញុំសើច . . . ការដែលខ្ញុំសើចនេះ គឺសើចបន្ទប់ដោយពុំឆ្លើយថាអ្វី ។ ខ្ញុំក្រោកឈរឡើងងក់ក្បាលគោរពគេហើយលាគេ តែគេឥតមានគោរពខ្ញុំវិញសោះឡើយ គេអង្គុយធ្វើព្រងើយដូចដើម ។ បែបភាពឫកពាររបស់គេយ៉ាងនេះ ខ្ញុំនឹកក្នុងចិត្តថា ជាការសមមុខរកណាស់ហើយ ដែលមិត្តសំឡាញ់របស់ខ្ញុំ បានដាក់មេរៀនឲ្យគេ ទាល់តែនៅមានស្នាមជាំក្អែកនោះ ។

នាង យូ៉េត បានជូនខ្ញុំចេញមកដល់មាត់ទ្វារ ។

— សុំឲ្យខៈនរកសនាបានមកជួបនឹងអ្នកនាងម្ដងទៀត (ខ្ញុំនិយាយតិចៗ ដោយជឿជាក់ថា ពុំឮដល់បុរសនោះឡើយ) ។



នាងញញឹមហើយងក់ក្បាលដាក់ខ្ញុំ ។

— ខ្ញុំអាចមកជួបពេលណា ?

— ចាស ! ល្ងាចស្អែក

ខ្ញុំដូចជានឹកអរព្រួច ។ សេចក្ដីសង្ស័យកាលពីអម្បាញ់មិញថា កិច្ចការរបស់ខ្ញុំក្នុងថ្ងៃនេះ ពុំបានសម្រេចលទ្ធផលអ្វីនោះ ឥឡូវមើលទៅដូចជាមានសង្ឃឹមខ្លះឡើងវិញ ព្រោះនាងព្រមឲ្យខ្ញុំមកជួបម្ដងទៀត ។

ខ្ញុំបានធ្វើដំណើរត្រឡប់ទៅផ្ទះវិញ ។ ក្នុងពេលត្រឡប់ទៅផ្ទះវិញនេះ ខ្ញុំចេះតែគិតសាំញ៉ាំក្នុងចិត្តថា ខ្ញុំគួរប្រាប់មិត្តរបស់ខ្ញុំឲ្យដឹងឬទេ អំពីការដែលខ្ញុំបានទៅជួបនឹងនាង យូ៉េតនោះ? ខ្ញុំគិតពុំដាច់ស្រេច ទាល់តែត្រីចក្រយានបាននាំខ្ញុំទៅដល់ផ្ទះ ។ ប៉ុន្តែខ្ញុំដូចជានឹកត្រេកអរជាខ្លាំងថា ខ្ញុំដូចជាមានសង្ឃឹមអ្វីម្យ៉ាងនៅក្នុងចិត្ត ។

លុះគិតយូរៗទៅ ខ្ញុំបានសម្រេចចិត្តថា គួរតែប្រាប់

រឿងនេះ ឲ្យមិត្តសំឡាញ់របស់ខ្ញុំបានដឹងផង ក្រែងគេចង់ទៅស្គាល់ផ្ទះរបស់នាងដែរ ហើយម្យ៉ាងទៀតខ្ញុំគិតថា ខ្ញុំដូចជាកំពុងតែបានជួបប្រទះនូវរឿងរ៉ាវអាថ៌កំបាំងបិទមុខអ្វីម្យ៉ាង-ទៀត ។

គាប់ជួនជាពេលនោះ សុខ-សម្បូរ ក៏បានមកលេងផ្ទះខ្ញុំ ។ ខ្ញុំបាននិយាយរឿងរ៉ាវនោះប្រាប់គេទាំងអស់ ។

– គ្នាត្រេកអរណាស់ដែលឯងបេះទៅរកឃើញ ។

– ការដែលគ្នាពុំបានបបួលឯងទៅផងនោះ មកពីគ្នាគិតថា ឯងជាមនុស្សចិត្តខ្លាំង ក្រែងលោទៅមានរឿងនិងគេទៀត ។

ខ្ញុំពុំបានប្រាប់អំពីពាក្យសំដីដែលស័ក្តិ ២ ស៊ី និយាយដល់មិត្តសំឡាញ់របស់ខ្ញុំឡើយ ព្រោះក្រែងមានរឿងធំដុំកើតឡើងទៀត ។ ខ្ញុំគ្រាន់តែប្រាប់ថា ខ្ញុំនឹងទៅជួបនាងយូរ៉េតទៅល្ងាចថ្ងៃស្អែកទៀតតែប៉ុណ្ណោះ ។ ដំបូងខ្ញុំគិតក្រែងគេសុំ



ទៅដែរ តែគេក៏មានសុជីវធម៌ ល្មមតែពុំធ្វើដូច្នោះ ...

ពេលល្ងាចនៃថ្ងៃមួយទៀត ខ្ញុំបានទៅដល់ផ្ទះនាងយូរ៉េត ដោយរថយន្ត ។ ខ្ញុំគិតថាប្រសិនបើខ្ញុំអាចបបួលនាងដើរលេងបាននោះ គឺជាលាភដ៏ប្រសើររបស់ខ្ញុំ ។

ខ្ញុំពុំបាននឹកស្មានថា ខ្ញុំនឹងបានសំរេចបំណងដល់ទៅម្ល៉ោះឡើយ ... ខ្ញុំដូចជានឹកប្លែកក្នុងចិត្តជាខ្លាំង ... ពេលដែលខ្ញុំទៅដល់នាងយូរ៉េត បានអង្គុយរង់ចាំខ្ញុំនៅខាងមុខផ្ទះជាមួយនឹងស្ត្រីចំណាស់ដែលខ្ញុំបានឃើញកាលពីម្សិលមិញៗ

– លោកមានការទៅណាទៀតដែរឬ ? (នាងសួរខ្ញុំ)

– បាទ ! គ្មានទេ មករកអ្នកនាងតែប៉ុណ្ណោះ ។

– បើអញ្ចឹងយើងគិតជិះឡានលេងបន្តិច ...

ខ្ញុំគិតថា ខ្ញុំយល់សប្តិទេដឹង ? ... ខ្ញុំមានរាសនាដល់ទៅពុំគួរជឿ ... អម្បាញ់មិញនេះ ខ្ញុំនឹកថា ប្រសិនបើខ្ញុំអាចបបួលនាងដើរលេងបាននោះ ក៏ជ លាភដ៏ប្រសើររបស់ខ្ញុំ ...

ផ្លូវនេះ លោកនោះបានមកដល់មែន ដោយខ្ញុំពុំបានទឹកស្មាន ថានឹងដល់ម្ល៉ឹងសោះ . . . ខ្ញុំបានប្រាប់នាងតាមហូរហែហើយ បន្ថែមថា ខ្ញុំត្រេកអរណាស់ក្នុងការដែលខ្ញុំមានវាសនាបានដើរ លេងជាមួយនាង . . .

យើងបាននាំគ្នាឡើងជិះរថយន្ត ។ ពេលនេះ ខ្ញុំនឹក សរសើរវាសនាខ្លួនឯងម្តងទៀតថា ខ្ញុំមានវាសនាល្អណាស់... នាង យូរ៉ែត បើកទ្វាររថយន្តខាងមុខ ហើយចូលមកអង្គុយ ទន្ទឹមនឹងខ្ញុំ ហើយស្ត្រីចំណាស់នោះអង្គុយនៅខាងក្រោយ ។

រថយន្តរបស់យើងបានលូនចេញពីទីនោះ សំដៅទៅ ទិសខាងកើត ។ នាងបានសួរខ្ញុំថា :

— យើងគិតទៅលេងឯណា ?

គិតទៅលេងតាមផ្លូវទៅកំពង់ស្ពឺ ព្រោះកន្លែងនោះ មានទេសភាពនិងអាកាសល្អ ។

— លោកចូលចិត្តទេសភាពនិងអាកាសល្អដែរឬ ?



— ខ្ញុំបូជារបស់ល្អបរិសុទ្ធណាស់ ពុំថាជាទីកន្លែង ឬ ជាមនុស្សទេ ។

នាងពុំនិយាយថាអ្វីតទៅទៀត ។ ខ្ញុំបេះតែបើក-បររថយន្តទៅមុខ ដោយបត់តាមមហាវិថីព្រះបាទនរោត្តម ហើយចេញតាមផ្លូវពោធិ៍ចិនតុង ។

— ខ្ញុំបានសន្យាឲ្យលោកមកជួបថ្ងៃនេះ ( នាង យូរ៉ែត និយាយក្នុងខណៈដែលរថយន្តបានលូនចេញផុតពីទីក្រុង ) - ព្រោះពុំចង់ឲ្យលោកជួបនឹងលោកស័ក្តិពីរ — បើជួបទៅយើង មុខជាដើរលេងពុំបានទេ ។

— ការនេះ ជាវាសនាល្អរបស់ខ្ញុំណាស់ហើយ ។

ខ្ញុំគិតថា ការដែលខ្ញុំសង្ឃឹមហើយដែលធ្វើឲ្យខ្ញុំសប្បាយ ចិត្តជាទីបំផុតនោះ គឺនាង យូរ៉ែត ពេញចិត្តជួបនឹងខ្ញុំដោយ ពុំចង់ឲ្យលោក ស៊ី ឃើញ ការនេះមានសារៈសំខាន់ ព្រោះ នាងបានឲ្យកិត្តិយសដ៏ខ្ពង់ខ្ពស់ដល់រូបខ្ញុំ . . . សំដីសំដៅ

សភាពរៀមទន់សេចក្ដីក្លាហានរបស់នាង ដែលហ៊ានជិះរថយន្តជាមួយខ្ញុំ នៅពេលដែលនាងទើបតែស្គាល់ខ្ញុំក្នុងវេលាពីរបីថ្ងៃប៉ុណ្ណោះ បានបញ្ជាក់ឲ្យឃើញថា នាងយូរ៉េត មានគំនិតចាស់ទុំ ... ខ្ញុំពិបាកស្មានថានាងមានអាយុប៉ុន្មាន ? ប៉ុន្តែពាក្យសំដីនិងកិរិយាបុគ្គលរបស់នាង បានបង្ហាញឲ្យខ្ញុំគិតថា នាងជាមនុស្សម៉ត់ចត់ល្អិតសុខុម ... ខ្ញុំគិតថា ការដែលនាងហ៊ានដើរលេងជាមួយនឹងខ្ញុំនេះ ក៏ប្រហែលជានាងបានសំគាល់ថា ខ្ញុំជាមនុស្សរៀមទុកចិត្តបាន ហើយម្យ៉ាងទៀតប្រហែលជានាងជឿជាក់ខ្លួនឯងថា មុខជាគ្មានបុរសណាមួយហ៊ានប្រព្រឹត្តល្មើសលើសលស់លើរូបនាងបានឡើយ ។

យើងបានទៅដល់ខាងលិចបែកបាន ... យើងបានបញ្ឈប់រថយន្តនៅទីនោះ...

មេឃស្រឡះអាកាសល្អ ... នាងយូរ៉េត ក៏ល្អ



ប្រហែលគ្នានឹងបុប្ផា ដែលទើបនឹងរីកឡើងសម្បុរស សាច់ម៉ដ្ឋ អាចបញ្ចេញនូវលំអស្រស់បំព្រង ដោយពុំចាំបាច់តុបតែងប៉ុន្មាន នាងស្លៀកពាក់សមសួន ទឹងប្លុកពាសុភាពរបស់នាង សភាពសម៉ដ្ឋនៃពណ៌របស់នាង បានធ្វើឲ្យខ្ញុំអត់ទ្រាំពុំសំឡឹងមើលពុំបាន ...

ព្រះអាទិត្យកំពុងតែរៀបអស្ដង្គតទៅទិសបស្ចិម ដោយបានបញ្ចេញនូវរស្មីពណ៌ក្រហមឆ្អៅ មកប៉ះត្រូវរាងកាយរបស់នាងយូរ៉េត ... ពណ៌សម្បុរសាច់របស់នាងក្នុងពេលនេះមើលទៅហាក់ដូចជា មានដួងព្រះអាទិត្យជ្រែកចូលទៅក្នុងរាងកាយរបស់នាង ស្ទើរតែនឹងធ្លុះឲ្យឃើញនូវសរសៃទាំង-អស់ដែលកំពុងតែមានឈាមរត់ចុះឡើងពេញសព្វាង្គកាយ ...

—ខ្ញុំគិតថា ទេសភាពអង្គរនៅពេលថ្មើរនេះល្អជាងនេះទៅទៀត (ខ្ញុំចាប់ផ្ដើមនិយាយឡើង) បើខ្ញុំមានវាសនា ខ្ញុំមុខជាបានជួបអ្នកនាងនៅទីនោះពុំខាន ។

- ខ្ញុំគិតថា បើទុកជាលោកអញ្ជើញទៅ ក៏ខ្ញុំពុំអាចជូននូវការសប្បាយរីករាយដល់លោកបានដែរមើលទៅ ។

- អ្នកនាងគិតថា ខ្ញុំគួរមានវាសនាបានទៅលេងដែរឬទេ ?

- មើលទៅក៏ដូចជាគ្មានទាស់ខុសអ្វីដែរ តែក្រែងខ្ញុំពុំអាចជូននូវការសប្បាយរីករាយដល់លោកបាន ។

- រឿងនេះពុំជាសំខាន់អីទេ ខ្ញុំត្រូវការតែម្យ៉ាង គឺចង់ទៅជួបនឹងអ្នកនាង ហើយនឹងនាំគ្នាដើរមើលទេសភាពលេងតែប៉ុណ្ណោះ ។

- ចាំមើល ខ្ញុំគិតមើលបន្តិចសិនលោក ។

- មានបញ្ហាស្មុគស្មាញពិបាកអីឬ ?

- ប្រសិនបើមាន ក៏ជាបញ្ហាផ្ទាល់ខ្លួនខ្ញុំតែប៉ុណ្ណោះ ។

ដោយវាសនាបានជួយខ្ញុំ . . . ខ្ញុំគិតថា ការដែលនាងយុវតីបាននិយាយដោយទឹកមុខញញឹមយ៉ាងនេះ ជាការ



សំដែងឲ្យឃើញថា នាងបានបើកផ្លូវឲ្យខ្ញុំសាកសួររឿងរ៉ាវក្នុងជីវិតរបស់នាង . . .

- ខ្ញុំសង្កេតឃើញថា អ្នកនាងដូចជាមានរឿងអាថ៌កំបាំងអីម្យ៉ាងកប់នៅក្នុងខ្លួនមែនឬទេ ?

- អ្វីដែលធ្វើឲ្យលោកសង្កេតឃើញយ៉ាងហ្នឹង ?

- ខ្ញុំសង្កេតឃើញអ្នកនាង តាំងពីពេលបានជួបអ្នកនាងជាគ្រាដំបូង មើលទៅបែបភាពអ្នកនាង ដូចជាពុំសូវមានការសប្បាយរីករាយក្នុងជីវិតសោះ !

- លោក ! ពិភពលោក ជាកន្លែងដែលយើងពុំគួរសប្បាយរីករាយសោះ ពុំដូច្នោះឬលោក ?

- ខ្ញុំធ្លាប់បានគិតមកថា ពិភពលោកទុកដូចជាផ្ទាំងកញ្ចក់មួយសំរាប់ឆ្លុះមើលមុខយើង បើយើងសើច ពិភពលោកក៏សើចតាម បើយើងយំ ពិភពលោកក៏យំតាមយើងដែរ ។

- ខ្ញុំក៏ធ្លាប់បានគិតមកថា អញ្ចឹងដែរ តែជួនកាលខ្ញុំ

ត្រូវតែសើចពុំកើតសោះ ព្រោះអីជីវិតជាធម្មជាតិពិបាកណាស់ៗ

— បាទ អញ្ចឹងមែនហើយ រឿងជីវិតជារឿងដែលយើងត្រូវតស៊ូ យើងបានតស៊ូតាំងពីពេលដែលយើងកើតមក ហើយយើងត្រូវតែតស៊ូតទៅទៀតរហូតដល់ពេលស្លាប់ ធម្មជាតិបានឲ្យមានខ្លួនកម្លាំងរបស់យើង ឲ្យខួរការបេះដូងដល់យើង ក៏ពុំមែនដើម្បីប្រយោជន៍អីដែរ គឺដើម្បីការតស៊ូតែម្យ៉ាងប៉ុណ្ណោះមិនថាអញ្ចឹងឬ ?

— តែក្នុងការតស៊ូនោះ ចួនកាលយើងក៏ត្រូវទទួលបរាជ័យដែរ មែនទេលោក ?

— ចួនកាលយើងត្រូវចាញ់មែន តែយើងក៏ត្រូវតែចេះវិធីការតស៊ូ យើងត្រូវរកកម្លាំងជាជំនួយ គឺយើងត្រូវរកកល្យាណមិត្ត . . .

— ចាស ! មិត្តល្អហ្នឹងឯងហើយ ពុំងាយរកបានទេលោក ។



— បាទ ! រកបានដោយកម្រណាស់ តែក៏ពុំមែនប្រែថា យើងពុំអាចរកបានសោះនោះទេ ព្រោះការនេះត្រូវអាស្រ័យនូវក៏ពុកសនាផង ចួនកាលយើងអាចជួបមិត្តល្អ ដោយពុំបានជាទំនាក៏មាន ចួនកាលយើងបានជួបហើយ តែយើងពុំបានគិតថា ជាមិត្តល្អពិតប្រាកដរបស់យើងក៏មាន ខ្ញុំជឿជាក់ថា យើងមុខជាបានជួបនឹងអ្នកណាម្នាក់ដែលជាមិត្តល្អ ដែលសុខចិត្តជួយយើង សុខចិត្តលះបង់អ្វីៗគ្រប់បែបយ៉ាង ដើម្បីយើងក្នុងថ្ងៃណាមួយពុំខាន ។

— តែជាគ្រោះអាក្រក់របស់ខ្ញុំ ដែលខ្ញុំពុំដែលបានធ្វើអ្វីល្អឲ្យអ្នកណាម្នាក់ ល្មមនឹងឲ្យគេមកសុខចិត្តលះបង់អ្វីៗ ដើម្បីខ្ញុំវិញសោះ ។

— អ្នកនាង ! អ្នកនាងជឿចំពោះមិត្តភាពរបស់ខ្ញុំ តាំងពីពេលដែលខ្ញុំបានឃើញអ្នកនាងនៅគ្រាដំបូងដែរឬអី ? ការនេះ ខ្ញុំពុំសំដៅដល់ការវែងឆ្ងាយពេកទេ គឺខ្ញុំចង់និយាយថា

មានមិត្តភាពតាំងពីពេលឃើញគ្នានៅគ្រាដំបូងមកម៉្លេះ !

— លោកជឿដែរឬទេ ចំពោះមិត្តភាពបែបនោះ ?

— បាទ ! សំរាប់រូបខ្ញុំៗជឿ ព្រោះវាធ្លាប់កើតមានឡើងក្នុងខ្លួនរបស់ខ្ញុំ ។

នាងពោលកន្ទុយភ្នែកមើលមកខ្ញុំ ហើយក៏បែរទៅវិញៗ អាការៈបែបនេះ បានធ្វើឲ្យខ្ញុំសង្កេតឃើញនូវសភាពមុតនៃភ្នែករបស់នាង ដែលអាចស្រូបទាញនូវទឹកចិត្តនៃបុរសភាគច្រើនបាន ហើយជួនកាលអាចរួមបញ្ចូលរូបខ្ញុំមួយទៅផងក៏ពុំដឹង ។ នាងនៅស្ងៀម តែកន្ទុយភ្នែករបស់នាងបានបង្ហាញលក្ខណៈឲ្យខ្ញុំយល់ថា ក៏ព្រេងវាសនាបានជួយខ្ញុំម្តងទៀត ។

ខ្ញុំគិតថា ទ្វារមិត្តភាពបានបើកចំហទទួលខ្ញុំហើយ នៅសល់តែបញ្ហាមួយទៀតថា ខ្ញុំហ៊ានឈានជើងដើរចូលទៅតាមទ្វារនោះដែរឬក៏ពុំហ៊ានតែប៉ុណ្ណោះ ។

— មិត្តភាពក្នុងពេលឃើញគ្នានៅគ្រាដំបូង (ខ្ញុំនិយាយ



ផ្ទួនបញ្ជាក់ម្តងទៀត) បានកើតឡើងដល់ខ្ញុំ !

— កើតឡើងតាំងពីពេលណា ?

— តាំងពីពេលដែលខ្ញុំឃើញអ្នកនាង នៅឯអង្គតាសោម គ្រាន់តែខ្ញុំបានឃើញអ្នកនាងភ្លាម ខ្ញុំក៏ចង់ធ្វើជាមិត្តភក្តិនឹងអ្នកនាងភ្លាមដែរ ខ្ញុំគិតថា ប្រសិនបើអ្នកនាងរើសយករូបខ្ញុំធ្វើជាមិត្តភក្តិនោះ មើលទៅក៏ដូចជារើសមនុស្សពុំខុស ហើយអ្នកនាងមុខជាបានឃើញនូវមិត្តភាពដ៏ល្អពិតប្រាកដរបស់ខ្ញុំ ។

ប៉ុន្តែក្រែងយើងគ្មានពេលបានស្គាល់គ្នាយូរ ។

ប្រសិនបើមានការចាំបាច់ ដែលត្រូវធ្វើប្រយោជន៍ដល់មិត្តភក្តិបាន ខ្ញុំគិតថា យើងអាចស្គាល់គ្នារហូតដល់ថ្ងៃស្លាប់បាន ។

— តែលោកដូចជាគ្មានបានទទួលលទ្ធផលអី ក្នុងការដែលលោកមកស្គាល់ខ្ញុំនេះសោះ ។

— បើទុកណាជាគ្មានបានប្រយោជន៍អី ក៏ខ្ញុំប៉ះតែពេញ

ចិត្ត ក្នុងការដែលខ្ញុំបានបំពេញប្រយោជន៍ដល់មិត្តភក្តិជានិច្ច អ្នកនាង ! សុំអ្នកនាងមានប្រសាសន៍មកចុះ បើអ្នកនាងយល់ថា រូបខ្ញុំអាចធ្វើប្រយោជន៍អីដល់អ្នកនាងក្នុងផ្លូវណាបាន ក៏សុំឲ្យអ្នកនាងប្រើខ្ញុំតាមសេចក្ដីត្រូវការមកចុះ ។

— ខ្ញុំសូមអរគុណនឹងលោកណាស់ហើយ តែខ្ញុំគិតថា ជាការពុំគួរសមសោះ ដែលធ្វើឲ្យលោកពិបាកដោយសារខ្ញុំ ព្រោះយើងទើបនឹងបានស្គាល់គ្នាត្រឹមតែពីរបីថ្ងៃប៉ុណ្ណោះ ។

— តែជួនកាល ខ្ញុំជាមិត្តភក្តិដ៏ល្អរបស់នាង គ្រាន់បើជាជាងមនុស្សដែលអ្នកនាងធ្លាប់ស្គាល់មកយូរហើយក៏មាន ។

— ខ្ញុំពុំគិតអញ្ចឹងទេ ! ខ្ញុំគិតថា រូបខ្ញុំពុំគួរមានសិទ្ធិទៅយកមនុស្សដែលទើបនឹងបានស្គាល់គ្នាថ្មីៗ ហើយដែលរូបខ្ញុំនៅពុំទាន់ដែលបានធ្វើប្រយោជន៍អ្វីឲ្យគេសោះនោះ មកឲ្យពិបាកដោយសាររឿងខ្ញុំទេ ។

— នេះ យើងពុំមែននិយាយគ្នាដល់រឿងសិទ្ធិអីទេ យើង



និយាយគ្នាតែពីរឿងមេត្រីចិត្តទេតើ ។

— ចាស នុះឯងហើយ ខ្ញុំគិតពុំយល់ថា ហេតុអីក៏លោកខំយកមេត្រីចិត្ត របស់លោកមកប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ក្នុងផ្លូវដែលលោកត្រូវទទួលនូវការលំបាកអញ្ចឹង ?

— រឿងនោះពិបាកប៉ុណ្ណា ? (ខ្ញុំសួរដោយការចង់ដឹង)

នាង យូរ៉េត ពុំឆ្លើយថាអ្វី ។ ខ្ញុំយល់ដល់ចិត្តថ្លើមរបស់នាង ព្រោះបើនាងឆ្លើយនឹងសំនួរនេះ ក៏ដូចជានាងត្រូវនាំយករឿងក៏វៃនជីវិតរបស់នាង មកបរិយាយឲ្យខ្ញុំស្ដាប់វែងពេក ម្យ៉ាងទៀតដោយឯណានឹងឲ្យនាងហ៊ាននិយាយរឿងពិបាកចិត្តប្រាប់មនុស្សដែលនាងទើបបានស្គាល់ថ្មីៗ ដូចរូបខ្ញុំនេះបាន ។

— អ្នកនាង ! (ខ្ញុំនិយាយ) ខ្ញុំយល់ដល់ចិត្តអ្នកនាង ហើយក្នុងការដែលអ្នកនាងឲ្យកិត្តិយសដល់រូបខ្ញុំ ដោយមកលេងជាមួយខ្ញុំ ហើយបានធ្វើឲ្យខ្ញុំមានឱកាសសាកសួរពីរឿង

ផ្សេងៗ យ៉ាងនេះ តែគឺជាការធម្មតាទេ ដែលអ្នកនាងពុំអាចទុកចិត្តទុកថ្លើមលើរូបមនុស្ស ដែលអ្នកនាងទើបនឹងបានស្គាល់ ខ្ញុំគិតថា បើខ្ញុំមានវាសនាបានជួបអ្នកនាងម្តងទៀតនោះ ខ្ញុំនឹងពិសោធឲ្យអ្នកនាងឃើញ ថារូបខ្ញុំជាមនុស្សដែលអ្នកនាងគួរទុកចិត្តជឿបាន ។

ព្រះអាទិត្យបានលិចបាត់ទៅទិសខាងលិចហើយ ។ យើងបាននាំគ្នាត្រឡប់មកផ្ទះវិញ ។ ខ្ញុំដូចជាពុំបានជឿថា នាង យូរ៉េត ដាច់ចិត្តនិយាយរឿងរ៉ាវរបស់នាងប្រាប់ខ្ញុំឡើយ តែខ្ញុំមានសង្ឃឹមខ្លះដែរថា ប្រសិនបើយើងបាននិយាយគ្នាយូរបន្តិចទៀត ឬក៏បានជួបគ្នាម្តងឬពីរដងទៀតនោះ មុខជាបានស្តាប់រឿងរ៉ាវរបស់នាងហើយ ។

— អ្នកនាង ! (ខ្ញុំចាប់និយាយ ដើម្បីទម្លាយនូវបរិយាកាសស្ងប់ស្ងៀម) ខ្ញុំនឹងមានវាសនាជួបអ្នកនាងទៀត នៅពេលណា ?



— ល្ងាចៗ លោកមានពេលទំនេរជានិច្ចឬ ?

— បើអញ្ចឹងល្ងាចស្អែកបានឬទេ ?

— ណ្ហើយ ! ស្អែកយើងកុំអាលជួបគ្នាធ្វើអ្វី ចាំខានស្អែកវិញទៅ ព្រោះបើជួបគ្នាញឹកពេកយ៉ាងនេះ នាំឲ្យគេសង្ស័យ ។

— សុំទោសអ្នកនាង ខ្ញុំមានឱកាសតែស្អែកមួយថ្ងៃទៀតប៉ុណ្ណោះ ព្រោះខានស្អែកខ្ញុំត្រូវចេញទៅប្រតិបត្តិការ នៅកំពង់ធំ អស់ពេល ៥ ថ្ងៃ ។

— បើអញ្ចឹង ចាំលោកត្រឡប់មកពីកំពង់ធំវិញសិនទៅ ។

— អ្នកនាងជឿឬ ថាយើងនៅមានឱកាសអាចជួបគ្នាបានទៀត ?

— ចា៎ស ! ខ្ញុំជឿជាក់ថា យើងអាចបានជួបគ្នាទៀត ។

ក្នុងខណៈដែលខ្ញុំបានជូននាងទៅដល់ផ្ទះនោះ គាប់បួនជារថយន្តរបស់លោកស៊ឺ បានលួនទៅដល់ដែរ ។ ខ្ញុំសង្កេតឃើញថា នាងយូរ៉េត មានទឹកមុខពុំស្រួល ដែលជាការ

បង្ហាញឲ្យដឹងថា នាងខ្លាចបុរសនោះជាខ្លាំង ។

ក្រោយពីបានជូននាងទៅដល់ផ្ទះហើយ ខ្ញុំក៏បានបើករថយន្តទៅរកមិត្តសំឡាញ់របស់ខ្ញុំ ។ ខ្ញុំបាននិយាយរឿងដែលខ្ញុំបាននាំនាង យូរ៉េត ដើរលេង ប្រាប់គេ ។

– ការនេះបានសេចក្ដីថា ឯងកំពុងតែធ្លាក់ខ្លួនចុះទៅក្នុងអន្លង់ស្នេហាមែនឬទេ ? (សុខ-សម្បូរ និយាយ)

– ពុំមែនអញ្ចឹងទេ គ្នាគ្រាន់តែចង់ដឹងរឿងអាថ៌កំបាំងបិទមុខតែប៉ុណ្ណោះ ។

– តែនាង យូរ៉េត ល្អណាស់ ល្អគួរឲ្យស្រឡាញ់

– ការល្អនិងការបិទមុខច្រើនជាគូនឹងគ្នា តែបើគ្នាខ្វល់ខ្វាយនឹងស្រីនេះ ក៏ពុំមែនដោយសារលំអរបស់នាងទេ ។

ខ្ញុំបានបណ្ដោយពេលវេលា ឲ្យកន្លងផុតទៅយ៉ាងស្ងប់ស្ងៀម ។ ដំដើមខ្ញុំបាននឹកថា អគ្គសេនាធិការយោធពលខេមរភូមិន្ទ ប្រុងនឹងបញ្ជូនរូបខ្ញុំ ឲ្យទៅប្រតិបត្តិការនៅខេត្ត



កំពង់ធំ តែឥឡូវនេះ បែរជាបញ្ជូនអ្នកដទៃទៅវិញ ។ ខ្ញុំបានជាប្រាប់នាង យូរ៉េត ជ្រុលទៅហើយ បើខ្ញុំទៅរកនាងក្នុងបន្ទោះពេលបីបួនថ្ងៃនោះ នាងមុខជាយល់ថា ខ្ញុំកុហកនាង ។ ដូច្នេះខ្ញុំខំទ្រាំរង់ចាំឲ្យគ្រប់ ៥ ថ្ងៃ ទើបទៅជួបនាង ។

ខ្ញុំនឹកឆ្ងល់ជាខ្លាំង ព្រោះពុំដឹងជាហេតុអ្វី ក៏បានជាភាពនៃរូបនាង យូរ៉េត បេះតែប្រាកដឡើងដល់ភ្នែករបស់ខ្ញុំជានិច្ច ។ ពាក្យដែលគេនិយាយថា បុរសដែលស្រឡាញ់ស្ត្រីបើទុកណាជាពុំបានឃើញរូប ក៏សុំឲ្យបានឃើញត្រឹមតែដំបូលផ្ទះ ក៏អស់ចិត្តដែរនោះ ជាពាក្យត្រូវពិតណាស់ ។ ខ្ញុំនៅពុំព្រមទទួលខុសថា ខ្ញុំស្រឡាញ់នាង យូរ៉េត តែខ្ញុំក៏ធ្លាក់ចុះទៅក្នុងសភាពដូចពោលខាងលើដែរ គឺក្នុងកំឡុងពេលពីរបីថ្ងៃនោះ ខ្ញុំបានបើករថយន្តកាត់មុខផ្ទះនាងរាប់ដងពុំអស់ ហើយបេះតែគិតមួយពាន់មួយហ្មឺនជំពូក ។ ជួនកាលខ្ញុំគិតទៅក្នុងផ្លូវពុំល្អ គឺគិតថា នាង យូរ៉េត អាចធ្លាក់ខ្លួនទៅក្រោមឥទ្ធិ-

ពលរបស់បុរសនោះក្នុងផ្លូវណាមួយពុំមាន ។ គំនិតបែបនេះ រឹងរឹតតែធ្វើឲ្យខ្ញុំរំពៃគិតដល់នាងយ៉ាងខ្លាំងថែមទៀត ។

ខ្ញុំគិតថា រូបខ្ញុំដូចជាផ្ដេសផ្ដាសហើយ . . . បើពុំមានផ្ដេសផ្ដាស គឺដូចជាគេកល់ផ្ដេសផ្ដាសដែរ ព្រោះខ្ញុំចេះតែស្រមៃឃើញនាង យូរ៉េត ជានិច្ច ។ ប្រសិនបើឪពុកម្ដាយរបស់ខ្ញុំបានដឹងរឿងនេះ លោកមុខជាពិបាកចិត្តមិនតិចឡើយ ។ អ្វីជាហេតុធ្វើឲ្យខ្ញុំជាប់ចិត្តនឹងស្រី ដែលទើបនឹងស្គាល់គ្នាថ្មីៗនេះ ខ្ញុំក៏ដូចជាគេឆ្លើយពុំរួច ។ ចួនកាលខ្ញុំគិតថា ខ្ញុំប្រហែលជានៅក្មេងពេក ឬក៏ធ្លាប់ឃើញស្ត្រីតិចពេកក៏ពុំដឹង បានជាគ្រាន់តែមកឃើញស្ត្រីដូចនាងយូរ៉េតប៉ុណ្ណោះ ក៏យល់ថាល្អ ហើយបានបណ្ដោយខ្លួនឲ្យធ្លាក់ចុះទៅក្នុងអន្លង់ស្នេហាភ្លាម ។ តែក៏ជាការពិតណាស់ ខ្ញុំនៅពុំដែលបានឃើញស្ត្រីឯណាដែលល្អដូចនាងយូរ៉េតសោះ ។

វគ្គទី ៤

# អត្តឃាតកម្ម

បួនថ្ងៃបានកន្លងផុតទៅយ៉ាងស្ងប់ស្ងៀម ដោយគ្មានអ្វីនឹងពោល ក្រៅពីការដែលខ្ញុំបាននឹករលឹកដល់នាង យូរ៉េត...

លុះមកដល់ថ្ងៃទី ៥ ហេតុការណ៍ដែលខ្ញុំពុំបានជាគិតឬនឹកនាក៏កើតឡើង . . .

ខ្ញុំស្រឡាំងកាំង ក្នុងខណៈដែលសុខ-សម្បូរ មិត្តសំឡាញ់ស្និទ្ធជិតរបស់ខ្ញុំមកប្រាប់ខ្ញុំថា ក្រុមប៉ូលិសបានឃើញខ្មោចនាង យូរ៉េត ហើមអណ្ដែតឡើងនៅទន្លេបាសាក់ ត្រង់មុខវត្តកែវព្រះភ្លើង ហើយគេសន្និដ្ឋានថា នាង យូរ៉េត ប្រហែលជាធ្វើអត្តឃាតកម្ម ដោយការលោតទឹកសម្លាប់ខ្លួនឯង ។

ខ្ញុំដូចជាស្លុតរន្ធត់ចិត្តជាខ្លាំង ដូចជាថាតាំងពីកើតមកនៅពុំដែលមានពេលណាស្លុតរន្ធត់ចិត្តឲ្យខ្លាំងដូចពេលនេះឡើយ ។

– ពិតមែនឬ ? (ខ្ញុំសួរមិត្តរបស់ខ្ញុំ) ខ្មោចនោះពិតជាខ្មោចនាង យូរ៉េត មែនឬ ?

– ហ្នឹងហើយ ! ក្រុមប៉ូលិសគេបានពិនិត្យមើលឃើញជាអញ្ចឹង ៗ

– ជាខ្មោចដែលហើមហើយអណ្តែតឡើងមែនឬ ?

– ហ្នឹងហើយ !

ដំណឹងនេះ ជាដំណឹងអាក្រក់សំរាប់រូបខ្ញុំ . . .

ខ្ញុំគិតថា បើទុកណាជានាង យូរ៉េត នៅពុំទាន់បានមកជាគូសង្សាររបស់ខ្ញុំ ដោយនាងពុំទាន់ទទួលការស្នេហាពីខ្ញុំ ហើយខ្ញុំក៏នៅពុំទាន់បាននិយាយប្រាប់នាងថា ខ្ញុំស្រឡាញ់នាងក៏ដោយ ដល់បានដឹងថានាង យូរ៉េត ស្លាប់ ខ្ញុំក៏ស្លុតរន្ធត់ចិត្តឥតឧបមា . . .

ហេតុអ្វីបានជានាង យូរ៉េត ធ្វើអត្តឃាតកម្ម ? ការនេះផុតវិស័យដែលខ្ញុំគិតដល់ . . . ប៉ុន្តែមានខណៈខ្លះ ចិត្តខ្ញុំជួប



ជាពុំជឿ . . .

នៅមានខណៈខ្លះទៀត ចិត្តខ្ញុំសង្ស័យឬសង្ឃឹមថា នាង យូរ៉េត នៅពុំទាន់ស្លាប់ . . . ខ្ញុំគ្មានហេតុផលអ្វីមួយសំរាប់ជួយពន្យល់នូវសេចក្តីសង្ស័យនោះ ក្រៅពីបំណងល្អរបស់ខ្ញុំចំពោះនាងឡើយ ព្រោះខ្ញុំពុំចង់ឲ្យនាងស្លាប់ . . .

យើងបាននាំគ្នាទៅផ្ទះ ដែលនាង យូរ៉េត សំណាក់ ហើយបានជួបនឹងស្ត្រីចំណាស់ ដែលបានជូននាង យូរ៉េត ដើរលេងជាមួយខ្ញុំកាលពីថ្ងៃមុន ៗ យើងបានសាកសួរដឹងការណ៍ថា គាត់ជាម្ចាស់ផ្ទះនេះ ៗ ការដែលនាង យូរ៉េត មកសំណាក់នៅផ្ទះនេះ ក៏ព្រោះលោកស័ក្តិពីរ ស៊ី នាំយកមកផ្ញើជាបណ្តោះអាសន្ន ៗ គាត់ធ្លាប់បានស្គាល់លោកស័ក្តិពីរនេះបីបួនខែមកហើយ ដោយសារលោកនេះស្គាល់រាប់អានគ្នានឹងកូនប្រុសរបស់គាត់ម្នាក់ ដែលធ្វើការនៅសៀមរាប ៗ គាត់បានបញ្ជាក់ប្រាប់យើងថា លោកអនុសេនីយ៍ទោនេះ

ជាសេនាសំណាប់របស់ ដាប-ឈួន ។ ឯរូបនាង យូរ៉េត គឺលោកស័ក្ដិពីរបានចាប់យកមកពីស្រុកពួក តាមបញ្ជាពី ដាប-ឈួន ដើម្បីយកមកធ្វើជាប្រពន្ធចុង ។ ប៉ុន្តែនាប់ជួនជាពេលនេះ ដាប-ឈួន មានជម្ងឺ ត្រូវចូលទៅព្យាបាលរោគនៅមន្ទីរពេទ្យ ទើបគេនាំនាងយកមកផ្ញើឲ្យនៅសំណាក់នៅផ្ទះគាត់សិន ។ ស្ត្រីម្ចាស់ផ្ទះនេះ បាននិយាយប្រាប់យើងថា ល្ងាចមួយគាត់បានឃើញលោកស័ក្ដិពីរ ស៊ីប៊ើករថយន្តមកទទួលយកនាង យូរ៉េត ទៅជាមួយនឹងស្ត្រីចំណាស់ម្នាក់ទៀត (ស្ត្រីចំណាស់ដែលខ្ញុំបានឃើញឯអគ្គគាសោមជាមួយនាង យូរ៉េត) ដែលមកពីសៀមរាបជាមួយគ្នា ដោយបានយកអីវ៉ាន់ទាំងអស់ទៅជាមួយផង ។ គាត់បានសួរគេ ។ ប្រាប់ថា នាំនាង យូរ៉េត ទៅជូនលោកមេទ័ព ដាប-ឈួន ហើយគេនឹងពុំត្រឡប់មកវិញទេ ព្រោះលោកមេទ័ពបានចាត់ការឲ្យនាង យូរ៉េត ទៅនៅឯផ្សារ



កាប៉ោត ។

យើងបាននាំគ្នាត្រឡប់ទៅផ្ទះវិញ ដោយការអស់សង្ឃឹម ...

ក្នុងរយៈពេលពីរបីថ្ងៃដែលកន្លងទៅនេះ ខ្ញុំខំទប់ចិត្តកុំឲ្យនឹកដល់នាង យូរ៉េត ទៀត ខំបំភ្លេចនាងចោល តែទប់ពុំបាន បំភ្លេចពុំកើត ... ខ្ញុំចេះតែស្រមៃឃើញនាងនៅជាប់នឹងភ្នែក ...

មានយប់ខ្លះ ខ្ញុំបានយល់សប្តិឃើញនាង យូរ៉េត ប៉ុន្តែដោយជំនឿរបស់ខ្ញុំធ្ងន់ទៅក្នុងផ្លូវថា នាង យូរ៉េត បានស្លាប់បាត់បង់ជីវិតទៅហើយនោះ មានយប់ខ្លះ ខ្ញុំបានបន់ស្រន់សូមឲ្យវិញ្ញាណក្ខន្ធរបស់នាងទៅកើតក្នុងទីបរមសុខ ហើយសូមឲ្យនាងរង់ចាំជួបនឹងខ្ញុំនៅទីនោះ ... ខ្ញុំបានបន់ស្រន់ សូមឲ្យវិញ្ញាណក្ខន្ធរបស់នាងមកពន្យល់ប្រាប់ខ្ញុំថា ហេតុអ្វីក៏បានជានាងសម្លាប់ខ្លួនឯងដូច្នេះ ? ... តែខ្ញុំពុំដែលយល់សប្តិ

ឃើញដូច្នេះសោះ... ខ្ញុំច្រើនតែយល់សប្តិឃើញថា នាង យូរ៉េត នៅពុំទាន់ស្លាប់... សព្វថ្ងៃនាងកំពុងតែធ្លាក់ខ្លួនចុះក្នុងសេចក្តីទុក្ខលំបាក ហើយនាងស្រែកអំពាវនាវសុំឲ្យខ្ញុំជួយនាង... ខ្ញុំពុំសូវជឿថា នាង យូរ៉េត នៅមានជីវិតរស់នៅឡើយ ហើយសុំឲ្យខ្ញុំជួយដោះទុក្ខនាងនោះទេ... ការដែលខ្ញុំយល់សប្តិឃើញបែបនេះ ក៏ដោយសារតែពីចិត្តរបស់ខ្ញុំរវើរវាយប៉ុណ្ណោះ... ហើយ, ទីបំផុត ខ្ញុំក៏គិតថា បើទុកជាខ្ញុំគិតយ៉ាងណា ក៏គ្មានបានប្រយោជន៍អ្វីដែរ...

ព្រឹកថ្ងៃសុក្រមួយ ក្នុងពេលដែលខ្ញុំកំពុងអង្គុយធ្វើការ លេខាហារីបានចូលមកប្រាប់ខ្ញុំថា មានស្ត្រីម្នាក់ត្រូវការជួបនឹងខ្ញុំ ។ ខ្ញុំដូចជារកនឹកពុំឃើញថា អ្នកណាត្រូវការជួបនឹងខ្ញុំ ហើយខ្ញុំមានការអ្វីជាមួយគេ ?

ខ្ញុំបានអនុញ្ញាតឲ្យស្ត្រីនោះចូលមកទាំងការងឿងឆ្ងល់ ។ ស្ត្រីចំណាស់នេះ ខ្ញុំពុំដែលបានឃើញមុខ ពុំដែល



ស្គាល់មែន ។ គាត់បានចូលមកជួបនឹងខ្ញុំដោយអាការៈសុភាពរាបសារ ។

— អ្នកមីងមានធុរៈអ្វី ? (ខ្ញុំសួរនៅពេលដែលគាត់បានជំរាបសួរខ្ញុំ រួចហើយខ្ញុំបានអញ្ជើញឲ្យគាត់អង្គុយដោយស្រួលបួល) ។

— ចាស លោក ! ខ្ញុំយកសំបុត្រមកជូនលោក (ស្ត្រីនោះនិយាយ ហើយហុចសំបុត្រមកឲ្យខ្ញុំ) ។

— សំបុត្រអ្នកណាមីង ?

— ស្ត្រីម្នាក់ពឹងខ្ញុំឲ្យយកមកជូនលោក ។

— ស្ត្រីណា ? ឈ្មោះអី ?

— ចាស ! ខ្ញុំក៏មិនស្គាល់ឈ្មោះគេដែរលោក ។

— ចុះគេនៅឯណា ?

— ចាសគេនៅឯកំពត ។

ខ្ញុំបានហែកសំបុត្រមើលដោយការងឿងឆ្ងល់ ព្រោះ

តួអក្សរនៅលើស្រោម ដែលជាក់ឈ្មោះរបស់ខ្ញុំយ៉ាងត្រឹមត្រូវ នោះ ខ្ញុំពុំដែលស្គាល់សោះឡើយ ។

សេចក្ដីសំបុត្រនោះមានត្រឹមតែពីរបីបន្ទាត់ថា ៖

លោកជាទីគោរព,

សព្វថ្ងៃនេះ ខ្ញុំកំពុងឋិតនៅក្នុងសេចក្ដីអន្តរាយ — សូមលោកមេត្តាជួយដោះទុក្ខខ្ញុំផង អ្នកដែលកាន់សំបុត្រមកជូនលោកនេះ អាចនាំផ្លូវលោកទៅជួបនឹងខ្ញុំ ។

ខ្ញុំសង្ឃឹមថា មានតែលោកម្នាក់ប៉ុណ្ណោះ ដែលអាចជួយដោះទុក្ខខ្ញុំបាន ។

ហត្ថលេខា : យូរ៉ែត

ខ្ញុំបានសាកសួរស្រីចំណាស់នោះ ដល់ស្រុកទេសទីកន្លែងរបស់គាត់ ។ គាត់បានប្រាប់ថា គាត់នៅស្រុកកូនសត្វ (កំពត) ជិតផ្ទះដែលអ្នកម្ចាស់សំបុត្រនោះនៅដែរ ។

— អ្នកមីង ! ម្ចាស់សំបុត្រនេះ គេទៅនៅស្រុកនោះ



យូរហើយឬ ? (ខ្ញុំសួរ)

— ចាស ! ទើបនឹងទៅនៅប្រហែលជាជាងមួយអាទិត្យប៉ុណ្ណោះ ។

— ម្ចាស់ផ្ទះនោះ ជាបងប្អូននឹងម្ចាស់សំបុត្រនេះឬ ?

— មើលទៅដូចជាពុំមែនបងប្អូនទេ ព្រោះម្ចាស់ផ្ទះជាអ្នកស្រុកនោះ ខ្ញុំធ្លាប់ស្គាល់យូរណាស់មកហើយ ស្គាល់តាំងពីដូនអម្បូរទៀតផង ពុំដែលស្គាល់តែម្ចាស់សំបុត្រប៉ុណ្ណោះ ។

— កាលដែលម្ចាស់សំបុត្រនេះ ទៅនៅស្រុកនោះ គេទៅតែម្នាក់ឯងទេឬ ?

— ចាសទៅជាមួយនឹងស្ត្រីម្នាក់ និងប្រុសម្នាក់ទៀត ។

— ចុះអ្នកមីងមានសង្កេតឃើញអ្នកទាំងនោះ យ៉ាងម៉េចខ្លះ ?

— មើលទៅ អ្នកទាំងពីរនាក់នោះ ព្រមទាំងម្ចាស់ផ្ទះដូចជាកោតក្រែងអ្នកម្ចាស់សំបុត្រនេះណាស់ ។

- ចុះគេមានផ្ដាំមកខ្ញុំថាម៉េចខ្លះទៀតដែរឬទេ ?

- ចា៎ស គេគ្រាន់តែប្រាប់ថា ឲ្យខ្ញុំនាំផ្លូវលោកទៅតែប៉ុណ្ណោះ ។

ខ្ញុំបានសាកសួរស្ត្រីនោះដល់ទីកន្លែងដែលគាត់សំណាក់នៅក្រុងភ្នំពេញ ។ គាត់បានប្រាប់ថា គាត់សំណាក់នៅនឹងផ្ទះលោកកុម្មីស្សែរផេង នៅផ្សារសួនចាស់មាត់ទន្លេ ដែលខ្ញុំអាចទៅរកឃើញបានដោយងាយហើយ ។ ខ្ញុំបានសន្យានឹងគាត់ថា ស្អែកនេះថ្ងៃសៅរ៍ម៉ោង ១២ ខ្ញុំនឹងទៅទទួលគាត់នៅដើមពោធិ៍មុខផ្ទះលោកផេង ដើម្បីធ្វើដំណើរទៅកំពតជាមួយគ្នា ។

ខ្ញុំនឹកគិតដល់ការយល់សប្តិរបស់ខ្ញុំពីថ្ងៃមុន ដែលធ្លាប់ស្រមៃឃើញថា នាង យូរ៉េត កំពុងឋិតនៅក្នុងសេចក្ដីអន្តរាយ ហើយស្រែកហៅឲ្យខ្ញុំជួយនាង ។ ការយល់សប្តិបែបនេះ អាចជានិមិត្តរូបនៃការស្មានរបស់ខ្ញុំថា នាង យូរ៉េត



នៅមានជីវិតរស់នៅឡើយ ក៏ថាបាន ។

សំបុត្រនេះ ខ្ញុំជឿខ្លះ ពុំជឿខ្លះ ។ ការដែលខ្ញុំបានសន្យាជាមួយស្ត្រីចំណាស់នោះ ក៏សន្យាដោយឥតបើគិតវែងឆ្ងាយ ។ ខ្ញុំត្រូវប្រើគំនិតយ៉ាងខ្លាំង ។ ខ្ញុំគិតថា នាង យូរ៉េត បានធ្វើអត្តឃាតកម្មសម្លាប់បាត់បង់ជីវិតទៅហើយ ឥឡូវនាងបែរជាមានជីវិតរស់នៅឡើងវិញហើយ ។ រឿងនេះយ៉ាងណាទៅវិញ ? ក្រែងលោមាននរណាត្រូវការបោកបញ្ឆោតខ្ញុំលេងទេដឹង ព្រោះគេដឹងថា ខ្ញុំស្រឡាញ់នាង យូរ៉េត ? ឬក៏មានគេត្រូវការជីវិតខ្ញុំ ? ប្រសិនបើមានអ្នកណាត្រូវការជីវិតខ្ញុំមែននោះ អ្នកនោះគឺលោកអនុសេនីយ ស៊ី សេនា សំណាប់ ជាប - ឈ្លួង ព្រោះគេគិតថា ខ្ញុំមានការទាក់ទងនឹងនាង យូរ៉េត ឬក៏គេសង្ស័យថា នាង យូរ៉េត ស្រឡាញ់ខ្ញុំ ហើយគេក៏ស្អប់ខ្ញុំ ចង់សម្លាប់ខ្ញុំចោលក៏ពុំដឹង ?

មួយអន្លើ ខ្ញុំចង់យករឿងនេះទៅប្រាប់មិត្ត សុខ-សម្បូរ

តែមួយអន្លើ ខ្ញុំគិតថា កុំនាំឲ្យរវល់នឹងរឿងផ្ទាល់ខ្លួនរបស់ខ្ញុំ ។ រឿងនេះ ក្លាយទៅជាបញ្ហាដ៏ស្មុគស្មាញសំរាប់ខ្ញុំ ក្នុងថ្ងៃនេះ ព្រោះត្រូវខ្ញុំគិតតែម្នាក់ឯង ។

តើខ្ញុំគួរទៅ ឬពុំគួរទៅកំពត ?

ទីបំផុត ខ្ញុំបានសំរេចចិត្តថា ត្រូវតែទៅ ទៅតែម្នាក់ឯង ទៅរកនាង យូរ៉េត បើទុកជាការនេះ ត្រូវគេបញ្ឆោតយកខ្ញុំ ទៅសម្លាប់ចោលក៏ដោយ ។

លុះដល់កំណត់ពេល ខ្ញុំក៏បានទៅទទួលយកស្ត្រីចំណាស់នោះពីផ្សារស្ទួនតាស់ ហើយធ្វើដំណើរទៅកំពតដោយរថយន្តហ្ស៊ីបដែលខ្ញុំបានខ្ចីពីមិត្តភក្តិ ។ យើងបានទៅដល់ក្បាលរមាសនៅម៉ោង ១៤ ។ តែពេលនោះស្ត្រីចំណាស់អ្នកនាំផ្លូវបានឲ្យយោបល់ដល់ខ្ញុំថា គាត់ពុំគួរនៅជិះឡានជាមួយនឹងខ្ញុំទៅដល់ទីកន្លែងដែលនាង យូរ៉េត នៅឡើយ ព្រោះក្រែងមានរឿងកើតពុំស្រួលដល់គាត់ ។ គាត់បាន





ឲ្យខ្ញុំបើកឡានទៅមុនគាត់ ហើយគាត់ជិះរ៉ឺម៉កទៅតាមក្រោយ ដោយគាត់បានប្រាប់ឲ្យខ្ញុំទៅរកផ្ទះ ដែលនាង យូរ៉េត នៅនោះ យ៉ាងល្អិតល្អន់ ។ ខ្ញុំក៏យល់ព្រមតាម ។

ខ្ញុំក៏ចាប់ផ្តើមសង្ស័យដល់រឿងពុំគួរជួបមុនទៀត គឺសង្ស័យថា ក្រែងគេបញ្ឆោតយកខ្ញុំទៅសម្លាប់ចោល ព្រោះស្រុកកូនសត្វជាស្រុកព្រៃ នៅឆ្ងាយពីទីរួមខេត្ត ឆ្ងាយពីប៉ូលិសទាហាន ។ តែចិត្តមួយគិតថា ចំណាប់ជាជ្រុលមកប៉ុណ្ណេះហើយ ត្រូវតែទៅឲ្យដល់ ទោះជាយ៉ាងណាក៏ដោយ ។ បើទុកជាគេចង់បញ្ឆោតខ្ញុំ យកទៅសម្លាប់ចោលមែននោះ ក៏មើលទៅដូចជាពុំងាយនឹងសម្លាប់លេងបានដោយងាយៗទេ ព្រោះខ្ញុំដឹងខ្លួនមុន ខ្ញុំពុំប្រមាទ ខ្ញុំមានកាំភ្លើង – ការសម្លាប់មនុស្សដែលដឹងខ្លួនមុនហើយ ដែលបានប្រុងខ្លួនមុនដូចខ្ញុំនេះ ក៏ជាការពុំងាយប៉ុន្មានឡើយ ។

ខ្ញុំបានទៅរកផ្ទះ ដែលនាង យូរ៉េត នៅនោះឃើញ ។

ខ្ញុំបានជួបនាង យូរ៉េត របស់ខ្ញុំ ដូចពាក្យណែនាំរបស់ស្ត្រីអ្នកនាំផ្លូវនោះមែន ។ ខ្ញុំបានសង្កេតឃើញអ្នកនៅជាមួយនាងទាំងអស់សង្ស័យលើរូបខ្ញុំ ។ ពេលនោះខ្ញុំគិតថា ខ្ញុំត្រូវប្រើឧបាយកល "អូសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក" ។ ខ្ញុំបានសំដែងអាការរាក់ទាក់ ជាមួយអ្នកម្ចាស់ផ្ទះព្រមទាំងមនុស្សអ្នកនៅក្បែរនាង យូរ៉េត យ៉ាងស្រួល ។ ខ្ញុំនិយាយស្តីជាមួយនាង យូរ៉េត ដោយការគោរពល្មមតែសំដែងឲ្យអ្នកទាំងនោះយល់ថា រូបខ្ញុំជាអ្នកបំរើរបស់អ្នកណាមួយ ។ ឯនាង យូរ៉េតវិញ ក៏ហាក់ដូចជាដឹងចិត្តខ្ញុំ ព្រោះនាងបាននិយាយស្តីជាមួយខ្ញុំ តាមទំនងនាយហៅហ្វាយនិយាយទៅកាន់អ្នកបំរើ ។ ខ្ញុំនិយាយប្រាប់នាង ព្រមទាំងអ្នកទាំងអស់នោះថា លោកបានប្រើឲ្យខ្ញុំបាទមកទទួលយកនាងទៅភ្នំពេញ តែយកទៅតែម្នាក់ឯង ដោយពុំចាំបាច់ឲ្យអ្នកដែលនៅក្បែរទៅជាមួយផងឡើយ ព្រោះនាង យូរ៉េត



នឹងត្រូវត្រឡប់មកទីនេះ នៅថ្ងៃខាងស្អែក ។ ការដែលខ្ញុំធ្វើជានិយាយថា លោកបានប្រើឲ្យខ្ញុំបាទមកទទួលយកនាងទៅភ្នំពេញនោះ ក៏ព្រោះខ្ញុំគិតថា អ្នកទាំងអស់នោះមុខជាថាពាក្យ "លោក" ដែលខ្ញុំហៅនោះ ក៏គឺដែលលោកយកនាង យូរ៉េត មកលាក់ទុកនៅទីនេះនុ៎ះឯង ។

ការនេះពិតដូចខ្ញុំស្មានមែន ។ អ្នកទាំងនោះ គ្មានសាកសួរដេញដោលអ្វីច្រើនឡើយ ។ ពួកគេបាននាំគ្នាជួយរៀបចំសំពត់អាវ នាង យូរ៉េតទៀតផង ។ ខ្ញុំពេញចិត្តចំពោះគំនិតរបស់ខ្ញុំនេះជាខ្លាំង ។

ខ្ញុំបាននាំនាង យូរ៉េត ចេញពីទីនោះ នៅម៉ោង ១៦ កន្លះ ។ ខ្ញុំបានសាកសួរនាងដល់រឿងរ៉ាវផ្សេងៗ ដែលនាងត្រូវទៅនៅស្រុកកួនសត្វនេះ ។ ខ្ញុំបាននិយាយប្រាប់នាងអំពីរឿងខ្មោចដែលគេឃើញនៅមុខវត្តកែវព្រះភ្លើង ហើយគេបានសន្និដ្ឋានថា ជាខ្មោចនាងដែលធ្វើអត្តឃាតកម្ម ហើយខ្ញុំ

ក៏ជឿថាដូច្នោះដែរ ។

នាងដូចជាភ្ញាក់ខ្លួនព្រឺត ហើយនាងបាននិយាយរឿងក៏ប្រាប់ខ្ញុំថា ការដែលនាងត្រូវទៅនៅស្រុកកូនសត្វនេះ គឺលោកអនុសេនីយ៍ទោ ស៊ី ជាអ្នកនាំនាងទៅ ដោយការបង្ខិតបង្ខំ ហើយបានចាត់មនុស្សពីរនាក់ទៀត គឺប្រុសម្នាក់ស្រីម្នាក់ ឲ្យទៅនៅចាំយាមនាង កុំឲ្យនាងទៅណា ដែលមើលទៅដូចជាគេយកនាងទៅឃុំឃាំងទុក ។

លុះខ្ញុំបានស្តាប់ពាក្យសំដីនាង យូរ៉េត ដូច្នេះ ខ្ញុំក៏ចាប់ផ្តើមសង្ស័យឡើងថា រឿងនេះប្រហែលកលឧបាយរបស់អនុសេនីយ៍ទោ ស៊ី ទេ ព្រោះថាដំបូង ដាប-ឈួន បានបង្គាប់ឲ្យចាប់យកនាង យូរ៉េត មកឲ្យ — អនុសេនីយ៍ទោ ស៊ី ក៏ប្រតិបត្តិតាម តែលុះយកបានមកហើយ អនុសេនីយ៍ទោ ស៊ី ក៏ប្រហែលស្រឡាញ់នាងដែរ — ដើម្បីបំបាត់ដាននេះ (បើតាមខ្ញុំគិត) អនុសេនីយ៍ទោនោះ ត្រូវនាំនាង យូរ៉េត



យកទៅលាក់បំពួនទុកនៅស្រុកកូនសត្វ គេយកស្រីណាម្នាក់ផ្សេងទៀតយកទៅសម្លាប់ ហើយបោះចោលទៅក្នុងទន្លេ ដោយយកសំលៀកបំពាក់និងចិញ្ចៀនរបស់នាង យូរ៉េត ទៅបំពាក់នឹងរូបស្រីដែលគេសម្លាប់នោះ ព្រោះថានៅពេលដែលប៉ូលិសឃើញខ្មោច ហើយផ្សាយដំណឹងថា ជាខ្មោចនាង យូរ៉េត នោះ គឺផ្សាយតាមការអះអាងក្នុងការស្គាល់របស់អនុសេនីយ៍ទោនោះ ដែលបានឲ្យការប៉ូលិសថា ក៏ស្គាល់ ដោយសារសម្លៀកបំពាក់និងចិញ្ចៀនរបស់នាងដែរ ។

ខ្ញុំបាននិយាយពីការសង្ស័យរបស់ខ្ញុំ ដូចខាងលើឲ្យនាង យូរ៉េត ស្តាប់ ៗ នាងជឿខ្លះពុំជឿខ្លះ ។ នាងនិយាយថា ដូចជាពុំគួរគិតដូច្នោះសោះ ព្រោះអនុសេនីយ៍ទោនេះ ខ្លាចលោកមេទ័ពសៀមរាបណាស់ ហើយខ្លួនគេជាសេនាសំណប់របស់មេទ័ពនោះផង តែមានការគួរឲ្យគិតយ៉ាងនោះខ្លះៗដែរ គឺមានពេលច្រើនផងដែលអនុសេនីយ៍នោះ បានប្រើពាក្យសំដី

ប្រលោមលួងលោមក្នុងផ្លូវស្នេហាមករកនាង ហើយនាងក៏បានបាត់របស់ដូចជាគេរកឃើញជាប់នឹងខ្លួនខ្មោច នោះមែនដែរ ។

ខ្ញុំបាននិយាយប្រាប់នាងវិញថា ប្រសិនបើការស្មានរបស់ខ្ញុំពុំខុសទេនោះ ខ្ញុំគិតថា ធម្មតាចោរពុំដែលមានចិត្តស្មោះត្រង់នឹងគ្នាទេ ហើយយើងក៏ពុំគួរជាគិតថា ចោរនឹងពុំលួចចោរ ឬក៏ចោរនឹងមិនប្លន់ដណ្តើមពីចោរគ្នាវានោះសោះឡើយ ។

ឥឡូវខ្ញុំជឿជាក់ថា ខ្មោចស្ត្រីដែលគេរកឃើញថា ធ្វើអត្តឃាតកម្មនោះ ប្រាកដជាពុំមែនដូច្នោះទេ ។ ខ្មោចនោះគឺប្រាកដជាអនុសេនីយទោនោះ នាំស្ត្រីណាម្នាក់ យកទៅប្រហារសម្លាប់ចោល ហើយក៏យកសំពត់អាវនិងចិញ្ចៀននាងយូរ៉េត ទៅពាក់ឲ្យ ហើយក៏បោះចោលទៅក្នុងទន្លេចតុមុខ ៕



តែស្ត្រីនោះជាអ្នកណា? កូនចៅអ្នកណា? ខ្ញុំក៏ពុំអាចដឹងបានដែរ ។

ដំបូងខ្ញុំគិតថា នឹងនាំនាងយូរ៉េត ត្រឡប់មកភ្នំពេញវិញ តែលុះទៅដល់ក្បាលមោស ខ្ញុំក៏ហួសទៅលេងកែបសិន ។ ខ្ញុំក៏បានបញ្ជារថយន្តឲ្យលូនត្រោះទៅរកកែប ។

– ខ្ញុំគិតថា (ខ្ញុំនិយាយក្នុងខណៈដែលរថយន្តលូនសន្សឹមៗ តាមផ្លូវថ្នល់) យើងគួរស៊ើបសួរ ដើម្បីឲ្យបានដឹងច្បាស់ក្នុងរឿងខ្មោចនេះ ។

– ណ្ហើយ! វានាំឲ្យខូចខាតពេលវេលាឥតអំពើទេ ។

– ចុះវាមានទៅខូចខាតអី បើយើងគ្រាន់តែស៊ើបសួរឲ្យដឹងការពិតប៉ុណ្ណោះ ។

– ខ្ញុំមើលទៅដូចជាគ្មានប្រយោជន៍អ្វីទេ វាមានតែពីត្រូវនឹងទុក្ខទោសទៀតផង ព្រោះគេមានអំណាច អាចធ្វើអីយើងបានតាមចិត្ត – យើងកុំទៅរវល់នឹងរឿងនោះធ្វើអី –

យើងគិតតែពីរិះរកផ្លូវ ដើម្បីចាប់ផ្ដើមតាំងជីវិតសាជាថ្មីវិញទៅល្អជាជាង ។

តែខ្ញុំជឿជាក់ថា ខ្មោចនោះគឺសក្តិគីរ ស៊ី នុ៎ះឯង ជាអ្នកសម្លាប់ - សម្លាប់ដើម្បីបំបាត់ដាន ព្រោះវាចង់បានអ្នកនាង ។

នាងយូរ៉ែតពុំឆ្លើយថាអ្វី ។ ខ្ញុំដឹងថា នាងពុំចង់ដឹងពុំចង់ឮនូវរឿងនោះ ។ ខ្ញុំបាននិយាយបំបែរទៅរឿងថ្មី ។ ខ្ញុំប្រាប់នាងថា យប់នេះចង់ទៅសម្រាកកាយឯកែប ។ នាងយូរ៉ែត បានព្រមព្រៀងតាមខ្ញុំ ។

លុះហួសផ្លូវបំបែកទៅដំណាក់បន្ទើរបន្ទិច ខ្ញុំបានបញ្ឈប់រថយន្ត ។ យើងបាននាំគ្នាចុះពីរថយន្ត ហើយទៅឈរមើលទេសភាពនានា - មើលព្រះអាទិត្យ ដែលបញ្ចេញរស្មីនៅពេលជិតព្រលប់ ។

ចាប់តាំងពីពេលដែលខ្ញុំបានជួបស្គាល់នាង យូរ៉ែតមក



ខ្ញុំនិងនាងពុំដែលបាននិយាយគ្នាពីរឿងស្នេហាដល់ម្ដងសោះ ។ ឥឡូវខ្ញុំព្រមទទួលខុសថា ខ្ញុំស្រឡាញ់នាង យូរ៉ែត ហើយ តែខ្ញុំនៅពុំទាន់ដឹងថា តើនាង យូរ៉ែតស្រឡាញ់ខ្ញុំ ដូចខ្ញុំស្រឡាញ់នាងដែរឬទេ ? ខ្ញុំរកស្មានពុំត្រូវថា តើនាងនឹងថាដូចម្ដេច ប្រសិនបើខ្ញុំបញ្ចេញនូវពាក្យប្រាប់នាងថា ខ្ញុំស្រឡាញ់នាងនោះ ។

ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ការធ្វើដំណើរតែពីរនាក់កាត់ទេសភាពដ៏ល្អពីធម្មជាតិយ៉ាងនេះ មើលទៅគឺហាក់ដូចជាមានអ្វីមកជម្រុញចិត្តយើងឲ្យធ្លាក់ក្នុងផ្លូវស្នេហាទាំងឡើងៗ យើងឃើញបក្សីហើរត្រៀលធ្លាក់កាត់រកអាហារ ហើយប្រុងប្រៀបខ្លួនប្រាណហើរត្រឡប់ទៅរកសំបុកវិញ ។ ចំណែកខាងយើងតាំងពីនោកឯណោះ យើងពុំទាន់ដឹងថា តើសំបុករបស់យើងនៅឯណាឡើយ ?

ពន្លឺព្រះអាទិត្យក៏ចេះតែចុះទន់ស្ទើមបន្តិចៗ ។ ភូមិភាគ

ដែលមានផ្ទៃដីដ៏ធំល្វឹងល្វើយវែងឆ្ងាយ ដាច់កន្ទុយភ្នែកដូច្នេះ យើងគិតថា កាលបើអស់រស្មីព្រះអាទិត្យទៅហើយ គឺមុខជាងងឹតស្ងាត់ឈឹងគួរឲ្យខ្លាច ។

ពុំយូរប៉ុន្មាន ព្រះអាទិត្យក៏បាំងខ្លួនបាត់ទៅ ទិសខាងលិច ហើយសភាពងងឹតក៏គ្របដណ្តប់ជុំវិញខ្លួនយើង ។

– លោក! (នាង យូរ៉េត ចាប់ផ្តើមនិយាយឡើង) ខ្ញុំគិតថា លោកកំពុងតែគិតរឿងអីម្យ៉ាង យ៉ាងជ្រាលជ្រៅ ។

– ទេ! ខ្ញុំគ្មានគិតអ្វីទេ ខ្ញុំកំពុងតែប្រាថ្នាថា សូមឲ្យគ្រោះកាចចង្រៃទាំងអស់របស់អ្នកនាងអន្តរធានបាត់ទៅ ដូចជារស្មីនៃព្រះអាទិត្យដែលទើបលិចអម្បាញ់មិញនេះ ។

– តែខ្ញុំពុំចង់ឈានចូលទៅក្នុងសភាពងងឹត អញ្ចឹងទេលោក ។

– ពុំងរ៉ែកទេ! ព្រះអាទិត្យលិចបាត់ទៅទិសខាងលិចមែន តែព្រះច័ន្ទនឹងរះឡើងពីទិសខាងកើតមកជំនួសវិញ ។



– តែទំរាំយើងបានឃើញពន្លឺព្រះច័ន្ទ យើងក៏ងងឹតអស់ពេលច្រើនម៉ោងទៅដែរ ។

– ក៏ប៉ុន្តែ កាលបើមានអ្នកនាងនៅជាមួយ (ខ្ញុំបាននិយាយធ្វើដូចជាពុំដែលធ្លាប់និយាយជាមួយនាង យូរ៉េត សោះ) ខ្ញុំក៏ក្ដីជានិច្ច – រូបអ្នកនាងជាពន្លឺនៃដួងចិត្តរបស់ខ្ញុំ គ្រប់ពេលវេលា ។

នាង យូរ៉េត បែរមុខមកសំឡឹងមើលខ្ញុំ... នាងសំឡឹងមើលដោយក្រសែភ្នែកដ៏មុត... ក្រសែភ្នែកដែលអាចចាក់បេះដូងរបស់ខ្ញុំឲ្យមុតធ្លុះធ្លាយ ...

– ខ្ញុំស្រឡាញ់អ្នកនាង ...! (ខ្ញុំពោលនៅពេលដែលក្រសែភ្នែកដ៏មុតរបស់នាង សំឡឹងចំមកភ្នែករបស់ខ្ញុំ ហើយក្រសែភ្នែកនោះ គឺមិនផ្លាស់កន្លែងទៅខាងណាទៀត ដែលធ្វើឲ្យខ្ញុំនឹកក្រែងថា ពាក្យសំដីយ៉ាងនេះ នឹងធ្វើឲ្យនាងពុំសប្បាយចិត្ត) ។ តែបន្តិចមក ខ្ញុំឃើញនាងញញឹមបន្តិចៗ ដែលធ្វើ

ឲ្យការក្រែងរបស់ខ្ញុំសន្សឹមបាត់ទៅម្ដងបន្តិចៗ ។

— កេកេ! (នាង យូរ៉េត និយាយដោយសំឡេងញ័រៗ) ខ្ញុំពុំដឹងជាឆ្លើយតបលោកវិញថាយ៉ាងម៉េចទេ ...

— ពិបាកណាស់ទៅឬអ្នកនាង? ពិបាកណាស់ឬ ដែលអ្នកនាងនឹងឆ្លើយប្រាប់ខ្ញុំ ឲ្យបានដឹងផងនោះ?

— ចុះបើខ្ញុំឆ្លើយតបលោកថា ខ្ញុំស្រឡាញ់លោកដែរនោះ តើផលវាយ៉ាងណាទៅ?

— ផលគឺធ្វើឲ្យខ្ញុំសប្បាយចិត្តតែប៉ុណ្ណោះ ។

តែជួនកាល វាបានផលផ្ទុយទៅវិញក៏មិនដឹង ។

— ផ្ទុយ? ផ្ទុយយ៉ាងម៉េចទៅ?

— ព្រោះខ្ញុំគិតថា ចាប់តាំងពីពេលដែលយើងបានស្គាល់គ្នាមក រឿងរ៉ាវរបស់ខ្ញុំ បានធ្វើឲ្យលោកពិបាកច្រើនណាស់ទៅហើយ។ ប្រសិនបើខ្ញុំឆ្លើយថា ខ្ញុំស្រឡាញ់លោកទៀតនោះ ខ្ញុំគិតក្រែងលោវាតែធ្វើឲ្យលោកពិបាកថែមទៀតទេដឹង?



— នុ៎ះជារឿងផ្សេងដោយឡែកពីគ្នា — រឿងស្រឡាញ់ ឬពុំស្រឡាញ់នោះ ជាបញ្ហានៅក្នុងផ្លូវចិត្ត ឯរឿងពិបាក ឬពុំពិបាកនោះ ជាបញ្ហាទាក់ទងនឹងហេតុការណ៍ — យើងគួរបែកឲ្យដាច់ដោយឡែកពីគ្នា ។

— លោកមានគុណលើរូបខ្ញុំច្រើនណាស់ ។

— តែពាក្យសំដីរបស់អ្នកនាងទាំងអស់ នៅពុំទាន់បានបញ្ជាក់ប្រាប់ខ្ញុំថា អ្នកនាងស្រឡាញ់ខ្ញុំ ឬក៏ពុំស្រឡាញ់នៅឡើយទេ ។

ខ្ញុំជាមនុស្សខ្សត់ស្នេហា — ខ្ញុំពុំដែលដឹងសោះឡើយថា សេចក្ដីស្នេហានោះ មានរសជាតិយ៉ាងណា? ប្រសិនបើខ្ញុំនិយាយថា ខ្ញុំចាប់ផ្ដើមស្គាល់នូវសេចក្ដីស្នេហានោះ ក៏គឺខ្ញុំទើបនឹងបានស្គាល់ក្នុងកាលដែលខ្ញុំបានជួបនឹងលោកនេះឯងៗ

ខ្ញុំយល់ថា នុ៎ះឯងហើយ ជាចំឡើយរបស់នាង យូរ៉េត ថា នាងស្រឡាញ់ខ្ញុំដែរ ព្រោះខ្ញុំគិតថា ខ្ញុំពុំអាចសន្សឹមនូវ

ពាក្យពេចន៍អ្វីច្បាស់លាស់ជាងនេះបានឡើយ ។ បើតាមក្បួនតម្រាចិត្តវិជ្ជាដែលខ្ញុំធ្លាប់បានអានថា ស្ត្រីប្រៀបដូចជាផ្កាថ្កាវនៃកាណាបក្រគាចិកប៉ាំង — ស្ត្រីពុំងាយនឹងប្រាប់នូវទឹកចិត្តរបស់នាងដល់បុរសឡើយ ព្រោះពួនកាលសូម្បីតែខ្លួនឯងក៏ពុំដឹងដែរថា ទឹកចិត្តរបស់នាងនោះមានសភាពយ៉ាងណាឡើយ ។ ដូច្នេះ ការដែលខ្ញុំបានទទួលនូវចំឡើយពីនាងយ៉ូវ៉េតត្រឹមតែប៉ុណ្ណោះ ខ្ញុំក៏ពេញចិត្តណាស់ទៅហើយ ។

ខ្ញុំបានចាប់ដៃនាង ... ខ្ញុំដឹងថា ដៃនាងញ័រៗ សមនឹងពាក្យដែលនាងនិយាយថា នាងពុំធ្លាប់ស្គាល់នូវសេចក្តីស្នេហានោះមែន... នាងពុំបានហាមឃាត់ ឬបម្រះទាញដៃចេញទៅវិញឡើយ .. ខ្ញុំលើកដៃនាងយកមកថើប ... នាងភិតភ័យញាប់ញ័រជាខ្លាំង .....

— ខ្ញុំស្រឡាញ់អ្នកនាងណាស់ (ខ្ញុំនិយាយដើម្បីរម្ងាប់នូវការភិតភ័យរបស់នាង) ហើយសេចក្តីស្រឡាញ់នេះ វាប់



ជាជាសេចក្តីស្នេហាជាគ្រាដំបូងក្នុងជីវិតរបស់ខ្ញុំ ហើយអ្នកនាង ក៏ជាស្ត្រីទីមួយដែលខ្ញុំស្រឡាញ់ដែរ ...

— លោក ក៏ជាបុរសទីមួយក្នុងសេចក្តីស្នេហារបស់ខ្ញុំដែរ ។

ម៉ោង ១៩ ហើយ យើងក៏នាំគ្នាឡើងជិះរថយន្តបន្តទៅដល់ផ្សារដែប ។ យើងបាននាំគ្នាទៅទទួលទានអាហារ និងសំណាក់នៅសណ្ឋាគារដាហៀរ ។

ពេលវេលាបះតែកន្លងផុតទៅជានិច្ច ។ សភាពស្ងប់ស្ងាត់នៃរាត្រីកាល ក្រៅពីសំឡេងខ្យល់បោកបក់មកប៉ះនឹងស្លឹកឈើ និងសំឡេងនៃរលកទឹក ដែលបោកមកប៉ះនឹងច្រាំងនោះ បានធ្វើឲ្យខ្ញុំគិតថា ក្នុងលោកនេះដូចជាគ្មានអ្នកណាក្រៅពីរូបខ្ញុំនិងនាង យ៉ូវ៉េត ឡើយ ។ នេះក៏ជាការល្អណាស់ហើយ ព្រោះខ្ញុំគ្មានត្រូវការអ្វីទៀតសោះ សូម្បីរូបខ្ញុំនៅកំឡោះ ហើយមានអនាគតវែងឆ្ងាយ ក៏មើលទៅដូចជាថាខ្ញុំគ្មានប្រាថ្នាអ្វីក្រៅពីការមានជីវិតរស់នៅជាមួយនាង យ៉ូវ៉េត

ខ្ញុំឱបរឹតកងកាយរបស់នាង យូរ៉េត ផ្ទប់នឹងដើមទ្រូងរបស់ខ្ញុំ ។ ការញាប់ញ័រនៃកងកាយរបស់នាង បានប្រាកដឡើងដូចពេលដែលខ្ញុំបានថើបដៃនាងនៅពេលមុននោះដែរ ។ ព្រះពាយបោកបក់រំភើយ ៗ លាយដោយធាតុត្រជាក់មកប៉ះនឹងកងកាយរបស់យើង ដែលមើលទៅហាក់ដូចជាជួយសម្រើបចិត្តខ្ញុំ និងនាង យូរ៉េត ឲ្យរឹងរឹតតែខ្លាំងឡើងទៀត ។ រស្មីព្រះចន្ទ បានសាចជះតាមបង្អួចមកត្រូវវង់ភក្ត្ររបស់នាង យូរ៉េត មើលទៅឃើញនូវលំអរបស់នាង ពិបាករកគូប្រៀបផ្ទឹមបាន ។

ពេលនោះ ដូចជាពិបាកអធិប្បាយដល់សភាពនៃទឹកចិត្តរបស់ខ្ញុំ ព្រោះខ្ញុំដូចជាលែងគិតអ្វីទាំងអស់ សូម្បីអនាគតយ៉ាងណា ក៏ឥតគអង្គឹមាន ។ យើងនឹងត្រូវជួបប្រទះនឹងជោគជ័យ ឬ ឧបសគ្គយ៉ាងណានោះ ខ្ញុំក៏ពុំដឹង ? ខ្ញុំដឹងតែម្យ៉ាង គឺខ្ញុំប៉ងបាននាង យូរ៉េត យកមកធ្វើជាគូប្រចាំជីវិតរបស់ខ្ញុំ



នោះដែរ ។

- អ្នកនាង ! អ្នកនាងជឿឬទេ ?

- ខ្ញុំជឿ ! (នាង យូរ៉េត ឆ្លើយកាត់ឡើង ក្នុងខណៈដែលខ្ញុំនិយាយពុំទាន់ផុតពាក្យ) បើលោកនិយាយយ៉ាងណា ខ្ញុំជឿទាំងអស់ ។

- ខ្ញុំនឹកដល់អ្នកនាងគ្រប់ ៗ វិនាទី !

- ចាស ! ខ្ញុំជឿ ។

- ម៉េចក៏អ្នកនាងជឿ ?

- ព្រោះ ... ខ្ញុំគេអធិប្បាយដកបពុំបាន ...

- បើអញ្ចឹង ប្រែថា អ្នកនាងក៏នឹកខ្ញុំដែរមែនទេ ?

- ខ្ញុំពុំអាចបដិសេធបានទេ ព្រោះលោកជាសុភាពបុរសមានគុណសម្បត្តិល្អ ល្មមធ្វើឲ្យខ្ញុំនិយាយពាក្យពិតដំកបលោក — ខ្ញុំនឹកដល់លោក ... នឹកពាល់តែពិបាកនឹងនិយាយ ។

តែប៉ុណ្ណោះ ។

យប់កាន់តែជ្រៅណាស់ហើយ ។ យើងបានលាគ្នាចូលដំណេករៀងខ្លួន ។ នៅពេលមុនលក់ ខ្ញុំចេះតែគិតបន់ស្រន់ការនា សុំឲ្យខ្ញុំស្រមៃ ឬ យល់សប្ដិឃើញនាង យូវ៉េត ហើយសុំឲ្យនាងស្រមៃ ឬ យល់សប្ដិឃើញខ្ញុំវិញដែរ ក្នុងសភាពតែកាយ ដូចទើបកន្លងទៅអម្បាញ់មិញនេះ ។

ខ្ញុំបានភ្ញាក់ដឹងខ្លួនឡើងនៅពេលអរុណរះ ។ តែខ្ញុំឃើញនាង យូវ៉េត ក្រោកមុនខ្ញុំ ។

- លោក! លោកប្រហែលជាគេងលក់ស្រួលណាស់មើលទៅ?

- ខ្ញុំស្រមៃឃើញអ្នកនាងជានិច្ច ។

នាងយូវ៉េតពុំឆ្លើយថាអ្វី ។ នាងសំឡឹងមើលមុខខ្ញុំ ដោយក្រសែភ្នែកដ៏មុត ចាក់ជ្រែកចូលទៅក្នុងបេះដូងរបស់ខ្ញុំ, ក្រសែភ្នែក ដែលសំដែងចេញមកនូវសេចក្ដីស្នេហាស្មោះស្ម័គ្រ ។



ខ្ញុំអត់សង្កត់ចិត្តពុំប្រព្រឹត្តហួសលើសលស់លើរូបនាង យូវ៉េត ។ ឯនាងវិញ គឺពុំបានសំដែងអាការៈឲ្យខ្ញុំឃើញថា ប្រសិនបើខ្ញុំប្រព្រឹត្តហួសលើសលស់លើរូបនាងនោះ នាងនឹងមិនយកចិត្តទុកដាក់អ្វីឡើយ ។

- យូវ៉េត! បង... (ខ្ញុំចាប់ផ្ដើមនិយាយឡើងទៀតដោយហៅឈ្មោះនាងចំៗថាបង ព្រោះតាំងពីដើមមក ខ្ញុំពុំដែលហ៊ានហៅឈ្មោះនាងចំៗថាបងដូច្នេះសោះ) បងបានពិចារណារួចអស់ហើយថា ខ្លួនបងត្រូវតែតស៊ូសំរាប់សាងអនាគត — បងសំឡឹងមើលទៅឃើញនូវភារៈដ៏ធ្ងន់ធ្ងរនៅខាងមុខបង តែបងយល់ថា បងអាចទទួលធ្វើបាន ប្រសិនបើមានគូជីវិតដ៏ល្អ ហើយគូជីវិតនោះ បងពុំអាចរកអ្នកណាឲ្យបានល្អដូច យូវ៉េត បានដែរ ... ។

- ចុះបងបានគេងអស់ហើយ ឬ? (នាង យូវ៉េត ក៏ចាប់ផ្ដើមហៅខ្ញុំថាបងវិញដែរ)

— ទៅ! បងនៅពុំទាន់បានរកនៅឡើយទេ ។

ចុះបងនឹងដឹងយ៉ាងម៉េចបានថា បងនឹងរកស្រីល្អជាងអូនពុំបាន?

— ទឹកចិត្តបងបានប្រាប់បងថា បងពុំអាចរកគូជីវិតដែលល្អដូចអូន យូរ៉េត បានទេ បងត្រូវលើកដំកើងអូនទុកជាដួងកែវជីវិតរបស់បង — បងសុំប្រគល់ជីវិតរបស់បងឲ្យ យូរ៉េត តាំងស្រុង ។ —

នាង យូរ៉េត លែងនិយាយអ្វីតទៅទៀត ។ នាងសំឡឹងមើលមុខខ្ញុំ ដោយនេត្រាដែលមានទឹកដក់ជាប់នៅក្នុងក្រពក ។ ប៉ុន្តែទឹកភ្នែកនេះ មានន័យដូចម្តេច ក៏ពិបាកនឹងដឹងបានដែរ ព្រោះទឹកភ្នែកនៃស្ត្រីភេទ អាចប្រែសេចក្តីបានច្រើនយ៉ាង ព្រោះថាស្ត្រីភេទជាឆ្មាំទ្វារនៃអាណាចក្រអាថ៌កំបាំង សូម្បីខ្លួននាងដែលជាឆ្មាំទ្វារស្រាប់ ក៏ពុំអាចដឹងដែរថានៅក្នុងអាណាចក្រនោះមានអ្វីខ្លះផង? អ្នកណាជាម្ចាស់នៃអាណាចក្រនោះ?

វគ្គទី៩

# រំលែកគ្នាគ្រាលំបាក

ខ្ញុំបាននាំនាង យូរ៉េត ត្រឡប់មកភ្នំពេញវិញនៅវេលាម៉ោង ៩ កន្លះនៃថ្ងៃអាទិត្យ ។

ខ្ញុំបានយកនាងទៅផ្ញើនឹងមីងម្នាក់ ដែលខ្ញុំធ្លាប់ស្គាល់នៅស្ទឹងមានជ័យ ។ ខ្ញុំតែងតែទៅមើលសុខទុក្ខនាងរាល់ពេលល្ងាច ក្រោយពេលចេញពីធ្វើការ ។

យប់មួយ ខ្ញុំបាននិយាយប្រាប់នាង យូរ៉េត ពីគោលបំណងរបស់ខ្ញុំដែលចង់ស៊ើបសួររកការពិតពីរឿងឃាតកម្មដែលគេសន្និដ្ឋានថា ខ្មោចនោះ ជាខ្មោចនាង យូរ៉េត ។ ខ្ញុំចង់ដឹងថាខ្មោចនោះជាខ្មោចអ្នកណា? ជាខ្មោចដែលសម្លាប់ខ្លួនឯងមែន ឬក៏មានគេសម្លាប់? ប៉ុន្តែនាង យូរ៉េត នេះតែងហាមឃាត់ខ្ញុំ ពុំចង់ឲ្យខ្ញុំរើរំលឹងរឿងនោះ ៕

យូរ៉េត អូន ! (ខ្ញុំសួរ) ម៉េចក៏អូនហាមបងពុំឲ្យស៊ើបសួររកការពិតអញ្ចឹង ?

ព្រោះអូនគិតថា ក្រែងលោមានគ្រោះថ្នាក់ដល់បង ព្រោះគេជាអ្នកមានអំណាច មានឥទ្ធិពល ...

— ទេ ! បងដូចជាពុំឃើញថា មានគ្រោះថ្នាក់អីទេ— ថ្វីបើគេមានអំណាច គេអាចសម្លាប់រូបបងលេងៗ បាន ឬ ? ស្រុកនេះ ជាស្រុកមានច្បាប់ទម្លាប់ យើងពុំគួរជាខ្លាចអញ្ចឹងសោះ ។

ណ្ហើយ ខាតពេលឥតប្រយោជន៍ទេ — រឿងរបស់គេស្រេចនឹងគេទៅចុះ — សុំបងបណ្ដោយទុកឲ្យវាងងឹតងងល់អញ្ចឹងទៅចុះ — បងមើលមេឃ ផ្ទៃមេឃទាំងមូលជាផ្ទៃមេឃងងឹត — ងងឹតដូចជារឿងរ៉ាវក្នុងជីវិតនៃមនុស្សដែរ ..

ពិតដូចពាក្យដែលនាង យូរ៉េត និយាយមែន ។ ពេលនោះយើងឋិតនៅក្នុងសភាពងងឹត ។ នាង យូរ៉េត ប្រុង



ប្រៀបរៀបចំអុជភ្លើងនៅពេលដែលខ្ញុំទៅដល់ តែខ្ញុំបានហាមកុំឲ្យអុជ ព្រោះពុំមែនជាការចាំបាច់ ។ ខ្ញុំគិតថា គ្រាខ្លះឱកាសខ្លះ និងក្នុងស្ថានការណ៍ខ្លះ សភាពងងឹតបានផ្ដល់នូវការរីករាយដល់យើង ជាជាងសភាពភ្លឺ ។

ផ្ទះរបស់មីងនេះ មានយ៉ាងនឹមុខបន្តិច ។ យ៉ាងនេះ ជាវិមានសួគ៌របស់យើង ។ ជើងម៉ាលើយនៃផ្ទះនោះ បានផ្ដល់នូវសេចក្ដីសុខឲ្យយើង ពិបាកនឹងបំភ្លេចពេលបានក្នុងជីវិតនេះ ព្រោះមាននាង យូរ៉េត នៅជិតខ្ញុំ ។

ខ្ញុំធ្លាក់ខ្លួនចុះក្នុងអន្លង់ស្នេហ៍របស់នាងយ៉ាងពិតប្រាកដ តែខ្ញុំយល់ថា ការនេះ ពុំមែនមកពីសភាពនៃទឹកចិត្តមិនរឹងប៉ឹងរបស់ខ្ញុំ ឬក៏នាង យូរ៉េត មានស្នេហ៍ ឬមានអំណាចអាចស្រូបទាញទឹកចិត្តបុរសឲ្យវង្វេងនោះឡើយ ។ យើងនាំគ្នាអង្គុយសំឡឹងមើលមេឃ ។ យើងពិតតែឃើញច្បាស់តាមពាក្យដែលគេតែងនិយាយថា ផ្ទៃមេឃពិតតែងងឹត ផ្កាយពិត

តែក្ដីទៀនមែន ។ កាលបើឃើញសភាពដូច្នេះ ខ្ញុំគិតថា យើងនឹងនឹងដល់មិត្តល្អ ឬ មិត្តអាក្រក់នោះ ក្នុងខណៈដែលយើងធ្លាក់ខ្លួនទៅក្នុងសេចក្ដីទុក្ខលំបាក ដែលទុកដូចជាសភាពងងឹតនេះ ។ ក្នុងសម័យរុងរឿងដែលទុកដូចជាពេលក្ដី យើងក៏ពុំអាចដឹងថា មិត្តណាល្អ មិត្តណាអាក្រក់ ។

យើងនាំគ្នាអង្គុយសំឡឹងហ្វូងតារាលើផ្ទៃមេឃ ហើយយើងសួរគ្នាលេងថា ផ្កាយណាជាផ្កាយប្រចាំជីវិតរបស់អ្នកណា ? នាង យូរ៉េត ចូលចិត្តតែរើសយកផ្កាយណាដែលធំ ៗ ហើយក៏ថាថាជាផ្កាយប្រចាំជីវិតរបស់ខ្ញុំ ហើយនាងរើសយកផ្កាយណាដែលតូច ៗ មានពន្លឺស្រអាប់ ៗ ថាជាផ្កាយប្រចាំជីវិតរបស់នាង តែផ្កាយដែលនាងរើសយកថាជាផ្កាយប្រចាំជីវិតរបស់នាងនោះ នាងក៏រើសយកតែផ្កាយតូច ៗ ណាដែលឋិតនៅជិតផ្កាយធំ ៗ ដែលនាងប្រាប់ថា ជាផ្កាយប្រចាំជីវិតរបស់ខ្ញុំ ។ យើងភ្ជាប់ធ្វើសច្ចាប្រណិធានចំពោះ



មុខផ្កាយតារាទាំងនោះ ដោយសុំឲ្យផ្កាយតារាទាំងនោះ ជួយធ្វើជាសាក្សីទិព្វរបស់យើងថា យើងនឹងស្មោះត្រង់រកគ្នា ដោយមិនបោះបង់គ្នាពេលអស់មួយជីវិត ។

ខ្ញុំហ៊ានស្បថចំពោះវត្ថុស័ក្តិសិទ្ធិថា ខ្ញុំពុំដែលប្រព្រឹត្តល្មើសលើសលស់លើរូបនាង យូរ៉េត ក្រៅពីការឱបថើបឡើយ ។ ខ្ញុំលើកនាងទុកដូចជាទេពអប្សរនៃការស្អាតល្អបរិសុទ្ធ ។ ខ្ញុំនឹងខំព្យាយាមរក្សាទុកនូវគុណសម្បត្តិទាំងនោះឲ្យបានយឺនយូរជាទីបំផុត ដែលខ្ញុំអាចរក្សាទុកបាន ។ នាង យូរ៉េត បានទុកចិត្តខ្ញុំ ។ ប្រសិនបើខ្ញុំប្រព្រឹត្តលើសលស់លើនាងជាងនោះទៅទៀត ខ្ញុំជឿជាក់ថា នាងមុខជាបណ្ដោយតាមចិត្តខ្ញុំទាំងអស់ តែខ្ញុំស្រឡាញ់នាង ស្រឡាញ់ដោយទឹកចិត្តដ៏បរិសុទ្ធ ។ សេចក្ដីស្នេហាដ៏បរិសុទ្ធនេះ បានហាមប្រាមនូវគំនិតអាក្រក់របស់ខ្ញុំ ខ្ញុំចង់ឃើញនាង យូរ៉េត ឋិតនៅបរិសុទ្ធស្អាត ដូចបុប្ផាដែលរីកឡើងជាប់នៅនឹងសណ្ដាន់ ឲ្យ

បានយើនយូជាទីបំផុត ដែលក៏អាចបិតនៅបាន ។ ខ្ញុំអាចសរសើរខ្លួនឯងបានថា ខ្ញុំអាចរក្សានូវការបរិសុទ្ធរបស់ស្ត្រីភេទទុកបាន សូម្បីនៅជាមួយគ្នាតែពីរនាក់អស់ពេលដ៏យូរក៏ដោយ ។

យប់មួយ នាង យូរ៉េត បានថ្លែងនូវការព្រួយបារម្ភប្រាប់ខ្ញុំថា នាងបានសង្កេតឃើញបុរសចំឡែកពីរនាក់ចេះតែនាំគ្នាដើរចុះឡើងកាត់មុខផ្ទះនេះ ហើយចេះតែងាកមើលមកក្នុងផ្ទះដោយការសង្កេតពិនិត្យ ។ នាងគិតថា ក្រែងបុរសចំឡែកទាំងពីរនាក់នោះ ជាដៃជើងរបស់លោកអនុសេនីយទោ ស៊ី ។

ការនេះ បានធ្វើឲ្យខ្ញុំព្រួយបារម្ភដែរ ព្រោះក្រែងមានរឿងមិនល្អកើតឡើង ។ នាង យូរ៉េត បានបញ្ចេញយោបល់ថា ប្រសិនបើរឿងនេះ បានលេចឮដល់អនុសេនីយទោ ស៊ី ពិតមែន គួរតែផ្លាស់ទីកន្លែងយ៉ាងឆាប់ជាទីបំផុត ដើម្បីកុំឲ្យមានការអ៊ឺកើតឡើងបាន ។



ការធុញធុរក្នុងចិត្តបានកើតឡើងដល់ខ្ញុំហើយ ព្រោះម្យ៉ាងក្រែងលោកសក្តិពីរ ស៊ី ដឹងថាខ្ញុំនាំនាង យូរ៉េត យកមកលាក់ទុកនៅកន្លែងនេះ ហើយម្យ៉ាងទៀត រឿងឪពុកម្តាយរបស់ខ្ញុំ ដែលចេះតែបង្ខំខ្ញុំឲ្យរៀបការជាមួយនឹងនារីម្នាក់ដែលខ្ញុំពុំពេញចិត្ត ។ រឿងនេះខ្ញុំបានសារភាពអង្វរករលោកពីរបីដងហើយថា ខ្ញុំពុំអាចរៀបការបានឡើយ ព្រោះខ្ញុំបានជាស្រឡាញ់នាង យូរ៉េត ជ្រុលទៅហើយ ប៉ុន្តែលោកពុំព្រមតាមតែសោះ ។ រហូតដល់ទីបំផុត លោកបាននិយាយយ៉ាងដាច់អហង្ការថា លោកនឹងពុំព្រមឲ្យខ្ញុំយកនាង យូរ៉េត ធ្វើជាប្រពន្ធជាដាច់ខាត ។ ប្រសិនបើខ្ញុំពុំប្រតិបត្តិតាមលោកទេនោះ លោកនឹងកាត់កាល់ខ្ញុំចោល ។

ខ្ញុំចង់ប្រាប់នាង យូរ៉េត ពីរឿងនេះពីរបីដងមកហើយ តែខ្ញុំពុំហ៊ានប្រាប់ ព្រោះគិតថា ប្រសិនបើខ្ញុំប្រាប់នាងទៅ នាងមុខជាខូចចិត្តខូចថ្លើមជាពុំខាន ។

ខ្ញុំដកដង្ហើមធំ ព្រោះការពិបាកចិត្ត ។ ក្នុងខណៈនេះ ខ្ញុំហាក់ដូចជាមានកម្មកសង្កត់នៅលើដើមទ្រូងពីរត្រួត ។ មួយត្រួតគឺនារីជាទីស្នេហា មួយត្រួតទៀតគឺសត្រូវ ហើយមួយត្រួតទៀតគឺឪពុកម្ដាយ

សំរាប់រឿងអ្វីផ្សេង ពុំជាការអ្វីឡើយ ។ ប៉ុន្តែរឿងឪពុកម្ដាយនិងនារីជាទីស្នេហានោះ ជាបញ្ហាដែលខ្ញុំពិបាកនឹងដោះស្រាយបាន ព្រោះតាំងពីដើមរៀងមក ខ្ញុំបានតាំងខ្លួនជាកូនដ៏ល្អ ជាកូនដែលឋិតនៅក្នុងឱវាទរបស់ឪពុកម្ដាយជានិច្ច ។ ក្នុងវ័យសិក្សារៀនសូត្រ ខ្ញុំតែងប្រព្រឹត្តខ្លួនបានល្អជាប ។ រឿងស្នេហាពុំដែលមានក្នុងជីវភាពសិក្សារបស់ខ្ញុំឡើយ ។ មើលទៅប្រហែលជាដោយសារហេតុយ៉ាងនោះក៏ពុំដឹង បានជាឪពុកម្ដាយរបស់ខ្ញុំបានសម្រេចចិត្តរើសរកប្រពន្ធឲ្យខ្ញុំដោយមិនបាច់សាកសួរដល់ការពេញចិត្តរបស់ខ្ញុំផងនោះ ។

ខ្ញុំនឹងធ្វើដូចម្ដេច កាលបើខ្ញុំបានជាស្រឡាញ់នាង



យូរ៉ែត ជ្រុលហួសទៅហើយ ។ សេចក្ដីស្រឡាញ់នោះ ក៏បានរីកខ្លួនឡើងធំណាស់ទៅហើយ? បញ្ហានេះ ធំជាងបញ្ហាអ្វីផ្សេងទាំងអស់ ដែលខ្ញុំធ្លាប់បានជួបប្រទះមកក្នុងជីវិត ។ ខ្ញុំអាចលះបង់អ្វីផ្សេងបានទាំងអស់ ដើម្បីនាង យូរ៉ែត តែខ្ញុំពុំអាចលះបង់អ្នកមានគុណទោល ដើម្បីនាង យូរ៉ែត បានឡើយ ។

ប៉ុន្តែថ្វីបើមានការពិបាកចិត្តច្រើនបែបយ៉ាងនេះក៏ដោយ ខ្ញុំគិតថា ពេលនេះ ត្រូវតែដោះស្រាយរឿងផ្ទាល់ចិត្តខ្លួនជាមុនសិន ដោយទុកបញ្ហាផ្សេងដោះស្រាយជាក្រោយ ។ ខ្ញុំបានសម្រេចចិត្តថា នឹងនាំនាង យូរ៉ែត ឲ្យទៅនៅជាមួយនឹងមីងថែម ឯភូមិពោធិព្រហ្មស្រី ឃុំចំការសំរោង (បាត់ដំបង) ព្រោះខ្ញុំគិតថា ទីនោះឆ្ងាយពីក្រុងពុំងាយនឹងអ្នកណាតាមរកឃើញ ។

— ការនេះ មិនធ្វើឲ្យបងពិបាកណាស់ទៅហើយ ?

(នាង យូរ៉ែត សួរខ្ញុំ) ព្រោះបងជាប់ធ្វើការផង ។

– មិនអីទេ ចាំបងចាត់ការរកស្ត្រីម្នាក់ ដែលបងទុកចិត្ត ឲ្យជូនអូនទៅ ។

– ប្រែសេចក្ដីថា យើងពុំងាយបានជួបគ្នាទៀតទេ ។

– ពុំមែនអញ្ចឹងទេ បងពឹងឲ្យគេជូនអូនទៅមុន ហើយ បើយូរណាស់ដប់ថ្ងៃទៀត បងនឹងលៃលករកពេលទៅតាម អូនហើយ ។

– អញ្ចឹងបងក៏នៅតែពិបាកដែរ ព្រោះខាតពេលទៅតាមអូន ។

– មិនជាការអីទេសំរាប់រូបបង ព្រោះដូចបងធ្លាប់បាន និយាយប្រាប់អូនហើយថា បងអាចលះបង់ពេលវេលា ដើម្បី យូរ៉ែត បាន ។

យើងបានកំណត់ពេលថា ត្រូវរៀបចំចាត់ចែងឲ្យ យូរ៉ែត ធ្វើដំណើរទៅស្រុកពោធិញ៉ស្រ័ (បាត់ដំបង) នៅ ព្រឹកស្អែក តាមអយស្ម័យរថ ជាមួយនឹងនាងសាមុន ជាកូន



មីងថែម ដែលខ្ញុំបានពឹងពាក់ឲ្យជូនទៅ ។ ខ្ញុំបានលានាង ត្រឡប់ទៅផ្ទះវិញ ដើម្បីចាត់ការក្នុងរឿងនេះ ។

ខណៈនោះ នាងយូរ៉ែតឱបខ្ញុំ ។ នេះជាគ្រាដំបូង ដែលនាងឱបហើយថើបខ្ញុំ ព្រមទាំងខ្សឹបដាក់ត្រចៀកខ្ញុំថា :

– អូននឹងមិនភ្លេចគុណបងអស់មួយជីវិត ។

ខ្ញុំពុំដឹងជាឆ្លើយថាដូចម្ដេច ។ យើងនាំគ្នាឈរនៅ ស្ងៀមមួយសន្ទុះ បណ្ដោយពេលវេលាឲ្យកន្លងផុតទៅ ក្នុង ការឱបថើប ដោយមិនបាច់និយាយស្ដីអ្វីឡើយ ។

– បង ! (នាងយូរ៉ែតនិយាយថែមទៀត) សុំបង កុំបោះបង់ចោល យូរ៉ែត ណា៎បងណា៎ ! . . .

ខ្ញុំបានទទួលនូវពាក្យសន្យា ហើយខ្ញុំក៏ដើរមក ដោយ មនោសញ្ចេតនាដែលពិបាកនឹងអធិប្បាយ ។ ខ្ញុំចុះចេញពីផ្ទះ នោះមកទាំងការពិបាកចិត្តនិងសប្បាយចិត្ត ។ ការដែលធ្វើ ឲ្យខ្ញុំពិបាកចិត្តនោះ គឺការដែលខ្ញុំនឹកទៅដល់រឿងដែលឪពុក

ម្ដាយខ្ញុំបានបង្ខំខ្ញុំ ឲ្យរៀបការប្រពន្ធ ឯការដែលធ្វើឲ្យខ្ញុំសប្បាយចិត្តនោះ គឺការដែលខ្ញុំនឹកពេញចិត្តក្នុងការសម្រេចរបស់ខ្ញុំ ... ខ្ញុំនឹកសប្បាយរីករាយតែក្នុងចិត្តថា រឿងល្ខោនជីវិតរបស់ខ្ញុំហៀបនឹងបានសម្រេចទីអវសានហើយ ។

នៅវេលាម៉ោង ៨ កន្លះព្រឹក ខ្ញុំក៏បាននាំនាងសាមុនទៅទទួលនាង យូរ៉េត ឯស្ទឹងមានជ័យយកទៅដាក់នៅស្ថានីយអយស្ម័យយានដោយរថយន្ត ។ ខ្ញុំបាននិយាយណែនាំអ្នកទាំងពីរឲ្យស្គាល់គ្នា ហើយបានបញ្ជាក់ប្រាប់នាង យូរ៉េត ថា នាងសាមុននេះឯងហើយ ដែលត្រូវជូនទៅនៅឯផ្ទះនាងនៅភូមិពោធិហ្ស្រី ។

យើងបានបែកគ្នាទាំងក្រៀមក្រំទាំងក្ដីអាល័យ ។

× × ×

វគ្គទី ៦

# លាហើយស្នេហា

មួយសប្ដាហ៍ក្រោយមក ខ្ញុំក៏បានធ្វើដំណើរទៅតាមនាង យូរ៉េត ឯស្រុកពោធិហ្ស្រី ជាមួយនឹង សុខ-សម្បូរ ជាមិត្តចិត្តមួយរបស់ខ្ញុំ ។

នៅពោធិហ្ស្រី គ្មានហេតុការណ៍អ្វីទំនងពោលក្រៅពីការសប្បាយរីករាយ ដែលខ្ញុំបានជួបនាង យូរ៉េត ឡើយ ។

ទេសភាពនៃវាលស្រែដ៏ធំល្វឹងល្វើយ បានធ្វើឲ្យខ្ញុំចាំពុំភ្លេច ... យើងតែងនាំគ្នាដើរលេងនៅពេលល្ងាច ដើម្បីស្រូបយកអាកាសត្រជាក់ដ៏ល្អបរិសុទ្ធនៅវាលស្រែ ...

នៅថ្ងៃទី ៣ ថ្ងៃដែលខ្ញុំគិតថា ជាថ្ងៃត្រេកសំរាប់រូបខ្ញុំ ខ្ញុំនឹកដល់រឿងឪពុកម្ដាយរបស់ខ្ញុំ ដែលបង្ខំខ្ញុំឲ្យរៀបមង្គលការ ... នឹកដល់រឿងនេះកាលណា ខ្ញុំព្រួយចិត្តពេលនោះ ព្រោះខ្ញុំដោះស្រាយបញ្ហានោះពុំរួច ... ខ្ញុំបាននិយាយរឿង

នេះប្រាប់ សុខ សម្បូរ ដោយល្អិតល្អន់... ទីបំផុត គេក៏បានសួរមកខ្ញុំវិញថា :

– បើអញ្ចឹងឯងគិតយ៉ាងម៉េច ?

– ទេ ! គ្នាពុំដឹងគិតយ៉ាងម៉េចទេ ! គ្នាសុំឲ្យឯងជួយគិតផងទៅចុះ ។

– ឯងនឹងឲ្យគ្នាធ្វើយ៉ាងម៉េចបាន ព្រោះរឿងនេះពុំមែនជារឿងរបស់គ្នា ។

– ចុះបើឧបមាថា រឿងនេះជារឿងរបស់ឯងវិញ ? ឯងនឹងសម្រេចយ៉ាងណា ?

– ចុះខាងណាល្អជាង !

– ចាញ់ ឃ្យូរ៉េត ឆ្ងាយណាស់ ។

– ចុះនិស្ស័យចិត្តថ្លើម ខាងណាស្រួលជាង ?

– រឿងនេះគ្នាពុំដឹងទេ ព្រោះគ្នាពុំដែលបានស្គាល់គំនិតជិតស្និតស្នាលនឹងខាងខាងណោះ – តែសំរាប់ខាង ឃ្យូរ៉េត



វិញនោះ គ្នាពេញចិត្តគ្រប់យ៉ាង – គ្នាពុំជឿថានឹងរកគូដៃឯណាឲ្យវិសេសវិសាលជាង ឃ្យូរ៉េត បានឡើយ ។

– នេះ ជាបញ្ហានៃការជ្រើសរើស ស្រេចហើយតែឯងជ្រើសរើសយកខាងណាដែលឯងយល់ថាគួរទៅចុះ ។

– បើជ្រើសរើសស្ត្រី ឬ ជ្រើសរើសប្រពន្ធនោះ វាងាយតែបានទេ តែបើជ្រើសរើសឪពុកម្ដាយ និង ប្រពន្ធនោះ មិនងាយឡើយ មិនថាអញ្ចឹង ?

– ចុះបើឯងជំរាបលោកតាមត្រង់ ហើយសុំអង្វរលោកទៅមិនបានឬ ?

– គ្នាបានប្រើវិធីនេះរួចហើយ តែលោកពុំព្រមដាច់ខាត ។

– បើឯងជំរាបលោកតាមត្រង់ ហើយបណ្ដោយឲ្យលោកខឹងបន្តិចទៅ ក៏អស់រឿងទៅហើយ ។

– សំរាប់អ្នកដទៃឃើញថាធ្វើបាន តែសំរាប់ឪពុក

ម្តាយគ្នា មើលទៅដូចជាធ្វើពុំបានទេ ហើយចំពោះឪពុកគ្នា មើលទៅពុំសូវជាអីទេ យោគយល់ចិត្តថ្នមគ្នាខ្លះៗដែរ តែចំពោះម្តាយរបស់គ្នាវិញ ពុំបានជាជាប់ខាត ។

— ចុះបើអញ្ចឹង តើឯងគិតធ្វើយ៉ាងម៉េច ?

— ពុំដឹងទេ ។

— ចុះបើអញ្ចឹង គួរប្រាប់រឿងនេះឲ្យនាង យូរ៉ែត បានដឹងផងដែរ ឬទេ ?

— គឺគួរតែប្រាប់ឲ្យគ្នាដឹងដែរ ?

— ចុះគួរនឹងប្រាប់ដោយវិធីណា ?

— ហ្នឹងគ្នាក៏ពុំដឹងទៀត ។

— ប្រែសេចក្តីថា ឯងពុំដឹងស្តីទាំងអស់មែន ឬទេ ?

— ព្រោះបញ្ហានេះធំហើយពិបាកដោះស្រាយជាងបញ្ហាអ្វីទាំងអស់ — គ្នាអាចលះបង់ស្ទើរគ្រប់យ៉ាង ដើម្បី យូរ៉ែត បានទាំងអស់ តែគ្នាពុំអាចលះបង់ឪពុកម្តាយចោល ដើម្បី យូរ៉ែត ឡើយ ។



— បើអញ្ចឹង ឯងជាប់ចិត្តតាមឪពុកម្តាយឯង ?

— ត្រង់ហ្នឹងក៏គ្នាពុំដឹងដែរ ។

— ចុះបើឯងពុំដឹងអីទាំងអស់អញ្ចឹង ឲ្យគ្នាធ្វើម៉េច ?

— ឯងជួយគ្នាបន្តិចបាន ឬទេ ?

— ឯងចង់ឲ្យគ្នាធ្វើអី គ្នានឹងធ្វើទាំងអស់ ។

— គ្នាសុំពឹងឯងឲ្យនិយាយរឿងនេះប្រាប់ដល់នាង យូរ៉ែត ។

— ចុះម៉េចក៏ឯងពុំប្រាប់ខ្លួនឯង ?

— គ្នាដូចជាគេហាមាត់ពុំរួច ។

— គ្នាពុំដែលនឹកថា ឯងខ្លាចដល់ម្ល៉ឹងសោះ ។

— គ្នាពុំដែលខ្លាចអីអញ្ចឹងមែន តែពេលនេះ គ្នាបានក្លាយខ្លួនទៅជាមនុស្សកំខ្លាចកំសាកញីទៅហើយ ។

សុខ-សម្បូរ បានទទួលនាទី ជាអ្នកនាំរឿងនេះទៅប្រាប់នាង យូរ៉ែត ។ ខ្ញុំសង្កេតឃើញថា គេត្រូវប្រើ

ពេលវេលាគិតច្រើនណាស់ដែរថាខឹងទៅប្រាប់នាងដូចម្ដេច ? ប្រហែលជានឹងមួយម៉ឺន បានគេដាច់ចិត្តទៅប្រាប់ ។

គេបានត្រឡប់មកប្រាប់ខ្ញុំវិញថា នាង យូរ៉េត បានដេញដោលសាកសួរគេជាច្រើន ។ ទីបំផុត នាងកាត់ចិត្តថា ខ្ញុំត្រូវតែចូលខ្លួនទៅរៀបមង្គលការតាមបំណងរបស់ឪពុកម្ដាយ តែនាងត្រូវការជួបនឹងខ្ញុំ ដើម្បីពិភាក្សាគ្នាក្នុងរឿងនេះ នៅពេលឥឡូវនេះឯង ។

ខ្ញុំទទួលខ្លួនថា ក្នុងការចូលទៅជួបនឹងនាង យូរ៉េត ក្នុងគ្រានេះ ខ្ញុំខ្លាចជាងការចូលទៅក្រាបបង្គំគាល់ម្ចាស់ផែនដី ឬខ្លាចជាងការចូលទៅជួបមុខសត្រូវ ដែលត្រូវតែស៊ូប្ដូរជីវិតគ្នាទៅទៀត ។ ខ្ញុំភ្ញាក់ថ្ងើមក្ដុក ក្នុងខណៈឃើញនាង យូរ៉េត ។ ខ្ញុំរកនិយាយស្ដីអ្វីពុំរួច ។

— បង ! លោក សម្បូរ បាននិយាយប្រាប់ខ្ញុំពីរឿងបងអស់ហើយ — បងនឹងត្រូវតែបំពេញតាមបំណងលោកអ្នកមានគុណទៅមិនជាអញ្ចឹង ?



ខ្ញុំពុំឆ្លើយថាអ្វី ព្រោះដូចជាណែនបំពង់ករកនិយាយស្ដីថាអ្វីពុំរួច ។

— សុំកុំប្រួអូន (នាងយូរ៉េតនិយាយឡើងទៀត) អូនបានប្ដេជ្ញាចិត្តរួចស្រេចហើយថា អូនស្រឡាញ់តែរូបបងម្នាក់ក្នុងជីវិត — អូនប្រគល់ជីវិតជូនបង — តែបើដូច្នេះ សុំបងបំពេញតាមបំណងរបស់លោកឪពុកអ្នកម្ដាយទៅចុះ — អូនបានប្ដេជ្ញាទៀតថា អូននឹងពុំបូជាជីវិតស្នេហានេះ ឲ្យបុរសដទៃក្រៅពីរូបបងឡើយ ថ្វីបើយើងពុំបានជួបនៅរួមរ័កជាមួយគ្នាក៏ដោយ...

ខ្ញុំពុំអាចនិយាយឆ្លើយឆ្លងនឹងពាក្យសំដីរបស់នាង យូរ៉េត បានឡើយ ។

— ការនេះ ពុំមែនជាកំហុសរបស់ឪពុកម្ដាយទេ (នាង យូរ៉េត និយាយ) ព្រោះឪពុកម្ដាយគ្រប់រូបសុទ្ធតែចង់សាងអនាគតដ៏ល្អប្រសើរ ឲ្យកូនទៅតាមផ្លូវដែលលោកយល់ឃើញថាល្អ — យើងត្រូវតែស្ដាប់ ។

– ចុះ យូរទេ ? (ខ្ញុំសួរ)

– អូនចេះតែនៅត្រាំតាមគម្រូរបស់អូនអញ្ចឹងទៅ អូនឥតត្រូវការរៀបការជាមួយអ្នកណាជាដាច់ខាត អូនបូជាចំពោះតែបងម្នាក់ប៉ុណ្ណោះ ... បងក៏គួរទុកចិត្តចំពោះអូនក្នុងរឿងនេះបានដែរថា អូននឹងពុំប្រគល់ខ្លួនឲ្យបុរសណាដទៃទៀតក្រៅពីរូបបងឡើយ ។

សំដីនេះ ជាសំដីដែលមានឥទ្ធិពលអាចចូលទៅកាត់ទងបេះដូងរបស់ខ្ញុំ ... ខ្ញុំពុំដឹងជានឹងនិយាយជាមួយដូចម្ដេចតទៅទៀត ...

-- ចុះបងកំណត់ពេល ត្រឡប់ទៅភ្នំពេញវិញនៅថ្ងៃណា ?

-- ត្រូវទៅស្អែក ព្រោះសុំច្បាប់បានតែប្រាំថ្ងៃ ។

-- អូនត្រូវជូនបងទៅដល់បាត់ដំបង ។

សភាពរបស់ខ្ញុំក្នុងវេលានេះ ដូចក្មេងដែលឆោត ឬ ល្ងង់



ទៅ គ្មានដឹងការអ្វី ក្រៅពីការចាំស្ដាប់ និងប្រតិបត្តិតាមពាក្យសំដីរបស់ឪពុកម្ដាយ ពាក្យសំដីរបស់មិត្តភក្តិ ពាក្យសំដីរបស់នារីជាទីស្នេហា ហើយលុះត្រឡប់ទៅដល់ភ្នំពេញវិញ ក៏ប្រុងប្រៀបខ្លួនចូលទៅកាន់ពិធីមង្គលការ តាមបំណងដ៏ធំរបស់ឪពុកម្ដាយ ហើយក្រោយពិធីមង្គលការនោះទៅ ខ្ញុំក៏នឹងត្រូវទៅនៅជាមួយនារីម្នាក់ដែលខ្ញុំពុំដែលស្រឡាញ់ ព្រមទាំងត្រូវប្រតិបត្តិតាមពាក្យសំដីរបស់គេទៀត ព្រោះគេនឹងត្រូវជាប្រពន្ធ ។ ក្នុងវេលានេះ ខ្ញុំលែងគិតអ្វីឃើញទាំងអស់ ក្រៅពីការដែលត្រូវនាំខ្លួនចូលទៅក្នុងទ្រុងដែក ក្នុងអនាគតដ៏ឆាប់របស់នារីដែលឪពុកម្ដាយរកឲ្យ ដោយខ្ញុំត្រូវតែជឿតាមថា ជាមនុស្សល្អត្រឹមត្រូវ ព្រោះឪពុកម្ដាយនឹងពុំសាងអនាគតដ៏ខ្មៅងងឹតឲ្យកូនឡើយ ។

មុនពេលធ្វើដំណើរចេញពីស្រុកពោធិហ្ស្រី យើងបានទៅជំរាបលាមីងថែម គាត់បានឲ្យពរសព្ទសាធុការដល់ខ្ញុំ

និងសុខ-សប្បាយ ឲ្យបានប្រកបនូវសេចក្តីសុខសួស្តី ហើយគាត់សង្ឃឹមថា នឹងបានឃើញខ្ញុំ ត្រឡប់ទៅលេងស្រុកពោធិហ្នស្រីនេះទៀតជាពុំខាន ។

ខ្ញុំក៏ឆ្លើយថា ខ្ញុំក៏មានសង្ឃឹមដូច្នោះជានិច្ចដែរ តែតាមពិត ខ្ញុំគ្មានសង្ឃឹមអ្វីបន្តិចបន្តួចសោះ ព្រោះអនាគតដ៏ឆាប់នេះ ខ្ញុំនឹងត្រូវចូលទៅក្នុងទ្រុងដែក ដែលគ្មានសង្ឃឹមថា នឹងមានថ្ងៃណាបានរួចខ្លួនចេញមកនៅខាងក្រៅសោះឡើយ ។

យើងបាននាំគ្នាចេញដំណើរពីភូមិពោធិហ្នស្រីនៅវេលាម៉ោង ៤ រសៀល ។ មីងផែមនាងសាមុន និងនាងយូរ៉េត ក៏បានជូនដំណើរយើងមកដែរ ។ យើងបានដើរតាមផ្លូវលំ ដាត់អូរបត់ខ្វាត់ខ្វែងអស់ពេលពីរម៉ោង ទើបបានមកដល់ផ្សារបាត់ដំបង ដែលយើងប្រមាណមើលទៅថាផ្លូវនេះ មានចម្ងាយប្រហែលជាងប្រាំបីគីឡូម៉ែត្រ ។

នៅបាត់ដំបង យើងបានទៅសំណាក់នៅសណ្ឋាគារ



មួយនៅក្បែរផ្សារ ។

អ្នកទាំងអស់គ្នាដែលមកជាមួយ សុទ្ធតែបានដឹងថា នាង យូរ៉េត និងខ្ញុំជាអ្វីនឹងគ្នា ។ គេបានបណ្តោយពេលទុកឲ្យយើងនៅតែពីរនាក់ ដេកតែពីរនាក់នៅក្នុងបន្ទប់មួយ ។

ខ្ញុំចេះតែទុកនាទីជាទីបវសាននៃសេចក្តីសុខ ដែលចេះតែរិតចូលសង្រួម ៗ មកជានិច្ច ។ ខ្ញុំមានពេលត្រឹមតែមួយយប់ប៉ុណ្ណោះ ខ្ញុំដែលត្រូវបាននៅស្និទ្ធជិតនាង យូរ៉េត ជាទីស្នេហារបស់ខ្ញុំ ។ រាត្រីកាលរបស់យើងបានកន្លងទៅ ជាប់ដោយសេចក្តីសោកសៅ ច្រើនជាងសេចក្តីរីករាយ ។ នាង យូរ៉េត បានខំព្យាយាមរក្សានូវកំឡាំងចិត្តរបស់ខ្ញុំ ដោយពុំនិយាយអ្វីឲ្យខ្ញុំពិបាកចិត្តឡើយ តែពាក្យមួយមាត់ដែលនាងប្រកាន់ខ្ជាប់នោះ គឺនាងនិយាយថា នាងពុំព្រមយកប្តីអស់មួយជីវិត ។ នាងបានប្តេជ្ញាចំពោះវត្ថុសក្តិសិទ្ធិទាំងឡាយថា នាងនឹងរក្សាខ្លួនទុកជាសម្បត្តិរបស់ខ្ញុំ តែម្នាក់ទាំងក្នុងជាតិនេះ

និងជាតិខាងមុខ ។

នាង យូរ៉េត បានជួយបញ្ចូលហេតុផលដល់ខ្ញុំថា ឪពុកម្តាយតែងធ្វើការគ្រប់យ៉ាងជាផ្លូវល្អចំពោះកូន ។ ដូច្នេះ កូនត្រូវតែប្រតិបត្តិតាមឪពុកម្តាយ ។ នាងបានរំឭកដល់សេចក្តីល្អដែលខ្ញុំបានធ្វើចំពោះនាង ហើយដោយសារសេចក្តីល្អនេះ នាងសុខចិត្តលះបង់ជីវិតតាំងមូលដើម្បីប្តូរជាខ្ញុំ ។ ឯរូបនាងវិញនោះ នាងគ្មានបានធ្វើគុណប្រយោជន៍អ្វីដល់ខ្ញុំសោះ ។ ដោយសារការយល់យ៉ាងនេះ ទើបនាងពុំត្រូវការឲ្យខ្ញុំលះបង់អ្វីច្រើនជាងការដែលខ្ញុំបានធ្វើរួចមកហើយនោះឡើយ ។

នាងយូរ៉េតនិយាយច្រើនជាងខ្ញុំ ព្រោះខ្ញុំដូចជាទាល់ប្រាជ្ញរកនិយាយស្តីពុំរួច ។ ការប្រព្រឹត្តទៅនៃជីវិតប្រែប្រួលបានបិទមាត់ខ្ញុំពុំឲ្យនិយាយស្តីអ្វីរួច ។ ឯការដែលនាងជូនដំណើរខ្ញុំមកដល់ពាក់កណ្តាលផ្លូវដូច្នេះ ក៏ដូចជាដាក់ទោសយ៉ាងធ្ងន់មកលើរូបខ្ញុំ ព្រោះវាធ្វើឲ្យទឹកចិត្តរបស់ខ្ញុំសោប់.



សេលវែលវល់យ៉ាងខ្លាំង ។ នាងរឹតតែសាចជះនូវសេចក្តីស្នេហាមកលើរូបខ្ញុំ ខ្ញុំរឹតតែមានចិត្តបង្អៀតបង្អល់ខ្លាំងឡើងៗ នៅពេលជិតបែកគ្នា ។

រាត្រីនេះ ជារាត្រីទីបំផុតនៃសេចក្តីសុខរបស់យើង ព្រោះនាងជូនដំណើរខ្ញុំមកត្រឹមនេះ ហើយព្រឹកឡើងយើងត្រូវបែកគ្នា ដោយខ្ញុំត្រូវធ្វើដំណើរទៅភ្នំពេញ នាង យូរ៉េត ត្រូវធ្វើដំណើរត្រឡប់ទៅស្រុកពោធិហ្នស្រ៊ីវិញ ។

នៅពេលយប់ជ្រៅនាង យូរ៉េត អង្គុយសម្រក់ទឹកភ្នែក ។ ខ្ញុំគិតថា នាង យូរ៉េត ប្រហែលជាលួចសម្រក់ទឹកភ្នែកជាច្រើនមកពីថ្ងៃមុនហើយៗ នាងទំលាក់ពុំឲ្យខ្ញុំឃើញ តែយប់នេះនាងរកលាក់ពុំកើត ។ ទឹកភ្នែករបស់នាងបានធ្វើឲ្យខ្ញុំតឹងចិត្តនិងពិបាកចិត្តយ៉ាងខ្លាំង ។ ខ្ញុំបានឲ្យឈ្មោះរាត្រីនោះថា ជារាត្រីអវសានស្នេហា ដែលខ្ញុំពុំអាចបំភ្លេចបានក្នុងជីវិតនេះៗ

យូរៗ យើងឮសូរមាន់រងាវម្តង ។ មាត់មាន់រងាវនេះ

ពុំមែនការនឹកតាមពេលវេលាទេ តែមកពីយើងដេកពុំលក់ រហូតដល់យប់ជ្រៅ ទឹកសន្សើមធ្លាក់ត្រជាក់សព្វាង្គកាយ ។ នាង យូវ៉េត ពុំបានឃ្លាតចេញពីដើមទ្រូងរបស់ខ្ញុំឡើយ ដែលមើលទៅហាក់ដូចជា រូបកាយទាំងពីរលាយចូលគ្នាតែមួយ ។ ខ្យល់បក់រំភើយៗ ចូលតាមបង្អួច ផាប់ដោយអាកាសត្រជាក់មកជាមួយផង បានជំរុញយើងទាំងពីរនាក់ឲ្យរឹតតែជិតចូលជិតគ្នាថែមទៀត ។

– អូននៅមានសង្ឃឹមម្យ៉ាង ជាសេចក្ដីសង្ឃឹមក្នុងជីវិតរបស់អូន ( នាង យូវ៉េត និយាយ )

– អូន យូវ៉េត សង្ឃឹមអ្វី ?

– អូនសង្ឃឹមថា សេចក្ដីស្នេហាបរិសុទ្ធរបស់យើងនេះ អាចបណ្ដាលឲ្យអូនមានកូនជាមិនខាន – ប្រសិនបើបានកូនមែននោះ ការរស់នៅក្នុងជីវិតក៏នឹងបានធូរស្រាលឡើង ព្រោះជីវិតរបស់អូននឹងមិនស្ងាត់ស្ងៀមក្រៀមក្រំតែឯកឯង អូននឹង



បានកូនគ្រាន់បានជាគ្នា ហើយមុខជានឹងធូរទ្រូងខ្លះ ចងបានទុកកូនឲ្យនៅក្នុងពេលអរុណជិតរះ ដែលមានមាន់រងាវឆ្លើយឆ្លងគ្នាផងឆ្ងាយ ហៅឲ្យព្រះអាទិត្យប្រញាប់រះឡើង ជួយបំភ្លឺផ្លូវឲ្យកូនយើង – អូនសុំឲ្យកូននេះល្អដូចជារស្មីនៃព្រះអរុណ ។

ទីបំផុត ពេលព្រះអរុណរះក៏មកដល់ អរុណនៃការកំណាចសាហាវ អរុណដែលរះឡើងដូចជាបំបែកយើងទាំងពីរឲ្យបែកឆ្ងាយពីគ្នា ។

ខ្ញុំគិតថា ខ្ញុំពុំអាចត្រឡប់មកជួបនាង យូវ៉េត វិញបានឡើយ ព្រោះកាលបើខ្ញុំទៅដល់ភ្នំពេញហើយ ប្រាកដអាពាហ៍ពិពាហ៍ក៏មុខជាវណ្ណកខ្ញុំជាប់ ។ ខ្ញុំត្រូវតែនៅក្រោមការត្រួតត្រានៃស្ត្រី ដែលខ្ញុំពុំដែលមានមេត្រីចិត្ត មិនដែលស្គាល់និស្ស័យចិត្តថ្លើម ។ កាលបើពិធីមង្គលការបានធ្វើផុតទៅ សេរីភាពជាទីស្នេហារបស់ខ្ញុំ ក៏នឹងអស់អាយុជីវិតតាំងពីពេលនោះទៅដែរ ។

យើងលាបែកគ្នានៅពេលអ្នកបួរ៉ ចេញ ។ ខ្ញុំក្រឡេកមើលទៅក្រោយវិញតាំងអាល័យ ។ ខ្ញុំបានឃើញនាងយូរ៉ែន និងអ្នកដែលជូនមកជាមួយ ឈរនៅត្រង់កន្លែងដដែល លើកដៃឡើងជាសញ្ញានៃការលាគ្នា ។ ខ្ញុំខំសំឡឹងមើលទាល់តែស្រវាំងភ្នែក ឃើញដូចជាផែនដីបានបែកញែកចេញពីគ្នាយ៉ាងឆ្ងាយ ក្លាយទៅជាសមុទ្រផ្ទុកកន្ទុយភ្នែក ... ខ្ញុំងាកមុខមកវិញ ក្នុងខណៈដែលបេះដូងបានស្រែកតាំងក្តីអាល័យថា :

" លាហើយស្នេហា "

x
x x

# ជំពូកទី ២

## វគ្គទី ៧

## ការក្បត់ជាតិរបស់ខ្ញុំ

នៅក្នុងការិយាល័យដ៏ធំទូលាយ តុបតែងដោយតុទូយ៉ាងទំនើប ៗ ឯកឧត្តម ឧត្តមសេនីយ៍ ទេសរដ្ឋមន្ត្រីក្រសួងការពារប្រទេស កំពុងតែពិនិត្យសំណុំរឿងផ្សេងៗ ដែលគេដាក់នរនៅលើតុរបស់ឯកឧត្តម ។ មួយស្របក់ ឯកឧត្តមបានចាត់ការអស់ ហើយក៏ក្រោកដើរចុះឡើង ក្រពាត់ដៃទៅក្រោយ ដូចជាកំពុងត្រិះរិះគិតសម្រេចការអ្វីដ៏ធំមួយ ។ ដំណើរដំរីជាសក្តិភាពនៃសតិទីនទ ទីនជំហារ៉ើងប៉ុង ..., សភាពសក់ខ្មៅរួញ កាត់ខ្លីសុងប៉ូកណ ថៃកសោរបំពណ្តាល ជាគ្រឿងសំគាល់ពូជខ្មែរបុរាណមកពីកម្ពុជ ជាអ្នកចាស់ទុំ ។ ថ្លាសទូលាយ សំគាល់ថា ជាអ្នកប្រាជ្ញមានចិត្តទូលាយ ។

ចិញ្ចើមក្រាស់ហើយធំ សំគាល់ថា ជាអ្នកក្លាហាន ។ ភ្នែកវែងព្រាយ សំគាល់ថា ជាអ្នកមានចិត្តមេត្តា ។ កេមភ្នែកវែងហើយងើឡើងលើ សំគាល់ថា ជាអ្នកមានប្រាជ្ញាដោះខ្លួន ។ ច្រមុះខ្ពស់វែងធំ សំគាល់ថា ជាអ្នកចិត្តមុត ។ វង់មាត់មានរឹមជុំវិញ ហើយញញឹមជាប់ សំគាល់ថា ជាអ្នកមានចិត្តទូលាយនិងចិត្តករុណា ។ ថ្គាមទ្វា ចង្កាក្រាយវេះ សំគាល់ថា ជាជនមានបុណ្យនិងចិត្តក្លាហាន ។

ដើរបោះឡើងមួយស្របក់ ក៏ត្រឡប់ទៅអង្គុយនៅការិយាល័យវិញ ហើយហូតថតតុទាញយកក្រដាសមួយ មកឈ្ងោកពិនិត្យពិច័យ ហាក់ដូចជាមានវត្ថុអ្វីមួយ អាចស្រូបទាញខួរសតិអារម្មណ៍របស់ឯកឧត្តមឲ្យសំឡឹងមើលស្ទើរតែមិនព្រិចភ្នែក ។ ក្នុងខណៈមួយរំពេចនោះ ឯកឧត្តមក៏បានងើបមុខឡើងដោយអាការៈអន្ទះអន្ទែង ព្រោះការពិបាកចិត្ត បែបុ ខន្ទឹងចាំអ្វីមួយ ដែលឯកឧត្តមបានតម្រូវ ។



នាឡិកាបានរោយម៉ោង ១០ ឯកឧត្តមចុចកណ្ដឹង លោកអនុសេនីយឯក សំរេច បានចូលមក ។

— ឃើញលោក ហង្ស-ចំរើន មកឬទេ ? (ឯកឧត្តមបានសួរ)

— ប្របាទម្ចាស់ លោកវរសេនីយត្រី ហង្ស-ចំរើន អញ្ជើញមកហើយ លោកនៅខាងក្រៅ (អនុសេនីយឯក សំរេច បានឆ្លើយ)

— អញ្ជើញលោកចូលមក ។

លោកអនុសេនីយឯក សំរេច ក៏ចេញទៅអញ្ជើញលោកវរសេនីយត្រី ហង្ស ចំរើន ។

ឯកឧត្តម បិតបារី រង់ចាំដោយទឹកមុខញញឹម ដើម្បីទទួលមេក្រុមតារកម្ម ដែលត្រូវនាំរូបកាយពាហានមួយរូបមកជូនឯកឧត្តមស្គាល់មុខ ។

ក្នុងពេលជាបន្ទាប់នោះ លោកវរសេនីយត្រីហង្ស-ចំរើន

ក៏បានចូលមកដោយបាននាំទាំងសហការីរបស់លោកម្នាក់ គឺរូបខ្ញុំ ទៅជួបឯកឧត្តមទេសរដ្ឋមន្ត្រី ។

លោកឧត្តមសេនីយ ទទួលលោកវរសេនីយត្រី និងខ្ញុំ យ៉ាងកក់ទាក់ ដោយទឹកមុខញញឹម ។ ក្រោយពេលបានគោរពចំពោះឯកឧត្តមនិងអង្គុយក្នុងទីដ៏សមគួរហើយ លោកវរសេនីយត្រី ហង្ស - ចំរើន ក៏បានចាប់ផ្ដើមនិយាយជំរាបលោកឧត្តមសេនីយ ពីគុណសម្ប័ទរបស់ខ្ញុំ ។

— ឯកឧត្តម ! (លោកវរសេនីយត្រី ហង្ស - ចំរើន និយាយ) សហការីរបស់ខ្ញុំប្របាទម្ចាស់មួយរូបនេះឈ្មោះ... (ឈ្មោះខ្ញុំ) ដែលខ្ញុំប្របាទម្ចាស់បានជ្រើសរើសបានពីចំណោមនាយទាហានជាច្រើន ព្រោះជានាយទាហានដែលបានធ្វើឲ្យខ្ញុំប្របាទម្ចាស់ទុកចិត្តទុកថ្លើមអស់ពីពោះ ។

— ខ្ញុំក៏បានសង្កេតឃើញដូចលោកដែរ (ឯកឧត្តមមានប្រសាសន៍ហើយដើរមកអង្អែលស្មាខ្ញុំ) លោកស័ក្ដិពីរ ! លោក



ជាយុវជនខ្មែរមួយរូប ដែលស្ម័គ្រចិត្តចូលមកបំរើផែនដី លោកជានាយទាហានដ៏ប្រសើរ មានចរិយាទន់ភ្លន់ មានឫកពាដែលគួរឲ្យខ្ញុំទុកចិត្ត សមដូចពាក្យដែលលោកវរសេនីយត្រីបាននិយាយប្រាប់ខ្ញុំមែន ខ្ញុំសុំសំដែងនូវសេចក្ដីសរសើរចំពោះលោក ហើយខ្ញុំសង្ឃឹមថា មានតែលោកម្នាក់ទេដែលអាចបំពេញនូវបេសកកម្មដ៏ពិបាកជូនប្រទេសជាតិឲ្យសម្រេចបាន ។

លោកឧត្តមសេនីយ ដឹកដៃខ្ញុំឲ្យដើរទៅអង្គុយជិតហើយ លោកសំឡឹងមើលខ្ញុំស្ទើរតែពុំព្រិចភ្នែក ។

— លោក ! (លោកឧត្តមសេនីយមានប្រសាសន៍ទៅទៀត) រឿងដែលខ្ញុំត្រូវនិយាយប្រាប់លោកឥឡូវនេះ ជារឿងមានសារៈសំខាន់ជាទីបំផុត ដែលលោកត្រូវបិទបាំងឲ្យជិត ព្រោះជារឿងអាថ៌កំបាំង ដែលទាក់ទងនឹងជីវិតប្រទេសជាតិមាតុភូមិ ។

គ្រាន់តែឮប្រសាសន៍លោកឧត្តមសេនីយដូច្នេះ ខ្ញុំដូចជាភ័យបន្តិច អរបន្តិច ៗ ខ្ញុំអង្គុយនៅស្ងៀម ឥតឆ្លើយថាអ្វី ៗ ឯកឧត្តមសំឡឹងមើលមុខខ្ញុំម្តងទៀត ដែលធ្វើឲ្យខ្ញុំឱនមុខចុះ ព្រោះពុំហ៊ានឡើងប៉ះក្រសែភ្នែករបស់ឯកឧត្តម ។

— លោកស័ក្តិពីរ ! សុំលោកផ្ទៀងត្រចៀកចាំស្តាប់ខ្ញុំ ខ្ញុំនឹងសួរលោកនូវបញ្ហាមួយ ដែលពុំគួរដល់នាយទាហាន ដែលមានឋានៈខ្ពង់ខ្ពស់ សមជាអ្នកទទួលនូវសំលៀកបំពាក់ជាឯកសណ្ឋានរបស់កងយោធពលខេមរភូមិន្ទ ចង់ឮនូវសំនួរយ៉ាងនេះឡើយ ... ( ឯកឧត្តមឈប់នៅស្ងៀមបន្តិច ហាក់ដូចជាចង់សង្កេតមើលអាកប្បកិរិយារបស់ខ្ញុំ ហើយក៏ចាប់មានប្រសាសន៍តទៅទៀត) លោកស័ក្តិពីរ ! ខ្ញុំចង់សួរលោកថា តើលោកអាចក្បត់ប្រទេសជាតិមាតុភូមិរបស់លោកបានដែរឬទេ ?

ខ្ញុំដូចជាភ្ញាក់ខ្លួនព្រើត ៗ បេះដូងរបស់ខ្ញុំ ស្ទើរតែឈប់



លែងដើរការ ។ ទឹកមុខរបស់ខ្ញុំឡើងស្លេកស្លាំងមួយរំពេច ៗ ខ្ញុំគិតបន្តិចទើបដាច់ចិត្តសួរទៅឯកឧត្តមវិញ :

— សុំទានមេត្តាអភ័យទោសទានប្រោស ! ខ្ញុំប្របាទម្ចាស់ដូចជាពុំទាន់យល់ដល់ន័យនៃសំនួររបស់អ្នកប្របាទម្ចាស់សោះទានប្រោស ...

លោកឧត្តមសេនីយ និង លោកវរសេនីយសំឡឹងមើលមុខគ្នាទៅវិញទៅមកដោយអាការញញឹម ហាក់ដូចជាពេញចិត្តនឹងសភាពដែលខ្ញុំពុំយល់ដល់សំនួរនោះ ។

— លោកស័ក្តិពីរ ! (លោកឧត្តមសេនីយមានប្រសាសន៍ដោយអាការម៉ឺងម៉ាត់) លោកបានឮនូវសំនួររបស់ខ្ញុំហើយមែនឬទេ ? ការដែលលោកវរសេនីយនិងខ្ញុំ ហៅលោកមកជួបនេះ គឺដើម្បីសួរបញ្ជាក់លោកយ៉ាងខ្លីថា លោកអាចក្បត់មាតុភូមិលោកបានដែរឬទេ តែប៉ុណ្ណោះ ...

ដោយសារខ្ញុំនៅស្ងៀម ពុំដឹងជាឆ្លើយដូចម្តេច

លោកឧត្តមសេនីយក៏មានប្រសាសន៍ជូនឡើងទៀតថា ក្បត់ដើម្បីបំរើប្រទេសជាតិឲ្យបានប្រសើរជាងមុខការរបស់លោកសព្វថ្ងៃ ...

– សូមមេត្តាអត់ទោសដល់ខ្ញុំប្របាទម្ចាស់ផងចុះទានប្រោស ! (ខ្ញុំឆ្លើយដោយទឹកមុខដែលសំដែងនូវការពុំយល់) ខ្ញុំប្របាទម្ចាស់ពុំដែលបានជួបប្រទះនឹងសេចក្ដីស្នើយ៉ាងនេះសោះទានប្រោស – ខ្ញុំប្របាទម្ចាស់ពុំដែលបានគិតគូពីរឿងក្បត់ប្រទេសជាតិយ៉ាងនេះសោះ ...

– លោកសុក្ដីរ ! (ឯកឧត្តមមានប្រសាសន៍ដោយទឹកមុខញញឹម) ការជួបប្រទះនឹងបញ្ហាចំឡែកបែបនេះ ជាការនាំឲ្យលោកងឿងឆ្ងល់មែនហើយ តែសុំលោកចាំស្ដាប់សេចក្ដីពយការណ៍របស់ខ្ញុំឲ្យបានច្បាស់លាស់ តាមស្ថានការណ៍ពិត ... ខ្ញុំនឹងបំភ្លឺលោកត្រង់ចំណុចសំខាន់ខ្លះ នៃបេសកកម្មដែលខ្ញុំតម្រូវឲ្យលោកបំពេញ ... រួចហើយត្រូវ



លោកប្រាប់មកខ្ញុំវិញថា តើលោកអាចបំពេញនូវបេសក-កម្មនោះបានឬក៏ពុំបានតែប៉ុណ្ណោះ ...

– ប្របាទម្ចាស់ :

– លោក អស់ពេលជាងមួយខែមកហើយ ដែលអគ្គ-សេនាធិការយោធពលខេមរភូមិន្ទយើង បានទទួលដំណឹងថាពួក ដាប-ឈួន រួមគំនិតជាមួយ សម-សារី និង សឺង ង៉ុកថាញ់ ក្បត់ប្រទេសជាតិ ដោយមានអាមេរិក យួន និងសៀមនៅក្រោយខ្នង ពួកខ្មាំងបានប្រុងប្រៀបបំបែកប្រទេសខ្មែរជាពីរ តាមគំរោងការរបស់អាមេរិកាំង ដោយដណ្ដើមយកខេត្តសៀមរាប កំពង់ធំ និងបាត់ដំបង ឲ្យនៅក្នុងការត្រួតត្រារបស់វា ហើយវាប្រកាសខ្លួនធ្វើជាខ្មែរសេរី ដើម្បីវាយលុកចូលមកភ្នំពេញ – ក្រុមឃាតកម្មរបស់វា មានវត្ថុបំណងមុះមុត ដើម្បីលួចយកផែនការសម្ងាត់របស់យើងឲ្យបាន ពួកក្បត់បានទិញជនខ្លះឲ្យធ្វើការឲ្យវា ដោយធ្វើ

ពលិកម្មគ្រប់យ៉ាងក្នុងរឿងនេះ ឥឡូវខ្ញុំទើបបានទទួលដំណឹងពីចារកម្មរបស់យើងដែលបានតាមដានពួកក្បត់ថា មាននាយទាហានខ្មែរម្នាក់ បំរើឱលក់ផែនការសម្ងាត់របស់យើង ឲ្យពួកក្បត់តម្លៃសាមសិបម៉ឺនរៀល .

— អើអញ្ចឹង អ្នកប្របាទម្ចាស់ខឹងតម្រូវឲ្យខ្ញុំប្របាទម្ចាស់ដើរតួជាជនទុរយសនោះ ឬ ទានប្រោស ?

ឯកឧត្តមទេសរដ្ឋមន្ត្រី ងក់ក្បាលញញឹម ដោយអាការពេញចិត្ត ហើយមានប្រសាសន៍ថា :

— ត្រូវហើយ ! លោកស័ក្តិពីរ ! ... ជនដែលក្បត់ជាតិនោះ ពុំមែនក្រៅពីមនុស្សដែលយើងទុកចិត្តទុកថ្លើមនោះទេ វាសនានៃប្រទេសជាតិបានតម្រូវឲ្យយើងទុកចិត្តលើរូបលោក ដែលស្រឡាញ់ប្រទេសជាតិពិតប្រាកដ ... ជនក្បត់ជាតិដែលយើងត្រូវគិតដល់នេះ គឺរូបលោក .. លោកស័ក្តិពីរ លោកពុំចាំបាច់មកជួបនឹងខ្ញុំទៀតទេ ការទាំងអស់ខ្ញុំបាន



ប្រគល់ឲ្យលោកវរសេនីយត្រីរួចអស់ហើយ — បើលោកបញ្ជាយ៉ាងណា សុំឲ្យធ្វើតាមចុះ — ខ្ញុំជឿថា រូបលោកហ្នឹងឯងហើយដែលត្រូវបានទទួលប្រាក់សាមសិបម៉ឺនរៀល ជាថ្លៃនឹងផែនការសម្ងាត់របស់យើង — ការក្បត់របស់លោក នឹងប្រែក្លាយទៅជាកិច្ចប្រសើរបំផុត ក្នុងការបំរើប្រទេសជាតិមាតុភូមិ ... ម៉េចលោកយល់ ឬ ទេ ?

— ខ្ញុំប្របាទម្ចាស់ដូចជាពុំយល់ ហើយខ្ញុំប្របាទម្ចាស់ដូចជាធ្វើពុំកើតផង —

— ខ្ញុំក៏យល់ដល់ចិត្តថ្លើមលោកណាស់ដែរ (លោកវរៈសេនីយត្រី និយាយកាត់ឡើង) សុំលោកអនុញ្ញាតឲ្យខ្ញុំរំលឹកលោកបន្តិចចុះ លោកធ្លាប់បានដឹងហើយថា ទាហានមានកាតព្វកិច្ចត្រូវតែទទួលប្រតិបត្តិតាមបញ្ជារបស់នាយទៅហ្វាយដោយគ្មានការជជែក ...

— រឿងនោះខ្ញុំបាទ (ខ្ញុំនិយាយនឹងលោកវរសេនីយ

ពុំមែនជាមួយឯកឧត្តមទេ ) ខ្ញុំបានដឹងហើយ តែទាហានត្រូវតែស្មោះត្រង់នឹងប្រទេសជាតិ ...

— ត្រូវហើយលោកសេក្រេទែរ ! ( ឯកឧត្តមទេសរដ្ឋមន្ត្រីមានប្រសាសន៍កាត់ឡើង ) តែរឿងនេះជាបេសកកម្ម ដ៏ប្រយោជន៍ធំជាងកិច្ចការឯទៀតទាំងអស់ ពិតណាស់ហើយ ខ្ញុំក៏ទទួលស្គាល់ថា ការក្បត់ជាតិជាការខុសនឹងផ្លូវច្បាប់ ហើយសំខាន់បំផុត គេក៏ពុំដែលបញ្ជាតាំងពីមុនឱ្យទាហានណាម្នាក់ក្បត់មាតុភូមិរបស់ខ្លួនទេ ទោះបីកិច្ចការនោះប្រសើរយ៉ាងណាក៏ដោយ ... ខ្ញុំដឹងហើយថា ទាហានទាំងអស់ សុទ្ធសឹងតែស្ម័គ្រចិត្តធ្វើពលិកម្មចេញទៅប្រយុទ្ធនឹងខ្មាំងនៅសមរភូមិមិនខ្លាចស្លាប់ ព្រោះគេយល់ថា ជាការប្រសើរជាងការក្បត់ជាតិ តែពលិកម្មពិសេសដែលខ្ញុំត្រូវឱ្យលោកបំពេញនេះ ក៏ព្រោះយល់ឃើញថា មានតែលោកម្នាក់ប៉ុណ្ណោះទេ ដែលជាវរជន អាចបំពេញនូវពលិកម្ម



ដែលនឹងឱ្យសម្រេចបាន ...

បរិយាកាសបានស្ងប់ស្ងាត់មួយគ្រា ដោយខ្ញុំពុំដឹងជាឆ្លើយដូចម្ដេច ។ លោកឧត្តមសេនីយបានចាប់ផ្ដើមមានប្រសាសន៍ឡើងទៀត ដោយពាក្យសំដីបង្គាប់បញ្ជាយ៉ាងដាច់ខាត ៖

លោកសេក្រេទែរ ! លោកត្រូវតែធ្វើតាមខ្ញុំ ... លោកត្រូវពុះពារការពិបាកនេះ ដើម្បីឱ្យគម្រោងការយើងបានសម្រេចផល — ខ្ញុំសុំបញ្ជាក់ប្រាប់លោកថា យើងត្រូវការបំភាន់ខ្មាំង គឺយើងចង់ធ្វើឱ្យឯកសារនៃផែនការសម្ងាត់ ដូចជាត្រូវលួចយកបាន ដោយការប៉ុនប្រសប់នៃខាយទាហានម្នាក់តែប៉ុណ្ណោះ — រូបខ្ញុំនិងលោកវររេសេនីយត្រី បានគិតគ្រោងការនេះឡើងហើយ យើងក៏បានគិតដល់រូបលោកមុនគេ — ខ្ញុំសង្ឃឹមហើយជឿជាក់ថា លោកនឹងពុំធ្វើឱ្យយើងស្ដាយនូវការជ្រើសរើសរបស់យើងទៅលើរូបលោកនេះទេ ...

សភាពស្ងប់ស្ងៀម បានកើតឡើងទៀត ... ខ្ញុំបាន ដកដង្ហើមវែង ៗ ហើយសម្លឹងមើលផ្ទៃឥដ្ឋពណ៌ក្នុងការិយាល័យដោយសភាពចិត្ត ដែលពោរពេញដោយការគន្ធះកតាម មនោសញ្ចេតនាពីរចំណែកគឺ មួយចំណែក ខ្ញុំនឹកត្រេកអរ ព្រួច ព្រោះគិតថា នាយពៅហ្វាយបានទុកចិត្តលើរូបខ្ញុំ មួយចំណែកទៀត ខ្ញុំនឹកស្អប់ខ្ពើមចំពោះពាក្យថាក្បត់ជាតិនេះជាខ្លាំង ថ្វីបើការក្បត់នេះ ជាការធ្វើតាមបង្គាប់បញ្ជាពីពៅហ្វាយនាយក៏ដោយ ...

ប៉ុន្តែវិន័យទាហានបានតម្រូវឲ្យប្រតិបត្តិតាមបញ្ជារបស់នាយពៅហ្វាយ ... គិតដូច្នេះទ្រូងខ្ញុំឡើងតឹងណែនស្ទើរប្រេះ ... ខ្ញុំនឹកក្នុងចិត្តថា ខ្ញុំត្រូវតែទទួលគោរពតាមបង្គាប់បញ្ជានាយពៅហ្វាយទាំងពីររូបនេះ បើពុំដូច្នោះទេ ខ្ញុំនឹងត្រូវទទួលទោសព្រោះប្រកែក ...

× ×
×



បរិកាសតានតឹង ហាក់ដូចជាបានធូរស្រាលវិញបន្តិច ក្នុងខណៈដែលលោកវរសេនីយ៍ត្រី លាងកង្គមទេសរដ្ឋមន្ត្រី ហើយនាំខ្ញុំត្រឡប់ទៅការិយាល័យទី ២ វិញ ។ ប៉ុន្តែខ្ញុំក៏ចាប់ព្រួយចិត្តមួយជាន់ទៀត ព្រោះលោកវរសេនីយ៍ត្រីបានហៅខ្ញុំឲ្យអង្គុយទល់មុខនឹងលោក ហើយដកថតតុទាញយកកញ្ចប់ក្រដាសសមួយកញ្ចប់ហុចមកឲ្យខ្ញុំ ព្រមទាំងពាក្យបញ្ជាយ៉ាងដាច់ខាតថា :

លោកសក្តិពីរ ! នេះ ប្រាក់ដប់ម៉ឺនរៀល ... លោកត្រូវយកប្រាក់នេះទៅលេងល្បែងឲ្យទាល់តែចាញ់អស់ក្នុងថ្ងៃនេះ ហើយស្អែកលោកត្រូវមកជួបនឹងខ្ញុំនៅពេលរសៀល តែបើមិនទាន់ចាញ់អស់ប្រាក់ទេ កុំអាលមកជួបនឹងខ្ញុំ ...

— ព្រះតេជគុណ ! ខ្ញុំបាទពុំហ៊ានទទួលយកទេបាទប្រោស (ខ្ញុំឆ្លើយឡើងទាំងភិតភ័យ) ព្រោះមួយជាតិនេះ ខ្ញុំបាទពុំចេះលេងល្បែងទាល់តែសោះបាទប្រោស ...

— ហ៊ឺយកទៅ! (លោកវរសេនីយត្រីបញ្ជាដោយបង្ខិតបង្ខំ) នេះជាបញ្ជាការដាច់ខាតរបស់ខ្ញុំ...

ខ្ញុំត្រូវទទួលយកប្រាក់ដប់ម៉ឺនរៀលនេះទាំងប្រថុយ ហើយក៏គំនាប់លាលោកវរសេនីយត្រី ចេញពីការិយាល័យ ត្រឡប់ទៅផ្ទះវិញ...

ខ្ញុំដូចជាគេគិតពុំយល់ថា ហេតុអ្វីក៏ឯកឧត្តមទេសរដ្ឋមន្ត្រី និងលោកវរសេនីយត្រីបញ្ជាឲ្យខ្ញុំក្បត់ជាតិ? មិនតែប៉ុណ្ណោះសោត លោកវរសេនីយត្រីបានឲ្យប្រាក់ខ្ញុំដប់ម៉ឺនរៀលយកទៅលេងល្បែងស៊ីសងដោយមានបញ្ជាថា បើមិនទាន់ចាញ់អស់កុំអាលត្រឡប់ទៅជួបនឹងលោកវិញ ។ រឿងនេះប្រែសេចក្ដីថាដូចម្ដេច? បើខ្ញុំប្រតិបត្តិតាមបញ្ជានេះទៅ តើកិត្តិយសនាយទាហាននៅឯណា? ប៉ុន្តែវិន័យទាហានបានតម្រូវឲ្យទាហានប្រតិបត្តិតាមបង្គាប់បញ្ជារបស់នាយមេហ្វាយ... ។

ល្ងាចនៃថ្ងៃនេះ ខ្ញុំបានចូលខ្លួនទៅក្នុងវង់ល្បែងស៊ីសង



ក្នុងគេហដ្ឋានមួយដោយសម្លៀកបំពាក់ស៊ីវិល ។ តាំងពីកើតមក ខ្ញុំពុំដែលលេងល្បែងស៊ីសងពាល់តែសោះ តែខ្ញុំត្រូវតែប្រថុយលេងតាមបញ្ជារបស់នាយមេហ្វាយ... ពាក្យថាល្បែងស៊ីសង ដូចជាសមសួនណាស់ ព្រោះវាមានស៊ីមានសង... ខ្ញុំបានរើសល្បែងមួយបែបដែលស្រួល គឺជួ...

ខ្ញុំពុំបានបង្អង់ឲ្យខាតពេលឡើយ ខ្ញុំចាប់ផ្ដើមដាក់ដៃដំបូងប្រាំម៉ឺនរៀល... ពួកអ្នកលេងទាំងអស់សម្លឹងមើលមុខខ្ញុំដោយការគោរពក្រែង តែវាជាគ្រោះល្អសំរាប់ខ្ញុំ ព្រោះគេបានស៊ីខ្ញុំអស់ប្រាំម៉ឺនរៀលនេះ... ការដែលខ្ញុំចាញ់ហើយខ្ញុំថាជាគ្រោះល្អនោះ គឺព្រោះខ្ញុំពុំចង់លេងពាល់តែសោះ ហើយនៅពេលលេងនេះ ខ្ញុំចង់ឲ្យតែឆាប់ចាញ់អស់ប្រាក់ ដើម្បីឲ្យឆាប់បានត្រឡប់ទៅផ្ទះវិញ ។

នៅថ្ងៃទីពីរ ខ្ញុំដាក់ប្រាំម៉ឺនរៀលទៀត ។ គ្រោះកាចក៏បានកើតឡើងដល់រូបខ្ញុំ ព្រោះខ្ញុំត្រូវចំកៅទុ ហើយមេត្រូវ

សងខ្ញុំ ដប់ប្រាំម៉ឺនរៀល . . . ឥឡូវខ្ញុំមានប្រាក់ម្ភៃម៉ឺនរៀល គឺច្រើនជាងមុនមួយជាពីរ ។ ខ្ញុំបានសួរមេថា អាចឲ្យខ្ញុំចាក់ទាំងអស់ដែរឬអ្វី? គេឆ្លើយថា គេអនុញ្ញាតឲ្យដាក់តែដប់ម៉ឺនរៀលប៉ុណ្ណោះ ។ ដូច្នេះខ្ញុំត្រូវនៅសល់ប្រាក់ពាក់កណ្ដាល ។ នៅថ្ងៃទីបីនេះ មេស៊ីអស់ . . .

នៅថ្ងៃទីបួននិងទីប្រាំ ខ្ញុំបានលើកប្រាក់ដែលនៅសល់ចាក់ម្ដងប្រាំម៉ឺនរៀល តែត្រូវមេស៊ីទាំងអស់ ដែលមើលទៅសមនឹងពាក្យដែលគេឲ្យឈ្មោះថាមេមែន . . .

ខ្ញុំបានត្រឡប់ទៅផ្ទះវិញ ក្រោមសញ្ញាថា ចាញ់ជួ ។ ថ្ងៃនេះពេញមួយថ្ងៃ ខ្ញុំដូចជារសេះរសោះអស់កំឡាំងជាខ្លាំង រកធ្វើអ្វីពុំកើត ។ ក្នុងចិត្ត ខ្ញុំគិតមួយម៉ឺនមួយសែនជំពូក តែដូចជាគ្មានបានការអ្វីសោះ ព្រោះខ្ញុំនៅតែពុំយល់ផលបញ្ជា-ការរបស់ឯកឧត្ដម ឧត្ដមសេនីយ និង លោកវរសេនីយត្រី ហង្ស-ចំរើន ថា ហេតុអ្វីក៏លោកទាំងពីរបញ្ជាឲ្យខ្ញុំធ្វើដូច្នេះ?...



លុះពេលព្រឹកនៃថ្ងៃមួយទៀត ខ្ញុំក៏បានរៀបចំខ្លួនប្រាណចូលទៅជួបនឹងលោកវរសេនីយត្រី ហង្ស-ចំរើន ។

ក្រោយពេលបានធ្វើគារវកិច្ចរួចហើយ ខ្ញុំក៏បានរាយការណ៍ជំរាបលោកវរសេនីយត្រី ថា :

— ព្រះតេជ-គុណ ! ខ្ញុំបានប្រតិបត្តិតាមបញ្ជាការរបស់ព្រះតេជ-គុណ រួចស្រេចអស់ហើយពានទោស . . .

— ល្អហើយលោកសក្ដិពីរ ! ( លោកវរសេនីយត្រីនិយាយដោយទឹកមុខញញឹម ) ខ្ញុំសុំសំដែងនូវអំណរគុណចំពោះលោកជាច្រើន ដែលលោកចេះប្រតិបត្តិតាមបញ្ជាការរបស់ខ្ញុំ ឲ្យបានសំរេចដោយរៀបរយយ៉ាងនេះ - សុំអញ្ជើញអង្គុយលោកសក្ដិពីរ . . .

ខ្ញុំបានសំរុតខ្លួនចុះអង្គុយលើកៅអីមួយ ដែលឋិតនៅទល់មុខនឹងលោក ។ លោកបានដកយកស្រោមសំបុត្រមួយហុចមកឲ្យខ្ញុំ ព្រមទាំងនិយាយថា :

— លោកសក្ដិធំ ! នេះ ជាឯកសារពិសេស ដែលលោកត្រូវមានបេសកកម្មបំពេញមួយជាន់ទៀត . . .

— ព្រះតេជ-គុណ ! ការដែលព្រះតេជ-គុណ បានឲ្យកិត្តិយសដល់រូបខ្ញុំបាទ ដោយទុកចិត្តឃើញរូបខ្ញុំបាទមុនគេ ក្នុងការបំពេញនូវបេសកកម្មដ៏ពិបាកនោះ តើព្រះតេជ-គុណឲ្យខ្ញុំបាទនាំយកឯកសារពិសេសនេះទៅណា បានព្រោស . . . ?

— ចាំស្ដាប់ខ្ញុំ លោកសក្ដិធំ ! ខ្ញុំនឹងអធិប្បាយប្រាប់លោកពីបេសកកម្មនេះ (លោកបិតបារីហើយនិយាយតទៅទៀត) នៅពេលដែលលោកចេញពីនេះទៅ លោកនឹងឃើញឡានជីបមួយពណ៌ប្រផេះដែលមានលេខ ១០០.០៦៤ ចតនៅសៀម ដោយមានអ្នកបើកបរម្នាក់អង្គុយកាន់ចង្កូតចាំ អ្នកបើកបរនេះ ជាភ្នាក់ងារសម្ងាត់លេខ ៨ របស់យើង ហើយដែលក្រុមយើងបានប្រគល់ឲ្យកាន់ការសម្ងាត់ដែរ — ពេលដើរទៅដល់ លោកត្រូវឡើងជិះឡានភ្លាមដោយមិនបាច់សាកសួរអី



ពីក — ដើម្បីដឹកនាំលោកធ្វើដំណើរឆ្ពោះទៅកាន់ខេត្តសៀមរាបភ្លាមដែរ លោកទៅនៅសៀមរាបចាំស្ដាប់ទូរលេខបញ្ជាការអំពីខ្ញុំ ដែលតម្រូវឲ្យលោកត្រឡប់មកភ្នំពេញវិញ កាលបើបានទទួលទូរលេខបញ្ជាហើយ លោកត្រូវចេញដំណើរមកពេលយប់នៅតាមផ្លូវពីសៀមរាបមកកំពង់ធំ លោកនឹងត្រូវជួបនឹងចារបុរសរបស់ជាប-ឈួន ម្នាក់នៅត្រង់កន្លែងណាមួយមិនកំណត់ ដែលអ្នកបើកបរឡានជីបរបស់លោក បានដឹងសញ្ញារួចស្រេចអស់ហើយ — លោកគ្រាន់តែចាំធ្វើតាមពាក្យណែនាំរបស់អ្នកបើកឡាននេះ គឺជាការស្រេចទៅហើយ តែសុំលោកកុំភ្លេចខ្លួនថា លោកត្រូវដើរតួជានាយទាហានម្នាក់ដែលអស់សង្ឃឹម ហើយបានសម្រេចចិត្តជាស្រេចថា នៅរង់ចាំតែឱកាសល្អហុចឲ្យប៉ុណ្ណោះ លោកហ៊ានធ្វើការអ្វីគ្រប់យ៉ាងរហូតដល់ហ៊ានក្បត់ជាតិដើម្បីប្ដូរយកប្រាក់ណាលោក . . .

ខ្ញុំបានយកស្រោមសំបុត្រពណ៌សដែលមានបោះត្រាបិទ

ផ្ចិតដោយការកអាចម៍ល័ក្ខដើម្បីបង្កប់ឯកសារពិសេសដែលមាន តម្លៃស្មើនឹងប្រទេសមួយនៅខាងក្នុងនោះ សៀតនៅក្នុងហោប៉ៅអាវ ហើយក៏បិទខ្សែអាវជិតទៅវិញ ។

– សុំគោរព ! សុំលាព្រះតេជ-គុណសិនហើយបាន ប្រោស . . .

– អើ ! អញ្ជើញទៅចុះលោកសត្តិពរ !(លោកវរសេនីយត្រី ហង្ស-ចំរើន និយាយដោយទឹកមុខញញឹម ព្រមទាំងចាប់ដៃខ្ញុំរលាក់យ៉ាងណែន ដែលជាសញ្ញាមួយប្រាប់ឲ្យដឹងថា លោកបានផ្ញើសេចក្ដីទុកចិត្តលើរូបខ្ញុំយ៉ាងធំ) សុំលោកអញ្ជើញទៅឲ្យបានសម្រេចគ្រប់យ៉ាង ប្រទេសជាតិត្រូវការផ្ញើនូវសេចក្ដីទុកចិត្តទាំងស្រុងលើរូបលោក សុំឲ្យលោកមានជោគជ័យក្នុងបេសកម្មពិសេសនេះ . . . . . ។

## វគ្គទី ៨

# ស្ត្រីជាសត្រូវ

នាងជម្ពូលពេជ្រ ជាកញ្ញាមួយរូបមានអាយុប្រមាណ ២០ ឆ្នាំ ។ ប្រសិនបើគេបោលភ្នែកក្រឡេកមើលនាងដោយការសង្កេតពិនិត្យ គេមុខជាដឹងថា នាងជាស្ត្រីកូនកាត់ ព្រោះពណ៌សម្បុរសាច់ឈាមរបស់នាងមិនខុសគ្នា ពីស្រីកូនកាត់ចិនខ្មែរប៉ុន្មាន ។ នាងមានផ្ទៃមុខមូលទ្រវែងដូចកង់ពងមាន់ ។ ខ្នងច្រមុះមានចុងស្រួច បបូរមាត់ស្ដើងមានពណ៌ក្រហមស្រស់ ភ្នែកទាំងគូខ្មៅរលោងស្រិលដូចនិល ដុះក្រោមរោមចិញ្ចើមដ៏តូចងខ្វង់ក្ងូរលើបដូចស្លាបចំកេម បានធ្វើផ្ទៃមុខរបស់នាង ឲ្យមានសម្រស់គួរជាទីចាប់ចិត្តនៃបុរសដែលបានឃើញ ។ នាងទុកសក់វែងធ្លាក់ចុះទៅបញ្ចោសអន្លើលស្មា ដែលមានពណ៌សទ្រលុកក្រលង់ដូចភ្លុក

ដីរ ៗ នាងចូលចិត្តពាក់អាវក្រលកធំបញ្ចេញខ្លួនសាច់ច្រើន ដ៏សមិទ្ធ ដែលធ្វើឲ្យបុរសមានការសំរើបចិត្តជាខ្លាំង កាលបើបានឃើញរូបនាងហើយ ៗ

ពិតណាស់នាងជរីពុំមែនជានារីខ្មែរសុទ្ធសាធទេ ៗ ឪពុកនាងជាខ្មែរសុទ្ធ ហើយត្រូវជាបងប្អូនរបស់ឈួ ឆ មួយពោះ ម្ដាយនាងជាយួនសុទ្ធ ៗ នាងបានរៀនសូត្រចេះជ្រៅជ្រះណាស់ដោយបញ្ញាវៃឆ្លាត តាំងពីឪពុកនាងបានកាន់សក្តិការក្នុងតំណែងជាប - ឈួ ឆ ៗ

នៅពេលដែលខ្ញុំត្រូវទៅប្រតិបត្តិការនៅខេត្តសៀមរាប តាមបញ្ជាការរបស់អគ្គសេនាធិការយោធពលខេមរភូមិន្ទនោះ ខ្ញុំបានស្គាល់នាងជរីនេះ ដោយសារមិត្តភក្តិម្នាក់ណែនាំឲ្យស្គាល់ ៗ ក្នុងសប្តាហ៍ដំបូងដែលខ្ញុំបានឈានជើងចូលទៅកាន់ដីសៀមរាបនោះ ខ្ញុំបានស្គាល់នាងហើយកប់ភានជិតដិតស្និទ្ធស្នាលនឹងគ្នាដូចជាធ្លាប់ស្គាល់មកយូរហើយ ៗ ប៉ុន្តែ



ការកប់ភានដ៏ជិតដិតស្និទ្ធស្នាលនេះ ពុំមែនបានសេចក្ដីថា ខ្ញុំស្រឡាញ់នាង ឬ ជាប់ចិត្តជាប់ថ្លើមនឹងនាងឡើយ ៗ ខ្ញុំស្រឡាញ់នាងជរីដូចម្ដេចកើត បើខ្ញុំនៅតែនឹកស្រមៃឃើញនាង យូរ៉េត របស់ខ្ញុំនៅជាប់នឹងភ្នែកជានិច្ច គ្មានពេលភ្លេចពេលរសាយដូច្នេះ បេះដូងរបស់ខ្ញុំដែលមានតែមួយនេះ ខ្ញុំបានប្រគល់ឲ្យនាង យូរ៉េត រួចទៅហើយ ខ្ញុំគ្មានបេះដូងឯណាទៀតសំរាប់ប្រគល់ឲ្យនាងជរីឡើយ ម្ល៉ោះហើយការជិតដិតស្និទ្ធស្នាលគ្នារវាងខ្ញុំនឹងនាង ជរី នោះ កើតឡើងពី នាងជរីដែលចេះតែមកម៉ឺកម៉ក់រកខ្ញុំតែប៉ុណ្ណោះ ៗ

ក្រពីមួយនៃសប្ដាហ៍ទីពីរដែលខ្ញុំនៅសៀមរាប នៅគេហដ្ឋានរបស់នាង ជរី មានការរៀបពិធីជប់លៀងមួយយ៉ាងគគ្រឹកគគ្រេង ដោយឪពុករបស់នាង ជាអ្នកចាត់ចែង ៗ ខ្ញុំក៏ត្រូវបានគេអញ្ជើញឲ្យទៅចូលរួមសប្បាយក្នុងពិធីនេះដែរ ៗ យប់នេះដូចជាគ្រោះកាត្រក់បន្តិចសំរាប់រូបខ្ញុំ

ព្រោះខ្ញុំបានត្រូវមិត្តភក្តិបង្អកស្រាជាច្រើន ៗ មួយកែវហើយមួយកែវទៀតតាមសេចក្តីសុំពីមិត្តភក្តិនេះ បានធ្វើឲ្យខ្ញុំលែងដឹងខ្លួនប្រាណនៅពេលយប់ជ្រៅ....

ខ្ញុំបានដឹងខ្លួនប្រាណឡើងវិញ នៅពេលអរុណរះ...

នៅពេលដឹងខ្លួននេះ ខ្ញុំបានឃើញនាង ជរី រួមដំណេកជាមួយខ្ញុំនៅលើផ្ទះនាង ដោយដាក់ក្បាលផ្ទាល់នឹងដើមទ្រូងរបស់ខ្ញុំ ហើយដៃឆ្វេងរបស់នាងឱបខ្ញុំ ៗ ខ្ញុំនឹកឆ្ងល់ក្រៃណាឆ្ងល់ ហេតុអ្វីក៏បានជាខ្ញុំត្រូវមករួមដំណេកជាមួយនាងដូច្នេះ? ខ្ញុំលើកដៃនាង ជរី ដែលឱបខ្ញុំចេញ នាងភ្ញាក់ដឹងខ្លួនហើយសំឡឹងមើលមុខខ្ញុំ ដោយក្រសែភ្នែកដែលមានលេស មានន័យ....

— លោក! (នាង ជរី សួរខ្ញុំមុន) លោកភ្ញាក់ហើយឬ?

— បាទ! (ខ្ញុំឆ្លើយហើយសួរទៅនាងវិញ) ហេតុ



អ្វីក៏បានជាខ្ញុំត្រូវមកគេងជាមួយអ្នកនាងនៅទីនេះអញ្ចឹង ?

— ពីយប់មិញនេះ លោកស្រវឹងស្រាជាខ្លាំង - លោកប៉ាបានឲ្យគេគ្រាហ៍លោកមកគេងនៅកន្លែងនេះ ហើយបានឲ្យខ្ញុំនៅកំដរលោក ...

គ្រាន់តែនិយាយផុតពាក្យប៉ុណ្ណោះ នាង ជរី ក៏ក្រោកឡើងហើយចេញទៅក្រៅបន្ទប់ ៗ មួយសន្ទុះក្រោយមកនាងក៏ចូលមកក្នុងបន្ទប់វិញ ដោយមានចានដែកទឹកក្តៅនិងកន្សែងពោះគោ ៗ នាងបានជូតមុខមាត់និងខ្លួនប្រាណឲ្យខ្ញុំ ៗ ខ្ញុំក៏ចេះតែសម្ងំឲ្យនាងជូតទៅ ៗ

ខ្ញុំក្រោកឡើងជក់បារីយ៉ាងឈ្ងុយឆ្ងាញ់ ដូចជាធ្វើឲ្យការសាំញ៉ាំនៅក្នុងខ្លួនប្រាណនិងចិត្តគំនិត ហើរសាត់បាត់ទៅតាមផ្សែងបារី ...

ខ្ញុំនឹកដូចជាចង់បន្ទោសខ្លួនឯងថា ពុំគួរជាបណ្តោយឲ្យមានការធ្វេសធ្លោយដូច្នេះកើតឡើងសោះ ព្រោះជាការពុំ

សមគួរដល់ឋានៈនៃនាយទាហានដូចជារូបខ្ញុំ ..... អគ្គសេនាធិការគណៈយោធពលខេមរភូមិន្ទ បានចាត់រូបខ្ញុំឲ្យទៅប្រតិបត្តិការនៅសៀមរាប ពុំគួរជាខ្ញុំទៅមានរឿងពុំល្អ ពុំគប្បីយ៉ាងនេះឡើយ ....

នាង ធារី បានចូលមកម្ដងទៀត ។ នាងបានប្រាប់ខ្ញុំថា ឪពុកនាងកំពុងតែអង្គុយចាំខ្ញុំនៅបន្ទប់ទទួលភ្ញៀវ ។ ខ្ញុំក៏រៀបចំខ្លួនចេញទៅជួបទាំងខ្មាសអៀន ។

— ម៉េចលោក ? (លោកអនុសេនីយ៍ទោនោះសួរខ្ញុំ) លោកបាត់ស្រវឹងហើយឬ ?

— បាទ! បាត់ហើយ ..(ខ្ញុំឆ្លើយដោយការអៀនខ្មាស)

— ពីយប់មិញនេះ លោកស្រវឹងខ្លាំងណាស់

— បាទ ! ខ្ញុំស្រវឹងទាល់តែលែងដឹងខ្លួន លោកអនុសេនីយ៍ទោចាស់ បានសំឡឹងមើលមុខខ្ញុំស្ទើរតែពុំព្រិចភ្នែក ដែលមើលទៅ ហាក់ដូចជាចង់សង្កេតពិនិត្យមើលការពិតអ្វី



ម្យ៉ាងពីរូបខ្ញុំ ។ ខ្ញុំក៏ដាក់មុខចុះ ព្រោះពុំហ៊ានប៉ះក្រសែភ្នែកនឹងលោក ហើយបរិយាកាសបានស្ងប់ស្ងៀមទៅមួយសន្ទុះធំ ។

— លោក ! (លោកអនុសេនីយ៍ទោចាស់បានទម្លាយនូវបរិយាកាសស្ងប់ស្ងៀមនោះឡើង) ឥឡូវលោកគិតយ៉ាងម៉េចចំពោះរឿងពីយប់មិញនេះ ?

— រឿងពីយប់មិញយ៉ាងម៉េចលោក ? (ខ្ញុំសួរទៅវិញ ព្រោះពុំយល់ដល់សំនួរនោះ ។

— ឱ ! លោកនៅតែធ្វើពើដូចជាមិនដឹងទៀតឬ ! ធារី ជាកូនស្រីរបស់ខ្ញុំ លោកបានរួមរ័កជាមួយកូនស្រីរបស់ខ្ញុំ ឥឡូវខ្ញុំចង់ដឹងថា តើលោកគិតយ៉ាងណាក្នុងរឿងនេះ ?

តាមពិត ខ្ញុំឥតបានដឹងអ្វីទាំងអស់ ព្រោះខ្ញុំស្រវឹងស្រា ។ អ្នកណាគ្រាហ៍ខ្ញុំយកទៅដាក់ឲ្យដេកលើគ្រែនោះ ហើយនាង ធារី ទៅដេកជាមួយខ្ញុំពីពេលវេលាណានោះ ខ្ញុំក៏

ឥតបានដឹងពាល់តែសោះ ។ ខ្ញុំជឿជាក់ថា ខ្ញុំឥតបានប្រព្រឹត្តលើសលស់អ្វីលើរូបនាង ណារី ដល់តិចតួចសោះឡើយ កាលបើខ្ញុំស្រវឹងស្រាពាល់តែលែងដឹងខ្លួនដូច្នេះ ។ ប៉ុន្តែខ្ញុំក៏គ្មានហេតុផល អ្វីដែលនឹងត្រូវលើកយកមកធ្វើជាសំអាងដែរ ព្រោះតាមធម្មតាកំលោះនិងក្រមុំ កាលបើដេករួមគ្រែមួយជាមួយគ្នាយ៉ាងនេះ ក៏ពិបាកនឹងនិយាយឲ្យគេជឿថាខ្លួនជាមនុស្សត្រឹមត្រូវមិនប៉ះពាល់គ្នា ក្រៅពីពួកទេវតាដែលមានភ្នែកទិព្វត្រចៀកទិព្វប៉ុណ្ណោះ ។

— រឿងនេះ! (ខ្ញុំឆ្លើយទាំងប្រថុយ ព្រោះមិនដឹងជាឆ្លើយជាដូចម្ដេចក្រៅពីនេះ) ខ្ញុំក៏ពុំដឹងជាគិតយ៉ាងណាដែរ សុំឲ្យលោកមេត្តាជួយគិតខ្ញុំឲ្យបានស្រួលផងចុះ . . .

— រឿងនេះ ខ្ញុំក៏មិនថាអីដែរ ព្រោះវាបានជាជ្រុលហួសទៅហើយ ខ្ញុំសុំឲ្យលោកកុំធ្វើឲ្យខ្ញុំខ្មាសគេតែប៉ុណ្ណោះ . . . ខ្ញុំសុំបញ្ជាក់ថា យើងជាទាហានទាំងអស់គ្នា កាលបើលោក



មិនទុកមុខទុកមាត់ឲ្យខ្ញុំទេ ខ្ញុំក៏គ្មានអីឆ្លើយទៅលោកវិញ ក្រៅពីគ្រាប់កាំភ្លើងទេ . . . ហើយលោកនៅផឹកតែលេងសិនចុះ ខ្ញុំទៅធ្វើការហើយ . . . ។

លោកអនុសេនីយទោនេះ ក្រោកដើរចេញទៅក្នុងខណៈដែលនិយាយផុតពាក្យ ដោយមិនទុកពេលឲ្យខ្ញុំនិយាយតទៅទៀត ។ ខ្ញុំចង់ឆ្លើយថា ខ្ញុំក៏ជាទាហានដែរ ហើយការប្រើគ្រាប់រំសេវក៏ចេះប្រើដូចគ្នាដែរ តែខ្ញុំទប់ទាន់ ព្រោះគិតថា ខ្ញុំពុំគួរជាប្រើគ្រាប់រំសេវជាមួយនឹងបងប្អូនរួមលោហិតឡើយ . . .

ក្រោយពេលដែលឪពុកនាងចុះចេញផុតបន្ទប់ទៅ នាងណារី បានចូលមកអង្គុយនិយាយលេងពីនេះពីនោះជាមួយខ្ញុំ ។ ខ្ញុំប្រើវិធីត្រជាក់និយាយលេងជាមួយនាង ហាក់ដូចជាគ្មានរឿងរ៉ាវអ្វីកើតឡើង ។ នៅម៉ោង៩កន្លះ ខ្ញុំក៏បានលានាងត្រឡប់ទៅកងវិញ ។

ខ្ញុំអង្គុយគិតម្នាក់ឯងនៅក្នុងបន្ទប់ ... ខ្ញុំគិតពុំយល់ថា ហេតុអ្វីក៏គេគ្រោហ៍ខ្ញុំ ដែលស្រវឹងស្រាលែងដឹងខ្លួនឲ្យទៅដេកជាមួយនាង ជរី ដូច្នេះ ? មានខណៈចិត្តខ្លះ ខ្ញុំចង់គិតថា ក្រែងគេត្រូវការអ្វីពីរូបខ្ញុំទេដឹង ? ព្រោះគេឃើញខ្ញុំនៅកំឡោះ មានឋានន្តរស័ក្តិជាអនុសេនីយទោ ហើយនៅធ្វើការក្នុងក្រុមពារកម្មទៀតផង ។ នាង ជរី ជានារីមានការសិក្សាជ្រៅជ្រះ ឪពុកនាងទៀតសោតក៏មានឋានន្តរស័ក្តិជាអនុសេនីយទោដែរ មិនគួរណាជាពុំដឹងការអាក្រក់ល្អយ៉ាងនេះទេ ។ ពិតណាស់គេប្រហែលជាត្រូវការអ្វីម្យ៉ាងពីរូបខ្ញុំហើយមើលទៅ ... បើពុំដូច្នោះទេ គេមុខជាពុំធ្វើយ៉ាងនេះឡើយ ...

លុះគិតដូច្នេះហើយ ខ្ញុំក៏សំរេចចិត្តថា ពុំត្រូវបោះបង់នាង ជរី ចោល ។ ខ្ញុំត្រូវតែបំពេញបំណងរបស់នាង ជរី ដែលចង់បានរូបខ្ញុំធ្វើជាប្តី និងបំណងរបស់ឪពុកនាង ដែលចង់បានរូបខ្ញុំធ្វើជាកូនប្រសា ក្រែងលោបានដឹង



ការណ៍អាថ៌កំបាំងអ្វីអ្នកទាំងនេះ ។ ខ្ញុំជានាយទាហាន ធ្វើការក្នុងក្រុមពារកម្ម កាលបើបានមកជួបប្រទះនឹងហេតុការណ៍ដូច្នេះហើយ បោះបង់ចោលដោយដកខ្លួនថយនោះ គឺដូចជាធោតពេក ។ ខ្ញុំគិតថា គួរតែប្រថុយចាំមើលបន្តតទៅទៀតសិន ។

ខ្ញុំពុំមែនស្រឡាញ់នាង ជរី ទេ ប៉ុន្តែពាក្យដែលគេតែងនិយាយថា បើមានផ្កានៅជិតដៃបេះថើបលេងទៅ នោះជាពាក្យត្រូវណាស់សំរាប់រូបខ្ញុំ ។ ខ្ញុំបេះបុប្ផានេះថើបលេង ក៏ព្រោះវានៅជិតដៃ ហើយបុប្ផាដ៏ក្រអូបនេះអាចហុចប្រយោជន៍អ្វីម្យ៉ាងឲ្យខ្ញុំក្នុងពេលឆាប់ ៗ នេះផង ។

ចាប់តាំងពីថ្ងៃនោះមក ក្នុងចំណោមមិត្តភក្តិរបស់ខ្ញុំ គេដឹងគ្រប់គ្នាថា ខ្ញុំស្រឡាញ់នាង ជរី យកធ្វើជាប្រពន្ធ ។ ឯរូបខ្ញុំវិញ ក៏ពុំធ្វើអ្វីឲ្យនាងដឹងថាខ្ញុំពុំស្រឡាញ់នាងឡើយ ។

ព្រលប់នៃថ្ងៃមួយ ខ្ញុំត្រូវធ្វើដំណើរត្រឡប់ទៅភ្នំពេញ

តាមទូរលេខបញ្ជាការពិសេស ពីលោកវរសេនីយត្រី ហង្ស-ចំរើន នាយក្រុមបារគម្ម ដែលត្រូវជានាយទោហ្វាយផ្ទាល់របស់ខ្ញុំ

## វគ្គទី ៩

## បំពេញបេសកកម្មពិសេស

រាត្រីនេះ ជារាត្រីមួយប្រកបដោយមេឃស្រឡះអាកាសស្ងប់ ៗ យើងបានធ្វើដំណើរចេញផុតពីផ្សារកំពង់ក្តី ហើយ ៗ ភ្នាក់ងារសម្ងាត់លេខ ៨ បានកាន់បង្គួរចយន្ត ហើយបញ្ជាឲ្យល្បួនទៅមុខ ក្រោមស្រមោលនៃរុក្ខជាតិនានា ។

ការស្ងាត់ស្ងៀមក្នុងការធ្វើដំណើរនេះ បានធ្វើឲ្យខ្ញុំផ្ចង់គិតដល់បេសកកម្មរបស់ខ្ញុំ ... ខ្ញុំផ្ចង់គិតដោយការងឿងឆ្ងល់ជាខ្លាំងនូវកិច្ចការដែលខ្ញុំត្រូវធ្វើ ក្នុងគោលបំណងបំការទមតិខ្លាំងដែលអាចមានមនុស្សរាប់រយរាប់ពាន់នាក់ ត្រូវជាប់អន្ទាក់នេះ ... ខ្ញុំសំឡឹងមើលរុក្ខជាតិដែលដុះតដូរតាមបណ្តោយផ្លូវតាំងខាងឆ្វេងនិងតាំងខាងស្តាំ ក្រោមពន្លឺព្រះចន្ទថា ដែលឃើញដូចជាស្រមោលស្ពុង ១..ៗ ស្រមោលរុក្ខជាតិទាំងនេះ ហាក់ដូចជាបានខ្សឹបដាក់ត្រចៀករបស់ខ្ញុំថា ៖

អាក្បត់ ! ... អាក្បត់ !!! ។

ខ្ញុំបានបោលកន្ទុយភ្នែកមើលនាឡិការបស់ខ្ញុំ ឃើញទ្រនិចខ្លីបង្អុលមោងថ្ងៃ ។ ខ្ញុំបានសួរភ្នាក់ងារលេខ ៨ ថា៖

— ជិតដល់ហើយឬនៅ ?

— បាទទាន ! ជិតដល់ហើយ — ពួកវាត្រូវនៅចាំយើងត្រង់កន្លែងមួយជិតព្រំប្រទល់ខេត្តសៀមរាប កំពង់ធំ ដែលមានផ្លូវរទេះកាត់ ជិតភូមិប្រឡាយ ហើយវាឲ្យសញ្ញាយើង ដោយពន្លឺភ្លើងពិល ...

បន្តិចក្រោយមក យើងក៏បានឃើញសញ្ញាពន្លឺភ្លើងពិលបីដង ៗ ភ្នាក់ងារលេខ ៨ ក៏បញ្ឈប់រថយន្តតែជ្រុលហួសទៅមុខប្រហែល ១០ ម៉ែត្រ ។ យើងត្រូវថយរថយន្តមកក្រោយវិញ ហើយមកឈប់ចម្ងាយ ៥ ម៉ែត្រពីកន្លែងភ្លើងសញ្ញា ។ ខ្ញុំសង្កេតឃើញថា ពួកវាចតរថយន្តចាំតាម



ផ្លូវរទេះ ដែលចុះពីផ្លូវថ្នល់ទៅប្រហែលជា ៥ ម៉ែត្រដែរ ។ ភ្នាក់ងារលេខ ៨ បាននិយាយនឹងខ្ញុំតិច ១ ថា៖

ខ្ញុំត្រូវឈប់រថយន្តចម្ងាយ ៥ ម៉ែត្រអញ្ចឹងក្រែងលោមានការពុំស្រួល—សុំលោករង់ចាំខ្ញុំមួយភ្លែត ចាំខ្ញុំទៅមើលសិនបើបានការតាមសន្យាហើយ ចាំខ្ញុំមកនាំលោកទៅ ...

— ហ្នឹងហើយទៅចុះ

— លោក ! (ភ្នាក់ងារលេខ ៨ និយាយបែបចំអកក្រោយពេលដែលគ្រឿងចក្ររថយន្តរលត់) លោកប្រហែលជាពេញចិត្តក្នុងការក្បត់នេះដែរមែនទេលោក ?

— ខ្ញុំពុំសូវពេញចិត្តប៉ុន្មានទេ តែខ្ញុំពេញចិត្តទៅប្រយុទ្ធជាមួយខ្មាំងជាង ។

— លោក ! មុខងារចារបុរសក៏ពុំខុសគ្នាពីមុខងារដទៃដែរ ... មុខងារនេះមានសារៈប្រយោជន៍សំខាន់ណាស់ក្នុងខណៈដែលខ្មាំងនៅពុំទាន់ដឹងខ្លួន តែនៅពេលដែលខ្មាំងរក

ដឹងខ្លួនហើយ ក៏ចាប់រូបតារបុរសនោះបាន ក៏គ្មានអ្វីក្រៅពីគ្រាប់កាំភ្លើង ១២ គ្រាប់របស់ខ្មាំងជារង្វាន់ទេលោក ...

ខ្ញុំនៅស្ងៀមពុំឆ្លើយថាអ្វី ព្រោះខ្ញុំគិតថា មុខងារជាតារបុរសពុំមែនជាមុខងារស្រួលឡើយ ហើយខ្ញុំក៏ដូចជាពុំទើង(១) ឮនូវពាក្យថាតារបុរសនេះផង ។

ភ្នាក់ងារលេខ ៨ ក៏និយាយទៅទៀតថា ៖

— ខ្ញុំដូចជាចង់តែអស់សំណើច កាលបើខ្ញុំនឹកឃើញដល់រឿងដែលថា វាពុំគួរជាយកប្រាក់សាមសិបម៉ឺនរៀលមកទិញក្រដាសឥតតម្លៃនេះសោះ ! ...

និយាយចប់ហើយ ភ្នាក់ងារលេខ ៨ ក៏ចុះដើរតម្រង់ទៅកន្លែងដែលខ្មាំងរង់ចាំ ។ សភាពងងឹតបានបិទបាំងរូបកាយគេឲ្យមើលទៅឃើញតែស្រមោលស្គុន ១ ។ ខ្ញុំអុចបារីជក់ហើយដើរក្រេះក្រុះជុំវិញរថយន្ត ។

---

១ – ទើង ជាកិរិយាសព្ទប្រែថាចង់



ប្រហែលជាដប់នាទីបានកន្លងផុតទៅ សេចក្ដីបារម្ភរបស់ខ្ញុំក៏បានផុសឡើង ។ ខ្ញុំគិតថា ភ្នាក់ងារសម្ងាត់របស់ខ្មាំងប្រហែលជាបានដឹងនូវឧបាយកលទុច្ចរិតរបស់ខ្ញុំ តែក្នុងពេលដែលខ្ញុំកំពុងតែបារម្ភនោះ ខ្ញុំក៏ឮស្នូរស្បែកជើងមនុស្សដើរចូលមកជិតខ្ញុំ ។ ខ្ញុំបានពិនិត្យឃើញស្រមោលខ្មៅស្គុន ១ ពីរបានទិតចូលមកជិតខ្ញុំ ។ បន្តិចមកភ្នាក់ងារលេខ ៨ និងមនុស្សម្នាក់ទៀតបានដើរចូលមកចួបនឹងខ្ញុំ ។ ភ្នាក់ងារលេខ ៨ បានបញ្ចេញនូវកាយប្បកិរិយាគោរពខ្ញុំប្លែកពីធម្មតា ។

— ព្រះតេជ–គុណ ! (ភ្នាក់ងារលេខ ៨ ណែនាំខ្ញុំក្រោយដែលបានគោះកែងគោរពខ្ញុំ) ខ្ញុំបាទសុំបង្ហាញមនុស្សដែលយើងត្រូវចួបនោះប្រាស ។

— លោក ! (ខ្ញុំសួរដោយពាក្យដាច់ខាត) លោកមានប្រាក់គ្រប់ចំនួនហើយឬ ?

— បាទ ! មានគ្រប់ចំនួនហើយ (តារបុរសរបស់

ខ្លាំងបានឆ្លើយឡើងព្រមទាំងហុចកញ្ចប់ប្រាក់មកឲ្យខ្ញុំ) ។

ខ្ញុំទទួលយកហើយ ក៏ហុចស្រោមសំបុត្រដែលបង្កប់នូវឯកសារពិសេសទៅឲ្យគេវិញ ។ គេញញឹមញញែមដោយការពេញចិត្តជាខ្លាំង ។ គេបានសំដែងនូវអំណរគុណចំពោះខ្ញុំ រួចហើយក៏លាត្រឡប់ទៅវិញដោយមានភ្នាក់ងារលេខ ៨ ជាអ្នកជូនដំណើរទៅដល់កន្លែងដើម ។

មួយសន្ទុះក្រោយមក ភ្នាក់ងារលេខ ៨ ក៏ត្រឡប់មកវិញ ហើយយើងក៏នាំគ្នាបន្តដំណើរទៅភ្នំពេញ យ៉ាងរួសរាន់ ។ នៅតាមផ្លូវភ្នាក់ងារលេខ ៨ បានរាយការណ៍ប្រាប់ខ្ញុំពីរឿងនេះ ។ គេនិយាយរឿងនេះ ដូចជារឿងត្លុកកំប្លែងគួរឲ្យចង់សើចថា:

— លោក ! ខ្ញុំនិយាយប្រាប់ពួកវាថា លោកបានក្លាយក្នុងការលេងល្បែងស៊ីសង ដោយបានយកប្រាក់រដ្ឋការទៅលេងចាញ់អស់ជាច្រើន ហើយក្នុងការរកប្រាក់បង្គ្រប់វិញ



នេះ ជារឿងអាយុជីវិតរបស់លោកដែលត្រូវតែរកឲ្យទាន់នៅថ្ងៃខានស្អែកនេះ . .

តពីនោះមក ខ្ញុំក៏បានដេកលក់នៅលើរថយន្ត ។ លុះភ្ញាក់ឡើង ក៏ស្រាប់តែឃើញរថយន្តឈប់នៅលើសាឡាងព្រែកក្តាមដែលនឹងមកជិតដល់ត្រើយខាងលិចទៅហើយ ។

ខ្ញុំបានអុចបារីជក់ ហើយបណ្តោយឲ្យភ្នាក់ងារលេខ ៨ បើកបររថយន្តដោយស្ងប់ស្ងៀម . . .

រថយន្តបានលួនចូលដល់ទីក្រុងភ្នំពេញនៅម៉ោង ២៤ អាធ្រាត្រ ។ ខ្ញុំចេះតែមានសតិអារម្មណ៍រសាប់រសល់ ហើយនឹកការមួយម៉ឺនដំពូក ។ ខ្ញុំក៏បាននិយាយទៅកាន់ភ្នាក់ងារលេខ ៨ ថា ៖

— សុំនាំយកខ្ញុំទៅដាក់ឯផ្ទះចុះ . . .

— បាទ ! លោកវរសេនីយត្រីបានផ្តាំថា បើបានសំរេចការហើយ នៅពេលដែលត្រឡប់មកដល់រដ្ឋធានីវិញ

លោកឲ្យខ្ញុំនាំលោកទៅកំសាន្ត ក្នុងវង្គសាលណាមួយសិន ដើម្បីជាការផ្ទួនខួបជោគជ័យរបស់យើង ... ហេតុនេះយើងគួរទៅរកដាក់ម្នាក់មួយកែវសិន ...

យោបល់របស់ភ្នាក់ងារលេខ ១៨ នឹងបណ្តាំរបស់លោកវរសេនីយត្រីដូចជាគួរស្តាប់ណាស់ ៗ ខ្ញុំក៏យល់ព្រមតាម ៗ ភ្នាក់ងារលេខ ១៨ បាននាំខ្ញុំចូលទៅក្នុងវង្គសាល (ម៉ាឡៃយ៉ា) ឋិតនៅជិតវាលរេងបរសេះ ៗ យើងបានអង្គុយផឹកនឹងជជែកគ្នារឿយ ៗ នៅទីនោះ ភ្នាក់ងារលេខ ១៨ បានរៀបប្រាប់ខ្ញុំថា ចៅកែវង្គសាលនេះឈ្មោះយ៉ូយ៉ាំងញ៉ា ... វាត្រូវក្រុមប្រឆាំងនឹងចារកម្មរបស់យើងសង្ស័យថា វាជាចារបុរសរបស់ពួកដាប-ឈួន .. ការដែលយើងចូលមកក្នុងនេះ វា



មុខជានាំពតិមាននេះទៅប្រាប់ចៅហ្វាយវា ... ប្រសិនបើរឿងនេះពិតដូច្នោះមែន ក៏ជាការប្រសើរណាស់ដែរព្រោះវាអាចនាំនូវភាពសក្តិសិទ្ធិនៃរឿងក្បត់ជាតិរបស់យើង ឲ្យរឹងរឹតតែពិតប្រាកដឡើងទៀត ៗ

វគ្គទី ១០

# ការកាត់ទោសប្រហារជីវិត

យប់នេះ ខ្ញុំដេកលង់លក់ឥតដឹងខ្លួនប្រាណព្រោះខ្ញុំអត់ងងុយ ទាល់តែយប់ជ្រៅ ៗ ខ្ញុំភ្ញាក់ដឹងខ្លួនឡើងនៅពេលដែលស្នូរគោះទ្វារពីខាងក្រៅ ៗ ខ្ញុំចោលភ្នែកក្រឡេកមើលនាឡិកា ឃើញទ្រនិចចង្អុលលេខ ៦ ៗ ខ្ញុំក្រោកពីដំណេកទៅបើកទ្វារទាំងងងុយដោយមានការស្ញប់ពីរបីដង ៗ

ខណៈដែលខ្ញុំបើកទ្វារភ្លាម ខ្ញុំបានឃើញកងពលអាវុធហត្ថប្រហែលជាដប់នាក់ ឈរតម្រៀបគ្នានៅខាងក្រៅដោយមានអនុសេនីយត្រីម្នាក់ជាអ្នកនាំឈរមុខគេ ៗ ខ្ញុំដូចជាភ្ញាក់ផ្អើលក្តុក ព្រោះពុំដឹងជាមានការអ្វី ? ក្នុងពេលដែលខ្ញុំឈរស្រឡាំងកាំងនៅមាត់ទ្វារ អនុសេនីយត្រីនេះក៏គំនាប់ខ្ញុំហើយនិយាយឡើងថា ៖



— លោក ! អគ្គសេនាធិការដ្ឋានបញ្ជាពួកខ្ញុំឲ្យមកអញ្ជើញលោកទៅ ...

គ្រាន់តែឮពាក្យនេះខ្ញុំក៏ស្លស់ទឹកមុខ ព្រោះគិតថា ការដែលគេប្រើកំឡាំងយ៉ាងនេះ ក៏សម្រាប់តែមនុស្សដែលមានទោស ៗ ខ្ញុំទប់ស្មារតី ហើយសួរទៅវិញថា ៖

— ចុះបើគ្រាន់តែមកហៅខ្ញុំទេ ហេតុអីក៏ចាំនាំទាហានមកច្រើនម្ល៉េះ ?

— បាទ ! ខ្ញុំក៏ពុំដឹងដែរ តែខ្ញុំធ្វើតាមបញ្ជាអគ្គសេនាធិការ ...

— គេបញ្ជាថាម៉េចខ្លះ ?

— បាទ ! ឲ្យមកអញ្ជើញលោកទៅឲ្យខាងតែបាន តែបើលោករឹងរូស ត្រូវប្រើកំឡាំងអាវុធ,

— បើអញ្ចឹងបានសេចក្តីថា រូបខ្ញុំជាមនុស្សមានទោស?

— ការនេះ ខ្ញុំក៏ពុំដឹងដែរ ស្រេចតែលោកគិតចុះ ៗ

ក្រោយពេលបានលុបមុខនិងស្លៀកពាក់ស្រួលបួលហើយ ខ្ញុំក៏បានធ្វើដំណើរទៅទីបញ្ជាការអគ្គសេនាធិការ ជាមួយក្រុមកងអាវុធហត្ថ ដោយរថយន្តដែលចតចាំនៅខាងមុខផ្ទះ ។

ពួកនេះបាននាំខ្ញុំ ចូលទៅជួបនឹងលោកវរសេនីយត្រី មាស-ស្អាត នាយក្រុមប្រឆាំងនឹងចារកម្ម ។ ខ្ញុំត្រូវដើរឆ្លងកាត់ពួកកងអាវុធហត្ថ ដែលនៅឈរយាមច្រើនសន្ធាត់ ។ ខ្ញុំបានដើរចូលទៅគំនាប់លោកវរសេនីយត្រី ដែលកំពុងតែអង្គុយនៅក្នុងការិយាល័យតាំងព្រឹកព្រហាម ។

– អើ ! ( លោកវរសេនីយត្រីនិយាយហើយសំឡឹងមើលខ្ញុំដោយក្រសែភ្នែកដ៏មុត ) ចូលមកលោកស័ក្តិ-ពីរ ...

ខ្ញុំសំឡឹងមើលមុខលោកវរសេនីយត្រីពុំដាក់ភ្នែក ។ ខ្ញុំធ្លាប់ស្គាល់នាយទាហានជាន់ខ្ពស់រូបនេះតែក្នុងកិត្តិសព្ទដ៏ល្បីល្បាញតែប៉ុណ្ណោះ ។ ខ្ញុំបានសង្កេតឃើញថា ទឹកមុខ



នឹងអាកប្បកិរិយារបស់លោក មានសភាពសមនឹងកិត្តិយស-កេរ្តិ៍ឈ្មោះដ៏ល្បីល្បាញរបស់លោកមែន ។ លោកជាអ្នកចូលចិត្តកីឡា ។ រូបកាយរបស់លោកស្អាតស្អំ ។ ទឹកមុខរបស់លោកបានបង្ហាញនូវសភាពម៉ឺងម៉ាត់ ។ ក្រសែភ្នែករបស់លោក ដែលផ្ទុះខ្វាយចេញពីកែវកញ្ចក់វ៉ែនតាស បានបញ្ចេញឲ្យឃើញលក្ខណៈវាងវៃឆ្លៀវឆ្លាត និងប៉ិនប្រសប់ក្នុងការសង្កេត ។ លោកវរសេនីយត្រី មាស-ស្អាត មិនមែនមានកិត្តិសព្ទល្បីល្បាញក្នុងការប៉ិនប្រសប់ តែក្នុងមុខតំណែងរបស់លោកប៉ុណ្ណោះទេ លោកមានកិត្តិសព្ទល្បីល្បាញខាងការទាក់ទងនឹងស្រីទៀតផង ។ ថ្វីបើលោកមានវ័យចាស់បន្តិច ។ ប៉ុន្តែចួនកាលលោកអាចដណ្តើមយកជ័យជំនះ ក្នុងរឿងស្នេហាពីគូប្រណាំងប្រជែងកំលោះៗ ខ្លះបានគំមាន ។ ថ្វីដៃប៉ិនប្រសប់ក្នុងរឿងស្នេហារបស់លោកវរ-សេនីយត្រីនេះ បានធ្វើឲ្យអ្នកដែលធ្លាប់ស្គាល់លោកដាក់

ឈ្មោះក្រៅសម្រាប់ហៅលេងថា "ស្អាត ដាច់ចិត្ត" ។

— លោកសក្តិតែ! (លោកវរសេនីយត្រីចាប់និយាយឡើង) ខ្ញុំមានសេចក្តីស្តាយណាស់ក្នុងការដែលខ្ញុំបានដឹងថា លោកក្បត់ជាតិ — មនុស្សដូចលោកពុំគួរជាប្រព្រឹត្តនូវអំពើថោកទាបយ៉ាងនេះសោះ — ផ្អែកធម្មតាសំរាប់មនុស្សក្បត់ជាតិគឺប្រហារជីវិត — ខ្ញុំត្រូវទទួលភារៈ បញ្ជូនខ្លួនលោកឲ្យតុលាការសឹកជំនុំជំរះ កាត់ទោស — ខ្ញុំជឿជាក់ថាតុលាការសឹកមុខជាកាត់ទោសប្រហារជីវិតពុំខាន...

ខ្ញុំភ្ញាក់ខ្លួនព្រឺតដូចគេគគ្រោក់ ។ ខ្ញុំថ្ងួសទឹកមុខ ត្រជាក់ខ្លួនស្រឹប ហើយព្រឺព្រួចសព្វសព៌ាង្គកាយ ។

លោកវរសេនីយត្រីនិយាយតទៅទៀតថា!

— រឿងនេះជារឿងពិត, លោកដឹងខ្លួន ។ ឯងស្រាប់ហើយ...

— បាទ! (ខ្ញុំដំតាស់ឡើង) រឿងនេះខ្ញុំធ្វើតាមបញ្ជា...



— ឈប់! ឈប់និយាយលោកសក្តិតែ! (លោកវរសេនីយត្រីទះតុហើយស្រែកគំហក) លោកដឹងខ្លួនស្រាប់ហើយទេតើ — នៅក្នុងអគ្គសេនាធិការរបស់យើង គេបាត់សំណុំរឿងផែនការ សម្ងាត់សំរាប់វាយលុកចូលទៅចាប់ទាំង — ផែនការនេះជារបស់មានតម្លៃថ្លៃណាស់ ព្រោះជាផែនការដែលគេរៀបចំឡើង សំរាប់ការពារអាយុជីវិតនៃប្រទេសជាតិ — ឥឡូវនេះ ការស៊ើបអង្កេតបានឲ្យដឹងថា លោកជាអ្នកលួចយកផែនការនេះទៅលក់ឲ្យបច្ចាមិត្ត ដោយមានភស្តុតាងគ្រប់គ្រាន់ — លោកដឹងហើយថាផ្អែករបស់អ្នកក្បត់ជាតិនោះគឺគ្រាប់កាំភ្លើង ១២ គ្រាប់ — បើខ្ញុំពុំរវល់ធ្វើទោសដល់លោកដែលជាមនុស្សក្បត់ជាតិទេនោះ គឺដូចជាខ្ញុំចូលដៃចូលជើងជាមួយលោក...

ខ្ញុំស្រឡាំងកាំងដូចរូបតុក្កតា ឬ ដូចមនុស្សដែលគ្មានវិញ្ញាណ ។ ក្រសែភ្នែករបស់ខ្ញុំបែកគំពិលអំពែកព្រោង ។

ដំណក់ញើសដ៏ធំ ៗ បានជ្រាបចេញពីថ្ងាសដោយពុំដឹងខ្លួន ។ វិញ្ញាណរបស់ខ្ញុំ ដូចជាហោះហើរចេញពីរាងកាយបាត់ ។ ខ្ញុំលែងនឹកឃើញអ្វីទាំងអស់ ... លោកវរសេនីយត្រីសំឡឹងមើលមុខខ្ញុំដោយក្រសែភ្នែកដ៏មុត ៗ លោកប្រហែលជាសង្កេតឃើញថា ខ្ញុំមានសេចក្ដីភិតភ័យខ្លាំង ៗ ខណៈនោះ លោកក៏បញ្ជាឲ្យអនុសេនីយត្រី ក្រុមរាជអាវុធហត្ថចេញទៅក្រៅវិញ ហើយលោកក៏និយាយនឹងខ្ញុំ ដោយសម្លេងធូរជាប្រក្រតីថា :

— លោកស័ក្តិពីរ សុំលោកកុំភ័យខ្លាំងពេក ចាំខ្ញុំនិយាយប្រាប់លោក ឲ្យបានដឹងកិច្ចការក្នុងរឿងនេះ ... លោក ! ការក្បត់របស់លោកជាការមានប្រយោជន៍ធំណាស់ ព្រោះអាចធ្វើឲ្យយើងមានជោគជ័យ ... ហេតុនេះការក្បត់របស់លោកមានន័យថា ជាពលិកម្មដ៏ខ្ពង់ខ្ពស់ដែលអ្នកដទៃពុំអាចធ្វើបានក្នុងការបំរើប្រទេសជាតិ ... ខ្ញុំសុំបញ្ជាក់ប្រាប់



លោកថា ការប្រហារជីវិតលើរូបលោកនោះ ក៏គ្រាន់តែជាការដែលត្រូវធ្វើលើភាពខាងក្រៅតែប៉ុណ្ណោះ សុំលោកកុំយល់ច្រឡំឲ្យសោះ ...

— ព្រះតេជ-គុណ ! ភាពខាងក្រៅយ៉ាងម៉េចបាទប្រោស ?

— លោកស័ក្តិពីរ ខ្ញុំនិយាយប៉ុណ្ណេះគួរលោកយល់ហើយ-លោកពុំបាច់សួរខ្ញុំឲ្យវែងឆ្ងាយទៀតទេ-លោកមើល-មើល ! នេះគឺជាសំណុំរឿងដែលខ្ញុំបានធ្វើទុករួចស្រេចហើយ ដើម្បីចោទប្រកាន់លើរូបលោកពីការក្បត់ជាតិ ។ ឥឡូវនេះ ខ្ញុំត្រូវបញ្ជូនរូបលោកទៅឃុំឃាំងទុក រង់ចាំពេលជំនុំជំរះកាត់ទោសលោកតែប៉ុណ្ណោះ ។

— បើអញ្ចឹង សុំព្រះតេជគុណមេត្តាអនុញ្ញាតឲ្យខ្ញុំបានជូនដំណឹងនេះដល់ឪពុកម្ដាយខ្ញុំបានសិន បាទប្រោស ដើម្បីកុំឲ្យលោកព្រួយចិត្ត ...

– ពុំបានទេលោកស័ក្តិពីរ លោកធ្វើអញ្ចឹងពុំបានជាដាច់ខាត – លោកត្រូវដឹងថា យើងត្រូវធ្វើការនេះដោយស្ងាត់កំបាំងជាទីបំផុត កុំឲ្យរឿងនេះបែកការ – យើងសង្ឃឹមថា ផែនការអាថ៌កំបាំងនេះ អាចធ្វើឲ្យយើងមានជោគជ័យ – បើរឿងនេះបែកការ ប្រទេសជាតិទាំងមូលនឹងត្រូវទទួលនូវសេចក្តីអន្តរាយណាស់លោក . .

ការបង្អៀតបង្អល់ចិត្តយ៉ាងខ្លាំងបានកើតឡើងដល់រូបខ្ញុំៗ ខ្ញុំមានទឹកចិត្តពោរពេញដោយការសៅហ្មង ព្រោះខ្ញុំនឹកដល់វាសនាអាក្រក់របស់ខ្ញុំ ដែលកើតមកខុសគេ ៗ ខ្ញុំនឹកគួសវាសដល់ភាពទុក្ខព្រួយនៃឪពុកម្តាយបងប្អូនរបស់ខ្ញុំ និងពាក្យជេរប្រទេចផ្តាសារបស់មហាជនចំពោះរូបខ្ញុំ គ្រួសារខ្ញុំ ព្រោះជាអំពើដែលគេស្អប់ខ្ពើម ៗ

បួនថ្ងៃក្រោយមក សារពត៌មានទាំងអស់នៅទីក្រុងភ្នំពេញ បានចុះផ្សាយនូវដំណឹងមួយក្រោមចំណងជើងថា :



« ការប្រហារជីវិតជនក្បត់ជាតិ »

អនុសេនីយទោម្នាក់ នៃ កងយោធពលខេមរភូមិន្ទ (គេដាក់ឈ្មោះខ្ញុំ) ត្រូវគេចាប់បានក្នុងរឿងក្បត់ជាតិ ហើយឥឡូវត្រូវតុលាការសឹកកាត់ទោសប្រហារជីវិត . . .

ការប្រហារជីវិតជនក្បត់ជាតិនេះ នឹងត្រូវធ្វើនៅពេលព្រឹកនៃថ្ងៃទី ២ កុម្ភៈ ស្អែកនេះនៅទួលគី . . .

ដំណឹងនេះ បានធ្វើឲ្យមហាជនភ្ញាក់ផ្អើលជាខ្លាំង . . .

នៅពេលម៉ោង ៨ ព្រឹកនៃថ្ងៃទី ២ កុម្ភៈ . . .

អនុសេនីយទោម្នាក់នៅក្នុងក្រុមប្រឆាំងនឹងចារកម្ម បាននាំពលបាលឯកម្នាក់ និង ក្រុមនាយទាហានប្រហារមួយក្រុម មកយកខ្ញុំចេញពីបន្ទប់ឃុំឃាំងបណ្តើរឆ្ពោះទៅកាន់កន្លែងប្រហារដោយរថយន្ត ៗ ខ្ញុំត្រូវគេដាក់ខ្នោះដៃជាប់ ៗ នៅទីនោះគេបានជីករណ្តៅមួយសំរាប់កប់ខ្មោចខ្ញុំ ៗ មិនឆ្ងាយពីរណ្តៅនោះប៉ុន្មាន គេដាំបង្គោលមួយមានទំហំធំល្មម ហើយ

មានកំពស់ប្រហែលពីរម៉ែត្រ ។ បង្គោលនេះហើយដែលគេត្រូវយកខ្ញុំទៅចងភ្ជាប់ហើយប្រហារជីវិត ?

នៅក្រោមពន្លឺព្រិលៗ នៃអរុណដែលរះរៀបផុតជើងមេឃខាងកើត អនុសេនីយទោ ចម-ចៅ ជាសហការីរបស់លោកវរសេនីយត្រី មាស-ស្អាត បានបញ្ជាឲ្យខ្ញុំលុតជង្គង់ប្រឈមនឹងបង្គោល ហើយក្រាបមុខទៅនឹងបង្គោលនោះ ។ នៅពីខាងក្រោយខ្ញុំប្រហែលជា ១២ ម៉ែត្រ ពលទាហានមួយក្រុមចំនួន ១២ នាក់ បានឈរកាយគ្នាជាជួរបែរមុខមករកខ្ញុំ ក្រោមកិច្ចបញ្ជាការរបស់ពលបាលឯកម្នាក់ ។

លុះបានរៀបចំស្រេចហើយ អនុសេនីយទោ ចម-ចៅ បានលើកដៃស្តាំឡើងជាសញ្ញា ។ ពលទាហានទាំងអស់បានលើកកាំភ្លើងតម្រង់មករកខ្ញុំ ។ ក្នុងខណៈដែលអនុសេនីយទោ ចម-ចៅ ទម្លាក់ដៃចុះវិញ ពលបាលឯកនោះក៏ស្រែកឡើងយ៉ាងខ្លាំងថា :



— បាញ់ !

សូរគ្រាប់កាំភ្លើង ១១ គ្រាប់ ក៏បានលាន់ឮឡើងព្រមគ្នា ។ ខ្ញុំបានសំរុតខ្លួនចុះហើយផ្កាប់មុខទៅលើស្មៅ ។ អនុសេនីយទោ ចម-ចៅ បានដកកាំភ្លើងខ្លីចេញពីបង្កេះ ហើយយកមកផ្ទង់បាញ់ត្រង់ក្បាលរបស់ខ្ញុំជាការបង្ហើយ រួចហើយ គេក៏បញ្ជាទៅពលបាលឯកថា ឲ្យនាំពលទាហានត្រឡប់ទៅបន្ទាយវិញចុះ ឯរូបគេ ត្រូវបានទទួលបង្គាប់ឲ្យនៅចាំប្រគល់សពទៅឲ្យក្រុមញាតិរបស់ខ្ញុំ ដែលនឹងត្រូវមកទទួលយកក្នុងពេលឥឡូវនេះ ។

នៅពេលដែលក្រុមទាហានប្រហារ បានត្រឡប់ទៅបន្ទាយវិញអស់ហើយ លោកអនុសេនីយទោ ចម-ចៅ បានយកជើងមកផ្តើះគូថរបស់ខ្ញុំ ហើយគេនិយាយតិចៗថា :

— រួចហើយសំឡាញ់ ! រឿងកំប្លែងរបស់សំឡាញ់ឯង ត្រូវចប់សព្វគ្រប់អស់ហើយ . . .

ខ្ញុំងើបមុខឡើងទាំងប្រឡាក់ស្រមក ៗ អនុសេនីយ៍ទោ ចម-ចៅ បានស្រាយចំណងដៃចេញ ហើយនិយាយនឹងខ្ញុំទៀតថា :

— ទៅសំឡាញ់ ! ឡានខ្ញុំចតចាំសំឡាញ់ឯងនៅខាងនោះ ខ្ញុំប្រាប់សំឡាញ់ឯងពុំទាន់បានថា ខ្ញុំត្រូវនាំសំឡាញ់ឯងទៅណាទេ ៗ

យើងនាំគ្នាដើរតម្រង់ទៅជិះរថយន្តនោះ ៗ អនុសេនីយ៍ទោ ចម-ចៅ ជាអ្នកកាន់ចង្កូតហើយបើកបរចេញពីទីនោះទៅ ៗ

ក្នុងពេលដែលរថយន្តកំពុងតែល្បឿនលឿនស្ទុះទៅនោះ ខ្ញុំបានសាកសួរចង់ដឹងដល់រឿងប្រហារជីវិតរបស់ខ្ញុំ ៗ គេបានថ្លែងប្រាប់ខ្ញុំថា :

— សំឡាញ់ ! សំឡាញ់ឯងឆ្ងល់ឆ្ងើរ សព្វបើរឿងកាំភ្លើងអញ្ចឹង ... រូបខ្ញុំហ្នឹងឯង ដែលជាអ្នករៀបចំកាំភ្លើងទាំង ១៦ ដើម ព្រឹកមិញខ្ញុំបានប្រេកគ្រាប់ក្លែងក្លាយក្នុង



កាំភ្លើងទាំងនោះ រួចបានយកទៅឲ្យពលបាលឯកឡៃចែកដល់ពួកទាហានទាំងនេះ ពួកទាហានទាំងនោះ ក៏ពុំបានដឹងថាសំឡាញ់ឯងពុំទាន់ស្លាប់ដែរ ... (អនុសេនីយ៍ទោសើចក្អាកក្អាយរួចនិយាយតទៅទៀត) គ្រាន់តែ ១៦ គ្រាប់ចូលទៅក្នុងខ្លួនសំឡាញ់ឯង សំឡាញ់ឯងប្រហែលជាបានទទួលស្នាមមិនតិចទេមើលទៅ ...

— គ្មានបានទទួលស្នាមអ្វីទេ ! ... ខ្ញុំឆ្លើយឡើង ព្រោះខ្ញុំគិតថា សូរគ្រាប់កាំភ្លើង ១៦ គ្រាប់នេះបានចាក់ទម្លុះខួរបេះដូងឪពុកម្តាយនិងបងប្អូនរបស់ខ្ញុំ ព្រមទាំងបានបំផ្លាញនូវកិត្តិយសរបស់ខ្ញុំអស់មួយជីវិតទៀតផង ...

ដោយសារហេតុអ្វីក៏មិនដឹង នៅពេលនោះ ខ្ញុំចេះតែនឹកស្រមៃដល់នាង យូរ៉េត ទៀត យូរ៉េត ដែលខ្ញុំបានខំតាំងត្រាំបេះក្លូចនាងពោលច្រើនសប្តាហ៍ណាស់មកហើយ ... ខ្ញុំនឹកថានាង យូរ៉េត នឹងមានទុក្ខតាមខ្សែយ៉ាងណា នៅ

ពេលដែលនាងបានទទួលនូវផលនៃអកុសលរបស់ខ្ញុំនេះ ។

ខ្ញុំអង្គុយស្ងៀម ពោលក្លែកសំឡឹងមើលទៅខាងមុខ ដោយទឹកមុខសៅហ្មង ។ អារម្មណ៍របស់ខ្ញុំហាក់ដូចអណ្ដែតត្រសែតឆ្ពោះទៅរកនាង យូរើត ...

— សំឡាញ់ ! សំឡាញ់ឯងកុំឆ្ងល់អ្វីអ្វី (អនុសេនីយ៍ទោ ជម-ចៅ និយាយនឹងខ្ញុំ ក្នុងខណៈដែលខ្ញុំអង្គុយនៅស្ងៀមនោះ) ខ្ញុំបានទទួលបញ្ជាពីលោកស័ក្តិ ៤ មាស-ស្អាត ឲ្យខ្ញុំនាំសំឡាញ់ឯងទៅផ្ទះលោក ព្រោះលោករង់ចាំឃើញនៅទីនោះ ...

ខ្ញុំងក់ក្បាលទទួលដឹងដោយពុំបញ្ចេញស្ដីថាអ្វី !

លុះបានទៅដល់គេហដ្ឋានរបស់លោកវរសេនីយ៍ត្រី មាស-ស្អាត ហើយ អនុសេនីយ៍ទោ ជម-ចៅ បាននាំខ្ញុំចូលទៅក្នុងបន្ទប់ដ៏ស្ងាត់មួយនៅជាន់ខាងលើ ។ បន្ទប់នេះពុំមែនជាបន្ទប់ទទួលភ្ញៀវទេ គឺជាបន្ទប់ដេក ។ ខ្ញុំនឹក



ឆ្ងល់ជាខ្លាំងថា ហេតុអ្វីក៏បានជាគេនាំខ្ញុំចូលមកក្នុងបន្ទប់នេះ? តែខ្ញុំពុំសួរថាអ្វី ដោយទុកចាំមើលគេតទៅទៀត ។ គេបានប្រាប់ខ្ញុំថា ឲ្យខ្ញុំអង្គុយចាំគេនៅក្នុងបន្ទប់នោះ រួចគេនឹងចេញទៅក្រៅបន្តិច ។

មួយសន្ទុះក្រោយមក ក្នុងខណៈដែលខ្ញុំអង្គុយឆ្ងល់តែម្នាក់ឯងនោះ លោកវរសេនីយ៍ត្រី មាស-ស្អាត ក៏ដើរចូលមករកខ្ញុំ ។ លោកបាននិយាយយ៉ាងខ្លីហើយដាច់ខាតថា ឲ្យខ្ញុំដេកនៅក្នុងបន្ទប់ដ៏ស្ងាត់នេះ កុំឲ្យអ្នកណាឃើញឲ្យសោះ ដោយលោកបានតាំងឲ្យលោកអនុសេនីយ៍ទោ ជម-ចៅ ជាអ្នកចាត់ចែងរៀបចំឲ្យបានស្រួលអស់ហើយ ។ ជាអ្នកត្រូវទទួលខុសត្រូវក្នុងរឿងនេះទៀតផង ...

ចាប់តាំងពីពេលនោះមក ខ្ញុំក៏ត្រូវលាក់ខ្លួនពួនអាត្មា នៅក្នុងបន្ទប់ដ៏តូច លើគេហដ្ឋានរបស់លោកវរសេនីយ៍ត្រី មាស-ស្អាត យ៉ាងស្ងាត់ស្ងៀម ...

## វគ្គទី ១១

# ចោរកម្ម

ព្រឹកមួយថ្ងៃនៅក្នុងខែធ្នូដ៏ស្អាត លើគេហដ្ឋានរបស់លោកវរសេនីយត្រី មាស-ស្អាត ដែលខ្ញុំត្រូវលាក់ខ្លួនក្នុងគ្រានោះ ជាពេលវេលាដ៏យូរ យូរដូចជាពេលប្រាំ-មួយឆ្នាំសំរាប់រូបខ្ញុំដែលនៅទំនេរគ្មានការអ្វី ។

ប៉ុន្តែនៅពេលល្ងាចនេះ សភាពគគ្រឹកគគ្រេងបានកើតឡើងនៅគេហដ្ឋាននេះ ។ ខ្ញុំបានដឹងដោយសារការលបសួរអនុសេនីយទោ ជម-ចៅ ថាលោកវរសេនីយត្រី មាស-ស្អាត រៀបចំចាត់ចែងពិធីជប់លៀង ដើម្បីជាការធ្វើខួបរំលឹក ក្នុងការដែលលោកត្រូវបានឡើងឋានន្តរសក្តិពិសេសជាវរសេនីយទោ ។ ខ្ញុំក៏បានលបសំដែងនូវសេចក្តីត្រេកអរចំពោះលោកវរសេនីយទោថ្មីនេះដែរ ។



វេលាម៉ោងទី ១៩ ខ្ញុំបានលបមើលឃើញភ្ញៀវទាំងឡាយជាច្រើនបានមកជួបជុំ ។ ខ្ញុំបានឃើញ យ៉ូ-យ៉ាំងញ៉ ផ្លាស់វត្តសាករ „ម៉ាខៀវយ៉ា” មកដើរកាយឡើងជាមួយនឹងគេដែរ ។ ខ្ញុំនឹកឆ្ងល់ជាខ្លាំងថា យ៉ូ-យ៉ាំងញ៉ ជាបុរសសំខាន់ក៏ដែរ បានជាលោក មាស-ស្អាត អញ្ជើញគាត់មក ។ តែមួយសន្ទុះក្រោយមក ខ្ញុំបានយល់ច្បាស់ដោយការសង្កេតឃើញ គាត់ជាអ្នកចាត់ចែងបញ្ជាពួកអ្នកបំរើឲ្យយកម្ហូបអាហារនិងភេសជ្ជៈ ។ ពិតណាស់ (ខ្ញុំគិត) យ៉ូ-យ៉ាំងញ៉នេះ ជាអ្នកទទួលខុសត្រូវម្ហូបអាហារនិងភេសជ្ជៈក្នុងពិធីជប់លៀងនេះ ។ ខ្ញុំចេះតែលបមើលគេទៅទៀត ខ្ញុំភ្ញាក់ផ្អើលក្នុងខណៈដែលខ្ញុំបានឃើញនូវសុភាពស្ត្រីម្នាក់ ។ ខ្ញុំឈ្លក់ហើយខំពិនិត្យមើលម្តងទៀត ព្រោះដូចជាពុំទុកចិត្តភ្នែកខ្លួនឯង ។ ពិតណាស់ហើយ គឺពិតជានាង ឆវី នាងឆវី ដែលធ្លាប់រួមរស់ជាមួយខ្ញុំ ។ ប្រសិនបើការ

ស្មានរបស់ខ្ញុំពុំខុសទេនោះ ខ្ញុំយល់ថាលោកមាស-ស្អាត និងនាងជរី ជាមនុស្សស្រឡាញ់គ្នា ព្រោះខ្ញុំសង្កេតឃើញអាកប្បកិរិយារបស់នាងជរីពេលនោះ ដូចជាតាំងខ្លួនជាម្ចាស់នៃផ្ទះនេះ ។ ខ្ញុំលបមើលដោយការសោបសល់ក្នុងចិត្ត ព្រោះចង់ដឹងការគេទៅទៀតថា តើអ្នកទាំងពីរនាក់ គឺលោកមាស-ស្អាត និងនាងជរី បានគ្នាជាប្តីប្រពន្ធ ឬគ្រាន់តែលបស្រឡាញ់គ្នាទេ ?

នៅវេលាម៉ោង ២១ ភ្ញៀវទាំងឡាយបានលាត្រឡប់ទៅវិញអស់នៅសល់តែលោកវរសេនីយត្រី ហង្ស-ចំរើន ម្នាក់ ដែលត្រូវជាមិត្តភក្តិជិតស្និទ្ធរបស់លោកវរសេនីយទោ មាស ស្អាត និងនាងជរី ។ ខ្ញុំបានសង្កេតឃើញលោកទាំងពីរសប្បាយរីករាយជាខ្លាំង ដោយបាននាងជរីជាអ្នកចាក់ស្រាថែម ។ លោកដូចជាស្រវឹងស្រាបន្តិចទៅហើយ ព្រោះត្រូវនាងជរីថែមស្រាញឹកពេក ។



ខ្ញុំធ្លាក់ថ្លើមៗក ក្នុងខណៈដែលខ្ញុំបានឮលោកវរសេនីយទោ មាស-ស្អាត និយាយទៅកាន់នាងជរីថា ចាក់ស្រាឲ្យបងគួនសំឡាញ់ ! ហើយឃើញលោកឱបថើបនាងបង្អួតលោកវរសេនីយត្រី ហង្ស-ចំរើន ក្រោយពេលដែលបានចាក់ស្រាជូនលោករួចហើយ ។

ពិតណាស់ក្នុងលោកនេះ គ្មានបុរសណាមួយអាចឈរមើលសភាពនារីដែលខ្លួនធ្លាប់បានរួមរ័កពីមុនមក ហើយឥឡូវនាងទៅរួមរ័កជាមួយនឹងបុរសដទៃទៀត ក្នុងទីចំពោះមុខដូច្នេះបានឡើយ ។ ខ្ញុំទ្រាំលបមើលដោយការអន្ទះសន្ទួនចិត្ត ដែលជាការពិបាកសរសេរពណ៌នា អំពីសភាពនៃចិត្តរបស់ខ្ញុំ ក្នុងខណៈនោះបាន ។ មានខណៈចិត្តខ្លះខ្ញុំចង់ឈប់ទ្រាំលបមើលព្រោះក្រែងទប់ចិត្តពុំបាន តែចិត្តមួយទៀត បែរតែជម្រុញឲ្យលបមើលទាំងញ័រជើងដៃទៅទៀត ព្រោះការចង់ដឹង...,

ប្រហែលជាកន្លះម៉ោងក្រោយមក លោកវរសេនីយត្រី ហាជ័ន្ទ - ចិវ៉េង ក៏បានលាលោកវរសេនីយទោ មាស-ស្អាត ត្រឡប់ទៅគេហដ្ឋានរបស់លោកវិញ ។ លោក មាស-ស្អាត បានជូនមិត្តសំឡាញ់របស់លោក ចុះពីលើផ្ទះ ។ ខណៈនោះខ្ញុំអរព្រោះនឹកថា លែងបានឃើញ រឿងល្ខោនដ៏គាក្រក់សកប់ក្រសែភ្នែករបស់ខ្ញុំទៀតហើយ ។ តែខ្ញុំនៅតែទាក់ទាស់ចិត្តនឹងនាង ជរី ។ ខ្ញុំនឹកឆ្ងល់ថា ហេតុអ្វីក៏នាង ជរី ពុំសំដែងការគួរសមជូនដំណើរភ្ញៀវពិសេសនេះ ដូចភ្ញៀវឯទៃផង... ខ្ញុំលបមើលតទៅទៀត ។

ខ្ញុំរំភើបចិត្តដោយការឆ្ងល់ជាខ្លាំង ។ នៅពេលដែល លោកវរសេនីយទោ មាស-ស្អាត ជូនដំណើរភ្ញៀវចេញផុតពីកន្លែងនោះបន្តិចទៅ ខ្ញុំបានឃើញនាង ជរី ស្ទុះក្អែកទៅ ចាក់សោទូដែកដែលផ្អែកទៅនឹងជញ្ជាំងខាងកើត ។ ក្នុងខណៈជាបន្ទាប់នេះ នាងបានដកយកកញ្ចប់ក្រដាសមួយកញ្ចប់



ហើយបិទសោទៅវិញភ្លាម រួចហើយនាងបោះកញ្ចប់នេះឲ្យ ទៅ យ៉ុំ-យ៉ុំ ជញ៉ី ដែលកំពុងដើរប្រមូលកែវទុកដាក់ ។

ខ្ញុំដណ្ដឹងសួរខ្លួនឯងថា នាង ជរី លួចអ្វី ? មិនថាប្រាក់ក៏ដូចជាពុំសម ព្រោះមើលទៅដូចជាមិនជាច្រើនប៉ុន្មាន ល្មមឲ្យនាងដាច់ចិត្តលួច ? របស់អ្វី ? មាសពេជ្រក៏ដូចជាពុំទំនង ព្រោះកញ្ចប់នោះមានសភាពទន់ៗ ? ក្រែងមានកិច្ចការអ្វីទេដឹង ? ឬមួយនាងជាចារនារីចាំលបលួចការអ្វីពីលោក វរសេនីយទោ មាស-ស្អាត ? ខ្ញុំនឹកព្រួចដល់ការម្យ៉ាង ដែលខ្ញុំធ្លាប់ដឹង ៗ ខ្ញុំសន្និដ្ឋានថា កញ្ចប់ក្រដាសនោះប្រហែលជាកញ្ចប់ក្រដាសពិសេសអ្វីម្យ៉ាង ឬកិច្ចការសម្ងាត់ក្នុងកងទ័ព ឬ ក៏ជាអក្សរកូនសោសម្ងាត់សម្រាប់ប្រើប្រាស់ក្នុងកងទ័ពជាពុំខាន ព្រោះលោកវរសេនីយទោ មាស-ស្អាត ត្រូវបានទទួលភារៈជាអ្នកកែអក្សរកូនសោ និងកាន់ការសម្ងាត់ក្នុងកងទ័ព ។ ក្នុងខណៈដែលខ្ញុំគិតដូច្នេះ ខ្ញុំចង់បើកទ្វារចេញ

ទៅហែកមើល តែចិត្តមួយទៀតគិតថា ប្រសិនបើកញ្ចប់ក្រ-ដាសនោះមានតម្លៃដូច្នោះមែននោះ នាង ជរី ក៏ត្រូវស្លាប់ ។ ខ្ញុំដាច់ចិត្តសម្លាប់នាងកើតឬ កាលបើនាងជានារីធ្លាប់បានលះបង់អ្វីគ្រប់បែបយ៉ាងបូជាខ្ញុំ ធ្លាប់រួមរស់ជាមួយខ្ញុំ ។ តែចិត្តមួយទៀតគិតទៅដល់អាយុជីវិតនៃប្រទេសជាតិ ... គិតដូច្នេះហើយ ខ្ញុំក៏ដាច់ចិត្តបើកទ្វារចេញទៅជួបនាង ជរី ...

បង! (នាង ជរី ហៅខ្ញុំដោយការភ្ញាក់ ព្រមទាំងឈរស្រឡាំងកាំង) បង ឬ ? (នាងហៅទៀត ហើយក៏ស្ទុះចូលមកឱបខ្ញុំ) ។

– ហ្នឹងហើយបងណា៎ ជរី ... (ខ្ញុំនិយាយ)

– ចុះក្រែងបងស្លាប់បាត់ទៅហើយ ?

– ស្លាប់ក៏ដូចជាពុំស្លាប់ដែរ ។

យ៉ឺ-យ៉ាំ ជញ្ញី ឈរស្រឡាំងកាំង សំឡឹងមើលមកយើងទាំងពីរនាក់ដោយការងឿងឆ្ងល់ ។ ក្រោយនោះភ្លាម



មួយរំពេច លោកវរសេនីយ៍ទោ មាស-ស្អាត ក៏មកដល់ដែរ ។ លោកក៏ឈរស្រឡាំងកាំង ព្រោះឃើញខ្ញុំឱបនាង ជរី ។ លោកស្ទុះចូលមករកខ្ញុំ ដោយបំណងចង់ប្រទូស-រ៉ាយ ។ ខ្ញុំរុញនាង ជរី ដាក់ពីខាងមុខ ។ ពេលនេះខ្ញុំមានចិត្តគិតមួយម៉ឺនមួយសែនចំពូក ។ ខ្ញុំគិតថា ប្រសិនបើខ្ញុំផ្ដល់ការពិតដល់លោក នាង ជរី មុខជាត្រូវស្លាប់ តែប្រសិនបើខ្ញុំពុំផ្ដល់ការពិតដល់លោកទេ នោះប្រទេសជាតិក៏ត្រូវស្លាប់ដែរ ។ ក្នុងការដែលនាង ជរី នារីដែលខ្ញុំធ្លាប់រួមរក់ត្រូវស្លាប់ និងការដែលប្រទេសជាតិត្រូវស្លាប់នោះ តើខ្ញុំត្រូវរើសយកខាងណា ខ្ញុំដូចជាពិបាកគិតយ៉ាងខ្លាំង... តែទីបំផុត ខ្ញុំក៏ដាច់ចិត្តថា ស៊ូឲ្យប្រទេសជាតិមានជីវិតរស់នៅទៅចុះ ប្រសើរជាង... ខ្ញុំបានក៏ផ្ដល់លោកវរសេនីយ៍ទោ មាស-ស្អាត យ៉ាងសុភាព ក្នុងពេលដែលនាង ជរី កំពុងតែសម្រក់ទឹកភ្នែកដាក់ដើមទ្រូងរបស់ខ្ញុំ ជាសក្ខីភាព នៃ ការសំដែងឲ្យដឹងថា

នាងបានផ្ញើអាយុជីវិតលើរូបខ្ញុំ ។

— ព្រះតេជ-គុណ សុំព្រះតេជ-គុណមេត្តាឈប់សិន កុំអាលខឹងនឹងខ្ញុំបាទ សុំមេត្តាឆែកបុរសនោះមើលសិន ដើម្បីឲ្យដឹងថា តើវាមានស្នើនៅក្នុងខ្លួនវា ?

— អញបានបញ្ជាឲ្យឯងសម្ងំដេកនៅឲ្យស្ងៀមក្នុងបន្ទប់ ហេតុអីក៏ឯងចេញមក? ហើយឯងហ៊ានខុស ឆរី ទៀតផង...

— ឆរី ធ្លាប់ជាប្រពន្ធរបស់ខ្ញុំបាទ ទានព្រោស ! តែឆរី... (គ្រាន់តែខ្ញុំនិយាយបានប៉ុណ្ណោះ នាង ឆរី ក៏ឱបខ្ញុំយ៉ាងណែន ហើយរុញច្រានទៅខាងក្រោយ ហាក់ដូចជាចង់បិទមាត់ខ្ញុំ ពុំឲ្យខ្ញុំនិយាយ ឯលោកវរសេនីយ៍ទោ មាស-ស្អាត ក៏បើកភ្នែកធំៗ សំឡឹងមើលមកខ្ញុំ ហាក់ដូចជាចង់ដឹងនូវការអ្វីម្យ៉ាង ។

— ព្រះតេជព្រះគុណ ! សុំព្រះតេជ-គុណ ឆាប់ឆែកយួននោះមើលទៅទានព្រោស...

— ឆែកវាធ្វើអ្វី ?



ផែនការសម្ងាត់ ! (ខ្ញុំនិយាយទាំងប្រថុយ ព្រោះពុំដឹងថាគញ្ចប់នោះជាគញ្ចប់អ្វីផង) ផែនការសម្ងាត់បានត្រូវគេលួចយកហើយ...

គ្រាន់តែឮពាក្យថា ផែនការសម្ងាត់ លោកវរសេនីយ៍ទោក៏ស្ទុះចូលទៅរក យួ-យ៉ាំងញ៉ូ ភ្លាមដោយពុំបានជាប្រុងប្រយ័ត្ន ។ យួ-យ៉ាំងញ៉ូ បានដាល់លោក មាស-ស្អាត មួយដៃចំថ្គាមយ៉ាងដំណំ ធ្វើឲ្យលោកដួលប្រុសនៅលើឥដ្ឋ ហើយស្ទុះរត់ចុះទៅតាមជណ្តើរ ។ ខ្ញុំរលាស់នាង ឆរី ចេញ ហើយស្ទុះរត់ទៅដាក់វាមួយជើងចំកញ្ចឹក ធ្វើឲ្យដួលបោកក្បាលទៅនឹងជញ្ជាំងផ្ទះ ហើយវាផ្ងាកមកវិញដួលរមៀលធ្លាក់តាមកាំជណ្តើរ ខ្ញុំបានជាន់កវាថែមជាប់ពុំឲ្យរមៀលតទៅទៀត ។ លោកវរសេនីយ៍ទោក៏បានក្រោករត់មកជួយទាន់ដែរ តែខណៈជាមួយគ្នានេះ ដបស្រាមួយបានហោះពីខាងលើជម្រាលមកចំក្បាលលោកវរសេនីយ៍ទោ មាស-ស្អាត ។

ខ្ញុំបានប្រាប់លោកចេញឲ្យស្រែកទៅខាងបង្កាន់ដៃជណ្ដើរ ។ ឯដបស្រានោះក៏ហោះទៅប៉ះនឹងជញ្ជាំងបែកខ្ចាយ ។ លោកវរសេនីយទោត្រូវតែឡើងទៅចាប់នាង ជរី នៅខាងលើវិញ ។ ខ្ញុំក៏ចាប់គូស យ៉ូ-យ៉ុំ ដញ៉ យកទៅខាងលើវិញដែរ ។ នៅចំពោះមុខលោកវរសេនីយទោ មាស-ស្អាត ខ្ញុំបានដកយកកញ្ចប់ក្រដាសមួយពីហោប៉ៅអាវ យ៉ូ-យ៉ុំ ដញ៉ ជូនទៅលោក ។ ខ្ញុំបានរាយការណ៍ទាំងអស់ជូនលោកស្ដាប់ ។ លោកបានបង្គាប់ឲ្យពួកទាហានដែលនៅខាងក្រោយផ្ទះចាប់ យ៉ូ-យ៉ុំ ដញ៉ និងនាង ជរី ចង ហើយឲ្យនាំយកចេញពីទីនោះទៅ ព្រមទាំងបញ្ជាឲ្យខ្ញុំចូលទៅលាក់ខ្លួនពួនអាត្មានៅក្នុងបន្ទប់ដើមវិញ ។

វគ្គទី ១២

# តើចក្រពត្តិបំបែកប្រទេសខ្មែរជាពីរបានឬ ?

ខ្ញុំក៏ចេះតែខំប្រឹងសម្ងំនៅស្ងៀម ដើម្បីលាក់ខ្លួនពួនអាត្មានៅក្នុងបន្ទប់ដ៏ស្ងាត់លើគេហដ្ឋានរបស់លោកវរសេនីយទោ មាស ស្អាត តទៅទៀត ដោយពុំដឹងថា ថ្ងៃណានឹងបានរួចខ្លួនបានចេញមុខមាត់នឹងគេ ។ ខ្ញុំនឹករឭកដល់ឪពុកម្ដាយបងប្អូននិងនាង យូរ៉េត របស់ខ្ញុំជាខ្លាំង ទាល់តែពុំអាចនឹងពណ៌នាបាន ។ ខ្ញុំនឹករហូតដល់មានពេលខ្លះ ខ្ញុំចង់លបទៅជួបនឹងអ្នកទាំងនោះ ស្ទើរតែទ្រាំនៅពុំបាន ។

ថ្ងៃមួយ គឺថ្ងៃទី ១៧ រាប់ពីថ្ងៃដែលមានកើតហេតុនៅលើគេហដ្ឋានរបស់លោកវរសេនីយទោ មាស ស្អាតនោះមក លោកវរសេនីយទោ ក៏បានហៅឲ្យខ្ញុំចេញទៅជួបនឹងលោកនៅខាងក្រៅតែពីរនាក់ ។

– លោក ! (លោកវរសេនីយទោនិយាយ) ខ្ញុំសុំ

សរសើរលោកដោយស្មោះស្ម័គ្រ ក្នុងការដែលលោកបំពេញបេសកកម្មពិសេសជូនចំពោះជាតិមាតុភូមិ ហើយឯកឧត្តមទេសរដ្ឋមន្ត្រីក្រសួងការពារប្រទេស ក៏បានផ្តាំផ្ញើឲ្យខ្ញុំសំដែងនូវអំណរគុណចំពោះលោកផងដែរ ។

— ព្រះតេជ-គុណ ! បើអញ្ចឹងបេសកកម្មរបស់ខ្ញុំបាទបានត្រូវចប់ហើយឬ ? ហើយខ្ញុំបាទអាចចេញមុខមាត់បានហើយឬពានប្រោស ?

— ហ្នឹងហើយ ! លោកអាចចេញពីទីនេះបាន ប្រសិនបើលោកចង់ចេញ តែលោកកុំអាលប្រញាប់បង្ហាញមុខមាត់ឲ្យគេឃើញច្រើនពេក ព្រោះក្រែងមានគ្រោះថ្នាក់ដល់រូបលោកនៅថ្ងៃក្រោយ ។

— បើអញ្ចឹង ខ្ញុំបាទអាចចេញទៅជួបមុខឪពុកម្តាយរបស់ខ្ញុំបាទបានឬទេពានប្រោស ?

— បាន ! លោកអាចទៅជួបឪពុកម្តាយលោកបាន តែ



សុំលោកទៅជួបយ៉ាងស្ងាត់ៗ កុំឲ្យគេឃើញច្រើនពេក ហើយខ្ញុំសុំផ្តាំលោកថា បើលោកអាចលាក់ខ្លួនពួនអាត្មាឲ្យបានយូរតទៅទៀតនោះ ក៏ជាការប្រសើរណាស់ដែរ ...

តពីនោះមក លោកវរសេនីយទោមាស ស្អាត បាននិយាយរឿងរ៉ាវពិតឲ្យខ្ញុំស្តាប់ដូចតទៅ ៖

ពួកសេ—អាតូ ដែលមានការមេរកាំងជាមេក្លោងចង់សម្លាប់ប្រទេសខ្មែរយើង ដែលប្រកាន់យកនូវមាគ៌ានយោបាយអព្យាក្រឹត ក្រោមព្រះរាជកិច្ចដឹកនាំនៃសម្តេចព្រះ នរោត្តម សីហនុ ប្រធានចលនាសង្គមរាស្ត្រនិយម ពង្រួបពង្រួមជាតិ ហើយពុំព្រមចុះចូលជាមួយនឹងពួកគេ ។ គេបានណែនាំសៀមនិងយួនខាងត្បូង ឲ្យពន្យុះផ្ដែជាកញ្ចុះរបស់គេគឺ ចាញ់ - សារី និងឈួន ឲ្យបង្កបង្កើតជាបក្ស ដោយមានពួកនេះគាំទជួយពីខាងក្រោយ នូវគ្រឿងអាវុធយុទ្ធោបករណ៍ជាច្រើនផង ។ ក្រុមចារកម្មរបស់យើងបាន

ស៊ើបការដឹងច្បាស់ថា ឈួ ឈ ប្រុងក្បត់វាយដណ្តើមយកខេត្ត សៀមរាប-កំពង់ធំ និងបាត់ដំបង ហើយប្រកាសធ្វើជារដ្ឋខ្មែរសេរី ដើម្បីវាយដណ្តើមយកអាណាចក្រកម្ពុជាទាំងមូលតទៅទៀត ពួកយើងបានស៊ើបដឹងច្បាស់ដល់ពេលវេលាដែលវាបានកំណត់ទុក ។ ដើម្បីបំភាន់គំនិតរបស់ពួកវា ឯ. ឧ. ទេស រដ្ឋមន្ត្រីក្រសួងការពារប្រទេស លោក ហង្ស-ចំរើន និងរូបខ្ញុំ បានសំរេចចិត្តថា យើងត្រូវប្រើកលល្បិចក្នុងរឿងនេះ គឺត្រូវរៀបចំផែនការសម្ងាត់មួយ ដើម្បីវាយតទប់នឹងពួកវា រួចហើយយើងត្រូវរកវិធីធ្វើឲ្យវាដឹងថា យើងប្រើវិធីនេះ តែលឿនពេលជាងពួកវាមួយថ្ងៃ ដើម្បីឲ្យពួកវាត្រាកចិត្ត ដ្បិតវាយល់ថា ផែនការរបស់វាបានត្រូវពួកយើងដឹង ហើយពួកយើងក៏មានផែនការទប់ទល់ កាលបើពួកវាបានដឹងដូច្នេះ ហើយពួកវាមុខជាប្តូរផែនការថ្មីយកមកប្រើទៀត ដើម្បីកុំឲ្យពួកយើងយកផែនការតទប់របស់យើងនោះទៅប្រើកើត ។



ប៉ុន្តែតាមពិត ពួកយើងធ្វើដូច្នេះ ក៏គ្រាន់តែជាការបន្លំដានវាតែប៉ុណ្ណោះ ព្រោះយើងធ្វើឲ្យពួកវាដឹងទៀតថាផែនការតទប់របស់ពួកយើងនោះ បានត្រូវពួកវាដឹងហើយៗ ពួកយើងនឹងពុំប្រើផែនការនោះដែរ ។ ដូច្នេះហើយ បានជាអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទរបស់យើង ត្រូវការរូបលោកឲ្យដើរតួជាអ្នកក្បត់ជាតិ លួចយកផែនការសម្ងាត់របស់យើងនោះទៅលក់ឲ្យពួកវា ដើម្បីធ្វើឲ្យពួកវាបានដឹងនូវផែនការនោះ ។ តែក្រោយមកយើងធ្វើជាចាប់យកលោកទៅប្រហារជីវិត ជាលោកក្បត់ជាតិ ដោយលួចយកផែនការសម្ងាត់របស់ពួកយើងទៅលក់ឲ្យពួកវា ដើម្បីបន្លំដានពួកវាថាផែនការសម្ងាត់របស់ពួកយើង ត្រូវបានដឹងទៅដល់ពួកវាហើយៗ យើងនឹងលែងប្រើផែនការនោះ ។ តែតាមពិត យើងយកផែនការនោះទៅប្រើដដែល គ្រាន់តែប្រើមុនពេលកំណត់បីថ្ងៃតែប៉ុណ្ណោះ ។ ដោយសារការដែលពួកយើង

ធ្វើដូច្នេះ ពួកយើងក៏បានទទួលនូវជោគជ័យជាទីពេញចិត្ត ។

ខ្ញុំបានសួរលោកវរសេនីយ៍ទោ ពីរឿងធាន ដាវី និង យ៉ូ-យ៉ាំងដញ៉ី លោកបានមានប្រសាសន៍ថា :

រួចលោកបានទទួលភារៈត្រូវតាក់តែង រៀបចំនូវអក្សរកូនសោសម្ងាត់ សម្រាប់ប្រើប្រាស់ក្នុងកងទ័ពជាតិរបស់យើង ពួកវាដឹងដូច្នោះ ក៏បញ្ជូនអ្នកតាំងពីនេះឲ្យមកធ្វើល្បិចកលលួចយកអក្សរកូនសោសម្ងាត់នោះ ទៅពិនិត្យមើលមួយជាន់ទៀត ។

ទីបំផុត លោកបាននិយាយរៀបរាប់ពីជោគជ័យ នៃល្បិចកលរបស់កងទ័ពយើងថា : កងទ័ពរបស់យើងបានវាយប្រហារខ្មាំងបានជ័យជំនះយ៉ាងស្រួល ព្រោះវាមិនដឹងខ្លួន ។ លោកបានបញ្ជាក់ថា ទាហានយើងបានព័ទ្ធចាប់បាន ប៉ុស្តិ៍វិទ្យុ និង អ្នកបច្ចេកទេសយួនពីរនាក់ ដែល ដៅ ត្រុង ហ៊ីវ អ្នកតំណាងយួនខាងត្បូងបាននាំមក ដោយបន្លំឈ្មោះជាចិន



កំពុងតែប្រតិបត្តិការក្បត់ជាមួយ ស្វ៊ិយា-ឈ ប៉ ឈិតជាប្អូនថ្លៃរបស់ឈួន ព្រមទាំងមាសចំនួនជាងពីរយោគឡូផង ។ ចំណែក ដាប-ឈួន វាបានរត់ចេញទៅតែខោមួយបន្ទះ ហើយក៏ត្រូវពួកទាហានយើងដេញតាម សម្លាប់បានទៅ ស្រណូយទៅ ។

លោកបានបញ្ជាក់ថា ដាប-ឈួន សម-សារី ហ៊ានធ្វើដូច្នេះ មកពីសំអាងដល់ការគាំទ្រនៃឧត្តមនាវីអាមេរិកាំងនាម ហ្វិល្ត (Amiral Felt) នៃឧត្តមសេនីយ ឡាវសុន កុល ឡាំង (Général Lawson-Collins) នៃវរសេនីយឯក ឡង់ស្ដាល (Colonel Landsdale) នៃឧត្តមនាវីហុបវុត (Amiral Hopwood) និងនៃលិខិតរបស់លោកប្រធានាធិបតី អាយស៊ិនហាវ័រ (Eisenhower) ដែលអះអាងនូវគំរោងការក្បត់កំចាត់សម្ដេច ព្រះនរោត្តម សីហនុ និងអព្យាក្រឹតភាពខ្មែរ ធ្វើជាសាធារណរដ្ឋកម្ពុជាសេរីមួយថ្មី ។

× ×
×

ខ្ញុំបានជំរាបលាលោកវរសេនីយ៍ទោមាស-ស្អាត ទៅរកឪពុកម្ដាយខ្ញុំ ក្រោយដែលលោកបាននិយាយរឿងរ៉ាវចប់សព្វគ្រប់ហើយ ។

— សុំឲ្យបានសេចក្ដីសុខចំរើន! (លោកឲ្យពរសព្វសាធុការដល់ខ្ញុំ ព្រមទាំងហុចកញ្ចប់មួយឲ្យខ្ញុំ) នេះជាប្រាក់មួយសែនរៀល ដែលអគ្គសេនាធិការរបស់យើង បានឲ្យជារង្វាន់ដល់លោក — សុំលោកយកទៅចាត់ចែង ចាយវាយតាមត្រូវការ ហើយលោកនឹងត្រូវបានឡើងសក្តិជាអនុសេនីយ-ឯក ប៉ុន្តែលោកអាចឈប់សំរាក ៦ ខែ ឬ ១ ឆ្នាំសិនចុះ ទំរាំពេលណាដែលអគ្គសេនាធិការត្រូវការរូបលោក សុំគេហៅមក ...

ខ្ញុំបានទទួលយកកញ្ចប់ប្រាក់នោះពីដៃលោក ហើយក៏លាលោកម្ដងទៀត ។

ខ្ញុំបានជិះគ្រឿងយន្តហោះទៅផ្ទះខ្ញុំ ។ ខ្ញុំមើល



នាឡិកាដៃឃើញម៉ោង ២២ ហើយ ខ្ញុំនឹកអរព្រួច ព្រោះពេលវេលានេះជាពេលស្ងាត់ ដែលខ្ញុំអាចលបទៅជួបនឹងឪពុកម្ដាយរបស់ខ្ញុំបានដោយស្រួល ព្រោះបងប្អូនខិនក្មួយ ៗ គេដេកលក់អស់ហើយ ។

ខ្ញុំបានចូលទៅជួបនឹងម្ដាយរបស់ខ្ញុំ ដែលកំពុងតែអង្គុយសូត្រធម៌ក្នុងទីងងឹតតែម្នាក់ឯង ។ ម្ដាយខ្ញុំភ្ញាក់ព្រើតរៀបនឹងស្រែកឡូឡាឡើង ដោយការភិតភ័យព្រោះលោកគិតថាជាខ្មោចបិសាចរបស់ខ្ញុំទៅលងលោក តែខ្ញុំនិយាយកាត់ទាន់

— ម៉ែ! សុំម៉ែកុំភិតភ័យអ្វី.. ខ្ញុំមកវិញហើយ!

— កូន! កូនឬ?... (ម្ដាយរបស់ខ្ញុំនិយាយតែប៉ុណ្ណេះ ហើយក៏ឱបខ្ញុំជាប់)

— បាទខ្ញុំ!... ខ្ញុំមកវិញហើយ...

— ចុះក្រែងកូនស្លាប់ហើយ...?

— ទេម៉ែ! កូននៅពុំទាន់ស្លាប់ទេ... ចុះប៉ានៅឯណា

– ខុះ ! ... នៅឯក្នុងឯណោះ ។

ម្ដាយខ្ញុំគិតក្រោកទៅបើកភ្លើងអគ្គិសនីបំភ្លឺ តែខ្ញុំបាន សុំកុំឲ្យបើក ព្រោះក្រែងពួកក្មេងៗដឹង ជាហេតុនាំឲ្យ បែកការ ។ ម្ដាយខ្ញុំបានដឹកដៃខ្ញុំទាំងទឹកភ្នែកទៅរកឪពុកខ្ញុំ នៅឯក្នុងបន្ទប់ ។

ខ្ញុំពុំអាចនឹករកពាក្យណា យកមកសរសេរឲ្យសមតាម សេចក្ដីត្រេកអរនៃឪពុកម្ដាយរបស់ខ្ញុំ នៅពេលដែលលោក បានជួបមុខខ្ញុំវិញ ព្រោះលោកបានគិតថាគ្មានសង្ឃឹមនឹងបាន ជួបនោះឡើយ ។ ខ្ញុំសង្កេតឃើញលោកទាំងពីរនិយាយ មករកខ្ញុំ ដោយការប្រោសប្រណីដែលមានទឹកភ្នែកជាសក្ខី ភាព នៃសេចក្ដីមេត្តាករុណា ។

យប់នេះ យើងស្ទើរតែពុំបានដេក ព្រោះរវល់តែសំណេះ សំណាលរឿងផ្សេងៗក្នុងជីវិត ដែលមើលទៅម្ដាយខ្ញុំដូចជា និយាយច្រើនជាងគេ ព្រោះលោកចេះតែចង់ដឹងពុំចេះអស់



ពុំចេះហើយសោះ ។

នៅយប់ទីពីរ ខ្ញុំបានលបទៅជួបនឹង សុ១.សម្បូរ ដែលជាមិត្តសំឡាញ់ស្មោះដោយជីវិតរបស់ខ្ញុំ ដើម្បីសាកសួរ ដំណឹងពីនាង យូរ៉េត នារីជាទីស្នេហារបស់ខ្ញុំ ។

ខ្ញុំស្រងាកចិត្ត នៅពេលដែលបានឮសុ១.សម្បូរ និ-យាយប្រាប់ថា គេបានទទួលសំបុត្រមួយច្បាប់ពីនាង យូរ៉េត ក្រោយពេលដែលខ្ញុំត្រូវគេយកទៅប្រហារជីវិត ប្រហែលជា ប្រាំពីរប្រាំបីថ្ងៃ ។ ក្នុងសំបុត្រនោះ នាងបានសរសេរ រៀបរាប់យ៉ាងវែងឆ្ងាយពីជីវិតអភ័ព្វរបស់នាងដែលគ្មានទីពឹងទី សង្ឃឹម ។ នាងបានសុំលាគេដោយគ្មានថ្ងៃសង្ឃឹមថានឹង បានឃើញមុខគ្នាទៀត ដោយនាងត្រូវដើរផ្សងព្រេងទៅរក កន្លែងថ្មី ហើយនាងបានបួងសួងឲ្យវិញ្ញាណក្ខន្ធរបស់ខ្ញុំ ដែល នាងជឿជាក់ថា ខ្ញុំស្លាប់មែននោះ ទៅនៅរង់ចាំនាងនាជាតិ ខាងមុខ ។

សុខ-សម្បុរ បានទំលើកកកាយរកសំបុត្ររបស់នាង យូរ៉េត នោះយកមកឲ្យខ្ញុំអានដែរ តែរកពុំឃើញសោះ ព្រោះពុំដឹងជាគេប្រឡៀដៃទុកនៅត្រង់ណា ។

សុខ-សម្បុរ ក៏ដូចជាខ្ញុំដែរ យើងបានសន្និដ្ឋានថា នាង យូរ៉េត ពេលនេះមុខជាចេញផុតពីភូមិ ពោធិហ្នស្ត្រី ទៅហើយ តែថានាងទៅនៅឯណានោះ ក៏ជាការពិបាកនឹងដឹងដល់ដែរ ។

សេចក្តីទុក្ខក្រៀមក្រំបានគ្របសង្កត់លើបេះដូងរបស់ខ្ញុំ យ៉ាងធ្ងន់ ។ ខ្ញុំគិតថា ការដែលនាង យូរ៉េត ដើរចេញលែង នៅស្រុក ពោធិហ្នស្ត្រី នោះ ព្រោះនាងជឿជាក់ថា ខ្ញុំស្លាប់ ពិតប្រាកដមែនទុះឯង ។

ខ្ញុំបានលា សុខ-សម្បុរ ត្រឡប់ទៅផ្ទះវិញទាំងក្រៀមក្រំ ។ នៅតាមផ្លូវ ខ្ញុំចេះតែនឹកស្រមៃដល់នាង យូរ៉េត ។ ខ្ញុំនឹកនាងជាខ្លាំង ខ្លាំងពាល់តែខ្ញុំសំរេចចិត្តថា ខ្ញុំត្រូវតែធ្វើ



ដំណើរទៅស្រុក ពោធិហ្នស្ត្រី ថ្ងៃស្អែកនេះ ទោះបីជួបនាង ក៏ដោយពុំជួបក៏ដោយ ឲ្យតែបានទៅដល់ទីកន្លែងដែលនាង ធ្លាប់នៅនោះ ខ្ញុំនឹងបានធូរស្បើយរំហើយទុក្ខខ្លះៗ ជាពុំខាន ។

យប់នេះ ខ្ញុំបានចូលទៅជំរាបលាឪពុកម្តាយខ្ញុំ ។ ដំបូង លោកពុំចង់ឲ្យខ្ញុំទៅណាឆ្ងាយពីលោកឡើយ ។ ខ្ញុំព្យាយាម អធិប្បាយជំរាបលោកថា ពេលនេះ ខ្ញុំក៏នៅពុំទាន់ចេញមុខ មាត់បាន បើទុកជានៅទីនេះក៏គ្មានប្រយោជន៍អ្វីដែរ ហើយ សព្វថ្ងៃនេះ ខ្ញុំមានការធុញទ្រាន់នឹងជីវិតក្នុងទីក្រុងជាខ្លាំង ខ្ញុំ មានបំណងចង់ចេញទៅសម្រាកកាយសម្រាកចិត្ត នៅឯស្រុក ស្រែចំការ ហើយស្រុកស្រែចំការដែលខ្ញុំជ្រើសរើសនោះ គឺ ស្រុក ពោធិហ្នស្ត្រី ព្រោះស្រុកនោះខ្ញុំមានមិត្តភក្តិកប់អាន ស្គាល់គេច្រើនផង ។ កាលបើខ្ញុំចង្អុលហេតុផលយ៉ាងនេះ លោកក៏ព្រមអនុញ្ញាតឲ្យខ្ញុំទៅ ។

– សុំកូនរក្សាខ្លួនប្រាណឲ្យល្អណាកូន ! (ម្តាយរបស់

ខ្ញុំបានផ្តាំ) ម៉ែសង្ឃឹមថា កូនអាចមករកម៉ែវិញ ឲ្យម៉ែបានជួបមុខកូនទៀតជាពុំខាន ។

— កូន ! (ឪពុករបស់ខ្ញុំសួរ) កូនឯងទៅប៉ុន្មានថ្ងៃ ?

— ពុំកំណត់ទេប៉ា ! បើទីនោះស្រួលខ្ញុំក៏ចេះតែនៅឯណោះ ព្រោះពុំចង់ឲ្យអ្នកណាឃើញមុខមាត់ តែយូរៗខ្ញុំគង់នឹងមកលេងម្តង —

— កូន ! (ម្ដាយរបស់ខ្ញុំឆ្លើយឡើង) សុំកូនកុំទៅយូរពេកណា៎ ឆាប់មកវិញ ...

ព្រឹកស្អែកឡើង ខ្ញុំក៏សំពះលាឪពុកម្ដាយធ្វើដំណើរទៅបាត់ដំបង តាមរថភ្លើង ដើម្បីទៅកាន់ស្រុកពោធិហ្ស្រ្តី ។

ខ្ញុំព្រាំនៅភូមិ ពោធិហ្ស្រ្តី នេះ ទាំងទុក្ខក្រៀមក្រំ ព្រោះពុំបានជួបនឹងនាង យូរ៉ែត របស់ខ្ញុំ ។

មីង ជែម នាងសាម៉ុង ជាម្ចាស់ផ្ទះដែលនាង យូរ៉ែត



សំណាក់នៅ បាននិយាយប្រាប់ខ្ញុំពីរឿងនាង យូរ៉ែត យ៉ាងល្អិតល្អន់ ... និយាយពីរឿងដែលនាងមានសេចក្ដីទុក្ខសោក ... អស់សង្ឃឹម នៅពេលដែលនាងបានដឹងតាមសារពត៌មាន នឹងវិទ្យុថា ខ្ញុំត្រូវគេប្រហារជីវិតព្រោះរឿងក្បត់ជាតិ ... និយាយពីការដែលនាងបានចេញចាកស្រុកពោធិហ្ស្រ្តី នេះដោយឥតបានប្រាប់គេថា នាងទៅទៅទីណាពិតប្រាកដ តែនាងបានបញ្ចេញចេតនាយ៉ាងខ្លាំងថា នាងចង់ទៅប្រទេសសៀម ប្រសិនបើនាងអាចទៅបាន ព្រោះនាងមានបងប្អូនម្នាក់នៅក្រុងបាងកក ...

# ជំពូកទី ៣

## វគ្គទី ១៣

## តើឪពុកបំបែកកូនពីគូស្នេហាបានឬ ?

ខ្ញុំបានកំណត់ពេលទុកថា បីថ្ងៃទៀតនឹងត្រឡប់ទៅភ្នំពេញវិញ ...

ប៉ុន្តែនៅថ្ងៃទី ២ នៃការកំណត់នេះ ខ្ញុំបានទទួលដំណឹងថ្មីមួយតាមទូរលេខពីឪពុករបស់ខ្ញុំ ... ដំណឹងនេះជាដំណឹងកាចសាហាវ ជាដំណឹងដែលដូចជាមានអានុភាពកាប់ចូលទៅកាត់ផ្តាច់ទ្រូងនិងបេះដូងរបស់ខ្ញុំ ... គឺដំណឹងអំពីការអនិច្ចកម្មនៃម្តាយរបស់ខ្ញុំ ... ឪពុករបស់ខ្ញុំបានប្រាប់ថាម្តាយរបស់ខ្ញុំបានស្លាប់តាំងពីម្សិលមិញដោយរោគដាច់សរសៃឈាម ...

សេចក្តីទុក្ខសោករបស់ខ្ញុំក្នុងពេលនេះ ដូចជាមានទំហំធំ



ហួសវិស័យនឹងពណ៌នាដូចម្តេចបាន ... ខ្ញុំត្រូវសម្ងំនៅស្ងៀមស្ងាត់បណ្តោយពេលវេលាឲ្យកន្លងផុតទៅតាមអំពើចិត្តនៃអារម្មណ៍ដែលពោរពេញដោយសេចក្តីទុក្ខសោកនោះ ...

លុះដល់ថ្ងៃត្រូវត្រឡប់ទៅភ្នំពេញវិញ ខ្ញុំក៏ប្រែចិត្ត គិតថាប្រសិនបើម្តាយរបស់ខ្ញុំគ្រាន់តែមានជម្ងឺធ្ងន់ នៅពុំទាន់ស្លាប់ទេនោះ ខ្ញុំក៏គួរតែប្រញាប់ប្រញាល់ត្រឡប់ទៅឲ្យទាន់ដង្ហើម តែនេះលោកស្លាប់ផុតទៅហើយ បើទុកជាខ្ញុំត្រឡប់ទៅវិញក៏គ្មានប្រយោជន៍អ្វី ក្រៅពីការរឹងរិតតែនាំឲ្យមានទុក្ខសោកធ្ងន់ទៀតឡើយ ។ លុះគិតដូច្នេះហើយ ខ្ញុំក៏សំរេចចិត្តថា ត្រូវតែសម្ងំនៅទីនោះបន្តិចទៀតសិន ដើម្បីឲ្យបានធូរស្រាលនូវសេចក្តីទុក្ខក្រៀមក្រំ ។

ប្រាំថ្ងៃក្រោយពេលបានទទួលដំណឹងមរណភាពនៃម្តាយរបស់ខ្ញុំនៅភូមិពោធិឃ្លស្រី បានកន្លងផុតទៅជាប់ដោយសេចក្តីទុក្ខសោកក្រៀមក្រំសំកប់រូបខ្ញុំ ខ្ញុំក៏មានគំនិតថ្មីមួយ

ផុសឡើងថា កាលម្ដាយរបស់ខ្ញុំមានជីវិតរស់នៅឡើយ រឿងប្រពន្ធកូនរបស់ខ្ញុំនោះ គឺស្រេចនៅលើលោកជាអ្នកចាត់ចែង គឺថាបើលោកពេញចិត្តនារីណា ខ្ញុំត្រូវតែចូលចិត្តតាមខានពុំបាន ។ ការដែលធ្វើយ៉ាងនេះ ខ្ញុំក៏ឥតមានអាក់អន់ចិត្តអ្វីនឹងលោកដែរ ព្រោះម្ដាយខ្ញុំនៅកាន់ទម្លាប់បូរាណ ដែលពុំបានបើកសិទ្ធិឲ្យបុត្ររើសគូតាមចិត្តរបស់ខ្លួនឡើយ ។ ឯឪពុករបស់ខ្ញុំវិញពុំជាការអ្វីទេ លោកមុខជាយល់ដល់ចិត្តថ្លើមរបស់ខ្ញុំខ្លះៗជាពុំខាន ព្រោះលោកក៏ជាប្រុសដូចខ្ញុំដែរ ហើយមានការសិក្សាចេះដឹងគួរសមផង ។ ខ្ញុំគិតថា បើទុកជាយ៉ាងណា ក៏ខ្ញុំអាចអង្វរករលោកបាន ។ លុះគិតដូច្នេះហើយ ខ្ញុំក៏សំរេចខ្លួនឯងថា នឹងធ្វើដំណើរទៅតាមនាង យូរើត របស់ខ្ញុំ ។

ខ្ញុំបានលាកស្ញូរម៉ើង ចែម និងនាង សាម៉ុឌ ពីអាសយដ្ឋានរបស់នាង យូរើត នៅទីក្រុងបាងកក ។ គេធ្វើយ



ថាគេក៏ពុំបានដឹងដែរ ដោយដឹងត្រឹមតែថា នាងមានឪពុកមាម្នាក់ធ្វើការនៅក្នុងក្រសួងការបរទេសនៃប្រទេសថៃ ។ គេបានបញ្ជាក់ថា ប្រសិនបើនាង យូរើត ទៅបាងកកមែននោះ នាងមុខជាទៅនៅជាមួយនឹងឪពុកមាដែលឈ្មោះ ឌីរ៉ែដ នោះ ។

មួយសប្ដាហ៍ក្រោយមក ខ្ញុំក៏ប្រថុយធ្វើដំណើរទៅក្រុងបាងកកតែម្នាក់ឯង ដោយពុំបានប្រាប់ឲ្យអ្នកណាដឹងសោះឡើយ សូម្បីតែម៉ើង ចែម ជាម្ចាស់ផ្ទះនេះ ក៏ខ្ញុំពុំបានជំរាបឲ្យដឹងដែរ ។

លុះទៅដល់ក្រុងបាងកក ខ្ញុំក៏បានទៅសំណាក់នៅសណ្ឋាគារដ៏តូច ហើយស្នាក់នៅសួនលំ, នៅជិតស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំក្រុងបាងកក ។ ខ្ញុំពុំបានបណ្ដោយពេលវេលាឲ្យកន្លងផុតទៅដោយឥតប្រយោជន៍ ក្នុងការស៊ើបសួររកនាង យូរើត របស់ខ្ញុំឡើយ ។ បីថ្ងៃនៅក្រុងបាងកក ខ្ញុំបានទៅរកផ្ទះលោក ឌីរ៉ែដ ឃើញ ហើយខ្ញុំបានជួបនាង

យូរ៉េត របស់ខ្ញុំនៅទីនោះ ។

ខ្ញុំពុំអាចអធិប្បាយដល់ទឹកចិត្តរបស់ខ្ញុំនិងនាង យូរ៉េត ក្នុងពេលនោះបានឡើយ ... ក្នុងពេលដែលគេប្រាប់នាងថា មានមនុស្សមករកនាងនោះ នាងក៏ដូចជាឆ្ងល់ តែលុះនាងចេញដើរមកជិតខ្ញុំ នាងក៏ឈរសំឡឹងមើលមុខខ្ញុំស្រឡាំងកាំង ដោយឥតមាននិយាយស្ដីថាអ្វី ... បើតាមខ្ញុំស្មានថាដោយសារការត្រេកអរខ្លាំងពេក នាងពុំអាចហានិយាយស្ដីអ្វីរួច ... ខ្ញុំក៏ចាប់ផ្ដើមសួរនាងមុនថា :

— យូរ៉េត អូន ! អូនបានសុខសប្បាយជាទេ ?

— ចា៎ស ! ពុំសូវជាសុខសប្បាយប៉ុន្មានទេ ...

— ម៉េចអញ្ចឹង ?

— ប៉ុន្មានថ្ងៃមកនេះហើយ ខ្ញុំដូចជាបានធូរស្បើយសប្បាយរីករាយចង្អិតទៅហើយ តែលុះមកឃើញមុខបង ចិត្តក៏ដូចជាលែងសប្បាយរីករាយដូចថ្ងៃមុន ប្រែទៅជាក្រៀមក្រំទៅវិញ ។



— ម៉េចក៏ យូរ៉េត និយាយអញ្ចឹង ?

— ក៏ព្រោះខ្ញុំបានជួបមុខមនុស្សដែលខ្ញុំស្រឡាញ់ ដែលខ្ញុំពុំបានទឹកនាសោះថានឹងបានជួប – មនុស្សដែលខ្ញុំស្រឡាញ់នោះ បានធ្វើគុណប្រយោជន៍ដល់រូបខ្ញុំជាច្រើន ដែលខ្ញុំបានចងចាំទុកក្នុងចិត្តជានិច្ចថា ខ្ញុំពុំអាចបំភ្លេចគុណគេចោលបានក្នុងមួយជីវិតនេះ – ខ្ញុំបានលះបង់អ្វីគ្រប់យ៉ាង ដើម្បីជូនជាគុណបំណាច់មនុស្សនោះ – ទីបំផុតខ្ញុំសុខចិត្តលះបង់សេចក្ដីស្នេហាដ៏ធំរបស់ខ្ញុំចំពោះមនុស្សនោះ ដើម្បីអនាគតរបស់គេ– ហើយតមកខ្ញុំបានឮដំណឹងយ៉ាងក្រៀមក្រំថា មនុស្សដែលខ្ញុំស្រឡាញ់ស្មើដោយជីវិតនោះ ត្រូវស្លាប់ផុតបង់ជីវិតទៅហើយ ដែលជាការរឹតតែធ្វើឲ្យខ្ញុំមានជីវិតរស់នៅពោរពេញដោយការទុក្ខសោកនិងអស់សង្ឃឹម ...

ខ្ញុំបានអធិប្បាយរឿងរ៉ាវទាំងអស់ប្រាប់នាង យូរ៉េត រហូតដល់រឿងមរណភាពនៃម្ដាយរបស់ខ្ញុំ ... ខ្ញុំបានប្រាប់

នាងថា ខ្ញុំនៅមានសង្ឃឹមថា ឪពុករបស់ខ្ញុំមុខជាបណ្ដោយតាមចិត្តរបស់ខ្ញុំក្នុងរឿងនេះជាពុំខាន . . . ទីបំផុត ខ្ញុំបានប្រាប់នាងថា :

– គ្មានអ្វីណាចម្លែកក្នុងលោកនេះ ក្រៅពីសេចក្ដីស្លាប់ អាចមកពង្រាត់បម្រាស់យើងទាំងពីរ ឲ្យព្រាត់ប្រាស់ទុកស ចាកចេញពីគ្នាបានឡើយ . . .

នាង យូរ៉េត ក៏ពុំនិយាយស្ដីអ្វី . . . នាងអង្គុយសម្រក់ទឹកភ្នែកនៅចំពោះមុខខ្ញុំ . . .

តពីនោះមកប្រាំថ្ងៃ ខ្ញុំក៏លែងសំណាក់នៅលើសណ្ឋាគារ សួនលំ ។ ខ្ញុំបានទៅជួលផ្ទះនៅ ហើយបាននាំនាង យូរ៉េត ទៅនៅជាមួយ ។

ខ្ញុំបានផ្ញើសំបុត្រទៅជម្រាបឪពុករបស់ខ្ញុំនូវហេតុការណ៍ទាំងអស់ ។ ជាពិសេសខ្ញុំបានជំរាបអំពីរឿងនាង យូរ៉េត និងខ្លួនខ្ញុំយ៉ាងល្អិតល្អន់ ។ ខ្ញុំបានសុំអង្វរករលោកឲ្យលោក



មេត្តាយល់ព្រមតាមខ្ញុំ គឺសុំឲ្យលោកព្រមទទួលយកនាង យូរ៉េត ធ្វើជាកូនប្រសា ដែលក្នុងពេលពុំយូរប៉ុន្មាន ខ្ញុំនឹងត្រូវនាំនាងត្រឡប់ទៅស្រុកខ្មែរវិញ ។

ចាប់តាំងពីពេលនោះមក ខ្ញុំក៏បានប្រកបការងារចិញ្ចឹមជីវិតគ្រប់បែបយ៉ាង ដែលខ្ញុំអាចធ្វើបាន ហើយយើងក៏មានជីវភាពយ៉ាងចង្អៀត ។

ប្រហែលជាបីខែក្រោយមក ខ្ញុំបានទទួលដំណឹងតាមសំបុត្រពីឪពុករបស់ខ្ញុំមួយច្បាប់ ។ ដំណឹងនេះជាដំណឹងអាក្រក់សំរាប់រូបខ្ញុំ ប៉ុន្តែយ៉ាងហោចណាស់ ក៏ជាដំណឹងដ៏អាក្រក់សំរាប់ឪពុកដែលផ្ញើមកកូនដែរ ព្រោះគេកកបានសរសេរផ្ញើមកពាំងសេចក្ដីតាមនស្សៀជាខ្លាំងចំពោះរូបខ្ញុំ ដែលហ៊ានតាមស្ត្រីដល់ក្រុងបាងកក ។ លោកបានបញ្ជាក់ត្រង់ចំណុចខាងចុងថា លោកនឹងពុំព្រមឲ្យខ្ញុំយកនាង យូរ៉េត ធ្វើជាប្រពន្ធជាដាច់ខាត ។ មិនតែប៉ុណ្ណោះ លោកបាន

និយាយយ៉ាងដាច់ខាតទៀតថា ឲ្យខ្ញុំត្រឡប់ទៅស្រុកវិញយ៉ាងដាច់ ហើយត្រឡប់ទៅតែម្នាក់ឯង ដើម្បីរៀបចំខ្លួនប្រាណ រៀបមង្គលការតាមបណ្ដាំម្ដាយរបស់ខ្ញុំ ។ នាង យូរ៉េត នោះត្រូវតែលែងលះគ្នាឲ្យជ្រះស្រឡះទៅ ។

បញ្ហានេះជាបញ្ហាដ៏សំខាន់សំរាប់រូបខ្ញុំ ជាបញ្ហាដែលខ្ញុំពុំហ៊ានប្រាប់ឲ្យនាង យូរ៉េត ដឹងឡើយ ព្រោះកាលដើមខ្ញុំបានប្រាប់នាងថា សំរាប់ឪពុករបស់ខ្ញុំនោះពុំជាអ្វីប៉ុន្មានទេ បើអង្វរករលោកយូរៗទៅ លោកមុខជាយល់ព្រមតាមជាពុំខាន..., ហើយខ្ញុំបានតាំងបញ្ឈក់ប្រាប់នាងថា នៅមានសង្ឃឹមនឹងអង្វរករឪពុករបស់ខ្ញុំបានទៀតផង – តែឥឡូវដល់រឿងកើតប្រែដូច្នេះ ខ្ញុំក៏ពុំហ៊ានប្រាប់នាងឲ្យដឹងឡើយ...

ពេលនេះ សំរាប់រូបខ្ញុំវិញ ខ្ញុំក៏ពុំអាចលះបង់នាងយូរ៉េតចោល ហើយត្រឡប់ទៅស្រុកវិញតែម្នាក់ឯងបានឡើយ... សូម្បីតែត្រូវបែកគ្នាមួយពេលមួយគ្រាសិនក៏ដោយ ក៏ខ្ញុំដូច



ជាធ្វើពុំកើតដែរ... ការនេះប្រែសេចក្ដីថា ខ្ញុំពុំអាចត្រឡប់ទៅស្រុកវិញតែម្នាក់ឯងបានទេ ប្រសិនបើឪពុករបស់ខ្ញុំ ពុំយល់ព្រមតាមពាក្យអង្វររបស់ខ្ញុំ...

ខ្ញុំបានសរសេរសំបុត្រផ្ញើទៅជូនឪពុករបស់ខ្ញុំវិញ ដោយបាននិយាយពន្យល់ហេតុផលគ្រប់យ៉ាងជូនលោកស្ដាប់ ។ ខ្ញុំយល់ថា ការឆ្លើយឆ្លងគ្នាតាមផ្លូវសំបុត្ររវាងខ្ញុំនិងឪពុករបស់ខ្ញុំនោះត្រូវប្រើពេលយូរបន្តិច ។

យើងនៅរួមរស់ជាមួយគ្នាដោយសេចក្ដីសុខ នៅក្នុងគេហដ្ឋានមួយដ៏តូច ដែលតាំងនៅលើផ្លូវដ៏ធំគួរសម តែដាច់ស្រយាលពីគេនៅជាយក្រុង ។ យើងមានស្ត្រីបំរើម្នាក់ ដែលល្មមឲ្យសេចក្ដីសុខ តែសេចក្ដីសុខនេះជាសេចក្ដីសុខដែលខ្ញុំពុំអាចដឹងថា នឹងអាចឋិតថេរបើកាលយើងយូរទៅបានអស់ពេលត្រឹមណា...

ឪពុករបស់ខ្ញុំ ពុំបានសរសេរសំបុត្រឆ្លើយមកខ្ញុំវិញភ្លាមទេ..

ការដែលលោកពុំសរសេរឆ្លើយភ្លាមដូច្នេះ គឺប្រហែលជាលោកខឹងសម្បានឹងខ្ញុំខ្លាំងណាស់ ហើយចង់កាត់កាល់ខ្ញុំចោលក៏ពុំដឹង តែសំរាប់រូបខ្ញុំវិញ ខ្ញុំគ្មានខឹងសម្បាអ្វីនឹងលោកឡើយ ... ខ្ញុំគិតថាប្រសិនបើលោកខឹងនឹងខ្ញុំនោះ ក៏គួរនឹងហេតុមែន ព្រោះបើឧបមាថារូបខ្ញុំជាឪពុក ហើយមានកូនដែលខ្លួនខ្ញុំបានថ្នាក់ថ្នមចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំ ដោយបានទំនុកបំរុងឲ្យរៀនសូត្រទាល់តែបានចេះដឹងប៉ុណ្ណេះ ហើយទីបំផុតកូននោះពុំស្តាប់បង្គាប់ខ្ញុំជាឪពុកនោះ ក៏គួរឲ្យខ្ញុំខឹងនឹងវាដែរ ... តែយ៉ាងណាក៏ដោយចុះ ខ្ញុំក៏នៅតែមានសង្ឃឹមថា ឪពុករបស់ខ្ញុំក៏មុខជាយល់ព្រមតាមពាក្យអង្វរកររបស់ខ្ញុំជាពុំខាន ...

ក្រោយពីពេលនោះបន្តិចមកនាង យូរ៉េត បានប្រាប់ខ្ញុំថា នាងមានផ្ទៃពោះជាងពីរខែមកហើយ ។ ដំណឹងនេះបានធ្វើឲ្យខ្ញុំរឹងរឹតតែធ្ងន់ចិត្តឡើងទៀត ។



ពិតណាស់ហើយ កូនដែលនឹងត្រូវកើតមកនោះ មុខជានឹងក្លាយទៅជាចំណងសំរាប់ចងកខ្ញុំ ឲ្យរឹងរឹតតែតឹងឡើងទៀត លើពាក្យប្តេជ្ញាដែលយើងបានសន្យាចំពោះមុខគ្នាថា នឹងពុំព្រមឲ្យអំណាចអ្វីមួយក្នុងលោកមកពង្រាត់បម្រាស់យើងបានក្រៅពីសេចក្តីស្លាប់នោះឡើយ ... ប៉ុន្តែជួនកាលកូនដែលនឹងត្រូវកើតមកនេះ ក៏អាចជាប្រយោជន៍ដល់យើងខ្លះដែរ ព្រោះប្រសិនបើឪពុករបស់ខ្ញុំបានជ្រាបថា ឥឡូវនេះនាង យូរ៉េត មានផ្ទៃពោះហើយនោះ លោកមុខជាមានចិត្តទោរទន់អាណិតអាសូរខ្លះៗជាពុំខាន ... ខ្ញុំបានសរសេរសំបុត្រទៅជំរាបលោកថា ពេលនេះលោកឪពុកកំពុងតែក្លាយខ្លួនទៅជាជីតារបស់ទារកម្នាក់ដែលកើតពីនាងយូរ៉េត ព្រោះសព្វថ្ងៃនេះ នាងកំពុងតែមានផ្ទៃពោះ ... ខ្ញុំបានអង្វរករលោកថា ប្រសិនបើលោកឪពុកពុំអាណិតអាសូរនាងយូរ៉េតទេនោះ ក៏សូមឲ្យអាណិតតែទារកដែលកំពុងតែប្រុងប្រៀប

ខ្លួនចេញមកបើកភ្នែកមើលពិភពលោក ហើយដែលក៏ជាសាច់ឈាមរបស់លោកឪពុកដោយពិតៗនោះផងទៅចុះ...

ក្នុងពេលនោះ ខ្ញុំថ្នាក់ថ្នមនាង យូរ៉េត ដូចកែវភ្នែក ឬ ដូចកែវនៃជីវិត... ខ្ញុំជឿជាក់ថាកូនដែលនឹងត្រូវកើតមកនេះ មុខតែពុំមែនជាកូនដែលមានសភាពទន់ខ្សោយ ឬ ល្ងង់ខ្លៅឡើយ... ឯនាង យូរ៉េត វិញ ក៏បានប្រព្រឹត្តខ្លួនជាប្រពន្ធដ៏ល្អជាទីបំផុត... ខ្ញុំពុំដែលមានប្រពន្ធ ខ្ញុំពុំអាចលើកយកនាងទៅប្រៀបធៀបនឹងអ្នកណាឲ្យសមឡើយ តែប្រសិនបើពិនិត្យគិតថា នៅមានអ្វីខ្វះទៀតដែលខ្ញុំត្រូវការពីនាង យូរ៉េត ហើយនៅពុំទាន់បាននោះ ខ្ញុំក៏ដូចជានឹករកពុំឃើញ ព្រោះសព្វថ្ងៃ ខ្ញុំមានអ្វីគ្រប់បែបគ្រប់យ៉ាង ត្រូវតាមសេចក្តីប្រាថ្នាទាំងអស់... រូបខ្ញុំក្នុងពេលនេះដូចជាត្រូវតាមពុទ្ធដីការបស់ព្រះសង្ឃដែលតែងប្រទានពរថា "សូមឲ្យសេចក្តីប្រាថ្នាទាំងឡាយ ទាំងពួងបានសំរេចដល់អ្នក" ។



មានពេលច្រើនដងណាស់ ដែលនាង យូរ៉េត សួរខ្ញុំ កាលណាយើងនឹងត្រឡប់ទៅស្រុកវិញ? សំនួរនេះបានធ្វើឲ្យខ្ញុំពិបាកចិត្តជាខ្លាំង ព្រោះខ្ញុំពុំដឹងជាឆ្លើយប្រាប់នាងវិញជាដូចម្តេច... ខ្ញុំពុំអាចឆ្លើយប្រាប់នាងវិញថា ឪពុករបស់ខ្ញុំពុំព្រមទទួលយកនាងធ្វើជាកូនប្រសា ឬ ក៏ខ្ញុំបានទទួលសំបុត្ររបស់ឪពុកខ្ញុំ ដែលមានពាក្យបណ្តាំថា ឲ្យខ្ញុំត្រឡប់ទៅស្រុកវិញតែម្នាក់ឯង ឬ ក៏អ្វីៗដែលពុំមែនជាដំណឹងល្អសម្រាប់រូបនាងនោះបានឡើយ... ខ្ញុំគិតថា ខណៈនេះនាងកំពុងតែមានផ្ទៃពោះ – កូនដែលឋិតនៅក្នុងពោះរបស់នាងនោះ ជាជីវិតទីពីររបស់ខ្ញុំ... កូននេះនឹងអាក្រក់ឬល្អ ក៏ស្រេចនៅលើសភាពដួងចិត្តរបស់ម្តាយ ក្នុងពេលមានទម្ងន់ ព្រោះតែរឿងនេះ វាមានការទាក់ទងគ្នាសំខាន់ណាស់..

ប៉ុន្តែកាលបើនាងចេះតែសួររឿយៗ ខ្ញុំក៏ត្រូវរកពាក្យដោះសារផ្សេងៗដែរ... ខ្ញុំបានប្រាប់នាងថា ខ្ញុំដូចជាលែង

បងត្រឡប់ទៅស្រុកវិញហើយ ព្រោះការរកស៊ីចិញ្ចឹមជីវិតសព្វថ្ងៃនេះ គឺដូចជាបានចំរើនគួរសមដែរ...

— បើអញ្ចឹង (នាន់ យូរ៉េតនិយាយ) គឺប្រែសេចក្ដីថារូបអូនជាអ្នកទំលាយនូវអនាគតរបស់បង ...

— សុំអូនកុំនិយាយអញ្ចឹង យើងអាចគិតថា នេះជាការប្រែប្រួលនៃជីវិតទៅចុះ ...

បួនខែបានកន្លងផុតទៅទៀត ប្រសិនបើគិតពីពេលដែលខ្ញុំបានសរសេរសំបុត្រទៅជំរាបឪពុករបស់ខ្ញុំថា នាន់ យូរ៉េត មានផ្ទៃពោះនោះ ខ្ញុំក៏បានទទួលនូវសំបុត្ររបស់ឪពុកខ្ញុំមួយច្បាប់ទៀត ។ សំបុត្រនេះក៏ពុំបានធ្វើឲ្យស្ថានភាពការណ៍ផ្លាស់ប្ដូរប្រែប្រួលទៅជាយ៉ាងណាឡើយ ព្រោះឪពុករបស់ខ្ញុំនៅតែប្រកាន់យ៉ាងម៉ឺងម៉ាត់ថា លោកនៅតែពុំព្រមទទួលយកនាន់ យូរ៉េត ធ្វើជាកូនប្រសាដដែល សូម្បីនាន់មានកូនប៉ុន្មាននាក់ហើយក៏ដោយ ។ ក្រៅពីនោះ លោកនៅតែប្រាថ្នាឲ្យខ្ញុំត្រឡប់



ទៅស្រុកវិញ ដើម្បីរៀបការជាមួយនារីម្នាក់ដែលលោកបានផ្ដាំផ្ញើទុកឲ្យ តាមបណ្ដាំម្ដាយរបស់ខ្ញុំ ហើយលោកឲ្យត្រឡប់ទៅវិញតែម្នាក់ឯង ពុំព្រមឲ្យយកនាន់ យូរ៉េត ឬ កូនទៅជាមួយផងឡើយ ។

តាមពិត ឪពុករបស់ខ្ញុំក៏ពុំអាចរារាំង ឬ ហាមឃាត់ពុំឲ្យយកនាន់ យូរ៉េត ទៅជាមួយផងនោះបានឡើយ ខ្ញុំអាចនាំយកនាន់ទៅលាក់ទុកនៅកន្លែងណាមួយក៏បាន ដោយពុំឲ្យលោកដឹង តែប្រសិនបើខ្ញុំធ្វើដូច្នេះទៅ ផលអាក្រក់នឹងកើតឡើងដល់នាន់យ៉ាងណា ! ខ្ញុំគិតថា ថ្ងៃណាមួយនាន់មុខជាដឹងថា ឪពុកក្មេកនាន់ពុំព្រមទទួលយកនាន់ឲ្យចូលជាសមាជិកគ្រួសារ ហើយពេលនោះនាន់មុខជាមានសេចក្ដីទុក្ខទោមនស្សយ៉ាងខ្លាំង ។ ពិសេសជាងនោះទៅទៀត ប្រសិនបើខ្ញុំត្រូវរៀបការជាមួយនឹងនារីណាម្នាក់ទៀតនោះ ផលអាក្រក់យ៉ាងខ្លាំងគឺមុខជាកើតឡើងដល់នាន់ យូរ៉េត យ៉ាងពិត

ប្រាកដ គិតដូច្នេះហើយ ខ្ញុំក៏បានសរសេរសំបុត្រផ្ដាំសារ ផ្ញើទៅជូនលោកឪពុកខ្ញុំទៀត ក្នុងការដែលខ្ញុំនៅពុំទាន់បានត្រឡប់ទៅស្រុកវិញនោះថា ដោយសារតែពេលនេះ នាង យូរ៉េត កំពុងតែមានផ្ទៃពោះនោះ បានជាខ្ញុំពុំអាចលះបង់នាងបាន ។ ខ្ញុំបានអង្វរករលោកថា សូមឲ្យខ្ញុំបាននៅជាមួយនាង ទាល់តែដល់ពេលដែលនាងបានសម្រាលកូនរួចសិន ឬក៏ទុកពេលឲ្យខ្ញុំចាត់ការរៀបចំឲ្យនាង យូរ៉េត មានមុខរបរកស៊ីចិញ្ចឹមជីវិតឲ្យបានស្រួលបួលសមគួរដល់អត្តភាពសិននោះ ខ្ញុំនឹងត្រឡប់ទៅស្រុកវិញភ្លាម ។

ចាប់តាំងពីពេលនោះមក ខ្ញុំក៏លែងបានទទួលសំបុត្រ ឬដំណឹងអ្វីពីឪពុករបស់ខ្ញុំទៀតសោះ ។

ឥឡូវនាង យូរ៉េត បានសំរាលកូនហើយៗ ជាកូនប្រុសផង ។ ខ្ញុំពុំអាចអធិប្បាយអំពីមនោសញ្ចេតនារបស់ខ្ញុំឲ្យច្បាស់លាស់ជាលាយលក្ខអក្សរបានឡើយ ... សភាពនៃ



ទឹកចិត្តដែលដឹងខ្លួនថាជាឪពុក ឪពុកដែលមានកូនកើតមកដោយឈាមមួយដុំរបស់ខ្លួននោះ បានធ្វើឲ្យខ្ញុំមានសេចក្ដីត្រេកអររីករាយយ៉ាងលើសលប់រកអ្វីប្រៀបគ្មាន ... ជាសេចក្ដីស្នេហាដែលខ្ញុំពុំធ្លាប់មានពុំធ្លាប់ដឹងមកពីពេលមុនឡើយ ... ការបានមាសប្រាក់ ការប្រឡងជាប់ជាដើមទាំងនេះ ក៏បានធ្វើឲ្យខ្ញុំត្រេកអររីករាយសប្បាយចិត្តជាខ្លាំង ឬក៏ការបានជួបនឹងនាង យូរ៉េត វិញនោះ ក៏បានធ្វើឲ្យខ្ញុំត្រេកអររីករាយសប្បាយចិត្តខ្លាំងណាស់ដែរ តែការត្រេកអរឬរីករាយសប្បាយចិត្តទាំងនោះ ក៏នៅតែពុំទាន់ដែលជ្រួតជ្រាបដូចការត្រេកអរនឹងរីករាយសប្បាយចិត្ត ក្នុងពេលដែលខ្ញុំបានកូនប្រុសមួយនេះដែរ សូម្បីរូបខ្ញុំជាអ្នកសរសេររឿងក៏ខ្ញុំពុំអាចបរិយាយឲ្យបានច្បាស់លាស់ ថាការត្រេកអរ នឹងសេចក្ដីរីករាយសប្បាយចិត្តនោះ មានសភាពយ៉ាងណាឡើយ ...

ក្នុងពេលជាមួយគ្នានេះ ខ្ញុំបាននឹកទៅដល់ឪពុករបស់ខ្ញុំ

ជាលោកប្រហែលជាត្រេកអរីករាយសប្បាយស្រឡាញ់ខ្ញុំ ដូចខ្ញុំស្រឡាញ់កូនខ្ញុំដែរនៅពេលដែលខ្ញុំកើត ... បើដូច្នោះជាការសមគួរ ឬ ដែលខ្ញុំរឹងទទឹងនឹងលោក ជំទាស់នឹងលោកក្នុងការដែលលោកបានសំដែងនូវសេចក្ដីប្រាថ្នា យ៉ាងខ្លាំងក្លាថា ឲ្យខ្ញុំលះបង់ចោលនាង យូវ៉េត លះបង់ចោលកូនហើយត្រឡប់ទៅស្រុកវិញតែម្នាក់ឯង ?... ឧបមាថា កូនរបស់ខ្ញុំដែលទើបនឹងកើតនេះ កាលបើវាធំឡើងវានឹងទទឹងជំទាស់នឹងបំណងល្អរបស់ខ្ញុំ វាមិនទៅយកប្រពន្ធតាមទំនើងវាវិញនោះ តើខ្ញុំនឹងធ្វើយ៉ាងណា ?...

ខ្ញុំពិបាកចិត្តជាខ្លាំង ... ខ្ញុំគិតថា រូបខ្ញុំហាក់ដូចជាត្រូវឋិតនៅក្នុងចន្លោះថ្មជាដ៏ធំពីរដុំ ដែលកំពុងតែរមៀលទិតចូលជិតគ្នាមកសង្កត់ខ្ញុំ... ម្ខាងឪពុក ម្ខាងទៀតកូន! ... ខ្ញុំពុំដឹងជាគេចទៅខាងណាឡើយ... ក្នុងមួយជីវិតរបស់ខ្ញុំនេះ ខ្ញុំពុំដែលមានពេលណាពាល់ត្រូវដូចជាពេលនេះសោះឡើយ ...



ខ្ញុំបានសរសេរសំបុត្រជំរាបឪពុករបស់ខ្ញុំមួយច្បាប់ទៀតថា ឥឡូវនេះ នាង យូវ៉េត បានសំរាលកូនហើយៗ កូននេះជាប្រុសទៀតផង ៗ ខ្ញុំបានជំរាបលោកថា ខ្ញុំពុំចាំបាច់អធិប្បាយដល់មនោសញ្ចេតនារបស់ខ្ញុំ ថា យ៉ាងណាឡើយព្រោះខ្ញុំជឿជាក់ថា នៅពេលខ្ញុំកើតនោះ លោកឪពុកក៏ត្រេកអរីករាយសប្បាយចិត្ត ហើយស្រឡាញ់កូនរកអ្វីប្រៀបស្មើពុំបានដែរ ហើយប្រសិនបើពេលនោះមានអំណាចបន្ទើទៅពង្រាត់បម្រាស់លោកឪពុកពីកូនឲ្យព្រាត់ប្រាសបែកខ្ញែកចេញពីគ្នានោះ លោកឪពុកមុខជាមានទុក្ខទោមនស្សជាខ្លាំងដែរខ្ញុំជឿជាក់ថាលោកឪពុកមុខជាមិនប្រថុយស្លាប់ ដោយពុំព្រមព្រាត់ពីកូនឡើយ ឯឋានៈរបស់ខ្ញុំក្នុងពេលនេះ គឺដូចគ្នានឹងលោកឪពុកដែរ គឺខ្ញុំពុំអាចបែកចេញពីកូនខ្ញុំបានទេ សូម្បីខ្ញុំបានសន្យានឹងលោកឪពុកថា កាលបើនាងយូវ៉េតសំរាលកូនរួចកាលៈហើយនោះ ខ្ញុំក៏នឹងលះបង់នាងចោល តែឥឡូវនេះ

ខ្ញុំនៅពុំទាន់ដាច់ចិត្តបោះបង់នាងចោលបានឡើយ ព្រោះពីមុនខ្ញុំមានត្រឹមតែចំណងដៃ តែឥឡូវខ្ញុំមានចំណងកបន្ថែមមកមួយជាន់ទៀត ។ ដោយសារចំណងទាំងពីរនេះតឹងណែនជាប់ពេក ខ្ញុំក៏ពុំដឹងជានឹងស្រាយដូចម្ដេចបាន ដើម្បីឲ្យបានវិលត្រឡប់ទៅស្រុកវិញ ។

រឿងរ៉ាវទាំងអស់នេះ បានធ្វើឲ្យខ្ញុំពិបាកចិត្តជាខ្លាំង ព្រោះខ្ញុំត្រូវគិតតែម្នាក់ឯង ត្រូវសំរេចចិត្តតែម្នាក់ឯង ដោយខ្ញុំពុំអាចនិយាយប្រាប់ឲ្យនាង យូរ៉េត ដឹងបានឡើយ ព្រោះនាងទើបនឹងសំរាលកូនថ្មីៗ សរសៃនៅខ្ចី នាងនៅត្រូវការក្ដៅខ្លួនក្នុងដំណេកនៅឡើយ ម្ល៉ោះហើយខ្ញុំត្រូវតែប្រយ័ត្នប្រយែងជាទីបំផុត ដើម្បីកុំឲ្យមានរឿងរ៉ាវអ្វីពុំល្អប៉ះទង្គិចដល់ទឹកចិត្តនាងជាដាច់ខាត ។

ខ្ញុំស្រឡាញ់កូនប្រុសរបស់ខ្ញុំយ៉ាងពេញចិត្តជាខ្លាំង ។ វាជាក្មេងស្អាតបាតពុំដូចខ្ញុំទេ តែវាដូចម្ដាយរបស់វា ។



កាលបើថ្ងៃនឹងយប់ចេះតែកន្លងទៅ វាក៏ចេះតែចំរើនធំឡើងគ្រប់ៗខណៈដែរ ។ ខ្ញុំបានដាក់ឈ្មោះវាថា យូរ៉ា ដោយយកឈ្មោះម្ដាយនឹងឪពុកមកផ្សំគ្នា - ព្រោះវាជាជុំឈាម ជាដួងកែវជីវិតនិងជាដួងចិត្តរបស់យើងទាំងពីរនាក់ ។

ដោយសារការនឹកដល់សភាពពុំទៀងទាត់នៃសង្ខារ និងដោយសារការយល់ព្រមពីនាង យូរ៉េត ផងនោះ ខ្ញុំក៏បានទៅធានាជីវិតរបស់ខ្ញុំទុកជាប្រាក់ចំនួន បីសែនបាត (ប្រហែលជាប្រាំសែនរៀលនៃប្រាក់ខ្មែរ) ។ ក្នុងការធានានេះ មានកិច្ចសន្យាថា ប្រសិនបើខ្ញុំស្លាប់ដោយគ្រោះថ្នាក់ ក្រុមហ៊ុនដែលទទួលធានារ៉ាប់រងនឹងត្រូវសងប្រាក់បីសែនបាតនេះដល់នាង យូរ៉េត ឬដល់ យូរ៉ា ជាកូនរបស់ខ្ញុំ ។

ប្រាំបីខែបានកន្លងផុតទៅ យូរ៉ា កូនប្រុសរបស់ខ្ញុំ ក៏មានអាយុប្រាំបីខែដែរ ។ ស្ថានការណ៍ក៏គ្មានអ្វីផ្លាស់ប្ដូរប្រែប្រួលដែរ ។ ជីវិតក្នុងគ្រួសាររបស់យើងក៏បានប្រព្រឹត្តទៅ

ដូចជាឆ្មា ។ ដូចដែលយើងនិយាយថា ល្មមប្រព្រឹត្តទៅបាន ព្រោះមុខរបររកស៊ីចិញ្ចឹមជីវិតរបស់យើង ក៏បានចំរើននូវសមដែរ រហូតដល់មានប្រាក់កាសយកទៅធានាជីវិត ។

ណាង យូរ៉េត បានធ្វើខ្លួនជាប្រពន្ធដ៏ល្អជាទីស្រឡាញ់ពេញចិត្តរបស់ខ្ញុំរហូតមក ។ យើងពុំដែលទាស់ទែងខ្វែងគំនិតគ្នា ឬ ឈ្លោះប្រកែកគ្នាសោះឡើយ ។ យើងតែងស្រុះស្រួលជាមួយគ្នាជានិច្ច ហាក់ដូចជា បេះដូងពីរត្រូវយកមកផ្គុំគ្នានៅក្នុងដើមទ្រូងតែមួយ ។

តាំងពីនោះមក ខ្ញុំបានទិញរថយន្តមួយ ។ ការទិញរថយន្តនេះពុំមែនដើម្បីហ៊ឺហាទេ តែដើម្បីទុកសំរាប់ប្រើការចាំបាច់ ព្រោះខ្ញុំនៅជាយក្រុង ប្រសិនបើប្រពន្ធកូនឈឺថ្កាត់ ខ្ញុំអាចទៅតាមគ្រូពេទ្យបានទាន់ហ័ស ។ រថយន្តដែលខ្ញុំទិញនេះ ជារថយន្តតូចជំនំ ដែលមានតម្លៃយ៉ាងថោកគួរសម ។

ពេលនេះ ខ្ញុំពុំដែលបានទទួលសំបុត្រ ឬ ដំណឹងអ្វីពី



ឪពុករបស់ខ្ញុំទេ ។ ខ្ញុំចេះតែនឹកព្រួយថា ក្រែងលោះលោកមានជម្ងឺដំកាត់ ឬ អន្តរាយអ្វីបានជាបាត់ដំណឹងយ៉ាងនេះ ។

ខ្ញុំគិតម្យ៉ាងទៀតថា បើពុំដូច្នោះទេ ក៏ប្រហែលជាលោកកាត់កាល់ខ្ញុំចោល លែងនឹកនាខ្ញុំថាជាកូនទៀត ព្រោះឪពុករបស់ខ្ញុំពុំមែនមានកូនតែរូបខ្ញុំម្នាក់ឯងទេ នៅមានបងប្រុសរបស់ខ្ញុំម្នាក់ និងប្អូនស្រី-ប្រុសរបស់ខ្ញុំពីរនាក់ទៀត ។

## វគ្គទី ១៨

# កិច្ចការពិសេស

ខ្ញុំប្រះតែនៅក្រុងកន្លែងដើមនោះរហូតមក ព្រោះខ្ញុំគិតថា ដូចជាគ្មានហេតុការណ៍អ្វីដែលខ្លួនត្រូវផ្លាស់ប្តូរទីកន្លែងឡើយ ។

ថ្ងៃមួយ ខ្ញុំបានទទួលសំបុត្រមួយច្បាប់ ពីអ្នកចាំរើសណ្ឋាគារ រតនៈកោស៊ិន នៅក្រុងបាងកក ។ នៅពេលដែលខ្ញុំអានសេចក្តីនៃសំបុត្រនោះ ខ្លួនរបស់ខ្ញុំត្រជាក់ស្រឹប – ដៃទាំងពីរញាប់ញ័រ ។

ឪពុករបស់ខ្ញុំ បានអញ្ជើញមកដល់ក្រុងបាងកកហើយ លោកបានសំណាក់នៅសណ្ឋាគារនោះ ក្នុងសំបុត្រលោកបានប្រាប់ឲ្យខ្ញុំចូលទៅជួបនឹងលោកជាប្រញាប់ ។

ពេលនោះជាពេលយប់ ខានយូរ៉ែត កំពុងតែប្រឡែង



លេងជាមួយកូននៅក្នុងបន្ទប់ដេក ។ ខ្ញុំបានប្រាប់នាងថា ខ្ញុំត្រូវទៅទីក្រុងចង្កិប ព្រោះមានធុរៈសំខាន់ផ្ទាល់ខ្លួន ។ នាងបានផ្តាំខ្ញុំថា បើហាងលក់ដូរអីក៏នៅពុំទាន់បិទទ្វារទេ សូមទិញរបស់សំពត់ក្មេងលេងយកមកផ្ញើកូនផង ។ ខ្ញុំនឹកតែក្នុងចិត្តថាការនេះស្រួលដែរ ព្រឹកស្អែកខ្ញុំនឹងនាំកូនយកទៅបង្ហាញជីតាគាត់ ។ ខ្ញុំគិតទៀតថា បើទុកជាជីតាគាត់មានចិត្តរឹងយ៉ាងណា ក៏គង់តែអាណិតអាសូរចៅខ្លះៗ ជាពុំខាន ។ កាលបើជីតាបានជួបមុខចៅក្នុងពេលដែលចៅចេះសើចចេះការយ៉ាងនេះ ក៏មុខជាស្រឡាញ់ហើយចង់ដៃរបស់អ្វីមួយដ៏មានតម្លៃឲ្យចៅពុំលែង ។

ខ្ញុំពុំបាននឹកនាថា ឪពុករបស់ខ្ញុំមកតាមខ្ញុំដល់ក្រុងបាងកកដូច្នេះសោះ ។ ខ្ញុំក៏ដូចជានៅពុំទាន់ជឿថាឪពុករបស់ខ្ញុំមកតាមខ្ញុំពិតប្រាកដនៅឡើយទេ ប៉ុន្តែដើម្បីបញ្ជាក់ឲ្យដឹងពិតប្រាកដ ខ្ញុំបានទៅសុំមើលបញ្ជីនៃអ្នកសំណាក់សណ្ឋាគារ

មើល ៗ ខ្ញុំឃើញមានឈ្មោះឪពុករបស់ខ្ញុំមែន ៗ លោកពុំមែនអញ្ជើញមកម្នាក់ឯងទេ មានទាំងបងប្រុសរបស់ខ្ញុំមកជាមួយផង ៗ

ការមកដល់ដែលធ្វើឲ្យខ្ញុំទឹកប្លែកក្នុងចិត្តនោះ គឺក្នុងបញ្ជីនៃអ្នកសំណាក់នោះ ឪពុកខ្ញុំនិងបងប្រុសខ្ញុំ បានចូលមកតាំងពីប្រាំថ្ងៃមកហើយ ពុំមែនទើបមកដល់ទេ ៗ ខ្ញុំមានសេចក្ដីសង្ស័យជាខ្លាំង ព្រោះថា លោកត្រូវប្រើពេលវេលាស៊ើបសួររកខ្ញុំនោះ ក៏ដូចជាពុំមែនដែរ ព្រោះខ្ញុំបានជំរាបអាសយដ្ឋានដល់លោកតាមផ្លូវលិខិតយ៉ាងច្បាស់លាស់ណាស់ ៗ លោកធ្លាប់បានការខ្ញុំសំបុត្រផ្ញើមកខ្ញុំយ៉ាងត្រឹមត្រូវ ចុះហេតុអ្វីក៏បានជាលោកទើបនឹងប្រើគេយកសំបុត្រទៅឲ្យខ្ញុំ ? រឿងនេះក៏ដូចជារឿងដែលមានគាបិកំបាំងបិទមុខ គួរឲ្យពិចារណានឹងថាពុំមែនឪពុកខ្ញុំក៏ថាពុំបាន ព្រោះក្នុងបញ្ជីចុះឈ្មោះសំណាក់នៅសណ្ឋាគារ ខ្ញុំស្គាល់ច្បាស់ថាហត្ថលេខារបស់លោក



ប្រាកដណាស់ ហើយហត្ថលេខាមួយទៀត ក៏ពិតជាហត្ថលេខារបស់បងប្រុសខ្ញុំដែរ ៗ

ខ្ញុំមើលលេខបន្ទប់ហើយក៏ឡើងទៅរកលោក ៗ ខ្ញុំបានជួបនឹងឪពុករបស់ខ្ញុំ និងបងប្រុសរបស់ខ្ញុំមែន ៗ ខ្ញុំបានធ្វើគារវកិច្ចចំពោះលោក ហើយក៏សួរទៅនឹងបងប្រុសរបស់ខ្ញុំ ៗ បងប្រុសរបស់ខ្ញុំបានស្ទាបអង្អែលខ្លួនខ្ញុំយ៉ាងថ្នាក់ថ្នមជាទីបំផុត ខ្ញុំបានអង្គុយចុះទៅលើកៅអីមួយ ហើយក៏ចាប់ផ្ដើមសួរឪពុកខ្ញុំថា ៖

– ប៉ា ! ប៉ាមកសំណាក់នៅហូតែលនេះប្រាំថ្ងៃហើយឬ ?

– ម៉េចក៏ឯងដឹង ?

– ខ្ញុំបានបើកបញ្ជីហូតែលមើលនៅខាងក្រោមអម្បាញ់មិញហ្នឹងឯង

– ហ្នឹងហើយ ! ប៉ាមកសំណាក់នៅកន្លែងនេះប្រាំថ្ងៃហើយ

– ចុះម៉ែចក៏ប៉ា ទើបតែឲ្យដំណឹងទៅខ្ញុំបាទក្នុងថ្ងៃនេះ អញ្ចឹង ?

– ព្រោះប៉ាដឹងថា កូនឯងពុំចង់ជួបនឹងប៉ា ប៉ាចេះតែទៅស្ទាក់ស្ទើរបេកចិត្ត ទីបំផុតក៏ដាច់ចិត្តឲ្យគេទៅតាមកូនឯងមក

– ម៉ែចក៏ប៉ាប្រាប់ថា ខ្ញុំបាទពុំចង់ជួបប៉ា ?

– ចុះបើកូនឯងចង់ជួបនឹងប៉ាមែន ម៉េចក៏ពុំត្រឡប់ទៅស្រុកវិញ ?

– ខ្ញុំបាទ ចង់ត្រឡប់ទៅស្រុកវិញណាស់ ! ខ្ញុំបាទ នឹងត្រឡប់ទៅវិញភ្លាម បើប៉ាមេត្តាអនុញ្ញាតឲ្យខ្ញុំបាទ នាំយកប្រពន្ធកូនទៅជាមួយផង

– ចុះបើប៉ាពុំព្រមអនុញ្ញាត កូនឯងពុំព្រមត្រឡប់ទៅវិញដែរ – អញ្ចឹងឬ ?

– ប៉ា ? រឿងនេះខ្ញុំបាទ ក៏ពុំដឹងជាឆ្លើយយ៉ាងម៉េចទេ ព្រោះអ៊ី យូរ៉េត ក៏បានជាជ្រួលខ្លួនជាប្រពន្ធខ្ញុំបាទ ហួសទៅ



ហើយ ។ ឥឡូវត្រូលដល់ទៅមានកូនទៀតផង ។

– បើអញ្ចឹង កូនឯងស្រឡាញ់មី យូរ៉េត ជាងស្រឡាញ់ឪពុកឯង មែនទេ ?

– ខ្ញុំបាទ នឹងទៅនាំយកប្រពន្ធខ្ញុំបាទ ឲ្យមកជំរាបសួរប៉ា . . .

– កុំ ! កុំ ! មិនបានទេ – ប៉ាមិនត្រូវការជួបនឹងវាទេ

– ប៉ា (ខ្ញុំនិយាយបន្ទប់) ស្អែកខ្ញុំបាទ និងនាំកូនខ្ញុំបាទ ឲ្យមកជំរាបសួរជីតាវ . . .

– ទេ ! ទេ ! កុំនាំវាមក វាពុំមែនជាចៅអញទេ

– ប៉ា ! កូនរបស់ខ្ញុំបាទ ម្ដេចក៏ពុំត្រូវជាចៅរបស់ប៉ា ?

– មិនមែនចៅអញទេ ព្រោះវាមិនមែនជាកូនដែលកើតមកពីមនុស្សដែលអញត្រូវការឲ្យវាកើត – អញមិនទទួលស្គាល់វាថាជាចៅអញទេ

– ប៉ា ចុះម៉េចក៏ប៉ាមានប្រសាសន៍អញ្ចឹង !

– ព្រោះអញបានដណ្ដឹងកូនគេម្នាក់ ទុកឲ្យឯងរួចទៅហើយ ។ គេជាមនុស្សដែលមានចរិយាសណ្ដាប់ធ្នាប់ល្អគ្រប់បែប គ្រប់យ៉ាង – ឯងចង់ដឹងថានាងនោះជានរណាទេ ?

– ទេ ណ្ហើយចុះប៉ា កុំប្រាប់ខ្ញុំបាទ ធ្វើអ្វី ខ្ញុំបាទអត់ចង់ដឹងទេ

– តែកូនឯងត្រូវតែត្រឡប់ទៅស្រុកវិញ

– បាទ ប៉ា ខ្ញុំបាទ នឹងត្រឡប់ទៅវិញជាមួយប៉ា

– តែឯងត្រូវទៅតែម្នាក់ឯង ប្រពន្ធកូនយកទៅមិនបានទេ

– ចុះប៉ាឲ្យខ្ញុំបាទ ចោលប្រពន្ធកូនរបស់ខ្ញុំបាទ យ៉ាងដូចម្ដេចកើត សូម្បីតែប៉ាក៏នៅតែចោលខ្ញុំបាទពុំកើត ប៉ាស៊ូពិបាកអញ្ជើញមកតាមខ្ញុំបាទដល់បាងកកនេះ ក៏ព្រោះខ្ញុំបាទ ជាកូនប៉ា – បើអញ្ចឹងម៉េចក៏ប៉ាឲ្យខ្ញុំបាទ ចោលប្រពន្ធកូនរបស់ខ្ញុំទៅវិញ ?



– តែក្នុងពេលនេះ អញត្រូវតែនាំឯងទៅវិញ គឺត្រូវប្រើអំណាច បើនិយាយរៀងទៅ ឯងចេះតែមានលេសហារដោះសារជានិច្ច – ឯងមានហេតុផលរបស់ឯង អញក៏មានហេតុផលរបស់អញដែរ – ដរាបណាអញនៅមានជីវិត ដរាបនោះអញគឺនៅជាឪរបស់ឯងដែរ អញមានអំណាចលើឯងជាកូន – អញមិនចង់ប្រើអំណាចទេ តែបើមានការចាំបាច់ត្រូវអញប្រើអំណាចក៏ប្រើដែរ . . .

– ប៉ា ឲ្យខ្ញុំបាទធ្វើម៉េច ?

– ត្រូវទៅជិះយន្តហោះត្រឡប់ទៅស្រុកវិញជាមួយអញ នៅពេលព្រឹកស្អែកនេះ

– ប៉ា ទិញសំបុត្ររួចហើយឬ ?

– អញចាត់ចែងទិញរួចស្រេចអស់ហើយ

– ចុះ លិខិតឆ្លងដែន ?

– អញ ធ្វើរួចហើយ

– បើអញ្ចឹង ខ្ញុំបាទសុំទៅប្រាប់ប្រពន្ធកូនសិន

– មិនបានទេ! ឯងនឹងចេញពីបន្ទប់នេះមិនបានដាច់ខាត មុនពេលឡើងយន្តហោះ

– បើអញ្ចឹង ខ្ញុំបាទសុំឲ្យអ្នកបំរើហូតែលទៅហៅប្រពន្ធកូនខ្ញុំបាទមកកន្លែងនេះ

– មិនបាន! មិនបាច់ជួបគ្នា ហើយលាគ្នាទេ – ទៅឡើងយន្តហោះស្ងៀមៗតែម្តងទៅ

– បាទ – ម៉េចក៏បាទធ្វើអញ្ចឹង!

– ព្រោះគ្មានផ្លូវអីក្រៅអំពីនេះ អញនិយាយស្រួលមកយូរហើយ គ្មានបានផលប្រយោជន៍អីសោះ – ពេលនេះអញត្រូវធ្វើដូច្នេះ – អាសាច់មួយដុំ បើនឹងបោះចោលឲ្យឆ្កែស៊ីទៅក៏ដូចជានៅស្តាយ – បំណាច់អញខំមកតាមប៉ុណ្ណេះហើយ អញត្រូវតែនាំឯងទៅវិញឲ្យទាល់តែបាន – អញមកម្នាក់ឯងក្រែងចាប់ឯងពុំឈ្នះ បានជាអញនាំបងប្រុសឯងមកជាមួយ



ផង – បើឯងមិនព្រមឡើងយន្តហោះទេ អញនឹងបងឯងក៏ត្រូវតែចាប់ឯងម្នាក់ម្ខាងអូសទៅឲ្យខានតែបាន – បើឯងហ៊ានតតាំងនឹងអញជាដាច់ឯងក៏តាមចិត្តឯងទៅចុះ ឬបើឯងហ៊ានស្រែកឡូឡាឲ្យគេម្រួតចាប់អញនឹងបងឯងនោះ ក៏ស្រេចតែចិត្តឯងទៅចុះ តែពាក្យដាច់ខាតរបស់អញគឺមិនព្រមឲ្យឯងចេញពីបន្ទប់ហូតែលនេះមុនពេលឡើងយន្តហោះ

– ចុះធ្វើម៉េច នឹងឲ្យប្រពន្ធកូនរបស់ខ្ញុំបាទ បានដឹងផងបាទ?

– ឯងសរសេរសំបុត្រឲ្យដំណឹងទៅក៏ទៅ អញឲ្យអ្នកបំរើហូតែលយកទៅឲ្យក៏តាំងសំបុត្រតាំងឡាន ។

ឪពុករបស់ខ្ញុំបានបង្ខាប់បងប្រុសរបស់ខ្ញុំឲ្យចាត់ចែងរៀបចំអីវ៉ាន់ ។ ខណៈនោះ បងប្រុសរបស់ខ្ញុំក៏ដើរចេញទៅក្រៅបាត់ទៅ ។ ឪពុករបស់ខ្ញុំក៏ក្រោកដើរទៅចាក់សោបន្ទប់ ហើយក៏ដកកូនសោយកទៅដាក់ក្នុងហោប៉ៅអាវរបស់លោក ។

— កូន! (ឪពុករបស់ខ្ញុំនិយាយ) បើកូនឯងមិនចង់ផ្ដើម កូនសោពីឆ្នាំ ហើយចាក់សោបើកទ្វារគេចេញទៅក៏បាន តែឆ្នាំបានសំរេចចិត្តថា បើឆ្នាំនៅពុំទាន់ស្លាប់ទេនោះ កូនឯងមិនដណ្ដើមយកកូនសោនេះ ពុំបានជាដាច់ខាត ...

ពិតណាស់ហើយ ខ្ញុំមុខជាពុំហ៊ានដណ្ដើមយកកូនសោនោះឡើយ ។ ខណៈនោះខ្ញុំគិតថា បើទុកជាខ្ញុំខំនិយាយអង្វរករឪពុករបស់ខ្ញុំយ៉ាងណាក៏ពុំមានបានផលអ្វីដែរ ព្រោះខ្ញុំធ្លាប់បានដឹងនិស្ស័យចិត្តថ្មើមរបស់លោក ប្រសិនបើលោកតាំងចិត្តធ្វើអ្វីហើយ ក៏គ្មានអ្វីទៅជំទាស់លោកបានឡើយ ។

ការដែលខ្ញុំត្រូវធ្វើគង់ពេលនេះ ក៏មានតែមួយគត់គឺ ត្រូវសរសេរសំបុត្រឲ្យដំណឹងទៅនាង យូរ៉េត តាមសេចក្ដីអនុញ្ញាតពីឪពុករបស់ខ្ញុំ ។ ខ្ញុំក្រោកដើរទៅរកតុ ហើយក៏អង្គុយសរសេរសំបុត្រដោយពុំនិយាយស្ដីអ្វីជាមួយនឹងឪពុករបស់ខ្ញុំតទៅទៀត ។



ខ្ញុំពុំហ៊ានចាប់និយាយថា ខ្ញុំសរសេរសំបុត្រទៅប្រាប់នាង យូរ៉េត ជាដូចម្ដេចខ្លះឡើយ ... ខ្ញុំបានសរសេរការពិតគ្រប់បែបគ្រប់យ៉ាងប្រាប់នាង ... ការដែលខ្ញុំស្ដាយខ្លោចចិត្តជាខ្លាំងនោះ ក៏គឺខ្ញុំត្រូវព្រាត់ប្រាសគ្នាដោយពុំបានឃើញមុខ ... ខ្ញុំបានប្រាប់នាងថា ខ្ញុំពុំអាចទិញរបស់លេងយកទៅផ្ញើកូនលេងតាមពាក្យដែលនាងបានផ្ដាំនោះបានឡើយ ... ខ្ញុំបានអង្វរករនាងថា សុំកុំឲ្យនាងខឹងសម្បាអ្វីនឹងឪពុករបស់ខ្ញុំ ព្រោះការដែលលោកធ្វើដូច្នេះ ក៏ដោយសារតែលោកស្រឡាញ់រូបខ្ញុំដែលជាកូននោះឯង ...

ខ្ញុំត្រូវសរសេរសំបុត្រនោះវែងណាស់ គឺត្រូវសរសេររៀបរាប់មកតាំងពីដើម ព្រោះខ្ញុំធ្លាប់បានប្រាប់នាង យូរ៉េត ថា សំណប់ឪពុករបស់ខ្ញុំនោះមិនជាអ្វីប៉ុន្មានទេ ។ ខ្ញុំត្រូវលើកយករឿងចាស់មកនិយាយសារជាថ្មីទៀត ។ ខ្ញុំបានប្រាប់នាងថា សុំឲ្យនាងត្រឡប់ទៅភ្នំពេញវិញ ហើយទៅនៅ

ជាមួយមិត្តភ័ក្តិរបស់ខ្ញុំ ដោយកុំឲ្យអ្នកណាដឹង ហើយពឹងពាក់មិត្តភ័ក្តិនោះ ឲ្យទៅខ្សឹបប្រាប់ខ្ញុំ ។

ខ្ញុំអង្គុយសរសេរសំបុត្រនោះអស់ពេលពីរម៉ោងទើបចប់ ។ ខណៈនោះ បងប្រុសរបស់ខ្ញុំក៏បានត្រឡប់មកវិញជាមួយនឹងអីវ៉ាន់ជាច្រើន ។ ខ្ញុំមើលនាឡិកាឃើញម៉ោងមួយកន្លះហើយ ។ បងប្រុសរបស់ខ្ញុំបាននិយាយការអ្វីដែលខ្ញុំស្តាប់ពុំបាន រអ៊ូ ៗ ជាមួយនឹងឪពុករបស់ខ្ញុំ ។ មួយសន្ទុះក្រោយមកឪពុករបស់ខ្ញុំក៏ទារយកសំបុត្រដែលខ្ញុំសរសេរ និងកូនសោរថយន្តពីខ្ញុំ ដោយប្រាប់ថា ឲ្យបងប្រុសរបស់ខ្ញុំយករបស់តាំងនោះទៅពឹងពាក់អ្នកបំរើហូតែលឲ្យយកទៅឲ្យនាង យូរ៉េត ។ ខ្ញុំក៏បានប្រគល់សំបុត្រនិងកូនសោរថយន្តឲ្យទៅបងប្រុសរបស់ខ្ញុំ ។ បងប្រុសរបស់ខ្ញុំក៏បានចេញពីបន្ទប់នោះម្តងទៀត ។ ឪពុករបស់ខ្ញុំបង្គាប់ឲ្យខ្ញុំបិទភ្លើងអគ្គិសនីក្នុងបន្ទប់ ហើយយើងនឹងសម្ងំដេកស្ងៀមរៀងខ្លួន ។



ប្រហែលជាពីរម៉ោងក្រោយមក បងប្រុសរបស់ខ្ញុំ ក៏ត្រឡប់មកវិញ ហើយខ្សឹបដាក់ឪពុករបស់ខ្ញុំថា កិច្ចការតាំងអស់បានសំរេចរៀបរយអស់ហើយ ។

យប់នេះខ្ញុំដេកពុំលក់សោះ ។ ការគិតមួយម៉ឺនមួយសែនចំពូកបានផុសចេញពីចិត្តរបស់ខ្ញុំ តែជាការគិតដែលគ្មានបានការអ្វី ។ តាមពិតក្នុងពេលយប់នោះ ខ្ញុំគិតអ្វីពុំធ្លុះធ្លាយសោះឡើយ ។ ខ្ញុំដូចជាគ្មានកំឡាំងចិត្តនៅក្នុងខ្លួនសោះ ។ ខ្ញុំមានសង្ឃឹមតែម្យ៉ាងថា នាង យូរ៉េត នឹងទៅតាមខ្ញុំឯភ្នំពេញ តែក៏ជាសេចក្តីសង្ឃឹមដែលពុំពិតប្រាកដ ។ ខ្ញុំគិតម្យ៉ាងទៀតថា ប្រសិនបើនាង យូរ៉េត បានដឹងរឿងការដូច្នេះ ប្រហែលជានាងពុំទៅតាមខ្ញុំទេ ។ ខ្ញុំដូចជារកជ.ពុំបាន ស្មានពុំត្រូវនូវការពិបាកចិត្តរបស់ខ្ញុំ ។ ខ្ញុំព្រមទទួលបុះពាញ់ចំពោះកម្លាំងចិត្តរបស់ឪពុកខ្ញុំ ។ ខ្ញុំពុំទទឹងរឹងរូស ឬ គេចវៀសអ្វីនឹងលោកឡើយ ។

ខ្ញុំនឹកភាណិតនាង យូរ៉េត ទិន យូកី ស្ទើរតែដាច់ខ្យល់ស្លាប់ ។ ខ្ញុំនឹកថា នាង យូរ៉េត មុខជាចាំមើលផ្លូវថ្ងៃពាល់តែយប់ជ្រៅជាពុំខាន ព្រោះខ្ញុំពុំបានប្រាប់នាងថា ខ្ញុំទៅណាផង ។ ខ្ញុំនឹកគួរសាសភាពនាងថា ពាលបើនាងចាំមើលផ្លូវខ្ញុំពាល់តែយប់ជ្រៅហើយពុំឃើញខ្ញុំត្រឡប់ទៅផ្ទះវិញទេនោះ នាងមុខជាអន្ទះអន្ទែងអន្ទូលចិត្តជាខ្លាំងពុំខាន ។

តែពុំដឹងជាហេតុអ្វី ពេលនេះចិត្តរបស់ខ្ញុំបែរនៃនឹកដល់ដើមគគីរមួយដើមធំ ដែលដុះតាមផ្លូវជិតដល់ផ្ទះរបស់ខ្ញុំ ។ ខ្ញុំធ្លាប់ឃើញដើមគគីរនោះរាល់ថ្ងៃ តែពុំដែលបាននឹកនាថាជាដើមឈើសំខាន់អ្វីសោះឡើយ ចុះពេលនេះ ពុំដឹងជាមានហេតុអ្វីមកជំរុញចិត្តរបស់ខ្ញុំឲ្យបែរនៃនឹកដល់ដើមគគីរនោះ ...

លុះដល់ពេលលើ ៗ ជិតនឹងលក់ ខ្ញុំក៏ស្រមៃឃើញដើមគគីរនោះម្ដងទៀត ហើយហាក់ដូចជាមានសំឡេងអ្វីមួយមកខ្សឹបដាក់ត្រចៀកខ្ញុំថា "ដើមគគីរធំ" ហេតុអ្វីក៏ដូច្នេះ?



អ្វីជាហេតុបណ្ដាលឲ្យមនោគតិរបស់ខ្ញុំគួបទាក់ទៅដល់ដើមគគីរនោះ? អ្វីមកខ្សឹបដាក់ត្រចៀករបស់ខ្ញុំយ៉ាងនេះ? ខ្ញុំក៏ពុំដឹង-ពុំយល់ពុំចូលចិត្តពាល់តែសោះ ។

ម៉ោង ៦ គត់... ។ ឪពុករបស់ខ្ញុំ និងបងប្រុសរបស់ខ្ញុំ បាននាំខ្ញុំចុះពីសណ្ឋាគារ កេងៈកោស៊ុង ឡើងដំណើរទៅកាន់បំណកអាកាសយាន ដូងមឿង ដែលនឹងត្រូវធ្វើដំណើរត្រឡប់ទៅភ្នំពេញវិញនៅវេលាម៉ោងប្រាំពីរកន្លះ ។ ខ្ញុំរលែមុខស្ទើរតែខប់ខ្លួនពុំដាច់ ។ ខ្ញុំគិតថា ប្រសិនបើអ្នកដទៃក្រៅពីឪពុកហ៊ានមកធ្វើដូច្នេះ មុខជាមានការកាប់សម្លាប់គ្នាជាពុំខាន ។ តែនេះ ភពាស់តែជាឪពុក ហើយការដែលលោកហ៊ានធ្វើយ៉ាងនេះ គឺមកតែពីលោកស្រឡាញ់ខ្ញុំជាកូន ៗ លុះគិតដូច្នេះហើយ ខ្ញុំក៏ត្រូវតែយល់ដល់ចិត្តថ្មីម នឹងហេតុផលរបស់លោក សូម្បីហេតុផលនោះពុំត្រូវគ្នា ពុំស្របគ្នា នឹងហេតុផលរបស់ខ្ញុំក៏ដោយ ។

ឪពុកខ្ញុំយល់ថាធ្វើដូច្នេះ ជាអត្ថប្រយោជន៍ដល់ខ្ញុំជាកូន តែចំពោះរូបខ្ញុំវិញ ខ្ញុំយល់ថាការធ្វើបែបនេះជាអំពើទារុណ-កម្មយ៉ាងខ្លាំងក្រៃណាខ្លាំង ។ មនុស្សដែលអាចធ្វើបែបនេះ ជាមួយខ្ញុំបាន ក៏មានតែម្នាក់ប៉ុណ្ណោះ គឺឪពុករបស់ខ្ញុំ ឯអ្នកដទៃវិញធ្វើពុំបានជាដាច់ខាត ។

ខណៈនុះ ខ្ញុំដូចជាមួម៉ៅក្ដៅក្រហាយចិត្តជាខ្លាំងចំពោះ វាសនាអាក្រក់របស់ខ្ញុំ ព្រោះជីវិតរបស់ខ្ញុំចេះតែជួបប្រទះនូវ រឿងរ៉ាវប្លែកៗពុំដូចគេសោះ ។ អ្នកដទៃធ្លាប់តែមានរឿង រ៉ាវថា កូនក្រមុំរត់តាមកូនកំលោះ ហើយឪពុកម្ដាយខាងស្រី ទៅតាមយកកូនក្រមុំមកវិញ តែរឿងរ៉ាវរបស់ខ្ញុំ ជារឿងរ៉ាវ ដែលកូនកំលោះរត់តាមកូនក្រមុំ ហើយឪពុកមកចាប់អូស យកកូនកំលោះទៅវិញ ។ ការដែលខ្ញុំត្រូវប្រើពាក្យថា " ចាប់អូស " ក៏ព្រោះនៅពេលចេញពីសណ្ឋាគារទៅឡើង យន្តហោះនោះ ឪពុករបស់ខ្ញុំបានកាន់ដៃខ្ញុំជាប់ ពុំព្រមលែង



សោះឡើយ ។ ក្នុងពេលនោះរូបខ្ញុំដូចជាកូនក្មេងដែលគេ គេចខ្លួនពីផ្ទះ ព្រោះឪពុកដើររកឃើញក៏អូសដៃយកទៅផ្ទះវិញ ដូច្នោះដែរ ។ ក្នុងពេលនោះប្រសិនបើខ្ញុំស្រែកឲ្យឡូឡាឡើង រឿងរ៉ាវរបស់ខ្ញុំមុខជាក្លាយទៅជាអាហាររបស់តម្រួតឬរបស់ អ្នកសារពត៌មានទៅហើយ ។

ការចំឡែកម្យ៉ាង ដែលខ្ញុំរកគិតពុំយល់គឺលិខិតឆ្លងដែនៗ នៅពេលទៅដល់ស្ថានីយ៍អាកាសយាន ដុនមឿង ឪពុក របស់ខ្ញុំបានយកលិខិតឆ្លងដែនបីទៅចុះទិដ្ឋាការ ។ លិខិត ឆ្លងដែនមួយជារបស់ឪពុកខ្ញុំ មួយទៀតជារបស់បងប្រុសខ្ញុំ ហើយលិខិតទីបីជារបស់ខ្ញុំរូបថតរបស់ខ្ញុំ តែឈ្មោះវិញពុំមែន ឈ្មោះរបស់ខ្ញុំឡើយ ។ ប៉ុន្តែខ្ញុំត្រូវបិទមាត់ពុំស្ដីអ្វី ពុំសាក សួរអ្វី ចេះតែបណ្ដោយឲ្យរឿងរ៉ាវនោះ ទៅជារឿងរ៉ាវ អាថ៌កំបាំង ដែលខ្ញុំក៏ពុំបានដឹងថាជាយ៉ាងដូចម្ដេចដែរ ។

## វគ្គទី ១៥

# ទុក្ខព្រួយព្រោះព្រាត់

សភាពនៃចិត្តរបស់ខ្ញុំនៅពេលឡើងជិះយន្តហោះ ដូចជាពិបាកអធិប្បាយឲ្យត្រូវបាន ព្រោះមានទុក្ខកង្វល់ខ្លាំងពេក ៗ ខ្ញុំស្រក់ទឹកភ្នែកក្នុងកាលដែលគិតថា វិនាទីនេះ ជាវិនាទីដែលខ្ញុំត្រូវព្រាត់ប្រាសនឹងសហាកប្រពន្ធជាទីស្នេហា និង កូនសំឡាញ់ដែលទើបនឹងចេះសើចចេះកា ៗ

ឪពុករបស់ខ្ញុំបាននិយាយលេងជាមួយខ្ញុំ ហាក់ដូចជាគ្មានរឿងអ្វីកើតឡើង ៗ លោកនិយាយដល់ការធ្វើដំណើរតាមផ្លូវទឹកផ្លូវគោកនិងផ្លូវអាកាស និងការដើរលេងនៅក្រុងបាងកក ដោយបានប្រើពាក្យពេចន៍ពីរោះពិសា និង មេត្តាករុណាចំពោះខ្ញុំ ដែលនាំឲ្យខ្ញុំយល់ថា ឪពុករបស់ខ្ញុំមានជ័យជំនះលើរូបខ្ញុំហើយ ៗ

មួយសន្ទុះក្រោយមក ហូតែស្សយន្តហោះបាននាំយក



ទស្សនាវដ្តី និងសារព័ត៌មានគ្រប់យ៉ាងមកចែកអ្នកដំណើរ អានកំសាន្តដើម្បីរំលាប់ពេលវេលា នៃការធ្វើដំណើរកុំឲ្យធុញទ្រាន់ ខ្ញុំបានទទួលសារព័ត៌មានដែលចេញព្រឹកនេះមកអានលេង ៗ ខ្ញុំបានជួបនឹងហេតុការណ៍ដ៏ចំឡែកគួរឲ្យរំភើបចិត្តដែលខ្ញុំត្រូវពិនិត្យហើយពិនិត្យទៀត ៗ

សារព័ត៌មាននោះ ជាសារព័ត៌មានចេញផ្សាយកាលព្រឹកនៅទីក្រុងបាងកក ជាសារព័ត៌មានដែលមានឈ្មោះថា "អរុណបាងកក" ៗ គេដាក់ចំណងជើងធំៗថា "ដំណឹងពិសេសនៅម៉ោង ៤ ទៀបភ្លឺ" ៗ សារព័ត៌មាននេះបានអះអាងថា គេបានដំណឹងពិសេសមួយនៅម៉ោង ៤ ទៀបភ្លឺ ហើយគេក៏យកមកចុះផ្សាយក្នុងទំព័រសារព័ត៌មានរបស់គេនៅពេលអរុណរះ ៗ គេនិយាយថា ដំណឹងពិសេសនេះគឺហេតុការណ៍ដ៏សំខាន់ដែលកើតឡើងកាលពីពេលម៉ោង ៤ ភ្លឺ ហើយត្រូវប្រាកដរូបឡើងនៅក្នុងទំព័រសារព័ត៌មានរបស់គេ ដែលអាច

ធ្វើឲ្យអ្នកអានបានដឹងដំណឹងនេះនៅពេលឥឡូវនេះ ។ សភាព ដែលគាបស្រួចទាញក្រសែភ្នែក ទីងសតិអារម្មណ៍របស់ខ្ញុំ យ៉ាងខ្លាំងនោះ ក៏គឺដំណឹងអំពីមរណភាពនៃរូបខ្ញុំផ្ទាល់ខ្លួនឯងៗ

ខ្ញុំត្រូវឈឺភ្នែកក្នុងខណៈដែលខ្ញុំបានអានដំណឹងនេះ... ខ្ញុំសង្ស័យខ្លួនឯងថា ក្រែងភ្នែករបស់ខ្ញុំកាន់ប្រែខ្វាំ ឬ ក៏ស្មារតីរបស់ខ្ញុំពុំប្រក្រតីទេដឹង ? ព្រោះប្រសិនបើខ្ញុំនៅមានសតិសម្បជញ្ញៈដឹងខុសត្រូវដូចមនុស្សធម្មតានោះ ខ្ញុំក៏មុខជាពុំបានឃើញដំណឹងដូច្នេះនៅលើទំព័រសារពត៌មាន ឬក៏មានមនោសញ្ចេតនាដូចពេលនេះឡើយ ...

ដំណឹងនេះ ពុំមែនជាដំណឹងតូចតាចទេ គឺជាដំណឹងធំដុំណាស់ ។ គេបានសរសេរឈ្មោះខ្ញុំធំៗ ហើយយ៉ាងត្រឹមត្រូវនៅលើទំព័រសារពត៌មាន ។ គេនិយាយថា ខ្ញុំបានបើកបររថយន្តចូលទីក្រុងបាងកក ដើម្បីជួបនឹងញាតិមិត្រ ដែលសំណាក់នៅសណ្ឋាគារ រតនៈកោសិន លុះត្រឡប់មកវិញ



ខ្ញុំបានបើកបររថយន្តធ្លាក់ចេញពីផ្លូវថ្នល់ ហើយជ្រុលទៅពុកដើមគគីរយ៉ាងខ្លាំង ទាល់តែបណ្ដាលឲ្យមានភ្លើងឆេះរថយន្តនឹងម្ចាស់ខ្លោចខ្ទីអស់ គេបញ្ជាក់ថា ហេតុការណ៍នេះកើតឡើងប្រមាណជាម៉ោង ៣ ប្រហែលជាម៉ោង ៤ នាងយុវតីប្រពន្ធខ្ញុំក៏យក្នុងការបាក់ប្ដីពុំឃើញត្រឡប់មកផ្ទះវិញ ក៏នាងចេញទៅតាមរកប្ដី លុះទៅដល់ត្រង់កន្លែងដែលរថយន្តត្រូវភ្លើងឆេះនោះ នាងក៏សង្ស័យថា ជារថយន្តរបស់ប្ដីនាង ហើយនាងក៏ចូលទៅមើលសំណាករថយន្តនោះ ជារថយន្តរបស់ប្ដីនាងមែន ហើយសាកសពដែលត្រូវភ្លើងឆេះរោលខ្មៅដូចម នៅក្នុងរថយន្តនោះ ក៏នាងសន្និដ្ឋានថាជាសាកសពរបស់ខ្ញុំដែលជាប្ដីនាងដែរ — អ្នកនិពន្ធសារពត៌មាន បានសន្និដ្ឋាននៅចុងខាងក្រោយថា ប្រហែលជាខ្ញុំស្រវឹងស្រា ហើយបើកបររថយន្តលឿនពេក បានជាមានគ្រោះថ្នាក់ធ្ងរឲ្យស្លាប់ស្ងួនយ៉ាងនេះ ។

នេះ, ស្អីចេះ! ... (ខ្ញុំគិត) រូបខ្ញុំនៅជារូបខ្ញុំដដែល ម្ដេចក៏ថាខ្ញុំស្លាប់?... ឬថាជាបិសាចរបស់ខ្ញុំដែលស្លាប់ទៅហើយ?... បើតាមខ្ញុំធ្លាប់បានដឹងមកថា សារពត៌មាននេះ ពុំដែលចុះផ្សាយដំណឹងភូតភរកុហកផ្ដេសផ្ដាសឡើយ ហើយដំណឹងបែបនេះ ក៏ពុំងាយនឹងមានអ្នកណាហ៊ានកុហកលេងផ្ដេសផ្ដាសបានដែរ ព្រោះហេតុការណ៍បានកើតឡើងនៅក្នុងក្រុងបាងកកនោះឯងដែលកំទេចរថយន្ត នឹងស្លាកស្នាមផ្សេងៗ ក៏មុខជាមានសល់នៅកន្លែងនោះ ហើយបើជនានុជនចង់ទៅមើល ក៏អាចទៅមើលបានដោយងាយដែរ ។

ក្នុងខណៈដែលខ្ញុំកំពុងតែសង្ស័យនឹងខ្លួនឯងនោះ បងប្រុសរបស់ខ្ញុំក៏សំឡឹងមើលមុខខ្ញុំហាក់ដូចជាចង់ដឹងនូវការពិតអ្វីម្យ៉ាងពីខ្ញុំ ។

— បង! (ខ្ញុំសួរ) បងដឹងហើយនៅ?

— ដឹងស្អី? (បងខ្ញុំសួរមកវិញ)



ខ្ញុំហុចកាសែតជូនបងខ្ញុំ ។ បងខ្ញុំក៏អានយ៉ាងពិនិត្យពិច័យ ។ ខ្ញុំទម្ងំស្ងៀមចាំទាល់តែបងខ្ញុំអានចប់ ទើបខ្ញុំសួរថា :

— ម៉េចគញ្ចឹងបង?

— អើហ្នឹង! កាសែតនេះផ្សាយដំណឹងហើសមែន ...

— បងដឹងឬទេ ថារឿងនេះយ៉ាងម៉េចខ្លះ?

បងប្រុសរបស់ខ្ញុំ បានសំឡឹងមើលមុខខ្ញុំ ដោយក្រសែភ្នែកដែលពោរពេញទៅដោយសេចក្ដីអាណិតអាសូរ ។ បងខ្ញុំអង្អែលសក់ខ្ញុំតិចៗ ថ្នមៗ ហើយក៏និយាយរឿងរ៉ាវទាំងអស់ប្រាប់ខ្ញុំ ។

រឿងរ៉ាវដែលនិយាយនោះ រួមសេចក្ដីថា លោកឪពុកនិងបងខ្ញុំបានទៅដល់ទីក្រុងបាងកកនេះប្រាំថ្ងៃហើយ ។ ក្នុងកំឡុងពេលប្រាំថ្ងៃនេះ បងខ្ញុំបានទៅលបមើលការប្រព្រឹត្តទៅរបស់ខ្ញុំដឹងអស់ហើយ ។ បានឃើញនាង យូរ៉េត បានឃើញខ្ញុំ បានឃើញកូនខ្ញុំ បានឃើញការរស់នៅរបស់គ្រួសារខ្ញុំ

និងអ្វីៗគ្រប់សព្វទាំងអស់ ។ ឪពុករបស់ខ្ញុំបានសំរេចចិត្តថា ត្រូវតែនាំយករូបខ្ញុំត្រឡប់ទៅស្រុកវិញឲ្យទាន់តែបាន ហើយ ត្រូវប្រើកលឧបាយដោយវិធីណាមួយ ធ្វើឲ្យនាង យូរ៉េត អស់សង្ឃឹម ដើម្បីកុំឲ្យនាងតាមទៅរកខ្ញុំឯភ្នំពេញទៀត ។

រឿងនេះឪពុកខ្ញុំជាអ្នកគិត បងប្រុសខ្ញុំជាអ្នកធ្វើ ។ អ្នកគិតក៏ពូកែ អ្នកធ្វើក៏អង់អាចក្លាហាន បានជាធ្វើបានសំរេចយ៉ាងនេះ ។ ការនេះត្រូវប្រើចិត្តដាច់ខាត ត្រូវធ្វើដោយក្លាហានពុំខ្លាចបាប ។ ពិតណាស់ហើយការពង្រាត់បង្រាសកូនប្រពន្ធរបស់អ្នកណាមួយនោះ ជាការពិបាកណាស់ ។ អ្នកដែលហ៊ានធ្វើ ក៏ទាល់តែជាអ្នកដែលមានកំឡាំងចិត្តរឹងប៉ឹងមែនទែនណាស់ដែរ ។ កាលបើគេមានកំឡាំងចិត្តមុតហ៊ានពង្រាត់បង្រាសប្រពន្ធកូនអ្នកដទៃបានយ៉ាងនេះហើយ គេក៏អាចធ្វើបាបកម្មដទៃទៀត មានឃាតកម្មជាដើមបានយ៉ាងស្រួល ។



លុះបានស្តាប់រឿងរ៉ាវទាំងអស់នេះហើយ ខ្ញុំក៏ព្រមទទួលសារភាពថា ឪពុកនិងបងប្រុសរបស់ខ្ញុំពូកែជាងខ្ញុំមែន ព្រោះលោកទាំងពីរហ៊ានធ្វើនូវអំពើដែលខ្ញុំពុំហ៊ានធ្វើ ។ ខ្ញុំបានលើកដៃទាំងពីរឡើងលើ ហើយសូមចុះចាញ់លោកទាំងពីរនេះហើយ ។

គំនិតពង្រាត់បង្រាសនេះ ដោយពុំចង់ឲ្យនាង យូរ៉េត ទៅតាមនោះ លោកត្រូវធ្វើឲ្យនាងជឿថា ខ្ញុំស្លាប់បាត់ទៅហើយ ។ ក្នុងកំឡុងពេលពីរម៉ោង ដែលបងប្រុសខ្ញុំបានចេញពីបន្ទប់សណ្ឋាគារ រតនកោសិន ដើម្បីចាត់ការយកសំបុត្រនិងរថយន្តរបស់ខ្ញុំទៅប្រគល់ឲ្យនាង យូរ៉េតនោះ បងខ្ញុំបានទៅធ្វើបាបកម្មមួយដែលមានទម្ងន់ធ្ងន់ ។ បងខ្ញុំបានបើករថយន្តរបស់ខ្ញុំ ទៅទិញប្រេងសាំងពី ហ៊ាងយកដាក់លើរថយន្ត ហើយបើកសំដៅទៅផ្ទះរបស់ខ្ញុំ ។ តាមផ្លូវ ប ទៅផ្ទះរបស់ខ្ញុំនេះ មានចង្កៀងអគ្គិសនីបំភ្លឺតែពាក់កណ្តាល

ផ្លូវចុះណោះ ពាក់កណ្ដាលផ្លូវទៀតនោះងងឹតណាស់ ព្រោះឆ្ងាយពីក្រុង ។ ពេលយប់តែងមានមនុស្សដើរទៅមកពុំសូវដាច់ ។ អ្នកបើកបររថយន្តត្រូវប្រុងប្រយ័ត្នឲ្យមែនទែនទើបបាន សូម្បីតែខ្ញុំដែលបើកបររថយន្តតាមផ្លូវនោះរាល់ថ្ងៃក៏រះៗតែមានគ្រោះថ្នាក់ច្រើនដងណាស់ហើយ ។ ជាពិសេសទៅទៀត ប្រសិនបើមានរថយន្តមកពីខាងមុខហើយបើកហ្វាផងនោះ គឺរឹតតែមានគ្រោះថ្នាក់ច្រើនឡើងទៀត ព្រោះពចាំងភ្នែកមើលអ្នកដើរពុំឃើញ ហើយប្រសិនបើគាំងចិត្តបុកមនុស្សអ្នកដើរផងនោះ ក៏ជាការងាយណាស់ទៅទៀត ។

នេះជាអំពើដែលបងប្រុសរបស់ខ្ញុំបានធ្វើ ជាអំពើដ៏អាក្រក់លាមក តែបងខ្ញុំក៏ចាំបាច់ត្រូវតែធ្វើ ដើម្បីឲ្យបានសំរេចនូវលទ្ធផលសមតាមផែនការរបស់ឪពុកខ្ញុំ ។ ក្នុងពេលដែលបងខ្ញុំយករថយន្តរបស់ខ្ញុំបើកបរទៅនោះ ជាពេលក្រោយអាធ្រាត្រ ជាពេលស្ងាត់ កាលបើបងខ្ញុំបានជួបនឹងអ្នកដំណើរណា



ដែលដើរតែម្នាក់ឯង បងខ្ញុំក៏បើករថយន្តបុក បុកល្មមតែដួលសន្លប់កុំឲ្យមានឈាម ហើយក៏បញ្ឈប់រថយន្តចុះទៅលើកយកមនុស្សអ្នករងគ្រោះនោះទៅដាក់លើរថយន្ត ហើយក៏បើកបរតទៅទៀត ។ លុះទៅដល់កន្លែងដែលមានដើមគគីរធំដែលផ្លូវចុះត្រង់នោះបត់បន្តិច បងខ្ញុំក៏បញ្ឈប់រថយន្ត ទាញអ្នករងគ្រោះដាក់ចំបង្កូត ហើយក៏ដាក់លេខបញ្ចេះឲ្យរថយន្តលឿនទៅបុកដើមគគីរនោះ រួចក៏គូសឈើគូសដុតរថយន្តនោះចោលទៅ ។ ដោយយកឡាំងប្រេងសាំងពីរហ៊ុក និងប្រេងសាំងក្នុងធុងបំរុងនោះ ភ្លើងក៏ត្រូវឆាបឆេះឡើងភ្លាមយ៉ាំងខ្លាំងសន្ធោសន្ធៅ ល្មមឆេះទាំងរថយន្ត ទាំងមនុស្សឲ្យក្លាយទៅជាផេះបាន ។

— អូន ! ( បងប្រុសខ្ញុំបានពោលក្នុងពេលដែលបាននិយាយរឿងការប្រាប់ចប់ហើយ ) រឿងការក៏មានត្រឹមតែប៉ុណ្ណឹង . . .

— ត្រឹមតែប៉ុណ្ណឹង! (ខ្ញុំនិយាយផ្ទួនពាក្យ) បងនិយាយដូចជាធ្វើលេង ដូចជាថារឿងដែលបងធ្វើនោះ ជារឿងតូចតាចបន្តិចបន្តួច — បង! ចុះបងខំធ្វើអញ្ចឹង តើដើម្បីប្រយោជន៍អ្វី?...

— ដើម្បីឲ្យប្រពន្ធរបស់ឯងជឿជាក់ថា អូនឯងពិតជាស្លាប់ ហើយវាលែងរវីរវល់នឹកនាដល់អូនឯងទៀត...

— ចុះប៉ាក្ដី បងក្ដី អាចទ្រាំអង្គុយចាំយាមល្បាតរូបខ្ញុំមួយជីវិតឬយ៉ាងណា? ព្រោះអី ខ្ញុំអាចសរសេរសំបុត្រផ្ញើទៅប្រាប់ប្រពន្ធខ្ញុំវិញថា រូបខ្ញុំនៅរស់ ហើយមនុស្សដែលស្លាប់នោះពុំមែនជារូបខ្ញុំទេ ខ្ញុំត្រឡប់ទៅបាងកកវិញ ទៅនាំយកប្រពន្ធខ្ញុំមកក៏ស្រេចទៅហើយ...

— រឿងនេះបងជឿជាក់ថា អូនឯងមុខជាពុំហ៊ានធ្វើអញ្ចឹងជាដាច់ខាតណាអូន...

— ម៉េចក៏បងគិតថាខ្ញុំពុំហ៊ានធ្វើ?



— ព្រោះបើអូនធ្វើអញ្ចឹងទៅ ក៏ដូចជាអូនឯងបើកកកាយនូវការពិតប្រាប់ប៉ូលិសថា ប៉ានិងបងបានរួមគំនិតគ្នាធ្វើឃាតកម្មនោះ អូនឯងសុខចិត្តឲ្យប៉ានិងបងជាប់គុកឬ?...

— ខ្ញុំពុំប្រាប់ដល់អ្នកណាទេ! ខ្ញុំគ្រាន់តែប្រាប់ដល់ប្រពន្ធរបស់ខ្ញុំតែម្នាក់ប៉ុណ្ណោះ!...

— ហ្នឹងហើយ! បើអូនឯងប្រាប់រឿងនេះឲ្យវាដឹង វាក៏មុខជាខឹងនឹងប៉ានិងបងជាខ្លាំង ព្រោះប៉ានិងបងបានទៅពង្រាត់ប្ដីវា — អូនឯងទុកចិត្តទុកថ្លើមវាយ៉ាងម៉េចបាន កាលបើវាខឹងដល់ចិត្តវាមែនទែន វាមុខជាទៅប្ដឹងប៉ូលិសពុំខាន ។

ពិតណាស់ហើយ ផែនការនេះ ជាផែនការដែលលោកឪពុក និង បងប្រុសរបស់ខ្ញុំបានគិតទុកយ៉ាងហ្មត់ចត់ណាស់ ហើយទើបលោកនាំគ្នាធ្វើដោយជឿជាក់ថា ខ្ញុំមុខជាពុំធ្វើអ្វីផ្ដេសផ្ដាសដែលជាហេតុនាំឲ្យការអាថ៌កំបាំងនេះលេចឮខ្ចរ-ខ្ចាយឡើយ ព្រោះថា បើខ្ញុំធ្វើដូច្នោះទៅក៏ដូចជាខ្ញុំសម្លាប់

លោក ។ ម្យ៉ាងទៀតការនេះ សូម្បីខ្ញុំបានត្រឡប់មកដល់ភ្នំពេញវិញហើយ ខ្ញុំក៏ពុំហ៊ានទាក់ទងអ្វីនឹងនាង យូរ៉េត ទៀតឡើយ ឬសូម្បីបើទុកជាខ្ញុំបានត្រឡប់ទៅក្រុងប៉ារីសកក វិញ ក៏ខ្ញុំពុំអាចទៅរកនាងហើយនៅរួមរស់ជាមួយនាងបាន ទៀតឡើយ ព្រោះខ្លាចបែកការថា លោកឪពុកនិងបងប្រុសរបស់ខ្ញុំបានធ្វើនូវអំពើឃាតកម្មនុះ ។

វិធីនេះ ជាវិធីអាថ៌កំបាំងជ្រាលជ្រៅណាស់ ជ្រាលជ្រៅដែលពុំគួរជាឪពុក និងបងប្រុសរបស់ខ្ញុំ នាំយកទៅប្រើក្នុងករណីយដូចជារឿងប្ដូរទាំងនេះសោះ ហើយឪពុកនិងបងប្រុសរបស់ខ្ញុំ ក៏ពុំគួរជាធ្វើឲ្យរឿងនេះ ក្លាយទៅជារឿងរ៉ាវធំដុំ ដល់ទៅប៉ុណ្ណោះសោះឡើយ ។

– ចុះសំបុត្ររបស់ខ្ញុំ ? (ខ្ញុំសួរ) សំបុត្រដែលខ្ញុំសរសេរផ្ញើទៅឲ្យប្រពន្ធខ្ញុំនោះ ? ..,

– បងហែកចោលទៅហើយ ! ហែកចោលអម្បាញ់



មិញនេះឯង ...

ការនេះក៏រឹតតែអាក្រក់លាមកណាស់ទៅទៀត ... ខ្ញុំខឹងខ្លាំងណាស់ កំហឹងនិងសេចក្ដីទុក្ខ កាលបើកផ្ទុះឡើងព្រមគ្នា វាក៏កើតទៅជាសភាពនៃចិត្តដ៏ចម្លែកម្យ៉ាងខុសធម្មតា ដែលខ្ញុំពុំដឹងជាអធិប្បាយថាដូចម្ដេចឲ្យបានត្រូវ ... ខ្ញុំគិតថា ប្រសិនបើការពន្យារមកដោយស្ងៀម ៗ ដោយបណ្ដោយឲ្យខ្ញុំបានប្រាប់ដំណឹងដល់នាង យូរ៉េត ដូចសេចក្ដីនៃសំបុត្រដែលខ្ញុំបានសរសេរផ្ញើទៅឲ្យនាងនោះ ក៏ដូចជាទៅល្អជាងការធ្វើដូច្នេះបន្តិច ... តែនេះ លោកបានធ្វើឲ្យនាង យូរ៉េត ពុំដឹងជាមានសេចក្ដីទុក្ខសោកក្រៀមក្រំយ៉ាងណាទេ ? ... ហើយសេចក្ដីទុក្ខសោកក្រៀមក្រំនោះ នឹងមានទំហំធំប៉ុណ្ណាទៅ ? ... ការដែលឪពុកនិងបងប្រុសរបស់ខ្ញុំធ្វើដូច្នេះ ក៏ទុកដូចជាលោកបានសាងនូវស្ពាននៃសេចក្ដីទុក្ខសោកក្រៀមក្រំឲ្យស្ត្រីម្នាក់ដែលគ្មានកំហុសសោះ ... ខ្ញុំបានស្រឡាញ់

នាង ធ្វើឲ្យនាងព្រាត់ប្រាសនិកសចេញពីស្រុកទេស និងញាតិសន្តានសាច់សាលោហិត ហើយទីបំផុតថ្ងៃបណ្តាលចិត្តរបស់នាងក៏ត្រូវមានគ្រោះថ្នាក់ស្លាប់ – ស្លាប់ដោយមូលហេតុដែលពុំបានផាំនិកនា – ស្លាប់ក្នុងពេលដែលនាងបានផ្តែផ្តាំឲ្យទិញរបស់សំកប់ក្មេងលេងយកទៅផ្ញើកូនផង . . .

ខ្ញុំលែងនិយាយស្តីថាអ្វីតទៅទៀត ព្រោះដូចជាណែនដើមករកនិយាយអ្វីពុំរួច . . . បងប្រុសរបស់ខ្ញុំ ក៏ដូចជាដឹងថា ខ្ញុំទឹងសម្បាទិនរូបចិត្តតូបថ្មើមនឹងលោក . . .

យន្តហោះ ក៏បានមកដល់ចំណតអាកាសយានពោធិ៍ចិនតុង ហើយកំពុងតែបន្ទាបខ្លួនចុះ – យើងក៏បានប្រុងប្រៀបរៀបចំខ្លួនប្រាណដែរ ។

នៅពេលចេញពីក្នុងចំណតអាកាសយានមកខាងក្រៅ ខ្ញុំបានឃើញប្អូន ៗ របស់ខ្ញុំ គេនាំកូនប្រពន្ធរបស់គេមកចាំទទួលខ្ញុំ ។



គ្រាន់តែចុះឃើញកូនគេ (ក្មួយរបស់ខ្ញុំ) ខ្ញុំក៏ដូចជាស្លុតខ្លួតចិត្តជាខ្លាំង ព្រោះនឹកដល់កូនរបស់ខ្ញុំ . . . បេះដូងរបស់ខ្ញុំដូចជាដើរញាប់ខុសធម្មតា . . . ក្បាលរបស់ខ្ញុំដូចជាធ្ងន់ងេងងោង . . . ខ្ញុំងងឹតមុខស្លុប . . . ក្រោយពេលដែលអ្នកខ្លះជំរាបសួរ – អ្នកខ្លះឱបខ្ញុំបន្តិចមក ខ្ញុំក៏ខំដើរទៅរករថយន្តជារបស់ប្អូនខ្ញុំដែលចតចាំនៅខាងក្រៅ ដោយទប់ខ្លួនកុំឲ្យដួល . . . តែខ្ញុំនៅចាំបានថា ខ្ញុំទើបតែបើកទ្វាររថយន្តនៅពុំទាន់បានឡើងជិះផង ខ្ញុំក៏លែងដឹងអ្វីតទៅទៀតទាំងអស់ ។

## វគ្គទី ១៦

# ជីវិតថ្មី

ខ្ញុំបានដឹងខ្លួនប្រាណឡើងវិញ ក្នុងខណៈដែលខ្ញុំដេក នៅលើអង្គជិតគ្រែក្នុងបន្ទប់ដេករបស់ខ្ញុំ . . . ខ្ញុំសំឡឹងមើល ពិតាន មើលជញ្ជាំង មើលទ្វារនៃបន្ទប់ ៗ ខ្ញុំក៏នៅចាំបាន យ៉ាងពិតប្រាកដថា បន្ទប់នេះ ជាបន្ទប់ដែលខ្ញុំធ្លាប់ដេកមក តាំងពីដើម . . . នេះ ខ្ញុំស្រមៃ ឬ យល់សប្តិ ? . . . រឺអាច ដូច្នោះបាន ឬ ដែលខ្ញុំសន្លប់បាត់ស្មារតីតាំងពីពេលឡើងជិះ រថយន្តពីចំណតអាកាសយានពោធិចិនតុងមក ? . . . ? នេះ ជារឿងដែលពុំគួរជឿសោះឡើយ . . . ខ្ញុំប្រហែលជាស្រមៃ ឬ យល់សប្តិទេមើលទៅ ? . . .

ខ្ញុំខំធ្មេចភ្នែកទៅវិញ ដោយគិតថា ប្រសិនបើខ្ញុំស្រមៃ ឬក៏យល់សប្តិ ក៏ទុកឲ្យស្រមៃឬយល់សប្តិតទៅទៀតចុះ . . . ប៉ុន្តែនេះ ខ្ញុំពុំមែនជាស្រមៃ ឬក៏យល់សប្តិអ្វីទេ . . . ខ្ញុំកំពុង ភ្ញាក់ដឹងខ្លួនហើយបើកភ្នែកស្រស់ៗទេតើ . . .



ខ្ញុំស្ទុះក្រោកឡើងហើយពិនិត្យមើលសព៌ាង្គកាយ ក៏ ឃើញនៅស្រួលដូចដើម គ្មានស្លាកស្នាមអ្វី . . . ខោអាវ ដែលខ្ញុំស្លៀកពាក់ទៀតសោត ក៏ស្អាតបាត . . ខ្ញុំពិនិត្យមើល បន្ទប់ម្តងទៀត គឺឃើញថាជាបន្ទប់របស់ខ្ញុំពិតប្រាកដមែន . . . តែបន្ទប់នោះឥឡូវនេះ មានការប្លែកពីរយ៉ាងគឺ ម្យ៉ាងបង្អួច ដែលពីដើមគ្មានចំរឹងដែក ឥឡូវមានចំរឹងដែកយ៉ាងមាំទាំ ហើយម្យ៉ាងទៀតក្នុងបន្ទប់នោះ ពីមុនមានគ្រឿងតាំងជាច្រើន តែឥឡូវនេះបាត់អស់រលីង ពុំដឹងជាអ្នកណាយកទៅណា អស់ . . .

ខ្ញុំដើរតម្រង់ទៅមាត់ទ្វារ ដើម្បីបើកចេញទៅខាងក្រៅ តែទ្វារនោះត្រូវគេបិទសន្ធប់ជិតជាប់ ដែលមើលទៅដូចជា មានគេចាក់សោ ឬ ដាក់គន្លឹះជាប់ពីខាងក្រៅ ៗ ខ្ញុំដើរទៅ ត្រង់មាត់បង្អួច ហើយសំឡឹងមើលទៅសួនច្បារនៅក្នុងបរិវេណរបងផ្ទះ ក៏ឃើញមានលក្ខណៈដូចដើម ៗ នេះជាអ្វី?

ជាផ្ទះរបស់ខ្ញុំ ឬ ពុំមែនទេ ? នេះពិតជាផ្ទះរបស់ខ្ញុំ ផ្ទះរបស់ឪពុកម្ដាយខ្ញុំ តែអ្វីគ្រប់បែបគ្រប់យ៉ាង មើលទៅដូចជាមានសភាពទ្រុឌទ្រោមជាងមុន ។ ដើមឈើដែលខ្ញុំធ្លាប់ឃើញតូចៗពីមុនមក ឥឡូវនេះវាក៏ស្ទុះធំសន្ធឹក ។ សភាពយ៉ាងនេះ ដូចជាពុំគួរជឿថា គ្រាន់តែពេលជាងបីឆ្នាំដែលខ្ញុំពុំនៅប៉ុណ្ណោះ ផ្ទះនេះក៏ទ្រុឌទ្រោមហើយដើមឈើក៏ធំដល់ប៉ុណ្ណោះនោះឡើយ ។

ខ្ញុំក៏ដើរទៅរកមាត់ទ្វារម្ដងទៀត ។ ខ្ញុំគោះទ្វារប៉ុកៗច្រើនដង ហើយក៏ចាំស្ដាប់មើលថា មានអ្នកណាមកបើកទ្វារដែរ ឬ ក៏គ្មាន ។

– ប៉ា! ប៉ា! សំឡេងនេះ ជាសំឡេងក្មេងស្រី តែខ្ញុំក៏ពុំដឹងថាជាសំឡេងអ្នកណា ហៅអ្នកណាឡើយ) លោកពូគោះទ្វារទៀតហើយ! ..

– ស្រេចនឹកទៅចុះ! (នេះជាសំឡេងឆ្លើយឡើង



ជាសំឡេងដែលខ្ញុំល្មមនៅចាំបានថា ជាសំឡេងបងប្រុសរបស់ខ្ញុំ) កុំរវល់អីនឹងវា! . . .

ខ្ញុំគោះទ្វារប៉ុកៗម្ដងទៀត ហើយម្ដងនេះ ខ្ញុំគោះខ្លាំងនិងយូរជាងមុន ។

– ប៉ា! ប៉ា! (ខ្ញុំបានឮសំឡេងដដែលនោះទៀត) ។ មួយសន្ទុះក្រោយមក ខ្ញុំក៏បានឮសំឡេងបងប្រុសរបស់ខ្ញុំដែលនិយាយប្រាប់នឹងមាត់ទ្វារថា :

– គ្រាន់បើបួនដប់ថ្ងៃមកហើយ ចុះឥឡូវវាយ៉ាងម៉េចទៀតហើយ . . .

ខ្ញុំគោះទ្វារទៀត ។ បងប្រុសរបស់ខ្ញុំក៏ចាក់សោបើកទ្វារចូលមក ។

នេះជាបងប្រុសរបស់ខ្ញុំពិតប្រាកដមែន តែដូចជាចាស់ជាងមុន – លោកឈរនៅត្រង់មាត់ទ្វារសំឡឹងមើលមុខខ្ញុំមួយសន្ទុះទើបនិយាយថា :

– ហ៎ ! ចុះក្បាលអូនឯងទៅប៉ះនឹងស្អីទៀតហើយ ?

តាមពិត ខ្ញុំក៏ដូចជាដឹងថាឈឺត្រង់ក្បាលបន្តិចៗដែរ តាំងពីពេលដែលភ្ញាក់ពីដេក ។ លុះបងប្រុសខ្ញុំនិយាយដូច្នោះ ខ្ញុំក៏យកដៃស្ទាបក្បាលមើល ឃើញមានឈាមប្រឡាក់ជាប់ដៃ ។

– ឯងបានគ្រាន់មកបួនដប់ថ្ងៃហើយ (បងប្រុសខ្ញុំនិយាយឡើងទៀត) ចុះឥឡូវកយ៉ាំងម៉េចទៀតហើយ . . .

ខ្ញុំពុំឆ្លើយថាអ្វី ! ព្រោះខ្ញុំឋិតនៅក្នុងសភាពសង្ស័យ ដែលមើលទៅដូចជាឃើញលាំងៗថា ហេតុការណ៍ដូចម្ដេចខ្លះ ? . . . ខ្ញុំអាចក្លាយខ្លួនទៅជាមនុស្សវិគលចរិតអស់ពេលច្រើនឆ្នាំក៏ពុំដឹង ? ខណៈនោះ បងប្រុសខ្ញុំបានយកថ្នាំ ខឹង សំឡីមកលាបហើយបិទឲ្យខ្ញុំ ។

– បង ! (ខ្ញុំនិយាយដោយខំធ្វើសំឡេងឲ្យបានដូចធម្មតា) ខ្ញុំកើតអី ឬ បង ?

– ក្បាលរបស់ឯងបែក ! (បងខ្ញុំឆ្លើយ) អូនឯងប្រហែល



ជាយកក្បាលទៅផល់នឹងគ្រែហើយមើលទៅ បានជាវាបែកអញ្ចឹង

– ចុះពុកអញទៅណា ?

– ចេះតែសួរដដែលៗ – ប្រាប់ស្ទើររេចមាត់ហើយថា លោកស្លាប់យូរណាស់ទៅហើយនៅតែសួរទៀត

– លោកស្លាប់ប៉ុន្មានឆ្នាំហើយ ?

– ចុះបងឯងយកខ្ញុំមកពីបាត់ដំបងប៉ុន្មានឆ្នាំហើយ ?

លុះខ្ញុំសួររឿងនេះ បងប្រុសខ្ញុំ ក៏សំឡឹងមើលមុខខ្ញុំ ហើយចលូកដៃមកអង្អែលស្មាខ្ញុំ ។

– អូន ! អូនឯងជាហើយ ឬ ?

– ចុះខ្ញុំមានឈឺអីបង ?

– អូនឯងឆ្កួតអស់ពេលបីឆ្នាំមកហើយ

– ចាប់ផ្ដើមឆ្កួតតាំងពីពេលណាមកបង ?

– តាំងពីពេលចុះពីយន្តហោះ – ពេលនោះអូនឯងដួល

ប៉ះក្បាលទៅនឹងតុខៀន ហើយសតិក៏វិបល្លាសផ្តេសផ្តាសអស់ — ប៉ុន្តែបងព្រមតាំងប្អូន ៗ តាំងអស់ខ្ញុំមើលអ្នកឯងយ៉ាងណាក៏ពុំជា ចុះឥឡូវម៉េចក៏អ្នកឯងបានជាដូចដើមវិញអញ្ចឹង ?

— ពុំដឹងជាយ៉ាងម៉េចទេបង ប្រហែលដោយសារខ្ញុំដួលប៉ះក្បាលទៅនឹងគ្រែ សរសៃខួរក្បាលក៏ត្រឡប់ចូលទៅកន្លែងដើមវិញមើលទៅ

— អើ ! ប្រហែលជាអញ្ចឹងមែនហើយមើលទៅ

ខ្ញុំជឿពិតប្រាកដថាដូច្នេះមែន បានជាខ្ញុំជាសះស្បើយ ៗ ខ្ញុំធ្លាប់បានអានសៀវភៅផ្សេង ៗ ហើយខ្ញុំធ្លាប់បានជួបប្រទះនឹងករណីយដូចគ្នានឹងខ្ញុំ ៗ មនុស្សជាលាធម្មតា បើក្បាលទៅប៉ះទង្គិចនឹងអ្វីខ្លាំង ឬ ក៏ត្រូវគេវាយខ្លាំង សរសៃខួរក្បាលក៏កំរើកឃ្លាតចេញពីកន្លែងដើម ហើយមនុស្សនោះក៏ភ្លេចល្ងីល្ងើលែងដឹងអ្វី ក្លាយទៅជាមនុស្សមានសតិវិបល្លាស ប៉ុន្តែបើ



ក្បាលអ្នកនោះទៅប៉ះទង្គិចនឹងអ្វីម្តងទៀត ហើយគាប់ជួនជាប៉ះទង្គិចត្រូវត្រង់កន្លែងចាស់នោះ ក៏អាចធ្វើឲ្យសរសៃខួរក្បាលដែលកំរើកឃ្លាតចេញទៅនោះ ត្រឡប់ចូលមកត្រង់កន្លែងដើមវិញ ហើយអ្នកនោះក៏ត្រឡប់ជាបានជាលាជីងខ្លួនប្រាណតាមធម្មតា ឬក៏មានសភាពជាប្រក្រតីដូចដើមវិញ ៗ ឯព្រឹត្តិការណ៍របស់ខ្ញុំក៏មុខជាដូច្នោះដែរ ។

— ចុះសំឡេងក្មេងស្រីដែលស្រែកហៅបងអម្បាញ់មិញនេះជាសំឡេងអ្នកណា ?

— ការ៉ា ! (បងប្រុសរបស់ខ្ញុំឆ្លើយ) កូនរបស់អូនឯងហ្នឹងណា៎ !

— មើល៍ ! សុំមើលមុខបន្តិចមើល៍ ។

បងប្រុសខ្ញុំ បាននាំខ្ញុំចេញទៅខាងក្រៅ, ខ្ញុំបានជួបនឹងមនុស្សជាច្រើន ដែលខ្ញុំអាចស្គាល់បានក្លាមថា ជាក្មេងដែលខ្ញុំធ្លាប់បានឃើញកាលពីរនៅតូច ៗ ។ ខ្ញុំវិកលចរិត

អស់ពេលបីឆ្នាំ ។ ខ្ញុំគិតថា បើពួកក្មេងៗដែលត្រូវជាក្មួយរបស់ខ្ញុំ ធំប៉ុណ្ណោះទៅហើយ ម្ល៉េះសមកូនរបស់ខ្ញុំក្នុងពេលនេះក៏ធំក្រៃលែងដែរ ព្រោះបើគិតមកដល់ថ្ងៃនេះ យុវ៉ាក់ ត្រូវមានអាយុបីឆ្នាំប្រាំបីខែហើយ ។ ឯ យុវ៉ែត ដែលខ្ញុំទុកដល់មុនគេ នៅពេលដែលខ្ញុំបានជិះទូកក្រោណឡើងវិញនោះ ឥឡូវនេះ នាងត្រូវមានអាយុ ២៧ ឆ្នាំ ។ ការនេះដូចជាពុំគួរជឿថា នឹងប្រព្រឹត្តទៅដូច្នេះសោះឡើយ ព្រោះខ្ញុំដូចជានៅតាំងថ្មីៗថា ពីម្សិលមិញនេះឯង ដែលឪពុកខ្ញុំនិងបងប្រុសខ្ញុំបានបង្ខិតបង្ខំខ្ញុំឲ្យឡើងជិះយន្តហោះ ហើយបានគានសារពត៌មានដែលផ្សាយនូវដំណឹងនៃការស្លាប់របស់ខ្ញុំ ដែលខ្ញុំនៅតាំងយ៉ាងជាក់ច្បាស់ ។

— ឆ្នាំនេះ គ.ស. ប៉ុន្មាន ? (ខ្ញុំសួរ)

— ឆ្នាំ ១៩៦២ (បងប្រុសខ្ញុំឆ្លើយ) ឆ្នាំនេះសមាគមអ្នកនិពន្ធខ្មែរគេកំពុងតែប្រកាសបើកសម័យប្រឡងប្រជែងអក្សរ



សាស្ត្រ ឈ្មោះរង្វាន់អីទេ ?

— រង្វាន់ឥន្ទ្រទេវី លើកទី ២ ។

ខ្ញុំដូចជាព្រឺខ្លួនខ្លាក ព្រោះខ្ញុំចង់សរសេររឿងរ៉ាវរបស់ខ្ញុំយកទៅប្រឡងប្រជែង ។

— បង (ខ្ញុំនិយាយ) ខ្ញុំដូចជាចង់សរសេររឿងរ៉ាវរបស់ខ្ញុំយកទៅប្រឡងប្រជែងនឹងគេដែរ ! ...

— ល្អហើយអូន បងជឿជាក់ថា បើអូនសរសេរជាក់បាន មុខជាបានទទួលរង្វាន់លេខ ១ ខាងផ្នែកប្រលោមលោកជាពុំខាន ។

— តែក្រែងពុំដល់គេណាបង ព្រោះអ្នកនិពន្ធដែលមានឈ្មោះល្បីច្រើនណាស់ ។

ទេ ! មិនមែនទេ ! បងជឿជាក់ថា អ្នកទាំងនោះសរសេរមិនឈ្នះអូនទេ ព្រោះគេគ្រាន់តែជាអ្នកនិពន្ធដែលប្រឌិតរឿងរ៉ាវឡើងតែប៉ុណ្ណោះ — ឯអូនវិញ ពុំមែនប្រឌិតរឿងតាម

មនោគតិទេ អ្នកសរសេរទៅតាមរឿងពិតនៃជីវិតរបស់អ្នកឯង — ចង់ជឿជាក់ថា រឿងរបស់អ្នកឯងមុខជាឈ្នះគេទាំងអស់យ៉ាងពិតប្រាកដ — ព្រោះអ្នកមានឈ្មោះល្បីខាងសរសេរពិរោះហើយមានន័យ សូម្បីតែក្នុងកាសែត «ឈាមខ្មែរ», «កម្ពុជា», សង្គមរាស្ត្រនិយម, អ្នកជាតិនិយម ។ល។ ដែលអ្នកបានសរសេរផ្សាយ គឺមហាជនទូទៅនិយមគាន ហើយសរសើរពុំដាច់មាត់ ហើយម្យ៉ាងទៀត អ្នកធ្លាប់មានថ្វីដៃផង ដូចជាកាលឆ្នាំ ១៩៥៧ ក្នុងឱកាសពិធីបុណ្យរំលឹក ២៥០០ វស្សានៃព្រះពុទ្ធសាសនា អ្នកបានប្រឡងជាប់បានរង្វាន់ខ្ពង់ខ្ពស់ទៅហើយ ៗ សរសេរទៅអ្នក ៗ

ខ្ញុំអង្គុយគិត ខ្ញុំបានសំរេចចិត្តថា ត្រូវសរសេររឿងនេះយកទៅរួមក្នុងការប្រឡងប្រជែង ប៉ុន្តែដើម្បីឲ្យរឿងនេះមានសភាពច្បាស់លាស់ពិរោះពិសា ខ្ញុំត្រូវទៅរកប្រពន្ធនិងកូនរបស់ខ្ញុំសិន ដើម្បីបន្ថែមឲ្យបានចប់ចុងចប់ដើម —



ខ្ញុំគិតថា ឥឡូវនេះប្រពន្ធនិងកូនរបស់ខ្ញុំពុំដឹងជាយ៉ាងណាទៅហើយ ៗ — តាមព្រឹត្តិការណ៍ក្នុងគ្រួសារ ឃើញថាមានសភាពស្រួលជាងមុន តាមសេចក្ដីសង្កេតរបស់ខ្ញុំឃើញថាពេលនេះ បងប្រុសខ្ញុំគឺមានចិត្តអាណិតអាសូរចំពោះខ្ញុំជាខ្លាំង ៗ នៅពេលដែលខ្ញុំបានដឹងខ្លួនប្រាណឡើងវិញ លោកបាននិយាយប្រាប់ខ្ញុំថា ឪពុកខ្ញុំបានចែកទ្រព្យសម្បត្តិឲ្យខ្ញុំជាច្រើន ហើយបងខ្ញុំបានកាន់កាប់ថែរក្សាជំនួសខ្ញុំរហូតមកដល់សព្វថ្ងៃ ។

## វគ្គ ទី ១៧

# ខ្ញុំមានទោស

ចំណែកខាងរឿងប្រពន្ធកូនរបស់ខ្ញុំនោះ បងប្រុសខ្ញុំបាននិយាយប្រាប់ខ្ញុំថា លោកពុំដែលបានទទួលដំណឹងអ្វីសោះឡើយ ។ ខ្ញុំជំរាបបងខ្ញុំថា ជាការចាំបាច់ណាស់ដែលខ្ញុំត្រូវទៅរក ។ ប៉ុន្តែខ្ញុំបានសន្យាជាមួយបងខ្ញុំថា ខ្ញុំនឹងពុំបង្ហាញខ្លួនឲ្យអ្នកណាឃើញ ឬដឹងថា ខ្ញុំនៅមានជីវិតរស់នៅឡើយ ដែលជាហេតុធ្វើឲ្យមានការស៊ើបដល់រឿងឃាតកម្ម កាលពីបីឆ្នាំកន្លងមកហើយនោះ សាជាថ្មីឡើងទៀតទេ ព្រោះរឿងឃាតកម្មមានអាយុដល់ទៅម្ភៃ (២០) ឆ្នាំទើបរលត់ ។ ខ្ញុំបានជំរាបបញ្ជាក់ថា សូមឲ្យលោកជឿខ្ញុំចុះ ក្នុងការដែលខ្ញុំត្រូវតាមទៅរកប្រពន្ធ – កូនវិញនោះ ខ្ញុំនឹងត្រូវធ្វើដោយការប្រយ័ត្នប្រយែងជាទីបំផុត ដើម្បីកុំឲ្យមាន



ការស៊ើបដល់រឿងចាស់ឡើងវិញ ។

លុះបានទទួលនូវសេចក្តីអនុញ្ញាតពីបងប្រុសខ្ញុំរួចហើយ ខ្ញុំក៏បានធ្វើដំណើរចេញទៅប្រទេសសៀមម្តងទៀត ហើយទីបំផុតខ្ញុំក៏បានទៅដល់ទីក្រុងបាងកក ។

រឿងដែលខ្ញុំត្រូវបិទបាំងពុំឲ្យអ្នកណាដឹងថា ខ្ញុំនៅមានជីវិតរស់នៅឡើយនោះ ជាការសំខាន់ទីងចាំបាច់បំផុតសំរាប់រូបខ្ញុំ ព្រោះប្រសិនបើខ្ញុំសំដែងខ្លួនឲ្យគេឃើញ គេក៏អាចដឹងភ្លាមថា ខ្មោចដែលត្រូវភ្លើងឆេះពេលស្លាប់នៅក្នុងរថយន្តនោះ ពុំមែនជារូបខ្ញុំឡើយ ហើយរឿងរ៉ាវនោះក៏នឹងចូលទៅក្នុងឃាតកម្ម ព្រោះហេតុការណ៍បែបនេះ ពុំមែនជារឿងរ៉ាវថ្មីដែលទើបមានម្តងពីរដងឡើយ ។ រឿងរ៉ាវរបៀបនេះ ធ្លាប់មានរឿងពិតនៅអឺរ៉ុបរួចមកហើយ ។ រឿងពិតនោះគឺមានបុរសម្នាក់ បានទៅធានាជីវិតខ្លួនទុកក្នុងក្រុមហ៊ុនមួយជាប្រាក់ជាច្រើន ។ បុរសនោះបានប្រើកលៗដោយបើកបររថ

យន្តរបស់គេទៅបុកមនុស្សស្លាប់ ហើយក៏លើកខ្មោចនោះដាក់លើរថយន្តរបស់គេ រួចហើយក៏ក្លែងធ្វើជាបើកបររថយន្តនោះទៅបុកគល់ឈើ ។ ពេលនោះមក ក៏គេគូសឈើ-គូសដុតរថយន្តនោះចោល ដើម្បីឲ្យភ្លើងឆេះទាំងរថយន្តទាំងមនុស្ស ។ ឯរូបគេក៏គេចខ្លួនបាត់ទៅ ដោយទុកឲ្យប្រពន្ធទៅបើកយកប្រាក់សំណងពីក្រុមហ៊ុនធានាជីវិត ។ លុះបើកប្រាក់បានហើយ នាងជាប្រពន្ធនោះ ក៏ធ្វើដំណើរទៅជួបនឹងប្តីនៅត្រង់កន្លែងណាមួយដែលគេបានសន្យានឹងគ្នា ដើម្បីនាំគ្នារត់ទៅនៅឯបរទេស ដោយជឿជាក់ថាប្រាក់ដែលក្រុមហ៊ុនធានាជីវិតសងមកនោះ មានចំនួនច្រើនល្មមចិញ្ចឹមជីវិតបានស្រួលនៅបរទេស តែទីបំផុតគេក៏ចាប់បាន ។ វិធីការដែលបងប្រុសខ្ញុំបានធ្វើនោះ មើលទៅក៏ប្រហែលជាចំឡងយកបែបពីរឿងនោះមកប្រើ ព្រោះមានសភាពដូចគ្នាបេះបិទ ។ ខ្ញុំបានធានាជីវិតទុកបីសែនបាទ ។ ឥឡូវនាង យូរ៉េត



ប្រហែលជាទៅបើកយកប្រាក់នោះរួចទៅហើយ ។ ប្រសិនបើការនេះលេចឮឡើងថា ខ្ញុំនៅមានជីវិតរស់នៅឡើយទេនោះ មនុស្សទីមួយដែលប៉ូលិសត្រូវចាប់ គឺរូបខ្ញុំហ្នឹងឯង ព្រោះខ្ញុំមុខជាពុំហ៊ានផ្ញើយដាក់បងប្រុសខ្ញុំឡើយ ហើយខ្ញុំក៏ត្រូវជាប់ទោស ។ ដូច្នេះការធ្វើដំណើរក្តី ការសំណាក់នៅក្នុងក្រុងប៉ារីសក្តី ខ្ញុំក៏ត្រូវតែធ្វើយ៉ាងលាក់លៀមជាទីបំផុត ។

ឯរឿងធ្វើដែនពុំជាអ្វីទេ ព្រោះខ្ញុំធ្លាប់បានដឹងដល់កិច្ចការនៃស្ថានខុតយ៉ាងច្បាស់លាស់ណាស់ ដោយខ្ញុំធ្លាប់បានហែលឆ្លងរួចមកហើយ ។ ដូច្នេះខ្ញុំនៅមានការសំខាន់តែម្យ៉ាង គឺត្រូវសម្ងំខ្លួនពួនអាត្មានៅក្នុងទីស្ងាត់ ដើម្បីកុំឲ្យជួបនឹងមនុស្សដែលធ្លាប់ស្គាល់គ្នា ។

ខ្ញុំបានលបទៅមើលផ្ទះ ដែលខ្ញុំធ្លាប់នៅរួមរស់ជាមួយនាង យូរ៉េត ។ ខ្ញុំគិតថា ខ្ញុំពុំគួរនឹងចូលទៅបង្ហាញខ្លួន

ឲ្យនាង យូរ៉ែត ឃើញភ្លាមៗទេ ព្រោះប្រសិនបើខ្ញុំធ្វើដូច្នោះ ទៅនាងមុខជាភ័យភិត ហើយខ្ញុំនិយាយគ្នាស្ដាប់បាន នោះក៏មុខជាលេចឮដល់អ្នកដទៃជាពុំខាន ។ ខ្ញុំគិតថា ខ្ញុំគួរចូលទៅជួបនាងនៅពេលស្ងាត់ ដែលគ្មានអ្នកណានៅជាមួយនាង ឬក៏ពេលដែលអ្នកបំរើដេកលក់ ។

ដោយហេតុថា ខ្ញុំមានការចាំបាច់ត្រូវលាក់ខ្លួនពួនអាត្មានៅក្នុងបន្ទប់សណ្ឋាគារដ៏តូចក្នុងពេលថ្ងៃនោះ ខ្ញុំក៏ត្រូវទៅលបមើលនាង យូរ៉ែត តែក្នុងពេលយប់ៗ ។

ខ្ញុំបានពួននៅត្រង់ទីកំបាំងលបមើលនាងពីខាងក្រៅ ។ ខ្ញុំបានឃើញនាង យូរ៉ែត ដែលខ្ញុំនៅចាំច្បាស់ — ឃើញក្មេងប្រុសម្នាក់ដែលខ្ញុំជឿជាក់ថាជាកូនរបស់ខ្ញុំ — ឃើញស្រីបំណាស់ម្នាក់ដែលខ្ញុំពុំធ្លាប់ស្គាល់ ប្រហែលជាស្រីបំរើដែលទើបមកនៅថ្មី ។ ខ្ញុំពុំអាចចូលទៅជួបនាងក្នុងផ្ទះនៅពេលនេះបានឡើយ ព្រោះក្រែងនាងភ័យភិតហើយស្រែកឡូឡា



ឡើង ។ ខ្ញុំគិតថា គួរទៅរកកន្លែងណាសរសេរសំបុត្រយកទៅហុចឲ្យនាងតែម្ដង ។ បើធ្វើដូច្នេះ នាងមុខជាពុំភ័យភិតអ្វីឡើយ ព្រោះនាងបានអានសំបុត្រមុន បើចូលទៅនិយាយផ្ទាល់មាត់តែម្ដង ក្រែងនាងភ័យតក់ស្លុត ដោយគិតថាជាបិសាចរបស់ខ្ញុំមកលងនាង ។

ព្រះចន្ទរះឡើងក៏ត្រចះត្រចង់ ។ ខ្ញុំគិតថា យប់នេះប្រហែលជាគ្មានបានផលអ្វីឡើយ ព្រោះត្រូវចាំសរសេរសំបុត្រសិន តែចិត្តមួយទៀតគិតថា គួរចាំលបមើលបន្តិចទៀតសិន ព្រោះខ្ញុំដូចជានឹកនាងនិងកូនយ៉ាងខ្លាំង ។

មួយសន្ទុះក្រោយមក ខ្ញុំឃើញនាងបិទទ្វារផ្ទះ ហើយដើរចេញមកខាងក្រៅ ។ ខ្ញុំធ្លាក់ថ្លើមក្ដុក ក្នុងខណៈដែលបានឃើញនូវព្រឹត្តិការណ៍ដូច្នេះ ។ ខ្ញុំនឹកឆ្ងល់ថា នាងយូរ៉ែតទៅណាក្នុងពេលយប់ស្មើនេះ? ហេតុអ្វីក៏នាងទៅតែម្នាក់ឯងពុំយកកូនទៅជាមួយផង? នាង យូរ៉ែត ប្រហែលជាមានគួ

សង្ក្រាថ្មីហើយទេដឹង ឬមួយក៏នាងដើររកស៊ីក្នុងផ្លូវពុំល្អ ៗ

ដោយសារមានការងឿងឆ្ងល់យ៉ាងនេះ ខ្ញុំក៏ចេះតែចាំលបមើលប្រពន្ធខ្ញុំតទៅទៀត ឬបើនិយាយម្យ៉ាងទៀតថា ប្រពន្ធរបស់ខ្មោចខ្ញុំ ។

តែនាងពុំបានទៅណាទេ ។ នាងដើរទៅជ្រុងខាងជើងផ្ទះ សំដៅទៅរកកនទេព្ដា ។ កនទេព្ដានេះ ខ្ញុំបានធ្វើឡើងដោយដៃខ្លួនឯង កាលពីពេលដែលខ្ញុំនៅជាមួយនាង ។ លុះទៅដល់ហើយ នាងដុតទៀនធូបដោតលើកនទេព្ដានោះ ហើយលុតជង្គង់លើកដៃប្រណម្យ ហើយសូត្រធម៌ ឬ គាថាអ្វីដែលខ្ញុំឮរអ៊ូៗ តែស្ដាប់ពុំច្បាស់ ។ ពេលនោះ ខ្ញុំយល់ដល់កិច្ចវត្តនៃប្រពន្ធសំឡាញ់របស់ខ្ញុំថា នាងមកសូត្រធម៌បួងសួងចំពោះគុណទេព្ដា និងគុណបុណ្យព្រះរតនត្រ័យដើម្បីគោលបំណងអ្វីមួយ ។ លុះពិនិត្យឃើញថា ជាឱកាសល្អ ដោយគ្មាននរណានៅជិត ខ្ញុំក៏ដើរចូលទៅរកនាង ។ នាងបែរមុខ



មកមើលខ្ញុំក្នុងខណៈដែលបានឮស្នូរជើងរបស់ខ្ញុំចូលទៅជិតៗ

— យូរ៉េត អូន! (ខ្ញុំហៅឈ្មោះនាងតិចៗ ដើម្បីកុំឲ្យនាងខ្លាច ឬ ភ័យកិត ហើយស្រែកឡូឡាឡើង) យូរ៉េត! បងមកវិញហើយ — បងនៅពុំទាន់ស្លាប់ទេ — ឥឡូវបងត្រឡប់មករក យូរ៉េត វិញហើយ ។

ពេលនោះ ជាគ្រោះល្អរបស់ខ្ញុំ! នាង យូរ៉េត គ្រាន់តែស្រឡាំងកាំង ពុំបានស្រែកឡូឡាឡើងឡើយ ... នាងញ័ររន្ធត់អស់ទាំងខ្លួនប្រាណ តែឥតមាននិយាយស្ដីថាអ្វី ...

— បងទេតើ យូរ៉េត! (ខ្ញុំប្រញាប់និយាយតទៅទៀត) បងពុំមែនជាខ្មោចបិសាចអីទេ — បងជាប្ដីរបស់ យូរ៉េត — ឯមនុស្សដែលស្លាប់នៅក្នុងឡាននោះ ពុំមែនរូបបងទេ — យូរ៉េត កុំខ្លាច — កុំកិតភ័យអី ចាំបងនិយាយរឿងរ៉ាវឲ្យ យូរ៉េត ស្ដាប់ ។

— បង! (នាង យូរ៉េត និយាយដោយសំឡេងញ័រៗ

ព្រោះការរំភើបចិត្ត) បងទេឬ ?

— ហ្នឹងហើយ យូរ៉ែត អូន ! ប្ដីរបស់អូនដែលធ្លាប់បានប្ដេជ្ញាជាមួយអូនថា នឹងពុំព្រមឲ្យអំណាចអ្វីមួយក្នុងលោកមកពង្រាត់បម្រាសយើងចេញពីគ្នា ក្រៅពីសេចក្ដីស្លាប់ ។

ប្រហែលជាដោយសារការដែលខ្ញុំនិយាយដល់ពាក្យត្រង់នេះហើយ ដែលធ្វើឲ្យនាង យូរ៉ែត ជឿជាក់ថា ជារូបខ្ញុំពិតប្រាកដ ព្រោះអ្នកដទៃពុំអាចដឹងនូវពាក្យប្ដេជ្ញានោះឡើយ ។ នៅពេលដែលខ្ញុំបានពោលពាក្យនោះចប់ នាង យូរ៉ែត ក៏ស្ទុះចូលមកឱបខ្ញុំហើយយំខ្សឹកខ្សួល ។ ក្នុងពេលនោះ ខ្ញុំក៏ក្លាយខ្លួនទៅជាកូនក្មេងទន់ខ្សោយ ព្រោះខ្ញុំពុំអាចទប់ទឹកភ្នែកពុំឲ្យស្រក់ជាមួយនាងបាន ។

ខ្ញុំឱបនាង ថើបនាង ដោយពុំចាំបាច់និយាយអ្វីនឹងគ្នា ។ នាង យូរ៉ែត គ្មានអ្វីផ្លាស់ប្ដូរប្រែប្រួល សូម្បីតែកូនក្រអូបដោយធម្មជាតិរបស់នាងក៏នៅដូចដើម ដែលខ្ញុំនៅចាំបាន ។



យើងអង្គុយនិយាយគ្នាត្រង់កន្លែងនោះ — និយាយគ្នានៅចំពោះមុខកនទេព្ដាដែលនាងដំកល់ថូធាតុខ្មោចខ្ញុំ ។

ខ្ញុំបាននិយាយរឿងរ៉ាវទាំងអស់ប្រាប់នាង ចាប់តាំងពីកាលដែលឪពុករបស់ខ្ញុំ បានបង្ខំឲ្យខ្ញុំឡើងជិះយន្តហោះ ហើយខ្ញុំក៏វិលខ្លួនឆ្កួតអស់ពេលបីឆ្នាំ ។ ខ្ញុំបានអង្វរករនាងថា សុំកុំឲ្យនាងខឹងសម្បាអ្វីនឹងឪពុកក្មេកនាង ព្រោះឥឡូវលោកបានអនិច្ចកម្មទៅហើយ ។ ឯរូបខ្ញុំវិញនោះ ខ្ញុំសង្ឃឹមថានាង យូរ៉ែត មុខជាគ្មានការសង្ស័យថា ខ្ញុំបែកចិត្តពីនាង ឬក៏ធ្វើខុសពាក្យប្ដេជ្ញាឡើយ ។

— អូនសង្ស័យខ្លះដែរ ថាមុខជាមានការអាថ៌កំបាំងអ្វីម្យ៉ាងនៅក្នុងរឿងនេះជាពុំខាន

— ចុះមានហេតុអ្វីដែលធ្វើឲ្យអូនសង្ស័យថាអញ្ចឹង ?

— ព្រោះកាលបើមានរឿងរ៉ាវកើតឡើងថា រូបបងត្រូវភ្លើងឆេះពេលស្លាប់នៅក្នុងយន្តហោះ, ក្នុងថ្ងៃជាមួយគ្នានោះ

ក៏មានរឿងមនុស្សបាត់ខ្លួនម្នាក់ដែរ គឺបាត់សូន្យឈឹងគ្មានលេចឮដំណឹងអ្វីសោះ ។

– ចុះពួកតម្រួតដែលហៅអូនទៅសាកសួរដែរឬ ?

– ចាស ! ធ្លាប់ហៅទៅសួរបីដងដែរ – ក្នុងពេលសាកសួរនោះ អូនសង្កេតឃើញថា តម្រួតសង្ស័យជាខ្លាំងថា មនុស្សអ្នកត្រូវគ្រោះស្លាប់នោះពុំមែនជារូបបងទេ – គេសង្ស័យលើរូបមនុស្សបាត់ខ្លួននោះ – តម្រួតបានសួរអូនថា ការនេះអាចប្រព្រឹត្តទៅយ៉ាងនោះបានឬទេ ថាបងបើកឡានទៅបុកមនុស្សនោះស្លាប់ ហើយក៏លើកខ្មោចនោះដាក់លើឡានយកទៅដុតចោលជាមួយនឹងឡាន ដើម្បីធ្វើឲ្យអូនជឿជាក់ថាបងស្លាប់ពិតប្រាកដមែន ហើយបងក៏រត់ចោលអូន ឬ បើមិនអញ្ចឹងទេ ក៏ជារឿងដែលបងនិងអូនរួមគំនិតគ្នា ដើម្បីទៅឆបោកយកប្រាក់ពីក្រុមហ៊ុនធានាជីវិត ។

– ចុះអូនឆ្លើយប្រាប់គេថាម៉េច ?



– អូនប្រកែកដាច់ខាតថា ពុំមែនអញ្ចឹងទេព្រោះបងស្រឡាញ់អូនណាស់ តែតម្រួតក៏ឆ្លើយមកវិញថា រឿងរបៀបនេះធ្លាប់មានច្រើនមកហើយ ...

– ចុះសំរាប់ យូរ៉ែត វិញ តើអូនយល់យ៉ាងម៉េច ?

– អូនជឿជាក់ថា បងស្លាប់ពិតប្រាកដមែន – អូនពុំដែលគិតថា បងរត់ចោលអូនសោះ – ប្រសិនបើបងរត់ចោល បងមុខជាពុំធ្វើរបៀបនេះទេ ។

ខ្ញុំបានប្រាប់នាង យូរ៉ែត ថា ខ្ញុំបានសំណាក់នៅក្នុងសណ្ឋាគារមួយ ហើយខ្ញុំមានលិខិតឆ្លងដែនថ្មី ប្រែឈ្មោះថ្មី ។ តែបើទុកជាយ៉ាងនេះក៏នាង យូរ៉ែត នៅតែយល់ថា ពុំអាចរួចខ្លួនបាន ព្រោះមានគេស្គាល់ខ្ញុំច្រើនណាស់ ។ មិនតែប៉ុណ្ណោះនៅពេលកើតហេតុនោះ សារពត៌មានក៏បានដាក់រូបភាពរបស់ខ្ញុំផ្សាយផង ។ ដូច្នេះយើងត្រូវតែចេញពីក្រុងបាងកកយ៉ាងរួសរាន់ ហើយក្នុងចន្លោះពេលដែលយើងត្រូវ

រៀបចំចេញដំណើរនេះ ខ្ញុំត្រូវតែលាក់ខ្លួនពួនអាត្មាកុំឲ្យអ្នកណាឃើញ ។

— ចុះរឿងក្រុមហ៊ុនធានាជីវិតនោះយ៉ាងម៉េចទៅ ? គេបានសងប្រាក់ដល់អូនឬទេ ?

— សងហើយ ! សងគ្រប់តាមចំនួនដែលបងបានធានាជីវិតទុក ។

— ចុះកូនយើងយ៉ាងម៉េចខ្លះ អូន ?

— ស្រួលបួលទេ តែវាស្អាតបាតគួរឲ្យស្រឡាញ់ណាស់ៗ

— ធ្វើម៉េចបានជួបមុខកូនបន្តិច ?

— កុំអាលជួបធ្វើអី

ជារៀងរាល់រាត្រី ខ្ញុំបានលបទៅជួបនាងយូរ៉េកាហើយពិភាក្សាគ្នាពីការដែលយើងត្រូវរត់ចេញពីក្រុងបាងកក ។ នៅយប់ក្រោយនាង យូរ៉េកា បានឲ្យដំណឹងពុំល្អដល់ខ្ញុំថា មានមនុស្សឃើញនាង នឹងខ្ញុំអង្គុយនិយាយគ្នាត្រង់កន្លែងនេះ ។



ពិតណាស់ ការដែលខ្ញុំលបទៅជួបនឹងនាង យូរ៉េកា រាល់យប់នោះ ក៏ជាការពិបាកនឹងឆ្លងផុតពីការសង្កេតរបស់អ្នកដទៃណាស់ តែក៏ជាគ្រោះល្អម្យ៉ាងដែរ ព្រោះអ្នកទាំងនោះយល់ថា រូបខ្ញុំនេះជាខ្មោចបិសាច ហើយដំណឹងនេះក៏បានលេចឮខ្ចរខ្ចាយឮទៅជារឿងប្លែកពីរឿងធម្មតា ។

នាង យូរ៉េកា បានយកសារពត៌មានមកបង្ហាញខ្ញុំ ឲ្យខ្ញុំមើលរឿងរ៉ាវរបស់ខ្ញុំ ឬបើនិយាយម្យ៉ាងទៀតថា រឿងបិសាចរបស់ខ្ញុំ ដែលក្លាយទៅជារឿងធំដុំក្នុងទំព័រកាសែត ។ នាង យូរ៉េកា បានប្រាប់ខ្ញុំថា ពួកអ្នកកាសែតចេះតែមករុកគួននាង ដោយមកសុំធ្វើសម្ភាសន៍ សាកសួរនាង នាងបានឲ្យយោបល់ថា រឿងនេះបើត្រាំនៅយូរបន្តិចទៅទៀត ក្រែងរឿងបិសាចនោះរលត់ទៅ រកមុខជាលេចរឿងពិតគ្រោះកងរបស់ខ្ញុំវិញមិនខាន ។

ខ្ញុំបានព្រមព្រៀងគ្នាជាមួយនាងថា ខ្ញុំត្រូវធ្វើដំណើរចេញទៅចាំនាងឯផ្លូវជ្រៅមុន ដោយនាងសន្យាថា នាងនឹងលបធ្វើដំណើរទៅតាមក្នុងរវាងពីបីថ្ងៃក្រោយ ។

លុះដល់ពេលកំណត់ នាង យូរ៉េត បាននាំកូនមកតាមខ្ញុំមែន ។ ក្នុងពេលនោះ ខ្ញុំរកនិយាយអ្វីពុំរួច ព្រោះភ័យផងអរផង ។ ការដែលខ្ញុំភ័យនោះ គឺព្រោះក្រែងមានគេឃើញគេដឹង ឯការដែលខ្ញុំអរនោះ គឺព្រោះបានជួបមុខកូនសំឡាញ់ ។ តែក្នុងពេលជួបនោះ យូរ៉ា កូនប្រុសរបស់ខ្ញុំសំឡឹងមើលមុខខ្ញុំឡឹងឡង់ ៗ ដោយការខ្លាច ព្រោះវាពុំដែលស្គាល់ ។ មុខមាត់វាស្អាតដូចម្ដាយវាបេះបិទ ។ ម្ដាយវាលើកវាហុចមកឲ្យខ្ញុំ ។ ខ្ញុំទទួលយកមកបីថើប ហើយពេលនោះក៏ជាពេលដែលយើងទាំងអស់គ្នាចាប់ផ្ដើមបទបាតនៃការសម្រក់ទឹកភ្នែក ។ ខ្ញុំនិងនាង យូរ៉េត ស្រក់ទឹកភ្នែកក៏ព្រោះតែស្រណោះដល់



រឿងកំសត់នៃជីវិត ឯយូរ៉ាយំនោះ ក៏ប្រហែលជាវាមិនដែលស្គាល់ខ្ញុំហើយវាខ្លាចខ្ញុំ ។

ខ្ញុំគិតថា ក្នុងការដែលខ្ញុំជួបជុំប្រពន្ធកូនក្នុងគ្រានេះ ជាការមិនទាន់បញ្ចប់នូវរឿងរ៉ាវដ៏កំសត់ក្នុងជីវិតរបស់ខ្ញុំហើយ ...

ខ្ញុំមានបំណងតទៅអនាគតតែម្យ៉ាង គឺ សូមឲ្យខ្ញុំមានឱកាសបានធ្វើដំណើរការនៃជីវិតយ៉ាងស្ងប់ស្ងាត់ ប្រាសចាកការរុកគួននៃអ្នកដទៃ ...

ខ្ញុំបាននាំប្រពន្ធកូនកំសត់ទៅនៅត្រង់កន្លែងមួយដ៏ស្ងាត់ ដែលខ្ញុំយល់ថាល្មមរួចខ្លួនពីការដែលមានគេស្គាល់ ... តែដោយសារការដែលខ្ញុំត្រូវការបិទបាំងអាសយដ្ឋានរបស់ខ្ញុំនោះ បានជាខ្ញុំនៅពុំទាន់ដាក់បឲ្យដឹងពិតប្រាកដថា សព្វថ្ងៃនេះខ្ញុំនៅឯណា ?

ខ្ញុំគ្រាន់តែសូមជំរាបថា ខ្ញុំតែងគិតថា រូបខ្ញុំសព្វថ្ងៃនេះជាអ្នកមានទោសឧក្រិដ្ឋ តែខ្ញុំដូចជារកគិតខ្លួនឯងពុំយល់ដែរ

ថា ការដែលខ្ញុំមានទោសនេះ តើខ្ញុំមានទោសព្រោះអ្វី ? បើអ្នកដទៃក្រៅអំពីរូបខ្ញុំវិញ តើគេប្រព្រឹត្តទៅយ៉ាងណា ? តើគាបចៀសពន់នូវគន្លងដែលខ្ញុំបានត្រេចមកនេះបានឬទេ ? ។

ចប់

# កំណត់សំគាល់

“ខ្ញុំមានទោសព្រោះអ្វី” នេះ អ្នកនិពន្ធបានដាក់ជូនក្រសួងឃោសនាការពិនិត្យមុននឹងបោះពុម្ពផ្សាយ ។

ក្រសួងឃោសនាការ ដោយយល់ឃើញថា រឿងនេះមានការទាក់ទងនឹងកិច្ចការរបស់កងទ័ព ក៏បានបញ្ជូនទៅក្រសួងការពារប្រទេស ដើម្បីសុំយោបល់តាមលិខិតលេខ ១.៣៥២ ឃសក/កត ចុះថ្ងៃទី ៤-១២-៦៥ ។

ក្រសួងការពារប្រទេសបានពិនិត្យហើយ ពុំបានយល់ទាស់ទេ ចំពោះជំពូកទី ១ ឯជំពូកទី ២ ក្រសួងការពារប្រទេសបានផ្ញើសេចក្តីរាយការណ៍ ដាក់ជូនឯកឧត្តម ឧត្តមសេនីយ នាយករដ្ឋមន្ត្រីពិនិត្យកាលពីថ្ងៃទី ២៨-១១-៦៦ ។

ទីស្តីការនាយករដ្ឋមន្ត្រីបានអនុញ្ញាត ដោយឲ្យមានការកែប្រែខ្លះ តាមលិខិតលេខ១៦០ នរម/សព ចុះថ្ងៃទី ១៤-២ ៦៧

— ១ —

ក្រសួងការពារប្រទេស បានអនុញ្ញាតតាមលិខិតលេខ ១៩៨ – ពយ/ក ៩ ចុះថ្ងៃទី ១៧-២-៦៧ ។

ក្រសួងឃោសនាការ បានអនុញ្ញាត តាមលិខិតលេខ ២៨៣ ឃសក/កព ចុះថ្ងៃទី ២១-២-៦៧ ។

## វុធិញ-ចាំញ

# បញ្ជីរឿង


ជំពូកទី ១.–

វគ្គទី ១– រឿងគាថាកំបាំងបិទមុខ

វគ្គទី ២– ដើមហេតុនៃរឿង

វគ្គទី ៣- ខ្ទមជាខ្ទប

វគ្គទី ៤– អត្តឃាដកម្ម

វគ្គទី ៥ បែកគ្នាគ្រាលំបាក

វគ្គទី ៦– លាហើយស្នេហា

ជំពូកទី ២ –

វគ្គទី ៧– ការក្បត់ជាតិរបស់ខ្ញុំ

វគ្គទី ៨ ស្ត្រីជាសត្រូវ

វគ្គទី ៩– បំពេញបេសកកម្មពិសេស

វគ្គទី ១០– ការកាត់ទោសប្រហារជីវិត

វគ្គទី ១១– ឃាតកម្ម

វគ្គទី ១២– តើចក្រពត្តិបំបែកប្រទេសខ្មែរជាពីរបានឬ?

## ជំពូកទី៣.

វគ្គទី ១៣- តើឪពុកបំបែកកូនពីគូស្នេហាបានឬ?

វគ្គទី ១៤- កិច្ចការពិសេស

វគ្គទី ១៥- ទុក្ខព្រួយព្រោះព្រាត់

វគ្គទី ១៦- ជីវិតថ្មី

វគ្គទី ១៧- ខ្ញុំមានទោស